# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ចតុក្កនិបាត

## ភាគ ៤២

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ក្នុងចតុក្កនិបាត មាន ៣ បណ្ណាសកៈ

ចែកជា ១៥ វគ្គ មាន ១៥០ សូត្រ

ព្រះអដ្ឋកថាកែសេចក្តី ១៣២ សូត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ចតុក្កនិបាត

## ភាគ ៤២

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ក្នុងចតុក្កនិបាត មាន ៣ បណ្ណាសកៈ

ចែកជា ១៥ វគ្គ មាន ១៥០ សូត្រ

ព្រះអដ្ឋកថាកែសេចក្តី ១៣៦ សូត្រ

# អង្គុត្តរនិកាយ តិកនិបាត
## រួមមាន
## ៣ បណ្ណាសកៈ និង ១៥ វគ្គ
## ព្រះអដ្ឋកថាកែសេចក្តី ១៣៦ សូត្រ

### បឋមបណ្ណាសកៈ

| | | | |
|---|---|---|---|
| ១ ភណ្ឌគាមវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |
| ២ ចរវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៩ សូត្រ |
| ៣ ឱរុវេលវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |
| ៤ ចក្កវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |
| ៥ រោហិតស្សវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |

### ទុតិយបណ្ណាសកៈ

| | | | |
|---|---|---|---|
| ១ បុញ្ញាភិសន្ទវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |
| ២ បត្តកម្មវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៩ សូត្រ |
| ៣ អបណ្ណកវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៩ សូត្រ |
| ៤ មចលវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៦ សូត្រ |
| ៥ អសុរវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៩ សូត្រ |

### តតិយបណ្ណាសកៈ

| | | | |
|---|---|---|---|
| ១ បឋមវលាហកវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៩ សូត្រ |
| ២ កេសីវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |
| ៣ ភយវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |
| ៤ បុគ្គលវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |
| ៥ អាភាវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៦ សូត្រ |

# ស្រៈនិស្ស័យ

# *Signes et accents:*



# ស្រះពេញតួ
# Voyelles.

| | |
|---|---|
| ខ្មែរ Cambodgien | អ អា ឥ ឦ ឧ ឩ ឯ ឱ |
| រូប Romain | a . ā i i u ū e o |
| សៀម Siamois | อ อา อิ อี อุ อู เอ ไอ |
| លាវ Laotien | ອ ອາ ອິ ອີ ອຸ ອູ ເອ ໄອ |
| លង្កា Cinghalais | අ ආ ඉ ඊ උ ඌ එ ඔ |
| ភូមា Birman | အ အာ ဣ ဤ ဥ ဦ ဧ ဩ |

# ព្យញ្ជនៈ

# *Consonnes.*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| ឡ្រប Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| សិង្ហ Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ᨧ | ᨨ | ᨩ | ᨫ | ᨬ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម៉ាំង Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

# ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

*សុត្ត* បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។

*គេយ្យ* បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

*វេយ្យាករណ* គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

*គាថា* គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

*ឧទាន* គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

*ឥតិវុត្តក* គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

*ជាតក* គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

*អព្ភូតធម៌* គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

*វេទល្ល* គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្ដី

រីករាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្ដាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្ដីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុញ្ញាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្ដាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្អាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើង ហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ៗ

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់របូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡ: សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កាសម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្លះ ( សិរិកុដៈ ) ខ្លះ ( សិរិកូដ្ឋៈ ) ខ្លះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្តាប់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់ លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរីយៈ ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុជាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ន
ឧបាសក ធុំ ធួន
ឧបាសក ជឹម ជំនិត
ឧបាសក សន ម៉ារឌី
ឧបាសក អ៊ឹម វ៉ៃយ៉ា
ឧបាសក សោម រតនៈ
ឧបាសក ម៉ៅ ដុន
ឧបាសិកា ថាប់ លឿម
ឧបាសិកា ប៊ុត សុម៉ាលី
ឧបាសិកា ពូ ហ៊ាង
ឧបាសិកា ប៉ែន រមណី
ឧបាសក ឆាក់ ម៉ៅ
ឧបាសក ហុក សឹងហួត
ឧបាសក កើត ឌិត្យ
ឧបាសក ហាយ ចំរើន
ឧបាសក សុក្រ ហ៊ត
ឧបាសក សំ ធាយ
ឧបាសក ជា ស៊ីថាន
ឧបាសិកា ហាយ សាក៉ាត់
ឧបាសិកា យស សម្បត្តិ
ឧបាសិកា ប៊ុត សេដាដួង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គធិន្នោ | នូវ ប៉ូវ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ជុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ដុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុតេជធរោ | ធាវ ធាន | ធម្មាចារ្យ |

សាមណេរ កោវិទោ ឡោះស្វៀតសមណសិស្សសាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

ឧបាសក ជីម ជំនិត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់៥.០០០ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ–

ឧទ្ទិសថ្វាយ និងគោរពជូនៈ

–ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

–ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

–សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

–មាតាបិតានៃយើងទាំងអស់គ្នា

–លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

–លោកគ្រូធម្មបណ្ឌិត រស់ សុជាត

–សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

–សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌


| ឈ្មោះធម៌ | | ទំព័រ |
|---|---|---|
| **ចតុក្កនិបាត បឋមបណ្ណាសកៈ** | | |
| **ភណ្ឌគាមវគ្គ ទី ១** | | |
| អដ្ឋកថា អនុពុទ្ធសូត្រ | ទី ១ | ១ |
| អដ្ឋកថា បបត្តិសូត្រ | ទី ២ | ៤ |
| អដ្ឋកថា បឋមខតសូត្រ | ទី ៣ | ៦ |
| អដ្ឋកថា ទុតិយខតសូត្រ | ទី ៤ | ៨ |
| អដ្ឋកថា អនុសោតសូត្រ | ទី ៥ | ៩ |
| អដ្ឋកថា អប្បសុតសូត្រ | ទី ៦ | ១២ |
| អដ្ឋកថា សង្ឃសោភណសូត្រ | ទី ៧ | ១៥ |
| អដ្ឋកថា វេសារជ្ជសូត្រ | ទី ៨ | ១៦ |
| អដ្ឋកថា តណ្ហុប្បាទសូត្រ | ទី ៩ | ២៥ |
| អដ្ឋកថា យោគសូត្រ | ទី ១០ | ២៨ |
| **ចរវគ្គ ទី ២** | | |
| អដ្ឋកថា ចរសូត្រ | ទី ១ | ៣៣ |
| អដ្ឋកថា សីលសូត្រ | ទី ២ | ៣៥ |
| អដ្ឋកថា បធានសូត្រ | ទី ៣ | ៣៨ |
| អដ្ឋកថា សំវរសូត្រ | ទី ៤ | ៤០ |
| អដ្ឋកថា បញ្ញត្តិសូត្រ | ទី ៥ | ៤៣ |
| អដ្ឋកថា សោខុម្មសូត្រ | ទី ៦ | ៤៥ |
| អដ្ឋកថា បឋមអគតិសូត្រ | ទី ៧ | ៤៧ |
| អដ្ឋកថា ឆាកសូត្រ | ទី ៨ | ៤៨ |
| អដ្ឋកថា ទុតិយអគតិសូត្រ | ទី ៩ | ៤៩ |
| អដ្ឋកថា ភត្តុទេសកសូត្រ | ទី ១០ | ៥០ |

## ឧរុវេលវគ្គ ទី ៣


| | | |
|---|---|---|
| អដ្ឋកថា បឋមឧរុវេលសូត្រ | ទី ១ | ៥១ |
| អដ្ឋកថា ទុតិយឧរុវេលសូត្រ | ទី ២ | ៥៩ |
| អដ្ឋកថា លោកសូត្រ | ទី ៣ | ៦៧ |
| អដ្ឋកថា កាឡការាមសូត្រ | ទី ៤ | ៧៣ |
| អដ្ឋកថា ព្រហ្មចរិយសូត្រ | ទី ៥ | ៨៥ |
| អដ្ឋកថា កុហសូត្រ | ទី ៦ | ៨៧ |
| អដ្ឋកថា សន្តុដ្ឋិសូត្រ | ទី ៧ | ៨៩ |
| អដ្ឋកថា អរិយវំសសូត្រ | ទី ៨ | ៩១ |
| អដ្ឋកថា ធម្មបទសូត្រ | ទី ៩ | ១២៣ |
| អដ្ឋកថា បរិព្វាជកសូត្រ | ទី ១០ | ១២៤ |


## ចក្កវគ្គ ទី ៤


| | | |
|---|---|---|
| អដ្ឋកថា ចក្កសូត្រ | ទី ១ | ១២៨ |
| អដ្ឋកថា សង្គហសូត្រ | ទី ២ | ១៣០ |
| អដ្ឋកថា សីហសូត្រ | ទី ៣ | ១៣៣ |
| អដ្ឋកថា បសាទសូត្រ | ទី ៤ | ១៤៧ |
| អដ្ឋកថា វស្សការសូត្រ | ទី ៥ | ១៤៩ |
| អដ្ឋកថា ទោណសូត្រ | ទី ៦ | ១៥២ |
| អដ្ឋកថា អបរិហានិយសូត្រ | ទី ៧ | ១៥៩ |
| អដ្ឋកថា បដិលីនសូត្រ | ទី ៨ | ១៦០ |
| អដ្ឋកថា ឧជ្ជយសូត្រ | ទី ៩ | ១៦៤ |
| អដ្ឋកថា ឧទាយិសូត្រ | ទី ១០ | ១៦៧ |


## រោហិតស្សវគ្គ ទី ៥


| | | |
|---|---|---|
| អដ្ឋកថា សមាធិសូត្រ | ទី ១ | ១៦៩ |
| អដ្ឋកថា បញ្ហាព្យាករណសូត្រ | ទី ២ | ១៧២ |
| អដ្ឋកថា បឋមកោធសូត្រ | ទី ៣ | ១៧៤ |
| អដ្ឋកថា ទុតិយកោធសូត្រ | ទី ៣ | ១៧៥ |
| អដ្ឋកថា បឋមរោហិតសូត្រ | ទី ៥ | ១៧៦ |

| | | |
|---|---|---|
| អដ្ឋកថា ទុតិយរោហិតស្សសូត្រ | ទី ៦ | ១៨០ |
| អដ្ឋកថា សុវិទូរសូត្រ | ទី ៧ | ១៨១ |
| អដ្ឋកថា វិសាខសូត្រ | ទី ៨ | ១៨៣ |
| អដ្ឋកថា វិបល្លាសសូត្រ | ទី ៩ | ១៨៥ |
| អដ្ឋកថា ឧបក្កិលេសសូត្រ | ទី ១០ | ១៨៧ |


## ទុតិយបណ្ណាសកៈ

### បុញ្ញាភិសន្ទវគ្គ ទី ១


| | | |
|---|---|---|
| អដ្ឋកថា បឋមបុញ្ញាភិសន្ទសូត្រ | ទី ១ | ១៨៩ |
| អដ្ឋកថា ទុតិយបុញ្ញាភិសន្ទសូត្រ | ទី ២ | ១៩២ |
| អដ្ឋកថា បឋមសង្វាសសូត្រ | ទី ៣ | ១៩៣ |
| អដ្ឋកថា ទុតិយសង្វាសសូត្រ | ទី ៤ | ១៩៥ |
| អដ្ឋកថា បឋមសមជីវិសូត្រ | ទី ៥ | ១៩៦ |
| អដ្ឋកថា ទុតិយសមជីវិសូត្រ | ទី ៦ | ១៩៨ |
| អដ្ឋកថា សុប្បវាសាសូត្រ | ទី ៧ | ១៩៩ |
| អដ្ឋកថា សុទត្តសូត្រ | ទី ៨ | ២០១ |
| អដ្ឋកថា ភោជនសូត្រ | ទី ៩ | ២០២ |
| អដ្ឋកថា គិហិសាមិចិសូត្រ | ទី ១០ | ២០៣ |


### បត្តកម្មវគ្គ ទី ២


| | | |
|---|---|---|
| អដ្ឋកថា បត្តកម្មសូត្រ | ទី ១ | ២០៥ |
| អដ្ឋកថា អានណ្យសូត្រ | ទី ២ | ២១០ |
| អដ្ឋកថា សព្រហ្មសូត្រ | ទី ៣ | ២១២ |
| អដ្ឋកថា និរយសូត្រ | ទី ៤ | ២១៣ |
| អដ្ឋកថា រូបសូត្រ | ទី ៥ | ២១៤ |
| អដ្ឋកថា សរាគសូត្រ | ទី ៦ | ២១៧ |
| អដ្ឋកថា អហិសូត្រ | ទី ៧ | ២១៨ |
| អដ្ឋកថា ទេវទត្តសូត្រ | ទី ៨ | ២២១ |

| | | |
|---|---|---|
| អដ្ឋកថា បធានសូត្រ | ទី ៩ | ២២២ |
| អដ្ឋកថា អធម្មិកសូត្រ | ទី ១០ | ២២៣ |
| **អបណ្ណកវគ្គ ទី ៣** | | |
| អដ្ឋកថា បធានសូត្រ | ទី ១ | ២២៦ |
| អដ្ឋកថា ទិដ្ឋិសូត្រ | ទី ២ | ២២៧ |
| អដ្ឋកថា សប្បុរិសសូត្រ | ទី ៣ | ២២៨ |
| អដ្ឋកថា បឋមអគ្គសូត្រ | ទី ៤ | ២៣០ |
| អដ្ឋកថា ទុតិយអគ្គសូត្រ | ទី ៥ | ២៣១ |
| អដ្ឋកថា កុសិនារាសូត្រ | ទី ៦ | ២៣២ |
| អដ្ឋកថា អចិន្តេយ្យសូត្រ | ទី ៧ | ២៣៤ |
| អដ្ឋកថា ទក្ខិណាសូត្រ | ទី ៨ | ២៣៥ |
| អដ្ឋកថា វណិជ្ជសូត្រ | ទី ៩ | ២៣៧ |
| អដ្ឋកថា កម្ពោជសូត្រ | ទី ១០ | ២៣៩ |
| **មចលវគ្គ ទី ៤** | | |
| អដ្ឋកថា ចាណាតិចាតជាដើម សូត្រ | ទី ១ | ២៤១ |
| អដ្ឋកថា តមសូត្រ | ទី ៥ | ២៤២ |
| អដ្ឋកថា ឱណាតសូត្រ | ទី ៦ | ២៤៦ |
| អដ្ឋកថា បុត្តសូត្រ | ទី ៧ | ២៤៧ |
| អដ្ឋកថា សំយោជនសូត្រ | ទី ៨ | ២៥១ |
| អដ្ឋកថា ទិដ្ឋិសូត្រ | ទី ៩ | ២៥២ |
| អដ្ឋកថា ខន្ធសូត្រ | ទី ១០ | ២៥៣ |
| **អសុរវគ្គ ទី ៥** | | |
| អដ្ឋកថា អសុរសូត្រ | ទី ១ | ២៥៤ |
| អដ្ឋកថា បឋមសមាធិសូត្រ | ទី ២ | ២៥៥ |
| អដ្ឋកថា ទុតិយសមាធិសូត្រ | ទី ៣ | ២៥៦ |
| អដ្ឋកថា តតិយសមាធិសូត្រ | ទី ៤ | ២៥៧ |
| អដ្ឋកថា ឆវាលាតសូត្រ | ទី ៥ | ២៥៨ |

| | | |
|---|---|---|
| អដ្ឋកថា រាគសូត្រ | ទី ៦ | ២៦០ |
| អដ្ឋកថា និសន្តិសូត្រ | ទី ៧ | ២៦១ |
| អដ្ឋកថា អត្តហិតសូត្រ | ទី ៨ | ២៦៣ |
| អដ្ឋកថា សិក្ខាសូត្រ | ទី ៩ | ២៦៤ |
| អដ្ឋកថា ចោតលិយសូត្រ | ទី ១០ | ២៦៥ |


## តតិយបណ្ណាសកៈ

### វលាហកវគ្គ ទី ១


| | | |
|---|---|---|
| អដ្ឋកថា បឋមវលាហកសូត្រ | ទី ១ | ២៦៦ |
| អដ្ឋកថា ទុតិយវលាហកសូត្រ | ទី ២ | ២៦៧ |
| អដ្ឋកថា កុម្ភសូត្រ | ទី ៣ | ២៦៨ |
| អដ្ឋកថា ឧទករហទសូត្រ | ទី ៤ | ២៦៩ |
| អដ្ឋកថា អម្ពសូត្រ | ទី ៥ | ២៧០ |
| អដ្ឋកថា មូសិកាសូត្រ | ទី ៧ | ២៧១ |
| អដ្ឋកថា ពលិពទ្ទសូត្រ | ទី ៨ | ២៧២ |
| អដ្ឋកថា រុក្ខសូត្រ | ទី ៩ | ២៧៣ |
| អដ្ឋកថា អាសីវិសសូត្រ | ទី ១០ | ២៧៤ |


### កេសីវគ្គ ទី ២


| | | |
|---|---|---|
| អដ្ឋកថា កេសីសូត្រ | ទី ១ | ២៧៥ |
| អដ្ឋកថា ជវសូត្រ | ទី ២ | ២៧៦ |
| អដ្ឋកថា បតោទសូត្រ | ទី ៣ | ២៧៧ |
| អដ្ឋកថា នាគសូត្រ | ទី ៤ | ២៧៨ |
| អដ្ឋកថា ឋានសូត្រ | ទី ៥ | ២៧៩ |
| អដ្ឋកថា អប្បមាទសូត្រ | ទី ៦ | ២៨១ |
| អដ្ឋកថា អារក្ខសូត្រ | ទី ៧ | ២៨២ |
| អដ្ឋកថា សំវេជនីយសូត្រ | ទី ៨ | ២៨៣ |
| អដ្ឋកថា បឋមភយសូត្រ | ទី ១០ | ២៨៤ |

| | | | |
|---|---|---|---|
| អដ្ឋកថា ទុតិយភយសូត្រ | ទី ១០ | | ២៨៥ |

**ភយវគ្គ ទី ៣**

| | | | |
|---|---|---|---|
| អដ្ឋកថា អត្តានុវាទសូត្រ | ទី ១ | (បឋមភយសូត្រ) | ២៨៦ |
| អដ្ឋកថា ឩមិភយសូត្រ | ទី ២ | (ទុតិយភយសូត្រ) | ២៨៨ |
| អដ្ឋកថា នានាករណសូត្រ | ទី ៣ | (បឋមឈានសូត្រ) | ២៨៩ |
| អដ្ឋកថា ទុតិយនានាករណសូត្រ | ទី ៥ | (ទុតិយឈានសូត្រ) | ២៩២ |
| អដ្ឋកថា បឋមមេត្តាសូត្រ | ទី ៥ | | ២៩៤ |
| អដ្ឋកថា ទុតិយមេត្តាសូត្រ | ទី ៦ | | ២៩៥ |
| អដ្ឋកថា បឋមតថាគត...សូត្រ | ទី ៧ | | ២៩៦ |
| អដ្ឋកថា ទុតិយតថាគត...សូត្រ | ទី ៨ | | ៣០០ |
| អដ្ឋកថា អានន្ទអច្ឆរិយសូត្រ | ទី ៩ | | ៣០២ |
| អដ្ឋកថា ចក្កវត្តិអច្ឆរិយសូត្រ | ទី ១០ | | ៣០៤ |

**បុគ្គលវគ្គ ទី ៤**

| | | |
|---|---|---|
| អដ្ឋកថា សំយោជនសូត្រ | ទី ១ | ៣០៦ |
| អដ្ឋកថា បដិភាណសូត្រ | ទី ២ | ៣០៨ |
| អដ្ឋកថា ឧក្ឃដិតញ្ញូសូត្រ | ទី ៣ | ៣០៩ |
| អដ្ឋកថា ឧដ្ឋានសូត្រ | ទី ៤ | ៣១០ |
| អដ្ឋកថា សារជ្ជសូត្រ | ទី ៥ | ៣១២ |
| អដ្ឋកថា បឋមសីលសូត្រ | ទី ៦ | ៣១៣ |
| អដ្ឋកថា ទុតិយសីលសូត្រ | ទី ៧ | ៣១៤ |
| អដ្ឋកថា និក្កដ្ឋសូត្រ | ទី ៨ | ៣១៥ |
| អដ្ឋកថា ធម្មកថិកសូត្រ | ទី ៩ | ៣១៦ |
| អដ្ឋកថា វាទីសូត្រ | ទី ១០ | ៣១៧ |

**អាភាវគ្គ ទី ៥**

| | | |
|---|---|---|
| អដ្ឋកថា អាភាសូត្រ | ទី ១ | ៣១៨ |
| អដ្ឋកថា បភាសូត្រ | ទី ២ | ៣១៩ |
| អដ្ឋកថា បឋមកាលសូត្រ | ទី ៦ | ៣២៣ |

| | | |
|---|---|---|
| អដ្ឋកថា ទុតិយកាលសូត្រ | ទី ៧ | ៣២៤ |
| អដ្ឋកថា ទុច្ចរិតសូត្រ | ទី ៨ | ៣២៥ |
| អដ្ឋកថា សុចរិតសូត្រ | ទី ៩ | ៣២៦ |
| អដ្ឋកថា សារសូត្រ | ទី ១០ | ៣២៧ |

# អង្គុត្តរនិកាយ ចតុក្កនិបាត

## បឋមបណ្ណាសកៈ

## ភណ្ឌគាមវគ្គវណ្ណនាទី ១

## អដ្ឋកថា អនុពុទ្ធសូត្រទី ១

*"ពោលដោយអរិយសច្ច ៤"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនុពុទ្ធសូត្រទី ១ ដូចតទៅនេះ ៖*

[១] *បទថា* ***អននុពោធា*** *(ព្រោះមិនដឹងច្បាស់) បានដល់ ព្រោះមិនដឹង ព្រោះមិនជ្រាប ។ បទថា* ***អប្បដិវេធា*** *(ព្រោះមិនចាក់ធ្លុះ) បានដល់ ព្រោះមិនចាក់ធ្លុះ គឺ ព្រោះមិនធ្វើឲ្យប្រចក្ស ។ បទថា* ***ទីឃមទ្ធានំ*** *(អស់កាលយូរ) ប្រែថា អស់កាលដ៏យូរ ។ បទថា* ***សន្ធាវិតំ*** *(ត្រាច់រង្គាត់) បានដល់ ត្រាច់ទៅ ដោយទៅពីភពកាន់ភព ។ បទថា* ***សំសរិតំ*** *(អន្ទោលទៅ) បានដល់ អន្ទោលទៅ ដោយទៅមករឿយៗ ។ បទថា* ***មមញ្ចេវ តុម្ហាកញ្ច*** *(តថាគត និងអ្នកទាំងឡាយ) បានដល់ ដែលតថាគត និងអ្នកទាំងឡាយ ។ម្យ៉ាងទៀត ក្នុងបទថា* ***សន្ធាវិតំ សំសរិតំ*** *(ត្រាច់ទៅ អន្ទោលទៅ) នេះ គប្បីជ្រាបន័យយ៉ាងនេះថា ការត្រាច់ទៅ អន្ទោលទៅ*

បានមានហើយទាំងដល់តថាគត ទាំងដល់អ្នកទាំងឡាយ ។

បទថា **អរិយស្ស** (អរិយៈ) បានដល់ មិនមានទោស ។ ក៏ធម៌ទាំង ៣ នេះ គឺ សីល សមាធិ និងបញ្ញា គប្បីជ្រាបថា សម្បយុត្តដោយមគ្គ និងផលនោះឯង ។ ផលប៉ុណ្ណោះ លោកសម្តែងដោយឈ្មោះថា វិមុត្តិ ។ បទថា **ភវតណ្ហា** (តណ្ហាក្នុងភព) បានដល់ តណ្ហាក្នុងភពទាំងឡាយ ។ បទថា **ភវនេត្តិ** (គ្រឿងនាំទៅកាន់ភព) បានដល់ តណ្ហាដូចខ្សែចងសត្វទុកក្នុងភព ។ បទនោះ ជាឈ្មោះរបស់តណ្ហានោះឯង ។ ពិតណាស់ តណ្ហានោះ នាំសត្វទាំងឡាយទៅកាន់ភពនោះៗ ដូចមនុស្សយកខ្សែចងកគោនាំទៅកាន់ទីនោះៗ ដូច្នោះ ព្រោះដូច្នោះ តណ្ហានោះលោកទើបហៅថា **គ្រឿងនាំទៅកាន់ភព** ។

បទថា **អនុត្តរោ** (ដ៏កំពូល) បានដល់ ដែលជាលោកុត្តរៈ ។ បទថា **ទុក្ខស្សន្តករោ** (ធ្វើទីបំផុតទុក្ខ) បានដល់ ទ្រង់ធ្វើទីបំផុតនៃវដ្តទុក្ខ ។ បទថា **ចក្ខុមា** (អ្នកមានចក្ខុ) បានដល់ ទ្រង់មានចក្ខុដោយចក្ខុទាំង ៥ ។ បទថា **បរិនិព្វុតោ** (បរិនិព្វានហើយ) បានដល់ បរិនិព្វានហើយ ដោយកិលេសបរិនិព្វាន (គឺរំលត់កិលេស) ។ ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនាតាមលំដាប់អនុសន្ធិថា នេះជាការបរិនិព្វានគ្រាដំបូងរបស់ព្រះសាស្តានោះត្រង់

ពោធិមណ្ឌស្ថាន ។ តែក្រោយមក ព្រះអង្គបរិនិព្វានដោយអនុបាទិសេស-

និព្វានធាតុ រំលត់ខន្ធក្នុងចន្លោះឈើសាលទាំងគូ ដូច្នេះ ។

ចប់អដ្ឋកថា អនុពុទ្ធសូត្រទី ១

# អដ្ឋកថា បបតិតសូត្រទី ២

## *"បុគ្គលឃ្លាតចាកព្រះធម៌វិន័យ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បបតិតសូត្រទី ២ ដូចតទៅនេះ ៖*

[២] *បទថា* **បបតិតោ** *(អ្នកធ្លាក់) បានដល់ អ្នកឃ្លាតទៅ ។ បទថា* **អប្បបតិតោ** *(អ្នកមិនធ្លាក់) បានដល់ អ្នកតាំងនៅហើយ ។ បណ្ដាបុគ្គលទាំងនោះ លោកិយមហាជនឈ្មោះថា ធ្លាក់ទៅនោះឯង ។ ព្រះអរិយ-បុគ្គល មានព្រះសោតាបន្នជាដើម ឈ្មោះថា ធ្លាក់ទៅក្នុងខណៈនៃការកើតកិលេស ។ ព្រះខីណាស្រពឈ្មោះថា តាំងនៅហើយតែម្យ៉ាង ។ បទថា* **ចុតា បតន្តិ** *(បុគ្គលអ្នកឃ្លាតទៅ ឈ្មោះថាធ្លាក់ទៅ) សេចក្ដីថា ជនពួកណាឃ្លាតទៅ ជនទាំងនោះឈ្មោះថា ធ្លាក់ ។ បទថា* **បតិតា** *(អ្នកធ្លាក់ហើយ) សេចក្ដីថា ជនពួកណាធ្លាក់ទៅ ជនពួកនោះឈ្មោះថា ឃ្លាតទៅ ។ អធិប្បាយថា ឈ្មោះថា ធ្លាក់ ព្រោះឃ្លាតទៅ , ឈ្មោះថា ឃ្លាតទៅ ព្រោះធ្លាក់ ដូច្នេះ ។ បទថា* **គិទ្ធា** *(ញុំាងសេចក្ដីត្រេកអរ) បានដល់ បុគ្គលដែលជាប់ជំពាក់ព្រោះរាគៈ ។ បទថា* **បុនរាគតា** *(ត្រូវមកកើតទៀត) សេចក្ដីថា រមែងឈ្មោះថា ជាអ្នកមកកាន់ជាតិ ជរា ព្យាធិ មរណៈទៀត ។ បទថា* **កតកិច្ចំ** *(បុគ្គលធ្វើហើយនូវកិច្ចដែលគួរធ្វើហើយ) សេចក្ដីថា ធ្វើកិច្ចដែល*

គួរធ្វើដោយមគ្គទាំង ៤ ។ បទថា **រតំរម្មំ** (ត្រេកអរហើយក្នុងវត្ថុដែលគួរត្រេកអរ) សេចក្ដីថា ត្រេកអរហើយក្នុងគុណជាតិដែលគួរត្រេកអរ ។ បទថា **សុខេនានុប្បត្តំ សុខំ** (រមែងទៅអំពីសុខកាន់សុខតាមលំដាប់) សេចក្ដីថា បានទទួល គឺ ដល់ព្រមនូវសេចក្ដីសុខ អំពីសេចក្ដីសុខ អធិប្បាយថា អំពីសុខរបស់មនុស្ស សម្រេចសុខជាទិព្វ អំពីសុខក្នុងឈាន មកដល់សុខក្នុងវិបស្សនា អំពីសុខក្នុងវិបស្សនាមកដល់សុខក្នុងមគ្គ អំពីសុខក្នុងមគ្គមកដល់សុខក្នុងផល ពីសុខក្នុងផល ក៏មកដល់សុខក្នុងនិព្វាន ។

ចប់អដ្ឋកថា បបតិតសូត្រទី ២

# អដ្ឋកថា បឋមខតសូត្រទី ៣

## *"ហេតុរក្សាខ្លួនដែលខ្លួនត្រូវកម្ចាត់"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមខតសូត្រទី ៣ ដូចតទៅនេះ ៖*

*[៣] បឋមខតសូត្រទី ៣ ពោលទុកក្នុងអដ្ឋកថាទុកនិបាតហើយ ។ ចំណែកក្នុងគាថា គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បទថា* ***និន្ទិយំ*** *(បុគ្គលដែលគួរតិះដៀល) បានដល់ បុគ្គលគួរតិះដៀល ។ បទថា* ***និន្ទតិ*** *(តិះដៀល) បានដល់ រមែងតិះដៀល ។ បទថា* ***បសំសិយោ*** *បានដល់ បុគ្គលដែលគួរសរសើរ ។ បទថា* ***វិចិនាតិ មុខេន សោ កលឹ*** *(អ្នកនោះឈ្មោះថាបន្សំសេចក្ដីវិនាសដោយមាត់)[១] សេចក្ដីថា បុគ្គលនោះប្រព្រឹត្តយ៉ាងនេះហើយ ឈ្មោះថា រមែងបន្សំសេចក្ដីវិនាសដោយមាត់នោះឯង ។ បទថា* ***កលិនា តេន សុខំ ន វិន្ទតិ*** *(ព្រោះសេចក្ដីវិនាសនោះ គេក៏មិនបានសុខ) សេចក្ដីថា គេរមែងមិនបានសេចក្ដីសុខព្រោះទោសនោះ ។ បទថា* ***សព្វស្សាបិ សហាបិ អត្តនា*** *(ព្រមទាំងទ្រព្យរបស់ខ្លួន) សេចក្ដីថា ការចាញ់ល្បែងភ្នាល់ទាំងទ្រព្យរបស់ខ្លួន និងទាំងខ្លួនឯង ឈ្មោះថា ជាទោសប្រមាណតិច ។ បទថា* ***យោ សុគតេសុ*** *(បុគ្គលប្រទូស្តក្នុងពួកបុគ្គលដែលមានដំណើរជីវិត*

---

*(១) បិដក = បុគ្គលនោះឈ្មោះថា ជ្រើសរើសយកកំហុសដោយមាត់ ។*

ល្អ) សេចក្ដីថា ចំណែកបុគ្គលណា ធ្វើចិត្តគិតប្រទូស្តក្នុងបុគ្គលទាំងឡាយ ដែលប្រព្រឹត្តទៅដោយប្រពៃហើយ ការមានចិត្តគិតប្រទូស្តរបស់បុគ្គលនោះឯង មានទោសច្រើនជាងទោសនោះ ។ ឥឡូវនេះ កាលទ្រង់សម្ដែងបុគ្គលដែលមានចិត្តគិតប្រទូស្ត ក្នុងលោកដែលមានដំណើរជីវិតដោយប្រពៃនោះ មានទោសច្រើនជាង ទើបត្រាស់បទថា **សតំ សហស្សានំ** (សែន) ជាអាទិ៍ ។ បណ្ដាបទទាំងនោះ បទថា **សែន** បានដល់ អស់សែន ដោយការរាប់តាមនិរព្វុទៈ ។ បទថា **ឆត្តឹសតិ** (សាមសិបប្រាំមួយ) បានដល់ សាមសិប-ប្រាំមួយនិរព្វុទៈទៀត ។ បទថា **បញ្ច ច** (ប្រាំ) គឺ ប្រាំអព្វុទៈ ដោយការរាប់តាមអព្វុទៈ ។ បទថា **យមរិយំ គរហិ** (តិះដៀលព្រះអរិយៈ) សេចក្ដីថា បុគ្គលកាលតិះដៀលព្រះអរិយៈទាំងឡាយ រមែងចូលដល់នរកណា ក្នុងនរកនោះ ប្រមាណអាយុមានប៉ុណ្ណោះ ។

ចប់អដ្ឋកថា បឋមទុតសុត្រទី ៣

# អដ្ឋកថា ទុតិយខតសូត្រទី ៤

## *"ហេតុរក្សាខ្លួនដែលខ្លួនត្រូវកម្ចាត់"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយខតសូត្រទី ៤ ដូចតទៅនេះ ៖*

[៤] *ក្នុងបទថា* ***មាតរិ បិតរិ ច*** *(បដិបត្តិខុសក្នុងមាតា ក្នុងបិតា) ជាអាទិ៍ នាយមិត្តវិន្ទុកៈ ឈ្មោះថា បដិបត្តិខុសក្នុងមាតា ។ ព្រះបាទអជាតសត្រូវ ឈ្មោះថា បដិបត្តិខុសក្នុងបិតា ។ ព្រះទេវទត្ត ឈ្មោះថា បដិបត្តិខុសក្នុងព្រះតថាគត ។ កោកាលិកភិក្ខុ ឈ្មោះថា បដិបត្តិខុសក្នុងព្រះសាវករបស់ព្រះតថាគត ។ បទថា* ***ពហុញ្ច*** *បានដល់ ច្រើន ។ បទថា* ***បសវតិ*** *(ប្រសព្វ) បានដល់ រមែងបាន ។ បទថា* ***តាយ*** *(ព្រោះការប្រព្រឹត្តមិនមែនជាធម៌... នោះ) សេចក្ដីថា ដោយការប្រព្រឹត្តអធម៌ ពោលគឺ ការបដិបត្តិខុសនោះឯង ។ បទថា* ***បេច្ច*** *(ស្លាប់ទៅហើយ) គឺ ទៅអំពីលោកនេះ ។ បទថា* ***អបាយញ្ច គច្ឆតិ*** *(នឹងទៅអបាយផង) គឺ គេត្រូវកើតក្នុងនរកជាដើមកន្លែងណាមួយ ។ ចំណែកក្នុងសុក្កបក្ខ (ធម៌ចំណែកល្អ) ក៏ន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា ទុតិយខតសូត្រទី ៤

# អដ្ឋកថា អនុសោតសូត្រទី ៥

## *“បុគ្គលដែលទៅតាមក្រសែ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនុសោតសូត្រទី ៥ ដូចតទៅនេះ ៖*

[៥] *បុគ្គលឈ្មោះថា **អនុសោតគាមី** (ទៅតាមក្រសែ) ព្រោះទៅតាមក្រសែ ។ ឈ្មោះថា **បដិសោតគាមី** (ទៅច្រាសក្រសែ) ព្រោះទៅច្រាសក្រសែនៃក្រសែ គឺ កិលេស ដោយការបដិបត្តិដែលជាសត្រូវ ។ បទថា **ឋិតត្តោ** (ជាអ្នកតាំងនៅហើយ) គឺ ព្រោះមានភាវៈតាំងមាំ ។ បទថា **តិណ្ណោ** (ឆ្លង) បានដល់ ឆ្លងឱឃៈតាំងនៅហើយ ។ បទថា **បារគតោ** បានដល់ ដល់ត្រើយដទៃ ។ បទថា **ថលេ តិដ្ឋតិ** (នៅលើគោក) បានដល់ នៅលើគោក គឺ និព្វាន ។ បទថា **ព្រាហ្មណោ** (ជាព្រាហ្មណ៍) បានដល់ ជាបុគ្គលប្រសើរ រកទោសមិនបាន ។ បទថា **ឥធ** (នេះ) ក៏គឺក្នុងលោកនេះ ។ បទថា **កាមេ ច បដិសេវតិ** (សេពកាមផង) បានដល់ សេពវត្ថុកាមផង កិលេសកាមផង ។ បទថា **បាបញ្ច កម្មំ ករោតិ** (ធ្វើបាបកម្មផង) បានដល់ រមែងធ្វើកម្ម មានបាណាតិបាតជាដើម ដែលជាបាប ។ បទថា **បាបញ្ច កម្មំ ន ករោតិ** (និងមិនធ្វើបាបកម្ម) បានដល់ មិនធ្វើកម្ម គឺ ពៀរវេរា ៥ ។ បទថា **អយំ វុច្ចតិ ភិក្ខវេ ឋិតត្តោ** (នេះហៅថា បុគ្គលមាន*

ខ្ជួនតាំងមាំហើយ) សេចក្តីថា ព្រះអនាគាមីបុគ្គល ឈ្មោះថា មានខ្ជួនតាំងមាំហើយ ព្រោះមិនត្រឡប់មកពីលោកនោះ ដោយអំណាចបដិសន្ធិទៀត ។

បទថា **តណ្ហាធិបន្នា** (ត្រូវតណ្ហាគ្របសង្កត់) សេចក្តីថា ពពួកជនដែលត្រូវតណ្ហាគ្របសង្កត់ គឺ ញាំញី ឬចូលដល់ គឺ ធ្លាក់ចុះកាន់តណ្ហា ។ បទថា **បរិបុណ្ណសេក្ខា** (មានសិក្ខាបរិបូរ) បានដល់ តាំងនៅក្នុងភាពបរិបូរដោយសិក្ខា ។ បទថា **អបរិហានធម្មោ** (មានការមិនវិនាសជាធម្មតា) បានដល់ មានការមិនវិនាសជាសភាវៈ ។ បទថា **ចេតោវសិប្បត្តោ** (បានជំនាញផ្លូវចិត្ត) បានដល់ ដល់ភាពជាអ្នកជំនាញផ្លូវចិត្ត ។ បុគ្គលបែបនេះ រមែងជាព្រះខីណាស្រព ។ តែក្នុងសេចក្តីនេះ ត្រាស់ដល់អនាគាមិបុគ្គល ។ បទថា **សមាហិតិន្ទ្រិយោ** (មានឥន្ទ្រិយតម្កល់មាំ) បានដល់ អ្នកមានឥន្ទ្រិយ ៦ តម្កល់មាំហើយ ។ បទថា **បរោបរ** (ដែលជាកុសលាកុសល) បានដល់ ធម៌ខ្ពស់ និងទាប អធិប្បាយថា កុសលធម៌ និងអកុសលធម៌ ។ បទថា **សមេច្ច** (ប្រកបដោយញាណ) បានដល់ មកព្រមគ្នាដោយញាណ ។ បទថា **វិធូបិតា** (កម្ចាត់) បានដល់ ដែលលោកកម្ចាត់ ឬដុតចេញហើយ ។ បទថា **វុសិតព្រហ្មចរិយោ** (សម្រេចព្រហ្មចរិយៈ) សេចក្តីថា នៅចប់មគ្គព្រហ្មចរិយៈ ។ បទថា **លោកន្តគូ** (ដល់ទីបំផុតលោក) សេចក្តីថា ដល់ទី

បំផុតនៃលោកទាំងបី ។ បទថា **បារគតោ** (អ្នកដល់ត្រើយហើយ) សេចក្តីថា អ្នកដល់ត្រើយដោយអាការ ៦ ។ ក្នុងសេចក្តីនេះ ត្រាស់ដល់ព្រះខីណាស្រពប៉ុណ្ណោះ ដល់វដ្តៈ និងវិវដ្តៈ (លោកិយៈ និងលោកុត្តរៈ) ត្រាស់ទុកទាំងក្នុងព្រះសូត្រ ទាំងក្នុងគាថា ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា អនុសោតសូត្រទី ៥

# អដ្ឋកថា អប្បស្សុតសូត្រទី ៦

## "បុគ្គលដែលមានសុតៈ ៤ ពួក"

គប្បីជ្រាបវិនិច្ឆ័យក្នុង អប្បស្សុតសូត្រទី ៦ ដូចតទៅនេះ ៖

[៦] បទថា **អនុបបន្នោ** (ទាំងមិនបានប្រយោជន៍) គឺ មិនចូលដល់ ។ ក្នុងបទមានជាអាទិ៍ថា **សុត្តំ** (សុត្តៈ) នេះ ឧភតោវិភង្គ និទ្ទេស ខន្ធកៈ បរិវារៈ សុត្តនិបាត មង្គលសូត្រ រតនសូត្រ នាលកសូត្រ តុវដកសូត្រ ព្រះតម្រាស់របស់ព្រះតថាគតសូម្បីដទៃ មានឈ្មោះថា សូត្រ គប្បីជ្រាបថា **សុត្តៈ** ។ ព្រះសូត្រដែលមានគាថាទាំងអស់ គប្បីជ្រាបថា **គេយ្យៈ** ។ ក្នុងសំយុត្តនិកាយ សគាថវគ្គ សូម្បីទាំងអស់មិនមែនជាគាថា អភិធម្មបិដកទាំងអស់ សូត្រដែលមិនមានគាថា ព្រះពុទ្ធវចនៈសូម្បីដទៃ ដែលមិនសង្គ្រោះចូលជាមួយអង្គ ៨ គប្បីជ្រាបថា **វេយ្យាករណៈ** ។ ធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធមិនមានឈ្មោះថាសូត្រក្នុងសុត្តនិបាត គប្បីជ្រាបថា **គាថា** ។ ព្រះសូត្រ ៨២ សូត្រ ប្រកបដោយគាថា ដែលសម្រេចមកពីសោមនស្សញ្ញាណ គប្បីជ្រាបថា **ឧទាន** ។ ព្រះសូត្រ ១១០ សូត្រ ដែលប្រព្រឹត្តទៅដោយន័យមានជាអាទិ៍ថា **វុត្តមិទំ ភគវតា** (ព្រះមានព្រះភាគត្រាស់ទុកដូច្នេះ) គប្បីជ្រាបថា **ឥតិវុត្តកៈ** ។ ជាតក ៥៥០ ជាតក មាន

អបណ្ណកជាតកជាដើម គប្បីជ្រាបថា **ជាតក** ។ ព្រះសូត្រដែលប្រកបដោយធម៌ដែលគួរអស្ចារ្យមិនធ្លាប់មានសូម្បីទាំងអស់ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ អច្ឆរិយអព្ភូតធម៌ ៤ មានហើយក្នុងអានន្ទ គប្បីជ្រាបថា **អព្ភូតធម៌** ។ ព្រះសូត្រសូម្បីទាំងពួង ដែលសួរហើយ បានសេចក្ដីដឹង និងសេចក្ដីត្រេកអរ មានចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហសូត្រ សង្ខារភាជនិយសូត្រ មហាបុណ្ណមសូត្រ ជាដើម គប្បីជ្រាបថា **វេទល្លៈ** ។

បទថា **ន អត្ថមញ្ញាយ ធម្មញ្ញាយ** (រកដឹងអត្ថ រកដឹងធម៌) សេចក្ដីថា មិនដឹងអដ្ឋកថា និងបាលី ។ បទថា **ធម្មានុធម្មប្បដិបន្នោ** (មិនបដិបត្តិធម៌សមគួរដល់ធម៌) សេចក្ដីថា រមែងមិនបដិបត្តិធម៌សមគួរដល់លោកុត្តរធម៌ ៩ គឺ វត្តបដិបត្តិខាងដើម ព្រមទាំងសីល ។ គប្បីជ្រាបសេចក្ដីក្នុងគ្រប់វារៈដោយឧបាយនេះ ។ ចំណែកវារៈទីមួយ ក្នុងព្រះសូត្រនេះ ត្រាស់ដល់បុគ្គលដែលមានសុតៈតិច ទាំងទ្រុស្តសីល ក្នុងវារៈទីពីរ ត្រាស់ដល់បុគ្គលដែលមានសុតៈតិចតែជាព្រះខីណាស្រព ក្នុងវារៈទីបី ត្រាស់ដល់បុគ្គលដែលមានសុតៈច្រើនតែទ្រុស្តសីល ក្នុងវារៈទីបួន ត្រាស់ដល់បុគ្គលដែលមានសុតៈច្រើន ទាំងជាព្រះខីណាស្រព ។

បទថា **សីលេសុ អសមាហិតោ** (មិនតាំងនៅក្នុងសីល) សេចក្តីថា មិនធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ។ បទថា **សីលតោ ច សុតេន ច** (ទាំងសីល ទាំងការស្តាប់) សេចក្តីថា អ្នកប្រាជ្ញទាំងឡាយរមែងតិះដៀលបុគ្គលនោះ ទាំងដោយចំណែកសីល ទាំងដោយចំណែកសុតៈយ៉ាងនេះថា បុគ្គលនេះទ្រុស្តសីល មានសុតៈតិច ។ បទថា **តស្ស សម្បជ្ជតេ សុតំ** (ការស្តាប់របស់គេសម្បូរ) សេចក្តីថា សុតៈរបស់បុគ្គលនោះ ឈ្មោះថា សម្បូរ ព្រោះហេតុនៃកិច្ច គឺ សុតៈដែលគេធ្វើហើយដោយសុតៈនោះ ។ បទថា **នាស្ស សម្បជ្ជតេ** (ការស្តាប់របស់គេមិនសម្បូរ) សេចក្តីថា សុតកិច្ច ឈ្មោះថា មិនសម្បូរ ព្រោះកិច្ច គឺ សុតៈដែលគេមិនបានធ្វើ ។ បទថា **ធម្មធរំ** (អ្នកទ្រទ្រង់ធម៌) បានដល់ ជាអ្នកចងចាំធម៌ដែលបានស្តាប់ហើយ ។ បទថា **សប្បញ្ញំ** (មានបញ្ញា) បានដល់ មានបញ្ញាល្អ ។ បទថា **នេក្ខំ ជម្ពោនទស្សេវ** (ដូចជាដុំនៃមាសជម្ពូនទ) សេចក្តីថា មាសធម្មជាតិ គេហៅថា ជម្ពូនទ ដូចដុំមាសជម្ពូនទនោះ គឺ ដូចមាសទឹក ៥ ។

ចប់អដ្ឋកថា អប្បសុតសូត្រទី ៦

# អដ្ឋកថា សង្ឃសោភណសូត្រទី ៧

## "បុគ្គលដែលធ្វើពួកក្រុមឲ្យស្អាត ៤ ពួក"

*គប្បីជ្រាបវិនិច្ឆ័យក្នុង សង្ឃសោភណសូត្រទី ៧ ដូចតទៅនេះ ៖*

*[៧] បទថា **វិយត្តា** (ដែលឆ្លាត) បានដល់ បុគ្គលដែលប្រកបដោយបញ្ញា ។ បទថា **វិនីតា** (មានវិន័យ) សេចក្តីថា អ្នកចូលដល់វិន័យ គឺដែលលោកណែនាំល្អ ។ បទថា **វិសារទា** (ក្លាហាន) សេចក្តីថា បុគ្គលប្រកបដោយសេចក្តីក្លាហាន គឺ ញាណសហគតដោយសោមនស្ស ។ បទថា **ធម្មធរា** (ទ្រទ្រង់ធម៌) គឺ ចងចាំធម៌ដែលស្តាប់មកហើយទុកបាន ។ បទថា **ភិក្ខុ ច សីលសម្បន្នោ** (ភិក្ខុសម្បូរដោយសីល) សេចក្តីថា ក្នុងគាថា ត្រាស់គុណតែម្យ៉ាងដល់បុគ្គលតែម្នាក់ទុកក៏ពិត តែគុណធម៌ទាំងពួងក៏រមែងគួរដល់លោកទាំងនោះសូម្បីទាំងអស់ ។*

ចប់អដ្ឋកថា សង្ឃសោភសូត្រទី ៧

# អដ្ឋកថា វេសារជ្ជសូត្រទី ៨

## *"វេសារជ្ជញាណរបស់ព្រះតថាគត"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វេសារជ្ជសូត្រទី ៨ ដូចតទៅនេះ ៖*

[៨] *ក្នុងបទថា **វេសារជ្ជានិ** (វេសារជ្ជញាណ) នេះ ធម៌ដែលជាបដិបក្ខចំពោះសេចក្ដីខ្លាច ឈ្មោះថា វេសារជ្ជៈ ។ វេសារជ្ជៈនេះ ជាឈ្មោះនៃសោមនស្សញាណដែលកើតឡើងដល់ព្រះតថាគត បុគ្គលពិចារណាឃើញការមិនមានសេចក្ដីខ្លាចក្នុងឋានៈ ៤ ។ បទថា **អាសភណ្ឋានំ** (ឋានៈដែលអង់អាច) បានដល់ ឋានៈដ៏ប្រសើរបំផុត គឺ ឋានៈខ្ពស់បំផុត ។ម្យ៉ាងទៀត អធិប្បាយថា ព្រះពុទ្ធក្នុងកាលមុនទាំងឡាយ ទ្រង់ជាអ្នកអង់អាច (សំដៅដល់) ឋានៈរបស់ព្រះពុទ្ធទាំងឡាយនោះ ។ ម្យ៉ាងទៀត គោមេហ្វូងរបស់គោមួយរយ ឈ្មោះថា ឧសភៈ , គោមេហ្វូងរបស់គោមួយពាន់ ឈ្មោះថា វសភៈ ឬគោឧសុភៈជាមេគោមួយរយក្រោល គោវសភៈជាមេគោមួយពាន់ក្រោល , គោនិសភៈ ប្រសើរបំផុតជាងគោទាំងអស់ អត់ធន់ចំពោះអន្តរាយគ្រប់យ៉ាង សម្បុរស គួរស្រឡាញ់ នាំការៈទៅបានច្រើន ទាំងមិនញាប់ញ័រដោយសំឡេងរន្ទះរយដង ពាន់ដង គោនិសភៈនោះ លោកបំណងថា គោឧសភៈ ក្នុងទីនេះ ។ នេះជាពាក្យហៅគោឧសភៈនោះ ដោយ*

បរិយាយ ។ ដែលឈ្មោះថា អាសភៈ (អង់អាច) ព្រោះនេះជាលក្ខណៈរបស់គោឧសភៈ ។ បទថា **ឋានំ** បានដល់ ការយកជើងទាំង ៤ កកាយផែនដីឈរដោយជំហររឹងមាំ ។ ក៏ឋានៈនេះ ឈ្មោះថា អាសភៈ ព្រោះដូចជាការឈរដ៏រឹងមាំរបស់គោឧសភៈ ។ ដូចគោឧសភៈ ដែលរាប់ថា គោនិសភៈ យកជើងទាំង ៤ កកាយផែនដីហើយ ឈរយ៉ាងមាំដោយមិនញាប់ញ័រ យ៉ាងណា សូម្បីព្រះតថាគតក៏កកាយផែនដី គឺ បរិស័ទ ៨ ដោយព្រះបាទ គឺ វេសារជ្ជញ្ញាណ ៤ មិនញាប់ញ័រចំពោះសត្រូវបច្ចាមិត្តណាៗក្នុងលោក ព្រមទាំងទេវលោក ឈរយ៉ាងមាំដោយជំហរ មិនញាប់ញ័រក៏ដូច្នោះ ។ តថាគតកាលឈរយ៉ាងមាំយ៉ាងនេះហើយ ទើបប្តេជ្ញាឋានៈនៃអ្នកអង់អាច ចូលដល់ មិនពោលលា ត្រឡប់លើកឡើងទុកក្នុងព្រះអង្គ ដោយហេតុនោះ ទើបត្រាស់ថា **អាសភណ្ឋានំ បដិជានាតិ** (ប្តេជ្ញាឋានៈដែលអង់អាច ដូច្នេះ ។

បទថា **បរិសាសុ** (បរិស័ទទាំងឡាយ) បានដល់ ក្នុងបរិស័ទទាំង ៨ ។ បទថា **សីហនាទំ នទតិ** (បន្លឺសីហនាទ) សេចក្តីថា បន្លឺសំឡេងសម្តែងអំណាចដ៏ប្រសើរបំផុត គឺ សំឡេងសម្តែងអំណាចរបស់រាជសីហ៍ ឬបន្លឺសំឡេងសម្តែងអំណាចស្មើដូចសំឡេងរបស់រាជសីហ៍ ។ សេចក្តីនេះ

គប្បីសម្តែងដោយសីហនាទសូត្រ ។ រាជសីហ៍ គេហៅថា **សីហៈ** ព្រោះអត់ធន់ និងទ្រាំក្នុងចំណី យ៉ាងណា តថាគតក៏យ៉ាងនោះ គេហៅថា សីហៈ ព្រោះទ្រង់អត់ធន់ក្នុងលោកធម៌ទាំងឡាយ និងព្រោះទ្រង់កម្ចាត់លទ្ធិដទៃ ។ ការបន្លឺរបស់សីហៈ ដែលលោកពោលយ៉ាងនេះ ហៅថា **សីហនាទ** ។ ក្នុងសីហនាទនោះ រាជសីហ៍ប្រកបដោយកម្លាំងរបស់រាជសីហ៍ ក្លាហានក្នុងទីទាំងពួង ប្រាសចាកការព្រឺរោមព្រឺស្បែក បន្លឺសីហនាទយ៉ាងណា សីហៈ គឺ ព្រះតថាគតក៏ដូច្នោះ ប្រកបដោយកម្លាំងរបស់តថាគត ជាអ្នកក្លាហានក្នុងបរិស័ទទាំង ៨ ប្រាសចាកការព្រឺរោមព្រឺស្បែក រមែងបន្លឺសីហនាទដែលប្រកបដោយលម្អនៃទេសនាផ្សេងៗ ដោយន័យជាអាទិ៍ថា យ៉ាងនេះជារូប ។ ដោយហេតុនោះ ទើបត្រាស់ថា **បរិសាសុ សីហនាទំ យទតិ** (បន្លឺសីហនាទក្នុងបរិស័ទទាំងឡាយ) ដូច្នេះ ។ បទថា **ព្រហ្ម** ក្នុងបទថា **ព្រហ្មចក្កំ បវត្តេតិ** (ប្រកាសព្រហ្មចក្ក) នេះ បានដល់ ចក្កដ៏ប្រសើរ ខ្ពង់ខ្ពស់ បរិសុទ្ធិ ។ ក៏ចក្កសព្ទនេះ រមែងប្រើក្នុងអត្ថថា

សម្បត្តិ លក្ខណៈ ចំណែកនៃរថ ឥរិយាបថ ទាន
ចក្ករតន៍ ធម្មចក្ក និងឧរចក្កជាដើម ក្នុងទីនេះដែល
ដឹងគ្នាមកថា ប្រើក្នុងអត្ថថា ធម្មចក្ក គប្បីបែងចែក

ធម្មចក្កឲ្យជាក់ច្បាស់ ជាពីរប្រការ ។

ពិតណាស់ ចក្កស័ព្ទនេះ រមែងប្រើក្នុងអត្ថថា **សម្បត្តិ** បានក្នុងបាលីជាដើមថា "ម្នាលភិក្ខុទាំងឡាយ ចក្ក ៤ ដែលទេវតា និងមនុស្សទាំងឡាយប្រកបព្រមហើយ" ដូច្នេះ ។ ប្រើក្នុងអត្ថថា **លក្ខណៈ** បានក្នុងបាលីនេះថា "ចក្កកើតលើផ្ទៃព្រះបាត" ដូច្នេះ ។ ប្រើក្នុងអត្ថថា **ចំណែកនៃរថ** បានក្នុងបាលីនេះថា "ដូចចក្កវិលទៅតាមស្នាមជើងគោ ដែលអូសរទេះ" ដូច្នេះ ។ ប្រើក្នុងអត្ថថា **ឥរិយាបថ** បានក្នុងបាលីនេះថា "មានចក្ក ៤ មានទ្វារ ៩" ដូច្នេះ ។ ប្រើក្នុងអត្ថថា **ទាន** បានក្នុងបាលីនេះថា "លោកចូរឲ្យ ចូរបរិភោគ និងចូរកុំប្រមាទ ចូរឲ្យចក្កប្រព្រឹត្តទៅដល់សព្វសត្វ" ដូច្នេះ ។ ប្រើក្នុងអត្ថថា **ចក្ករតន៍** បានក្នុងបាលីនេះថា "ចក្ករតន៍ដែលជាទិព្វបានប្រាកដហើយ" ដូច្នេះ ។ ប្រើក្នុងអត្ថថា **ធម្មចក្ក** បានក្នុងបាលីនេះថា ចក្កដែលតថាគតឲ្យប្រព្រឹត្តទៅហើយ" ដូច្នេះ ។ ប្រើក្នុងអត្ថថា **ឧរចក្រ** បានក្នុងបាលីនេះថា "កងចក្រវិលនៅលើក្បាលរបស់បុគ្គលត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់" ដូច្នេះ ។ ប្រើក្នុងអត្ថថា **បហរណចក្ក** (គ្រឿងប្រហារ) បានក្នុងបាលីនេះថា "បើប្រហារដោយចក្កមានមុខដោយជុំវិញ" ដូច្នេះ ។ ប្រើក្នុងអត្ថថា **អសនិមណ្ឌលៈ** បានក្នុងបាលីនេះថា ចក្កនៃខ្សែរន្ទះ" ដូច្នេះ ។

តែចក្កស័ព្ទនេះ ក្នុងទីនេះដឹងមកថា ប្រើក្នុងអត្ថថា **ធម្មចក្ក** ។

ក៏ធម្មចក្កនោះ មាន ២ គឺ បដិវេធញ្ញាណ ១ ទេសនាញ្ញាណ ១ ។ បណ្តាធម្មចក្ក ២ នោះ ញាណដែលបញ្ញាអប់រំ នាំអរិយផលមកថ្វាយព្រះអង្គឯង ឈ្មោះថា **បដិវេធញ្ញាណ** ។ ញាណដែលករុណាអប់រំ នាំអរិយផលមកឲ្យដល់សាវកទាំងឡាយ ឈ្មោះថា ទេសនាញ្ញាណ ។ បណ្តាញ្ញាណ ២ យ៉ាងនោះ បដិវេធញ្ញាណមាន ២ គឺ ដែលកំពុងកើតឡើង ដែលកើតឡើងហើយ ។ ក៏បដិវេធញ្ញាណនោះ ឈ្មោះថា កំពុងកើតឡើង ចាប់ពីកាលដែលទ្រង់ចេញព្រះផ្នួសដរាបដល់អរហត្តមគ្គ , ឈ្មោះថា កើតឡើងហើយក្នុងខណៈនៃអរហត្តផល ។ ម្យ៉ាងទៀត ឈ្មោះថា កំពុងកើតឡើង រាប់ពីភពជាន់តុសិត ដរាបដល់អរហត្តមគ្គ ត្រង់មហាពោធិបល្ល័ង្ក , ឈ្មោះថាកើតឡើងហើយ ក្នុងខណៈនៃអរហត្តផល ។ ម្យ៉ាងទៀត ឈ្មោះថា កំពុងកើតឡើង រាប់ពីគ្រាព្រះទីបង្ករពុទ្ធ ដរាបដល់អរហត្តមគ្គត្រង់ពោធិបល្ល័ង្ក , ឈ្មោះថា កើតឡើងហើយ ក្នុងខណៈនៃអរហត្តផល ។ ទេសនាញ្ញាណក៏មាន ២ គឺ ដែលកំពុងប្រព្រឹត្តទៅ ដែលប្រព្រឹត្តទៅហើយ ។ ទេសនាញ្ញាណនោះ ឈ្មោះថា កំពុងប្រព្រឹត្តទៅ ដរាបដល់សោតាបត្តិមគ្គរបស់ព្រះកោណ្ឌញ្ញៈ , ឈ្មោះថា ប្រព្រឹត្តទៅហើយ ក្នុងខណៈនៃសោតាបត្តិ-

ផល ។ បណ្តាញាណទាំង ២ នោះ បដិវេធញាណជាលោកុត្តរៈ ទេសនា-ញាណជាលោកិយៈ ។ ក៏ញាណទាំងពីរនោះ មិនទូទៅដល់សាវកដទៃ ជាញាណដែលកើតពីព្រះឱរៈរបស់ព្រះពុទ្ធទាំងឡាយ ប៉ុណ្ណោះ ។

បទថា **សម្មាសម្ពុទ្ធស្ស តេ បដិជានតោ** (ទ្រង់ប្តេជ្ញាថាជាព្រះសម្មាសម្ពុទ្ធ) សេចក្តីថា ទ្រង់ប្តេជ្ញាយ៉ាងនេះថា តថាគតជាសម្មាសម្ពុទ្ធ ធម៌ទាំងឡាយតថាគតបានត្រាស់ដឹងហើយ ។ បទថា **អនភិសម្ពុទ្ធា** (មិនទាន់ដឹង) សេចក្តីថា ធម៌ទាំងឡាយនេះ ទ្រង់មិនទាន់ដឹង ។ បទថា **តត្រ វត** (ក្នុងប្រការនោះ) គឺ ក្នុងធម៌ដែលទ្រង់សម្តែងទាំងនោះ យ៉ាងនេះថា មិនទាន់ដឹង ។ បទថា **សហធម្មេន** (ដោយត្រូវដល់ហេតុ) បានដល់ ដោយពាក្យព្រមដោយហេតុ ដោយការណ៍ ។ បុគ្គលក្តី ធម៌ក្តី លោកបំណងថា និមិត្តក្នុងបទថា **និមិត្តមេតំ** (និមិត្តនោះ) នេះ ។ ក្នុងសេចក្តីនេះ មានអត្ថដូច្នេះថា បុគ្គលណានឹងចោទតថាគត តថាគតក៏មិនទាន់ឃើញបុគ្គលនោះ បុគ្គលសម្តែងធម៌ណាហើយ នឹងចោទតថាគតថា ធម៌ឈ្មោះនេះ ទ្រង់មិនទាន់ដឹង ដូច្នេះ តថាគតក៏មិនឃើញធម៌នោះ ។ បទថា **ខេមប្បត្តោ** បានដល់ ដល់នូវសេចក្តីក្សេម ។ ពីរបទដ៏សេស ក៏ជាវេវចនៈរបស់បទនេះនុ៎ះឯង ។ ពាក្យទាំងអស់ ត្រាស់បំណងដល់វេសារជ្ជញាណតែម្យ៉ាង ។

ព្រោះថា ព្រះទសពលកាលទ្រង់មិនឃើញបុគ្គលដែលចោទ ឬធម៌ដែលមិនទាន់ដឹង ដែលជាហេតុចោទថា ធម៌ឈ្មោះនេះ ទ្រង់មិនទាន់ដឹង ទ្រង់ពិចារណាឃើញថា តថាគតត្រាស់ដឹងតាមសេចក្តីពិតហើយ ទើបប្រកាសថា យើងជាពុទ្ធៈ ដូច្នេះ ទើបកើតសោមនស្សដ៏មានកម្លាំង ញាណដែលប្រកបដោយសោមនស្សនោះ ឈ្មោះថា **វេសារជ្ជៈ** ។ ទ្រង់សំដៅដល់វេសារជ្ជញាណនោះ ទើបត្រាស់បទជាដើមថា **ដល់នូវសេចក្តីក្សេម** ដូច្នេះ ។ ក្នុងគ្រប់បទ គប្បីជ្រាបដោយន័យយ៉ាងនេះ ។

ក្នុងបទថា **អន្តរាយិកា ធម្មា** (ធម៌ដែលនាំឲ្យកើតអន្តរាយ) នេះ ឈ្មោះថា ធម៌ដែលធ្វើអន្តរាយ ព្រោះធ្វើអន្តរាយ ។ ធម៌ដែលធ្វើអន្តរាយទាំងនោះ ដោយអត្ថ បានដល់ អាបត្តិ ៧ កង ដែលតាំងចិត្តកន្លងល្មើស ។ សេចក្តីពិត ទោសដែលតាំងចិត្តកន្លងល្មើស ដោយទីបំផុតសូម្បីអាបត្តិទុក្កដ និងទុព្ភាសិត ក៏រមែងធ្វើអន្តរាយដល់មគ្គ និងផលបាន ។ តែក្នុងទីនេះ បំណងយកមេថុនធម្ម ។ ព្រោះថា កាលភិក្ខុរូបណាមួយ សេពមេថុនធម្ម រមែងអន្តរាយដល់មគ្គ និងផល ។ បទថា **យស្ស ខោ បន តេ អត្ថាយ** (លោក... ដើម្បីប្រយោជន៍ណា) សេចក្តីថា ដើម្បីប្រយោជន៍ដល់ធម៌ណា ក្នុងបណ្តាធម៌ជាទីអស់រាគៈជាដើម ។ បទថា **ធម្មោ ទេសិតោ**

(សម្តែងធម៌) សេចក្តីថា លោកពោលធម៌ មានអសុភកាវនាជាដើម ។ បទថា **តត្រ វត មំ** (“ចោទតថាគត” ក្នុងប្រការនោះ) គឺ ក្នុងធម៌ដែលមិននាំសត្វចេញចាកទុក្ខនោះ ។ បទដ៏សេស គប្បីជ្រាបដោយន័យដែលពោលទុកហើយក្នុងវិន័យ ។

បទថា **វាទបថា** (ពាក្យណាទីមួយ) គឺ វាទៈទាំងឡាយទុំះឯង ។ បទថា **បុថុ** (ដ៏ក្រាស់) គឺ ច្រើន ។ បទថា **សិតា** (ដែលតែងទុក) គឺ ដែលចងក្រងជាបញ្ហាឡើង ។ម្យ៉ាងទៀត បទថា **បុថុស្សិតា** (ដែលតែងទុកដ៏ច្រើន បានដល់ វាទៈដែលត្រៀម គឺ ចាត់ចែងទុកច្រើន ។ ម្យ៉ាងទៀត ឈ្មោះថា **តែងទុកដ៏ច្រើន** ព្រោះសមណព្រាហ្មណ៍ជាច្រើនចងក្រងទុក ។ បទថា **យំ និស្សិតា** (អាស្រ័យពាក្យណាទីមួយ) បានដល់ សូម្បីឥឡូវនេះ សមណព្រាហ្មណ៍អាស្រ័យវាទៈណា ។ បទថា **ន តេ ភវន្តិ** (រមែងមិនមានផល) សេចក្តីថា គន្លងវាទៈទាំងនោះ រមែងមិនមាន គឺ វិនាសទៅ ។ បទថា **ធម្មចក្កំ** (ធម្មចក្ក) នោះ ជាឈ្មោះរបស់ទេសនាញាណក៏មាន បដិវេធញ្ញាណក៏មាន ។ បណ្តាញាណទាំងពីរនោះ ទេសនាញាណជាលោកិយៈ បដិវេធញ្ញាណជាលោកុត្តរៈ ។ បទថា **កេវលី** (អ្នកដល់ព្រមលោកុត្តរធម៌) បានដល់ ទ្រង់ដល់ព្រមលោកុត្តរៈដោយសព្វគ្រប់ ។ បទថា **តាទិសំ** (បុគ្គល

*ដូច្នោះ) គឺ បុគ្គលជាយ៉ាងនោះ ។*

ចប់អដ្ឋកថា វេសារជ្ជសូត្រទី ៨

# អដ្ឋកថា តណ្ហុប្បាទសូត្រទី ៩

## “ទីកើតតណ្ហា ៤ យ៉ាង”

*គប្បីជ្រាបវិនិច្ឆ័យក្នុង តណ្ហុប្បាទសូត្រទី ៩ ដូចតទៅនេះ ៖*

[៩] *ឈ្មោះថា* ***ឧប្បាទា*** *(ហេតុកើតតណ្ហា) ព្រោះជាទីកើតឡើងនៃតណ្ហាទាំងនោះ ។ សួរថា អ្វីកើត ។ ឆ្លើយថា តណ្ហា ។ ការកើតឡើងនៃតណ្ហា ឈ្មោះថា តណ្ហុប្បាទៈ អធិប្បាយថា វត្ថុនៃតណ្ហា ហេតុនៃតណ្ហា ។ បទថា* ***ចីវរហេតុ*** *(ព្រោះចីវរជាហេតុ) សេចក្តីថា តណ្ហា រមែងកើតព្រោះមានចីវរជាហេតុថា យើងនឹងបានចីវរដែលគួរពេញចិត្តក្នុងទីណា ។ សព្ទថា* ***ឥតិ*** *(យ៉ាងនេះយ៉ាងនោះ) ក្នុងបទថា* ***ឥតិភវាភវហេតុ*** *(ព្រោះការមានការមិនមានយ៉ាងនេះយ៉ាងនោះ) នេះ ជានិបាតចុះក្នុងអត្ថថា ឧបមា ។ អធិប្បាយថា តណ្ហា រមែងកើតឡើងព្រោះការមិនមានយ៉ាងនេះយ៉ាងនោះជាហេតុ ដូចដែលកើតឡើងព្រោះមានចីវរជាដើម ជាហេតុ ។ចំណែកក្នុងបទថា* ***ភវាភវោ*** *(ការមានការមិនមាន) នេះ បំណងយកទឹកដោះថ្លា និងទឹកដោះខាប់ជាដើម ដែលប្រណីត និងប្រណីតជាងគ្នា ។ អាចារ្យពួកខ្លះពោលថា ភពដែលប្រណីតជាង និងប្រណីតជាទីបំផុតក្នុងសម្បត្តិភព ដូច្នេះក៏មាន ។*

បទថា ***តណ្ហាទុតិយោ*** *(មានតណ្ហាជាសំលាញ់) សេចក្ដីថា ក៏សត្វនេះអន្ទោលទៅក្នុងសង្សារវដ្ដ ដែលសត្វនោះឯងមិនដឹងទីបញ្ចប់ មិនមែនអន្ទោលទៅតែខ្លួនឯងប៉ុណ្ណោះ តែបានតណ្ហាជាសម្លាញ់អន្ទោលទៅផង ព្រោះហេតុនោះ ទើបត្រាស់ថា* ***មានតណ្ហាជាសំលាញ់*** *ដូច្នេះ ។ ក្នុងបទថា* ***ឥត្ថភាវញ្ញថាភាវំ*** *នេះ អត្តភាពនេះ ឈ្មោះថា ឥត្ថភាវៈ អត្តភាពក្នុងអនាគត ឈ្មោះថា អញ្ញថាភាវៈ ។ម្យ៉ាងទៀត អត្តភាពសូម្បីដទៃជាយ៉ាងនេះ ឈ្មោះថា ឥត្ថភាវៈ ដែលមិនមែនជាយ៉ាងនេះ ឈ្មោះថា អញ្ញថាភាវៈ ។ ដែលជាយ៉ាងនេះ និងជាយ៉ាងដទៃនោះ ។ បទថា* ***សំសារំ*** *(សង្សារ) បានដល់ តំណនៃខន្ធ ធាតុ អាយតនៈ ។ បទថា* ***នាតិវត្តតិ*** *(មិនកន្លងផុត) បានដល់ រួចផុតមិនបាន ។ បទថា* ***ឯតមាទីនវំ ញត្វា*** *(ដឹងទោសនោះ) សេចក្ដីថា ភិក្ខុដឹងដល់ទោសក្នុងខន្ធដែលជាអតីត អនាគត បច្ចុប្បន្ន យ៉ាងនេះហើយ ។ បទថា* ***តណ្ហំ ទុក្ខស្ស សម្ភវំ*** *(តណ្ហាជាហេតុកើតទុក្ខ) សេចក្ដីថា ដឹងដល់តណ្ហាយ៉ាងនេះថា តណ្ហានេះ ជាហេតុកើត ជាដែនកើត ជាហេតុនៃវដ្ដទុក្ខ ។ សេចក្ដីដែលភិក្ខុនេះ ចម្រើនវិបស្សនាហើយ សម្រេចព្រះអរហត្ត ទ្រង់សម្ដែងដោយហេតុប្រមាណប៉ុណ្ណោះ ។ ឥឡូវនេះ កាលទ្រង់សរសើរភិក្ខុជាខីណាស្រពនោះ ទើបត្រាស់ថា* ***វីតតណ្ហោ*** *(ជា*

អ្នកអស់តណ្ហា) ជាដើម ។ បណ្ដាបទទាំងនោះ បទថា **អនាទនោ** (មិនមានសេចក្ដីប្រកាន់) បានដល់ មិនប្រកាន់មាំ ។ បទថា **សតោ ភិក្ខុបរិព្វជេ** (គប្បី... មានសតិសម្បជញ្ញៈ) សេចក្ដីថា ភិក្ខុដែលជាខីណាស្រពជាអ្នកបរិបូរណ៍ដោយសតិសម្បជញ្ញៈ មានសតិសម្បជញ្ញៈប្រព្រឹត្តទៅហើយ ។ ដូច្នោះ ក្នុងសូត្រត្រាស់ដល់វដ្តៈ ក្នុងគាថាត្រាស់ទាំងវដ្តៈទាំងវិវដ្តៈ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា តណ្ហុប្បាទសូត្រទី ៩

# អដ្ឋកថា យោគសូត្រទី ១០

## *"យោគៈ ៤ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង យោគសូត្រទី ១០ ដូចតទៅនេះ ៖*

[១០] *កិលេសឈ្មោះថា* ***យោគៈ*** *ព្រោះចងសត្វទុកក្នុងវដ្តៈ ។ ក្នុងបទថា* ***កាមយោគោ*** *(កាមយោគៈ) ជាអាទិ៍ តម្រេកប្រកបដោយកាមគុណ ៥ ឈ្មោះថា* ***កាមយោគៈ*** *។ តម្រេកដោយអំណាចសេចក្តីពេញចិត្ត ក្នុងរូបភព និងអរូបភព ឈ្មោះថា* ***ភវយោគៈ*** *។ សេចក្តីពេញចិត្តក្នុងឈានក៏យ៉ាងនោះ ។ រាគៈប្រកបដោយសស្សតទិដ្ឋិ និងទិដ្ឋិ ៦២ ឈ្មោះថា* ***ទិដ្ឋិយោគៈ*** *។ សេចក្តីមិនដឹងក្នុងសច្ចៈ ៤ ឈ្មោះថា* ***អវិជ្ជាយោគៈ*** *។ មួយវិញទៀត ឈ្មោះថា* ***កាមយោគៈ*** *ព្រោះប្រកបសត្វទុកក្នុងកាម ។ ឈ្មោះថា* ***ភវយោគៈ*** *ព្រោះប្រកបសត្វទុកក្នុងភព ។ ឈ្មោះថា* ***ទិដ្ឋិយោគៈ*** *ព្រោះប្រកបសត្វទុកក្នុងទិដ្ឋិ ។ ឈ្មោះថា* ***អវិជ្ជាយោគៈ*** *ព្រោះប្រកបសត្វទុកក្នុងអវិជ្ជា ។ ពាក្យដូចពោលមកនេះ ជាឈ្មោះរបស់ធម៌ដែលពោលទុកហើយក្នុងខាងដើម ។*

*ឥឡូវនេះ កាលទ្រង់អធិប្បាយធម៌ទាំងនោះឲ្យពិស្តារ ទើបត្រាស់ថា* ***កតមោ ច ភិក្ខវេ*** *(ដូចម្តេច) ជាអាទិ៍ ។ បណ្តាបទទាំងនោះ បទថា* ***សមុទយំ***

(ការកើត) គឺ ការឧប្បត្តិ ។ បទថា **អត្ថង្គមំ** (ការរលត់) គឺ ការបែកធ្លាយ ។ បទថា **អស្សាទំ** (គុណ) គឺ សេចក្តីរីករាយ ។ បទថា **អាទីនវំ** (ទោស) គឺ ទោសដែលកើតពីសេចក្តីរីករាយ ។ បទថា **និស្សរណំ** (ការរលាស់ចេញ) គឺ ការរលាស់ចោល ។

បទថា **កាមេសុ** (ក្នុងកាម) គឺ ក្នុងវត្ថុកាម ។ បទថា **កាមរាគោ** (សេចក្តីត្រេកអរក្នុងកាម) គឺ រាគៈកើតព្រោះប្រារព្ធកាម ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះឯង ។ បទថា **អនុសេតិ** (រមែងជ្រុលជ្រប់) គឺ បង្កើត ។ គប្បីជ្រាបសេចក្តីក្នុងបទគ្រប់បទយ៉ាងនេះថា បទថា **អយំ វុច្ចតិ ភិក្ខវេ កាមយោគោ** (នេះហៅថា កាមយោគៈ) សេចក្តីថា ម្នាលភិក្ខុទាំងឡាយ នេះហៅថា កិលេសជាហេតុប្រកប កិលេសជាគ្រឿងចងសត្វទុកក្នុងកាមទាំងឡាយ ។

បទថា **ផស្សាយតនានំ** (នៃផស្សាយតនៈ) បានដល់ ព្រោះហេតុនៃចក្ខុសម្ផស្សជាដើមរបស់អាយតនៈទាំងឡាយ មានចក្ខុជាដើម ។ បទថា **អវិជ្ជា អញ្ញាណំ** (ការមិនដឹង សេចក្តីល្ងង់ខ្លៅ) សេចក្តីថា អវិជ្ជា គឺ ការមិនដឹង ព្រោះជាបដិបក្ខដល់សេចក្តីដឹង ។ បទថា **ឥតិ** ស័ព្ទ ក្នុងបទនេះថា **ឥតិកាមយោគោ** (កាមយោគៈ ដូច្នេះ) គប្បីប្រកបនឹងយោគៈសូម្បីទាំង

៤ ថា កាមយោគៈ ដូច្នេះ ភវយោគៈ ដូច្នេះ ជាដើម ។

បទថា **សម្បយុត្តោ** (ប្រកប) បានដល់ បុគ្គលដែលបាបធម៌រួបរឹតហើយ ។ បទថា **បាបកេហិ** (បាប) បានដល់ ដ៏លាមក ។ បទថា **អកុសលេហិ** (អកុសល) បានដល់ កើតពីសេចក្ដីមិនឆ្លាត ។ បទថា **សង្កិលេសិកេហិ** (ជាហេតុធ្វើចិត្តឲ្យសៅហ្មង) គឺ ជាហេតុធ្វើចិត្តឲ្យសៅហ្មង អធិប្បាយថា ប្រទូស្តដល់ភាពថ្លាផូរផង់នៃចិត្តដែលផូរផង់ហើយ ។ បទថា **បោនោព្ភវិកេហិ** បានដល់ ជាហេតុឲ្យកើតក្នុងភពថ្មី ។ បទថា **សទរេហិ** (ប្រព្រឹត្តទៅជាមួយសេចក្ដីក្ដៅក្រហាយ) បានដល់ មានសេចក្ដីខ្វល់ខ្វាយ ។ បទថា **ទុក្ខវិបាកេហិ** (មានទុក្ខជាផល) បានដល់ កាលដល់វេលាឲ្យផលក៏ធ្វើទុក្ខឲ្យកើតឡើង ។ បទថា **អាយតឹជាតិជរាមរណិកេហិ** (ធ្វើឲ្យមានជាតិ ជរា មរណៈតទៅ) បានដល់ ឲ្យកើតជាតិ ជរា មរណៈក្នុងអនាគតរឿយៗ ។ បទថា **តស្មា អយោគក្ខេមីតិ វុច្ចតិ** (ព្រោះហេតុនោះ តថាគតទើបហៅបុគ្គលនោះថា មិនរួចផុតចាកយោគៈ) សេចក្ដីថា ក៏ព្រោះហេតុដែលបុគ្គលលះបង់យោគៈមិនបាន រមែងជាអ្នកប្រកបដោយធម៌ទាំងនោះ ដូច្នោះ តថាគតទើបហៅថា អយោគក្ខេមី (មិនក្សេមចាកយោគៈ) ព្រោះគេមិនទាន់សម្រេចព្រះនិព្វានដែលក្សេមចាកយោគៈទាំង ៤ នោះ ។

បទថា **វិសំយោគា** (ការប្រាស) គឺ ហេតុនៃសេចក្ដីប្រាសចាក ។ បទថា **កាមយោគវិសំយោគោ** (ការប្រាសចាកកាមយោគៈ) គឺ ហេតុនៃការប្រាសចាកកាមយោគៈ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះឯង ។ បណ្ដាបទទាំងនោះ ការសម្ដែងអសុភកម្មដ្ឋាន ជាហេតុឲ្យប្រាសចាកកាមយោគៈ អនាគាមិមគ្គ ដែលព្រះអនាគាមីបានសម្រេចហើយ ព្រោះធ្វើអសុភឈាននោះឲ្យជាបាទ ឈ្មោះថា ជាការប្រាសចាកកាមយោគៈដោយពិត ។ អរហត្តមគ្គ ឈ្មោះថា **ជាការប្រាសចាកភវយោគៈ** សោតាបត្តិមគ្គ ឈ្មោះថា **ជាការប្រាសចាកទិដ្ឋិយោគៈ** អរហត្តមគ្គ ឈ្មោះថា **ជាការប្រាសចាកអវិជ្ជាយោគៈ** ។ ឥឡូវនេះ កាលទ្រង់អធិប្បាយការប្រាសចាកទាំងនោះ ឲ្យពិស្ដារ ទើបត្រាស់ថា **កតមោ ច ភិក្ខវេ** (ដូចម្ដេច) ជាអាទិ៍ ។ សេចក្ដីនៃព្រះតម្រាស់នោះ គប្បីជ្រាបដោយន័យដូចពោលហើយ ។

បទថា **ភវយោគេន ចូភយំ** (ភវយោគៈ និងទិដ្ឋិយោគៈទាំងពីរ) សេចក្ដីថា ប្រកបដោយភវយោគៈ និងនៅប្រកបដោយភវយោគៈ ទិដ្ឋិយោគៈ សូម្បីទាំងពីរឲ្យក្រៃលែងឡើងទៀត គឺ ប្រកបដោយយោគៈឯណានីមួយ ។ បទថា **បុរក្ខតា** (ចោមរោម) បានដល់ ធ្វើអវិជ្ជាទុកខាងមុខ គឺ ហែហម ។ បទថា **កាមេ បរិញ្ញាយ** (កំណត់ដឹងកាម) បានដល់ កំណត់ដឹងកាមសូម្បី

*ទាំងពីរយ៉ាង ។ បទថា **ភវយោគញ្ច សព្វសោ** (និងភវយោគៈដោយប្រការទាំងពួង) បានដល់ កំណាត់ដីងភវយោគៈទាំងអស់នោះឯង ។ បទថា **សមូហច្ច** (ដក) បានដល់ ដកអស់ហើយ ។ បទថា **វិភជយំ** (ទម្លាយ) បានដល់ កំពុងទម្លាយ គឺ កម្ចាត់ហើយ ។ ក៏កាលពោលថា **វិភជន្តោ** (កំពុងទម្លាយ) ក៏ជាការពោលដល់មគ្គ កាលពោលថា **វិភជេត្វា** (ទម្លាយហើយ) ក៏ជាការពោលដល់ផល ។ បទថា **មុនី** គឺ ព្រះខីណាស្រព ។ ដូច្នោះ ក្នុងសូត្រនេះក្តី ក្នុងគាថាក្តី ទើបត្រាស់ទាំងវដ្ដៈ ទាំងវិវដ្ដៈ ដូច្នេះឯង ។*

ចប់អដ្ឋកថា យោគសូត្រទី ១០

## ចប់ភណ្ឌគាមវគ្គទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# ចរវគ្គទី ២

## អដ្ឋកថា ចរសូត្រទី ១

### *"ភិក្ខុមិនលះអកុសលវិតក្កៈ ៣ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចរសូត្រទី ១ ដូចតទៅនេះ ៖*

[១១] *បទថា* ***អធិវាសេតិ*** *(ទទួលយក) បានដល់ លើកឡើងទុកឲ្យនៅក្នុងចិត្ត (គឺតាំងទុក) ។ បទថា* ***ន បជហតិ*** *(មិនលះបង់) បានដល់ មិនលះបង់ ។ បទថា* ***ន វិនោទេតិ*** *(មិនបន្ទោបង់) បានដល់ មិននាំចេញ ។ បទថា* ***ន ព្យន្តីករោតិ*** *(មិនកម្ចាត់) បានដល់ មិនធ្វើឲ្យដល់ទីបំផុត គឺមិនកម្ចាត់ដែនខេត្ត ។ បទថា* ***ន អនភាវំ គមេតិ*** *(មិនធ្វើឲ្យអស់ទៅ) បានដល់ មិនធ្វើឲ្យសូន្យទៅ គឺ វិនាសទៅ បានដល់ រលត់រលាយទៅ ។ បទថា* ***ចរម្បិ*** *(សូម្បីកាលដើរទៅ) គឺ សូម្បីដើរ ។ បទថា* ***អនាតាបី*** *(ជាអ្នកមិនមានសេចក្តីព្យាយាមខ្លាំងក្លា គឺ មិនមានសេចក្តីព្យាយាម ។ បទថា* ***អនោត្តប្បី*** *(មិនមានការភ័យខ្លាចបាប) គឺ វៀរចាកការខ្លាចការតិះដៀល ។ បទថា* ***សតតំ*** *(ជានិច្ច) គឺ សព្វកាល ។ បទថា* ***សមិតំ*** *គឺ មិនមានរវាំង ។ អ្នកសិក្សាជ្រាបសេចក្តីគ្រប់បទយ៉ាងនេះហើយ គប្បីជ្រាបសេចក្តីតាមការ*

បរិយាយដែលពោលទុកហើយក្នុងសុក្កបក្ខ (ចំណែកធម៌ស) ។

ក្នុងគាថា គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **គេហនិស្សិតំ** (ដែលទាក់ទងជាមួយផ្ទះ) បានដល់ អាស្រ័យកិលេស ។ បទថា **មោហនេយ្យេសុ** (ក្នុងអារម្មណ៍ដែលជាទីតាំងនៃសេចក្តីវង្វេង) បានដល់ ក្នុងអារម្មណ៍ដែលឲ្យកើតសេចក្តីវង្វេង ។ បទថា **អភព្វោ** (មិនគួរ) បានដល់ មិនដូចកាជនៈដែលជាទីទ្រទ្រង់ ។ បទថា **ផុដ្ឋុំ សម្ពោធិមុត្តមំ** (ដើម្បីត្រាស់ដឹងសម្ពោធិញ្ញាណ) បានដល់ ដើម្បីសម្ផស្សឧត្តមញាណ ពោលគឺ ព្រះអរហត្ត ។

ចប់អដ្ឋកថា ចរសូត្រទី ១

# អដ្ឋកថា សីលសូត្រទី ២

## "បារិសុទ្ធិសីល ៤"

គប្បីជ្រាបវិនិច្ឆ័យក្នុង សីលសូត្រទី ២ ដូចតទៅនេះ ៖

[១២] បទថា **សម្បន្នសីលា** (បុគ្គលមានសីលដល់ព្រម) បានដល់ អ្នកទាំងឡាយមានសីលបរិបូរណ៍ ។ បទថា **សម្បន្នបាតិមោក្ខា** (មានបាតិមោក្ខដល់ព្រម) បានដល់ មានបាតិមោក្ខបរិបូរណ៍ ។ បទថា **បាតិមោក្ខសំវរសំវុតា** (សង្រួមក្នុងព្រះបាតិមោក្ខ) សេចក្តីថា អ្នកទាំងឡាយចូរជាអ្នកសង្រួម បិទ ប្រកបដោយបាតិមោក្ខសំវរសីលនៅចុះ ។ បទថា **អាចារគោចរសម្បន្នា** (ដល់ព្រមដោយមារយាទ និងគោចរ:) សេចក្តីថា អ្នកទាំងឡាយចូរជាអ្នកដល់ព្រម គឺ ប្រកបព្រមដោយអាចារ: និងគោចរ:ចុះ ។ បទថា **អណុមត្តេសុ វជ្ជេសុ** (ក្នុងទោសមានប្រមាណតិច) បានដល់ ក្នុងទោសទាំងឡាយមានប្រមាណតិច ។ បទថា **ភយទស្សាវិនោ** (មានប្រក្រតីឃើញភ័យ) សេចក្តីថា ជាអ្នកមានប្រក្រតីឃើញទោសដែលមានប្រមាណតិចទាំងនោះថា ជាភ័យ ។ បទថា **សមាទាយ សិក្ខថ សិក្ខាបទេសុ** (សមាទានសិក្សានៅក្នុងសិក្ខាបទទាំងឡាយចុះ) សេចក្តីថា អ្នកទាំងឡាយចូរសមាទានកាន់យកនូវសិក្ខាបទដែលគួរសមាទាននោះៗ ក្នុងចំណែកនៃសិក្ខាទាំងអស់

ហើយសិក្សា ។ លុះទ្រង់ណែនាំ និងត្រាស់សរសើរក្នុងគុណដែលបានហើយ ដោយការត្រាស់ធម៌ប្រមាណប៉ុណ្ណេះថា **សម្បន្នសីលានំ ។បេ។ សិក្ខាបទេសុ** (កាលអ្នកទាំងឡាយមានសីលដល់ព្រម ។ល។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ) ឥឡូវនេះ កាលទ្រង់សម្តែងប្រយោជន៍ដែលនឹងគប្បីធ្វើឲ្យក្រៃលែងឡើងទៅ ទើបត្រាស់ថា **កិមស្ស** (អ្វី) ដូច្នេះជាដើម ។ ក្នុងបទនោះ បទថា **អ្វី** គឺ នឹងគប្បីមានអ្វីហ្ន៎ ។

បទថា **យតំ ចរេ** (គប្បីដើរសង្រួម) សេចក្តីថា ភិក្ខុគប្បីដើរសង្រួម ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។ បទថា **អច្ឆេ** បានដល់ គប្បីអង្គុយចុះ ។ បទថា **យតមេតំ បសារយេ** (លាអវយវៈចេញក៏សង្រួម) សេចក្តីថា គប្បីលាអវយវៈតូចធំសង្រួម គឺ រៀបរយ ។ បទថា **ឧទ្ធំ** គឺ ខាងលើ ។ បទថា **តិរិយំ** ខាងទទឹង ។ បទថា **អបាចីនំ** ខាងក្រោម ។ បញ្ចក្ខន្ធទាំងអតីត បច្ចុប្បន្ន និងអនាគត ត្រាស់ដោយហេតុប្រមាណប៉ុណ្ណេះ ។ បទថា **យាវតា** (គ្រប់) ជាបទដែលសម្តែងសេចក្តីកំណត់ ។ បទថា **ជគតោ គតិ** (ភូមិជាទីទៅរបស់សត្វ) បានដល់ សេចក្តីសម្រេចនៃលោក ។ បទថា **សមវេក្ខិតា ច ធម្មានំ ខន្ធានំ ឧទយព្វយំ** (ពិចារណាមើលការកើតឡើង ការវិនាសទៅនៃកងធម៌ទាំងឡាយ) សេចក្តីថា ពិចារណាមើលការកើតឡើង និង

សេចក្ដីសូន្យទៅនៃធម៌ គឺ បញ្ចក្ខន្ធដែលជាអតីតជាដើមទាំងនោះ ក្នុងលោកទាំងពួង គឺ បានពិចារណាឃើញដោយប្រពៃដោយលក្ខណៈ ៥០ ដែលលោកពោលថា កាលឃើញការកើតនៃបញ្ចក្ខន្ធ ក៏ពិចារណាឃើញលក្ខណៈ ២៥ កាលឃើញការសូន្យទៅ ក៏ពិចារណាឃើញលក្ខណៈ ២៥ ។ បទថា **ចេតោសមថសាមីចី** (បដិបទាដែលសមគួរដល់សេចក្ដីស្ងប់ចិត្ត) បានដល់វត្តបដិបត្តិដែលសមគួរដល់សេចក្ដីស្ងប់ចិត្ត ។ បទថា **សិក្ខមានំ** (អ្នកសិក្សា) សេចក្ដីថា កាលបដិបត្តិ គឺ បំពេញហើយ ។ បទថា **ឯកោទិភូតោ** (អ្នកមានចិត្តតែមួយ) បានដល់ ទំនេរ ។ បទថា **អាហុ** (ហៅ) គឺ ពោលហើយ ។ បទដ៏សេសក្នុងសូត្រនេះ ងាយទាំងអស់នោះឯង ។ ក៏ក្នុងសូត្រនេះ ត្រាស់លាយគ្នាជាមួយសីល ក្នុងគាថាត្រាស់ដល់ភិក្ខុជាព្រះខីណាស្រព ។

ចប់អដ្ឋកថា សីលសូត្រទី ២

# អដ្ឋកថា បធានសូត្រទី ៣

## *"សម្មប្បធាន ៤"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បធានសូត្រទី ៣ ដូចតទៅនេះ ៖*

[១៣] *បទថា* ***សម្មប្បធានានិ*** *បានដល់ សេចក្តីព្យាយាមល្អ គឺសេចក្តីព្យាយាមខ្ពស់បំផុត ។ បទថា* ***សម្មប្បធាន*** *(មានសេចក្តីព្យាយាមត្រូវ) បានដល់ ព្រះខីណាស្រពអ្នកមានសេចក្តីព្យាយាមបរិបូរណ៍ ។ បទថា* ***មារធេយ្យាភិភូតា*** *(គ្របសង្កត់នូវអន្ទាក់មារបាន) សេចក្តីថា ព្រះខីណាស្រពទាំងនោះគ្របសង្កត់ ឈានកន្លង អាណាចក្រនៃមារ ពោលគឺ តេភូមិកវដ្តៈ ។ បទថា* ***តេ អសិតា*** *(ជាអ្នកដែលកិលេសមិនអាស្រ័យ) បានដល់ ព្រះខីណា-ស្រពទាំងឡាយនោះ ឈ្មោះថា ជាអ្នកដែលកិលេសមិនអាស្រ័យហើយ ។ បទថា* ***ជាតិមរណភយស្ស*** *(ភ័យ គឺ មរណៈ និងសេចក្តីស្លាប់) បានដល់ ភ័យដែលកើតឡើងព្រោះអាស្រ័យការកើត និងការស្លាប់ ឬភ័យ ពោលគឺ ការកើត និងការស្លាប់ ។ បទថា* ***បារគូ*** *(ដល់ត្រើយ) គឺ ទៅដល់ត្រើយ ។ បទថា* ***តេ តុសិតា*** *(ត្រេកអរ) សេចក្តីថា ព្រះខីណាស្រពទាំងនោះ ឈ្មោះថា ត្រេកអរហើយ ។ បទថា* ***ជេត្វា មារំ សវាហនំ*** *(ឈ្នះមារព្រមទាំងសេនាមារ) បានដល់ ឈ្នះមារ និងទាំងកងទ័ពមារហើយ ។ បទថា* ***តេ អនេជា***

(មិនមានសេចក្ដីញាប់ញ័រ) សេចក្ដីថា ព្រះខីណាស្រពទាំងនោះ មិនញាប់ញ័រដោយសេចក្ដីញាប់ញ័រ គឺ តណ្ហា ឈ្មោះថា មិនញាប់ញ័រ ។ បទថា **នមុចិពលំ** (នូវកម្លាំងនៃមារ) បានដល់ ពលរបស់មារ ។ បទថា **ឧបាតិវត្តា** (កន្លងបាន) ប្រែថា កន្លងផុត ។ បទថា **តេ សុខិត** (ដល់នូវសេចក្ដីសុខ) បានដល់ ព្រះខីណាស្រពទាំងនោះ ឈ្មោះថា មានសេចក្ដីសុខដោយលោកុត្តរសុខ ។ ព្រោះហេតុនោះ លោកទើបពោលថា

ព្រះអរហន្តទាំងឡាយសុខពិតហ្ន៎ លោកមិនមានតណ្ហា
ដកអស្មិមានះបានដាច់ស្រឡះហើយ ទម្លាយសំណាញ់
គឺ មោហៈចេញបានហើយ ដូច្នេះ ។

ចប់អដ្ឋកថា បធានសូត្រទី ៣

# អដ្ឋកថា សំវរសូត្រទី ៤

## *"សេចក្តីព្យាយាម ៤"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សំវរសូត្រទី ៤ ដូចតទៅនេះ ៖*

[១៤] *សេចក្តីព្យាយាម ឈ្មោះ* ***បធាន*** *។ សេចក្តីព្យាយាមដែលកើតឡើងដល់បុគ្គលសង្រួមចក្ខុជាដើម ឈ្មោះ* ***សំវរប្បធាន*** *។ សេចក្តីព្យាយាមដែលកើតឡើងដល់បុគ្គលលះកាមវិតក្កៈជាដើម ឈ្មោះ* ***បហានប្បធាន*** *។ សេចក្តីព្យាយាមដែលកើតឡើងដល់បុគ្គលចម្រើនសម្ពោជ្ឈង្គៈ ឈ្មោះ* ***ភាវនាប្បធាន*** *។ សេចក្តីព្យាយាមដែលកើតឡើងដល់ភិក្ខុដែលតាមរក្សាសមាធិនិមិត្ត ឈ្មោះ* ***អនុរក្ខនាបធាន*** *។*

*ក្នុងបទថា* ***វិវេកនិស្សិតំ*** *(អាស្រ័យវិវេក) ជាអាទិ៍ មានវិនិច្ឆ័យដូច្នេះ សូម្បីបទទាំង ៣ គឺ វិវេក វិរាគៈ និរោធៈ ក៏ជាឈ្មោះរបស់និព្វាន ។ ពិតណាស់ និព្វាន ឈ្មោះ* ***វិវេក*** *ព្រោះស្ងាត់ចាកឧបធិ ឈ្មោះ* ***វិរាគៈ*** *ព្រោះរាគៈជាដើមវិនាសទៅ ព្រោះអាស្រ័យនិព្វាននោះ ។ ឈ្មោះ* ***និរោធ*** *ព្រោះរាគៈជាដើមរលត់ទៅបាន ព្រោះអាស្រ័យនិព្វាននោះ ព្រោះដូច្នោះ ក្នុងបទថា* ***ដែលអាស្រ័យវិវេក*** *ជាអាទិ៍ ទើបមានសេចក្តីថា អាស្រ័យនិព្វាន ដោយជាអារម្មណ៍ខ្លះ ដោយជាធម៌ដែលគប្បីចាក់ធ្លុះខ្លះ ។*

ក្នុងបទថា **វោស្សគ្គបរិណាមី** (បង្អោនទៅក្នុងវោស្សគ្គ) នេះ វោស្សគ្គៈមាន ២ គឺ **បរិច្ចាគវោស្សគ្គៈ ១ បក្ខន្ទនវោស្សគ្គៈ ១** ។ ក្នុងពីរយ៉ាងនោះ វិបស្សនាឈ្មោះ **បរិច្ចាគវោស្សគ្គៈ** ព្រោះលះបង់រាគៈក្នុងកិលេសនិងខន្ធ ដោយអំណាចតទង្គប្បហាន , មគ្គ ឈ្មោះ **បក្ខន្ទនវោស្សគ្គៈ** ព្រោះស្ទុះទៅកាន់និព្វានដោយអំណាចអារម្មណ៍ ។ ព្រោះដូច្នោះ ក្នុងបទថា **វោស្សគ្គបរិណាមី** (បង្អោនទៅក្នុងវោស្សគ្គៈ) នេះ ទើបមានសេចក្ដីដូច្នេះថា សតិសម្ពោជ្ឈង្គៈ ដែលភិក្ខុចម្រើនហើយដោយប្រការណា រមែងបង្អោនទៅដើម្បីលះបង់ រមែងដល់ភាពជាវិបស្សនា និងមគ្គ ភិក្ខុរមែងចម្រើនសតិសម្ពោជ្ឈង្គនោះ ដោយប្រការនោះ សូម្បីក្នុងបទដ៏សេសក៏ន័យនេះឯង ។ បទថា **ភទ្ទកំ** (ចម្រើន) បានដល់ ដែលបានហើយ ។ សមាធិដែលបានហើយ ដោយអំណាចអដ្ឋិកសញ្ញាជាដើម ហៅថា **សមាធិនិមិត្ត** ។ បទថា **អនុរក្ខតិ** (តាមរក្សា) បានដល់ ធ្វើរាគៈ ទោសៈ មោហៈ ជាធម៌ដែលជាសត្រូវដល់សមាធិឲ្យស្ងួតហួតហែងទៅ ហើយរក្សាទុក ។ ក៏សញ្ញា ៥ មានអដ្ឋិកសញ្ញាជាដើម ទ្រង់ត្រាស់ទុកក្នុងប្រការនេះ តែក្នុងទីនេះ គប្បីពោលអសុភសញ្ញា ១០ ឲ្យពិស្ដារផង ។ សេចក្ដីពិស្ដាររបស់អសុភសញ្ញានោះពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។

*ក្នុងគាថា លោកពោលសេចក្ដីព្យាយាមតែម្យ៉ាង ដែលឲ្យសម្រេចសំវរៈជាដើម ដោយឈ្មោះថា* ***សំវរៈ*** *។ បទថា* ***ខយំ ទុក្ខស្ស បាបុណេ*** *(ចាក់ធ្លុះដល់ការអស់ទុក្ខបាន) គឺ គប្បីសម្រេចព្រះអរហត្ត ពោលគឺ ធម៌ជាទីអស់ទុក្ខ ។*

ចប់អដ្ឋកថា សំវរសូត្រទី ៤

# អដ្ឋកថា បញ្ញត្តិសូត្រទី ៥

## "អគ្គបញ្ញត្តិ ៤"

គប្បីជ្រាបវិនិច្ឆ័យក្នុង សំវរសូត្រទី ៤ ដូចតទៅនេះ ៖

[១៥] បទថា **អគ្គបញ្ញត្តិយោ** បានដល់ ការបញ្ញត្តិដ៏ខ្ពង់ខ្ពស់ ។ បទថា **អត្តភាវីនំ** (បណ្តាអ្នកមានអត្តភាពធំ) បានដល់ មានអត្តភាពធំ ។ បទថា **យទិទំ រាហុ អសុរិន្ទោ** បានដល់ អសុរិន្ទ្ររាហូនេះ ឈ្មោះថា ដ៏ធំ បានឮថា ក្នុងប្រការនេះ អសុរិន្ទ្ររាហូកម្ពស់ ៤.៨០០ យោជន៍ ។ ចន្លោះដើមដៃ គឺ ពីស្មាម្ខាងទៅស្មាម្ខាង ១.២០០ យោជន៍ ។ បាតដៃ និងបាតជើងកម្រាស់ ៣០០ យោជន៍ ។ ថ្នាំងម្រាមដៃ ៥០ យោជន៍ ។ ចន្លោះចិញ្ចើមរបស់គេ ៥០ យោជន៍ ។ ថ្ងាស់ ៣០០ យោជន៍ សីសៈ ៩០០ យោជន៍ ។

បទថា **កាមភោគីនំ យទិទំ រាជា មន្ធាតា** (បណ្តាបុគ្គលអ្នកបរិភោគកាម ព្រះបាទមន្ធាតុជាកំពូល) សេចក្តីថា ព្រះបាទមន្ធាតុនេះ ឈ្មោះថា ជាកំពូលជាងសត្វអ្នកបរិភោគកាម ទាំងដែលជារបស់ទិព្វ ទាំងដែលជារបស់មនុស្ស ។ ពិតណាស់ ព្រះបាទមន្ធាតុនោះ កើតក្នុងមនុស្សទាំងឡាយដែលមានអាយុមួយអសង្ខេយ្យ បណ្តាលឲ្យភ្លៀងធ្លាក់ជាប្រាក់ ក្នុងខណៈដែលប្រាថ្នា បរិភោគកាមដែលជារបស់ពួកមនុស្សអស់កាលដ៏យូរ ចំណែក

ក្នុងទេវលោក ក៏បរិភោគកាមដ៏ប្រណីត រហូតអស់អាយុព្រះឥន្ទ្រ ៣៦ អង្គ ព្រោះដូច្នោះ ស្តេចទើបឈ្មោះថា ជាកំពូលនៃអ្នកបរិភោគកាមទាំងឡាយ ។ បទថា **អាធិបតេយ្យានំ** (បណ្តាបុគ្គលដែលជាធំ) សេចក្តីថា បណ្តាអ្នកគ្រប់គ្រងតំណែងជាអធិបតី តំណែងជាប្រធាន ។ បទថា **តថាគតោ អគ្គមក្ខាយតិ** (ព្រះតថាគត... មនុស្សលោកពោលថាដ៏ប្រសើរ) សេចក្តីថា មនុស្សលោកពោលថា ព្រះតថាគតជាបុគ្គលដ៏ប្រសើរខ្ពង់ខ្ពស់បំផុត ដោយគុណដែលជាលោកិយៈ និងលោកុត្តរៈ ។

បទថា **ឥទ្ធិយា យសសា ជលំ** (រុងរឿងដោយឫទ្ធិ និងយស) សេចក្តីថា រុងរឿងដោយសេចក្តីសម្រេចនៃទិព្វសម្បត្តិ និងដោយយស ពោលគឺ បរិវារ ។ បទថា **ឧទ្ធំ តិរិយំ អបាចីនំ** (ខាងលើ ខាងទទឹង ខាងក្រោម) បានដល់ ខាងលើ ខាងកណ្តាល ខាងក្រោម ។ បទថា **យាវតា ជគតោ គតិ** (គ្រប់ភូមិជាទីទៅរបស់សត្វ) បានដល់ ការកំណត់នៃលោកត្រឹមណា ។

ចប់អដ្ឋកថា បញ្ញត្តិសូត្រទី ៨

# អដ្ឋកថា សោខុម្មសូត្រទី ៦

## *“ញាណដ៏ល្អិត ៤”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សោខុម្មសូត្រទី ៦ ដូចតទៅនេះ ៖*

[១៦] *បទថា* ***សោខុម្មានិ*** *(ញាណជាគ្រឿងកំណត់ដឹងលក្ខណៈដ៏ល្អិត) បានដល់ ញាណដែលជាគ្រឿង ចាក់ធ្លុះលក្ខណៈដ៏ល្អិតបាន ។ បទថា* ***រូបសោខុម្មេន សមន្នាគតោ ហោតិ*** *(ជាអ្នកប្រកបដោយញាណជាគ្រឿងកំណត់ដឹងលក្ខណៈដ៏ល្អិតក្នុងរូប) បានដល់ ជាអ្នកប្រកបដោយញាណដែលកំណត់ដឹងលក្ខណៈដ៏ល្អិតល្អន់ក្នុងរូប ។ បទថា* ***បរមេន*** *(ក្រៃលែង) បានដល់ ខ្ពស់បំផុត ។ បទថា* ***តេន ច រូបសោខុម្មេន*** *(ញាណជាគ្រឿងកំណត់ដឹងលក្ខណៈដ៏ល្អិតក្នុងរូបនោះ) សេចក្តីថា ជាងញាណដែលកំណត់ដឹងលក្ខណៈដ៏ល្អិត ដែលប្រាកដល់អនុលោមញាណនោះ ។ បទថា* ***ន សមនុបស្សតិ*** *(រមែងមិនពិចារណាឃើញ) បានដល់ មិនពិចារណាឃើញដោយការមិនមាន ។ បទថា* ***ន បត្ថេតិ*** *(មិនប្រាថ្នា) បានដល់ មិនប្រាថ្នាដោយការមិនមាន ។ សូម្បីក្នុងញាណជាគ្រឿងកំណត់ដឹងលក្ខណៈដ៏ល្អិត ក្នុងវេទនាជាដើម ក៏មានន័យនេះដូចគ្នា ។*

*បទថា* ***រូបសោខុម្មតំ ញត្វា*** *(ដឹងសភាពល្អិតនៃរូបក្ខន្ធ) សេចក្តីថា*

ភិក្ខុដឹងថា រូបក្ខន្ធជារបស់ល្អិត ដោយញាណដែលជាគ្រឿងកំណត់ដឹងនូវលក្ខណៈដ៏ល្អិត ។ បទថា **វេទនានញ្ច សម្ភវំ** (ការកើតនៃវេទនាខន្ធ) ន័យថា ដឹងដល់ដែនកើតនៃវេទនាខន្ធ ។ បទថា **សញ្ញា យតោ សមុទេតិ** (ហេតុកើត... នៃសញ្ញាខន្ធ) សេចក្តីថា ដឹងហេតុដែលសញ្ញាខន្ធកើត គឺបង្កើត ។ បទថា **អត្ថំ គច្ឆតិ យត្ថ ច** (និងដែលរលត់) សេចក្តីថា ដឹងដល់សញ្ញាខន្ធដែលរលត់ ។ បទថា **សង្ខារេ បរតោ ញត្វា** (ដឹងសង្ខារក្ខន្ធថាមិនទៀង) សេចក្តីថា ដឹងដល់សង្ខារក្ខន្ធប្រែជាដទៃ ដោយសភាពទ្រុឌទ្រោម ព្រោះជារបស់មិនទៀង ។ ក៏អនិច្ចានុបស្សនាត្រាស់ដោយបទនេះ ។ ត្រាស់ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដោយបទនេះថា **ទុក្ខតោ នោ ច អត្តតោ** (ដោយភាពជាទុក្ខ និងមិនមែនខ្លួន) ។ បទថា **សន្តោ** (អ្នកស្ងប់ហើយ) សេចក្តីថា ឈ្មោះថា ស្ងប់ ព្រោះកិលេសស្ងប់ ។ បទថា **សន្តិបទេ រតោ** (ត្រេកអរហើយក្នុងសន្តិបទ) បានដល់ ត្រេកអរក្នុងនិព្វាន ។ ក្នុងសូត្រនេះ ត្រាស់វិបស្សនាក្នុងឋានៈ ៤ ប៉ុណ្ណោះ ក្នុងគាថា ទ្រង់ត្រាស់លោកុត្តរធម៌នោះឯង ។

ចប់អដ្ឋកថា សោខុម្មសូត្រទី ៦

# អដ្ឋកថា បឋមអគតិសូត្រទី ៧

## *"ការលំអៀង ៤"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអគតិសូត្រទី ៧ ដូចតទៅនេះ ៖*

[១៧] *បទថា **អគតិគមនានិ** (ការលំអៀង) បានដល់ មិនមានការដល់ការមិនលំអៀង ។ បទថា **ឆន្ទាគតឹ គច្ឆតិ** (រមែងដល់សេចក្ដីលំអៀងព្រោះពេញចិត្ត) សេចក្ដីថា បុគ្គលលំអៀងព្រោះពេញចិត្តនឹងគ្នា គឺ ធ្វើវត្ថុដែលមិនគួរធ្វើ ។ សូម្បីក្នុងបទដ៏សេសក៏ន័យនេះឯង ។*

*បទថា **ឆន្ទា ទោសា ភយា មោហា** (ព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះខ្លាច ព្រោះសេចក្ដីល្ងង់) សេចក្ដីថា បុគ្គលលំអៀងព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះខ្លាច ព្រោះល្ងង់ ។ បទថា **អតិវត្តតិ** (ល្មើស) បានដល់ កន្លង ។*

ចប់អដ្ឋកថា បឋមអគតិសូត្រទី ៧

# អដ្ឋកថា នាគតិសូត្រទី ៨

## *“ការមិនលំអៀង ៤”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង នាគតិសូត្រទី ៨ ដូចតទៅនេះ ៖*

[១៨] *ក្នុងសូត្រនេះ ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា នាគតិសូត្រទី ៨

# អដ្ឋកថា ទុតិយអគតិសូត្រទី ៩

*"សេចក្តីលំអៀង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអគតិសូត្រទី ៩ ដូចតទៅនេះ ៖*

[១៩] *ទ្រង់ត្រាស់ដោយន័យទាំងពីរ ដោយអំណាចនៃបុគ្គលដែលត្រាស់ដឹង ។*

ចប់អដ្ឋកថា ទុតិយអគតិសូត្រទី ៩

---

*(១) បិដក ស្ពួនមួយសូត្រ គឺ នាគតិសូត្រ ស្ពួនលេខឃ្នាប* [១៨]-[២០] ។

# អដ្ឋកថា ភត្តុទ្ទេសកសូត្រទី ១០

## *"ភត្តុទ្ទេសប្រកបដោយអគតិ ៤"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភត្តុទ្ទេសកសូត្រទី ១០ ដូចតទៅនេះ ៖*

[២០] *បទថា* ***ភត្តុទ្ទេសកោ*** *(ព្រះភត្តុទ្ទេសក៍) បានដល់ ភិក្ខុដែលចែកសលាកភត្តជាដើម ។ បទថា* ***កាមេសុ អសញ្ញតា*** *(មិនសង្រួមក្នុងកាមទាំងឡាយ) សេចក្តីថា ពពួកជនដែលមានកិលេសកាម មិនសង្រួមក្នុងវត្ថុកាមទាំងឡាយ ។ បទថា* ***បរិសកសាវោ ច បនេស វុច្ចតិ*** *(នោះតថាគតហៅថា ជាបុគ្គលកាកក្នុងបរិស័ទ) សេចក្តីថា បរិស័ទបែបនេះ ឈ្មោះថា* ***កាកក្នុងបរិស័ទ*** *។ បទថា* ***សមណេន*** *(សមណៈ) បានដល់ សមណបណ្ឌិត ។ បទថា* ***បរិសាយ មណ្ឌោ ច បនេស វុច្ចតិ*** *(នោះតថាគតហៅថា ជាបុគ្គលផូរផង់ក្នុងបរិស័ទ) សេចក្តីថា បរិស័ទបែបនេះ ហៅថាជាបុគ្គលផូរផង់ក្នុងបរិស័ទ ព្រោះប្រកបដោយសេចក្តីផូរផង់ ។*

ចប់អដ្ឋកថា ភត្តុទ្ទេសកសូត្រទី ១០

### ចប់វគ្គទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# ឧរុវេលវគ្គទី ៣

## អដ្ឋកថា បឋមឧរុវេលសូត្រទី ១

*“ការរំពឹងរបស់ព្រះមានព្រះភាគ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមឧរុវេលសូត្រទី ១ ដូចតទៅនេះ ៖*

[២២] *បទថា **ឧរុវេលា** ក្នុងបទថា **ឧរុវេលាយំ** នេះ បានដល់ដំបន់ដែលជាគំនរខ្សាច់ធំ អធិប្បាយថា គំនរខ្សាច់ធំ ។ មា៉្យងទៀត គប្បីឃើញអត្ថក្នុងសេចក្ដីនេះយ៉ាងនេះថា ខ្សាច់ ហៅថា ឧរុ ដែនខេត្ត ហៅថា **វេលា** ។ ខ្សាច់ដែលគេជញ្ជូនមក ព្រោះល្មើសកតិកាជាហេតុ ឈ្មោះថា **ឧរុវេលា** ។*

*បានឮថា ក្នុងអតីតកាល កាលព្រះពុទ្ធទ្រង់មិនទាន់ឧប្បត្តិ កុលបុត្រមួយម៉ឺននាក់បួសជាតាបសនៅក្នុងប្រទេសនោះ ក្នុងថ្ងៃមួយ ប្រជុំព្រមព្រៀងគ្នាហើយ បានតាំងកតិកាថា ឈ្មោះថា កាយកម្ម វចីកម្ម រមែងប្រាកដដល់ជនពួកដទៃបាន ចំណែកមនោកម្មមិនប្រាកដ ព្រោះដូច្នោះ បុគ្គលណាត្រិះរិះដល់កាមវិតក្កៈ ព្យាបាទវិតក្កៈ ឬវិហិង្សាវិតក្កៈ បុគ្គលដទៃឈ្មោះថានឹងដាស់តឿនបុគ្គលនោះមិនមាន បុគ្គលនោះដាស់តឿនខ្លួនដោយខ្លួនឯង ហើយ*

យកស្លឹកឈើជាក់ (ខ្ទប់) ខ្សាច់នាំមកចាក់ក្នុងទីនេះ ។ នេះចាត់ជាទណ្ឌកម្ម របស់បុគ្គលនោះ ។ តាំងពីនោះមក នរណាត្រិះរិះដូច្នោះ អ្នកនោះយកស្លឹកឈើខ្ទប់ខ្សាច់មកចាក់ក្នុងទីនោះ ទើបកើតជាគំនរខ្សាច់ធំ ដោយលំដាប់ក្នុងទីនោះដោយប្រការដូច្នេះ តមក ពួកអ្នកកើតខាងក្រោយ ទើបហោមព័ទ្ធគំនរខ្សាច់ធំនោះធ្វើជាចេតិយដ្ឋាន ។ លោកសំដៅដល់ចេតិយដ្ឋាននោះ ទើបពោលថា បទថា **ឧរុវេលា** បានដល់ **តំបន់គំនរខ្សាច់ធំ** អធិប្បាយថា **គំនរខ្សាច់ធំ** ដូច្នេះ ។ លោកសំដៅដល់ប្រការនោះឯង ទើបពោលទុក ។ ម្យ៉ាងទៀត គប្បីឃើញអត្ថក្នុងប្រការនេះយ៉ាងនេះថា ខ្សាច់ ហៅថា ឧរុ ដែនខេត្ត ហៅថា វេលា ខ្សាច់ដែលគេនាំមកព្រោះហេតុ ល្មើសកតិកាជាហេតុ ឈ្មោះ **ឧរុវេលា** ។

ដោយបទថា **នជ្ជា នេរញ្ជរាយ តីរេ** (ជិតឆ្នេរស្ទឹងនេរញ្ជរា) ទ្រង់សំដែងថា តថាគតអាស្រ័យឧរុវេលគ្រាម សម្រាកក្បែរឆ្នេរស្ទឹងនេរញ្ជរា ។ បទថា **អជបាលនិគ្រោធេ** (ក្រោមដើមអជបាលនិគ្រោធ) សេចក្តីថា ពួកអ្នកចញ្ចឹមពពែអង្គុយខ្លះ ឈរខ្លះ ក្នុងម្លប់នៃដើមនិគ្រោធនោះ ព្រោះហេតុនោះ ដើមនិគ្រោធនោះ ទើបហៅថា អជបាលនិគ្រោធ ។ អធិប្បាយថា ខាងក្រោមដើមអជបាលនិគ្រោធនោះ ។

បទថា **បឋមាភិសម្ពុទ្ធោ** (ត្រាស់ដឹងថ្មីៗ) សេចក្តីថា ជាអ្នកត្រាស់ដឹងថ្មីៗ នោះឯង ។ បទថា **ឧទបាទិ** (កើតឡើង) សេចក្តីថា វិតក្កៈនេះកើតក្នុងសប្តាហ៍ទី ៥ ។ សួរថា ព្រោះហេតុអ្វី ទើបកើតឡើង ។ ឆ្លើយថា ព្រោះជាអាចិណ្ណប្បដិបត្តិ និងអាសេវនប្បច្ច័យជាតិមុនរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ ។ ក្នុងហេតុប្រការនោះ គប្បីនាំតិត្តិរជាតកមកសម្តែង ដើម្បីប្រកាសអាសេវនៈ (ការសេព) ក្នុងជាតិមុន ។ បានឮថា សត្វទទា ស្វា និងដំរី កាលនៅក្នុងប្រទេសមួយកន្លែង ពោលថា "បណ្តាពួកយើង អ្នកណាចាស់ជាងគេ យើងទាំងឡាយនឹងគោរពក្នុងអ្នកនោះ" បានសម្តែងដើមជ្រៃឡើង ពិនិត្យសារចុះសារឡើង ហើយពោលថា "បណ្តាពួកយើង អ្នកណាហ្ន៎ចាស់ជាងគេ" ។ ដឹងថាសត្វទទាចាស់ជាងគេ ទើបធ្វើសេចក្តីគោរពដល់សត្វទទានោះ ជាអ្នកព្រមព្រៀង រីករាយដល់គ្នានិងគ្នា ក៏មានសួគ៌ជាខាងមុខ ។ទេវតាដែលស្ថិតនៅដើមឈើជ្រាបហេតុនោះ ទើបពោលគាថានេះថា

នរជនពួកណាឆ្លាតក្នុងធម៌ បន្ទោនគោរពអ្នកធំ
នរជនទាំងនោះបានទទួលសរសើរក្នុងលោកនេះ
និងក្នុងសម្បរាយភពក៏មានសុគតិ ។

ព្រះតថាគត សូម្បីកើតក្នុងកំណើតអហេតុកតិរច្ឆានយ៉ាងនេះ ក៏ទ្រង់

ពេញព្រះទ័យក្នុងការរស់នៅប្រកបដោយសេចក្ដីគោរព ឥឡូវនេះ ហេតុអ្វីទ្រង់មិនពេញព្រះទ័យហ្ន៎ ។ បទថា **អគារវោ** (មិនគោរព) គឺ មិនមានសេចក្ដីគោរពក្នុងបុគ្គលដទៃ ។ អធិប្បាយថា មិនតាំងបុគ្គលណាទុកក្នុងឋានៈគួរគោរព ។ បទថា **អប្បតិស្សោ** (មិនកោតក្រែង) គឺ មិនមានសេចក្ដីកោតក្រែង អធិប្បាយថា មិនតាំងនរណាទុកក្នុងឋានៈជាធំ ។ ក្នុងបទថា **សមណំ វា ព្រាហ្មណំ វា** (សមណៈ ឬព្រាហ្មណ៍) នេះ លោកបំណងយកសមណៈនិងព្រាហ្មណ៍អ្នកស្ងប់បាប និងអ្នកបណ្ដែតបាបហើយប៉ុណ្ណោះ ។ បទថា **សក្កត្វា គរុំកត្វា** (សក្ការៈ គោរព) សេចក្ដីថា ធ្វើសក្ការៈ និងចូលទៅតាំងសេចក្ដីគោរព ។

ក្នុងបទថា **សទេវកេ លោកេ** (ក្នុងលោក ព្រមទាំងទេវលោក) ជាអាទិ៍ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ឈ្មោះថា **ព្រមទាំងទេវលោក** ព្រោះប្រព្រឹត្តទៅព្រមជាមួយទេវតាទាំងឡាយ ក៏សូម្បីមារ និងព្រហ្មទាំងឡាយ ក៏ទ្រង់កាន់យកដោយ ទេវស័ព្ទ ក្នុងបទនេះ ។ បណ្ដា **មារ** អ្នកមានអំណាចរមែងប្រើអំណាចលើសត្វទាំងពួង ។ ធម្មតា **ស្ដេចមហាព្រហ្ម** អ្នកមានអានុភាពធំ រមែងផ្សាយពន្លឺទៅក្នុងមួយចក្រវាឡដោយម្រាមដៃមួយ ក្នុងពីរចក្រវាឡដោយម្រាមដៃពីរ រមែងផ្សាយពន្លឺទៅក្នុងម៉ឺនចក្រវាឡ ដោយម្រាម

ទាំង ១០ ទើបត្រាស់ចែកថា **សមារកេ សព្រហ្មកេ** (មារលោក ព្រហ្មលោក) ដោយតម្រិះថា "ជនទាំងឡាយកុំបានពោលថា បុគ្គលនោះជាអ្នកមានសីលសម្បូរណ៌ជាង ដោយសីលនេះ" ។ ធម្មតា សមណៈទាំងឡាយក៏ដូចគ្នា ជាពហុស្សូតដោយអំណាចនិកាយមួយជាដើម មានសីល ជាបណ្ឌិត ។ សូម្បីព្រាហ្មណ៍ទាំងឡាយជាពហុស្សូត ដោយអំណាចវិជ្ជាដឹងផែនដីជាដើម ជាបណ្ឌិត ទើបត្រាស់ថា **សស្សមណព្រាហ្មណិយា បជាយ** (ក្នុងពួកសត្វព្រមទាំងសមណៈ និងព្រាហ្មណ៍) ដោយទ្រង់ត្រិះរិះថា "ជនទាំងឡាយកុំបានពោលថា សមណៈ និងព្រាហ្មណ៍ទាំងនោះជាអ្នកមានសីលសម្បូរណ៍ជាង ដោយសីលនេះ" ។ ចំណែកបទថា **សទេវមនុស្សាយ** (ព្រមទាំងទេវតា និងមនុស្ស) នេះ ទ្រង់ត្រាស់រួមចូលគ្នា ដើម្បីទ្រង់សម្តែងដោយអស់ជើង ។ ម្យ៉ាងទៀត ក្នុងបទនេះ ៣ បទដំបូង ត្រាស់ដោយអំណាចលោក ២ បទក្រោយ ត្រាស់ដោយអំណាចពួកសត្វ ។ បទថា **សីលសម្បន្នតរំ** (ដែលមានសីលសម្បូរជាង) សេចក្តីថា អ្នកសម្បូរណ៍ជាង គឺ អ្នកក្រៃលែងជាងដោយសីល ។ ក៏ក្នុងសេចក្តីនេះ ត្រាស់ធម៌ ៤ ប្រការ មានសីលជាដើម ទាំងលោកិយៈទាំងលោកុត្តរៈ ។

វិមុត្តិញាណទស្សនៈ គឺ បច្ចវេក្ខណញ្ញាណ ជាលោកិយៈតែម្យ៉ាង ។

បទថា **បាតុរហោសិ** (មកប្រាកដ) សេចក្តីថា សហម្បតីព្រហ្មគិតថា “ព្រះសាស្តា កាលទ្រង់មិនឃើញអ្នកដទៃក្រៃលែងជាងព្រះអង្គ ដោយសីលជាដើម តាំងពីអវិចីដរាបដល់ភវគ្គព្រហ្ម ទ្រង់ត្រិះរិះថា តថាគតនឹងធ្វើសក្ការៈតែលោកុត្តរធម៌ ៩ ដែលតថាគតត្រាស់ដឹងហើយ ដែលជាទីពឹងអាស្រ័យព្រះមានព្រះភាគ ទ្រង់ត្រិះរិះដល់ហេតុ ទ្រង់ត្រិះរិះដល់ប្រយោជន៍ ដែលគុណវុឌ្ឍិពិសេស ចាំយើងនឹងទៅធ្វើឧស្សាហៈឲ្យកើតដល់ព្រះអង្គ ទើបបានប្រាកដចំពោះព្រះភ័ក្ត្រ ។ អធិប្បាយថា បានឈរចំពោះព្រះភ័ក្ត្រ ។

ក្នុងបទថា **វិហំសុ វិហរន្តិ** ច នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បុគ្គលណាគប្បីពោលថា ព្រះពុទ្ធទាំងឡាយមានច្រើនសូម្បីក្នុងបច្ចុប្បន្ន ព្រោះព្រះបាលីថា **វិហរន្តិ** ដូច្នេះ បុគ្គលនោះគប្បីត្រូវជំទាស់ដោយបាលីនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូម្បីព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធក្នុងកាលឥឡូវនេះ ដូច្នេះ ។ គប្បីសម្តែងសេចក្តីមិនមានព្រះពុទ្ធទាំងឡាយដទៃដល់បុគ្គលនោះ ដោយសូត្រទាំងឡាយមានជាអាទិ៍ថា

**តថាគតមិនមានអាចារ្យ មិនមានបុគ្គលដូចតថាគត**
**បុគ្គលក្នុងលោក ព្រមទាំងទេវលោក ដែលប្រៀបដូច**
**តថាគត មិនមាន ។**

បទថា **តស្មា** (ព្រោះហេតុនោះ) សេចក្តីថា ព្រោះដូច្នោះ ព្រះពុទ្ធគ្រប់ព្រះអង្គ ទើបទ្រង់គោរពព្រះសទ្ធម្ម ។ បទថា **មហត្តមភិកង្ខតា** (បំណងភាពជាធំ) សេចក្តីថា ប្រាថ្នាភាពជាធំ ។ បទថា **សរំ ពុទ្ធាន សាសនំ** (រឭកដល់ពាក្យទូន្មានរបស់ព្រះពុទ្ធទាំងឡាយ) សេចក្តីថា កាលមករឭកដល់ពាក្យទូន្មានរបស់ព្រះពុទ្ធទាំងឡាយ ។

បទថា **យតោ** (កាលណា) គឺ ក្នុងកាលណា ។ បទថា **មហត្តេន សមន្នាគតោ** (ដល់ព្រមដោយភាពជាធំហើយ) សេចក្តីថា សូម្បីសង្ឃ ប្រកបដោយភាពជាធំ ៤ យ៉ាងនេះ គឺ ភាពជាធំដោយជារត្តញ្ញូ (ដឹងរាត្រីយូរ) ១ ភាពជាធំដោយសេចក្តីចម្រើន ១ សេចក្តីជាធំដោយព្រហ្មចរិយៈ ១ ភាពជាធំព្រោះជាអ្នកប្រសើរដោយលាភ ១ ។ បទថា **អថ មេ សង្ឃេបិ គារវោ** (កាលនោះតថាគតនឹងគោរពក្នុងសង្ឃ) សេចក្តីថា កាលនោះតថាគតក៏កើតសេចក្តីគោរពសូម្បីក្នុងសង្ឃ ។ សួរថា ព្រះមានព្រះភាគទ្រង់ធ្វើសេចក្តីគោរពក្នុងសង្ឃក្នុងវេលាណា ។ ឆ្លើយថា ក្នុងវេលាព្រះនាងមហាប្រជាបតីថ្វាយគូសំពត់ ។ ពិតហើយ ក្នុងវេលានោះ ព្រះមានព្រះភាគ កាលត្រាស់ដល់គូសំពត់ ដែលព្រះនាងមហាបជាបតីបង្អោនចូលទៅថ្វាយចំពោះព្រះអង្គថា "គោតមី ព្រះនាងចូរថ្វាយក្នុងសង្ឃចុះ កាលព្រះនាងថ្វាយក្នុងសង្ឃហើយ

ទាំងតថាគត ទាំងសង្ឃ ក៏ឈ្មោះថា ព្រះនាងបូជាហើយ” ឈ្មោះថា ទ្រង់បានធ្វើសេចក្តីគោរពក្នុងសង្ឃ ។

ចប់អដ្ឋកថា ឧរុវេលសូត្រទី ១

# អដ្ឋកថា ទុតិយឧរុវេលសូត្រទី ២

## *“ការរំពឹងរបស់ព្រះមានព្រះភាគនៅតំបន់ឧរុវេលា”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយឧរុវេលសូត្រទី ២ ដូចតទៅនេះ ៖*

[២៣] *បទថា* ***សម្ពហុលា*** *(ច្រើននាក់) គឺ ពួកព្រាហ្មណ៍ដ៏ច្រើន ។ បទថា* ***ព្រាហ្មណា*** *(ព្រាហ្មណ៍) សេចក្ដីថា ពួកព្រាហ្មណ៍ដែលមកព្រមគ្នាជាមួយព្រាហ្មណ៍អ្នកនិយាយពាក្យគ្រោតគ្រាត ។ បទថា* ***ជិណ្ណា វុឌ្ឍា*** *(មនុស្សចាស់ មនុស្សដែលចម្រើនវ័យ) បានដល់ អ្នកគ្រាំគ្រាដោយជរា ចម្រើនដោយវ័យ ។ បទថា* ***មហល្លកា*** *(អ្នកធំ) បានដល់ ចាស់ដោយជាតិ ។ បទថា* ***អទ្ធគតា*** *(កន្លងវ័យ) បានដល់ កន្លងវ័យទាំងបីទៅហើយ ។ បទថា* ***សុតំ មេតំ*** *(ខ្ញុំបានឮមក) បានដល់ ប្រការនេះពួកយើងស្ដាប់មកហើយ ។ បទថា* ***តយិទំ ភោ គោតម តថេវ*** *(សេចក្ដីនេះក៏ដូចគេថា) សេចក្ដីថា ព្រះគោតម វត្ថុដែលពួកយើងស្ដាប់មកហើយ ក៏ពិតយ៉ាងនោះ ។ បទថា* ***តយិទំ ភោ គោតម ន សម្បន្នមេវ*** *(សេចក្ដីនេះជាការធ្វេសប្រហែសដោយពិត) សេចក្ដីថា ការមិនធ្វើអភិវាទជាដើមនោះ មិនសមគួរឡើយ ។*

*ក្នុងបទជាដើមថា* ***អកាលវាទី*** *មានវិនិច្ឆ័យដូច្នេះ ឈ្មោះថា អកាលវាទី ព្រោះនិយាយមិនស្គាល់កាល (បប៉ាច់ប៉ប៉ោច) ។ ឈ្មោះថា* ***អភូតវាទី***

ព្រោះនិយាយតែរឿងដែលមិនពិត ។ ឈ្មោះថា **អនត្ថវាទី** ព្រោះនិយាយតែរឿងដែលមិនជាប្រយោជន៍ មិននិយាយរឿងដែលជាប្រយោជន៍ ។ ឈ្មោះថា **អធម្មវាទី** ព្រោះនិយាយមិនមែនធម៌ មិននិយាយជាធម៌ ។ ឈ្មោះថា **អវិនយវាទី** ព្រោះនិយាយមិនមែនវិន័យ មិននិយាយជាវិន័យ ។ បទថា **អនិធានវតី វាចំ ភាសិតា** (ពោលពាក្យដែលគ្មានមូលដ្ឋាន) បានដល់ មិនពោលវាចាដែលគួរកម្កល់ទុកក្នុងហឫទ័យ ។ បទថា **អកាលេន** (មិនត្រូវកាល) បានដល់ ដោយកាលមិនគួរនឹងនិយាយ ។ បទថា **អនបទេសំ** (មិនមានទីអាង) បានដល់ និយាយខ្វះទីអាង មិននិយាយឲ្យមានទីអាង មានហេតុ ។ បទថា **អបរិយន្តវតី** (មិនមានព្រំដែន) បានដល់ និយាយមិនដឹងចប់ មិននិយាយមានកំណត់ (ចប់) ។ បទថា **អនត្ថសញ្ហិតំ** (ប្រកបដោយរឿងដែលមិនជាប្រយោជន៍) បានដល់ មិននិយាយអាស្រ័យនូវប្រយោជន៍ដែលជាលោកិយៈ និងលោកុត្តរៈ ។ បទថា **ពាលោ ថេរោត្វេវ សង្ខ្យំ គច្ឆតិ** (បុគ្គលនោះរាប់បានថា ថេរៈពាល) សេចក្តីថា រាប់បានថា ជាថេរៈអន្ធពាល (អ្នកល្ងង់) ។

បទជាដើមថា **កាលវាទី** គប្បីជ្រាបដោយអំណាចនៃធម៌ដែលផ្ទុយគ្នាដូចពោលមកហើយ ។ បទថា **បណ្ឌិតោ ថេរោត្វេវ សង្ខ្យំ គច្ឆតិ** (បុគ្គល

នោះរាប់បានថា ថេរៈបណ្ឌិត) សេចក្តីថា រាប់បានថាជាបណ្ឌិត ព្រោះប្រកប ដោយសេចក្តីធ្លាត ថាជាថេរៈ ព្រោះដល់នូវភាពជាអ្នករឹងមាំ ។

បទថា **ពហុស្សុតោ ហោតិ** (ជាពហូសូត) សេចក្តីថា ភិក្ខុនោះ មានសុតៈច្រើន អធិប្បាយថា នវង្គសត្ថុសាសន៍ភិក្ខុនោះរៀនហើយ ដោយ អំណាចខាងដើម និងខាងចុងនៃបាលី និងអនុសន្ធិ ។ បទថា **សុតធរោ** (ទ្រទ្រង់ធម៌ដែលបានស្តាប់ហើយ) បានដល់ ជាអ្នកទទួលសុតៈទុកបាន ។ ពិតហើយ ព្រះពុទ្ធវចនៈ ដែលរៀនយក រមែងវិនាសទៅ មិនតាំងនៅ ដូច ទឹកក្នុងឆ្នាំងធ្លុះ លោកមិនអាចនឹងពោល ឬប្រាប់សូត្រ ឬជាតកណាមួយ ក្នុងកណ្តាលបរិស័ទបាន ភិក្ខុនេះឈ្មោះថា ជាបុគ្គលមិនទ្រទ្រង់សុតៈ ។ ចំណែកព្រះពុទ្ធវចនៈ ដែលភិក្ខុណារៀនហើយ អស់វេលាដែលខ្លួនរៀនមក ហើយទុកឯង កាលលោកមិនធ្វើការស្វាធ្យាយ ១០ ឆ្នាំ ២០ ឆ្នាំ ក៏មិនវិនាស ភិក្ខុនេះឈ្មោះថា ជាអ្នកទ្រទ្រង់សុតៈ ។ បទថា **សុតសន្និចយោ** (សន្សំ ធម៌ដែលបានស្តាប់ហើយទុកបាន) បានដល់ អ្នកសន្សំសុតៈ ។ ក៏សុតៈ ដែលភិក្ខុណាសន្សំទុកក្នុងទូ គឺ ហទយៈ រមែងតាំងនៅដូចស្នាមចារឹកលើ សិលា និងដូចខ្លាញ់រាជសីហ៍ដែលគេរក្សាទុកក្នុងឆ្នាំងមាស ភិក្ខុនេះឈ្មោះ ថា សន្សំសុតៈ ។ បទថា **ធតា** (ចងចាំទុកបាន) គឺ ទ្រទ្រង់ចាំទុកបានរហ័ស ។

ពិតណាស់ ព្រះពុទ្ធវចនៈដែលភិក្ខុរូបខ្លះរៀនហើយ មិនទ្រទ្រង់ចាំបានរហ័ស មិនប្រាកដប្រជា កាលត្រូវគេនិយាយថា សូមលោកពោលសូត្រ ឬជាតក ឯណោះ លោកក៏ពោលថា យើងនឹងស្វាធ្យាយ ប្រៀបធៀប សាកសួរមុន ហើយ ទើបបានដឹង ។ ព្រះពុទ្ធវចនៈដែលភិក្ខុរូបខ្លះ ទ្រទ្រង់ចាំរហ័ស ដូចជាភវង្គសោត កាលត្រូវគេនិយាយថា សូមលោកពោលសូត្រ ឬជាតក ឯណោះ លោកនឹងលើកឡើងពោលសូត្រ ឬជាតកនោះបានភ្លាម ។ បទថា **ទ្រទ្រង់ទុកបាន** ត្រាស់សំដៅដល់ប្រការនោះ ។ បទថា **វចសា បរិចិតា** (រត់មាត់) បានដល់ ស្វាធ្យាយដោយវាចាដោយអំណាចនៃសូត្រ ១០ ពួក វគ្គ ១០ ពួក ៥០ ពួក ។ បទថា **មនសានុបេក្ខិតា** (ពិចារណាបានតាមចិត្ត) បានដល់ ពិចារណាដោយចិត្ត ។ ព្រះពុទ្ធវចនៈដែលភិក្ខុណាស្វាធ្យាយហើយដោយវាចា ប្រាកដច្បាស់ក្នុងទីនោះៗ ដល់លោកដែលគិតហើយដោយចិត្ត ដូចរូបប្រាកដច្បាស់ដល់បុគ្គលដែលឈរតាមប្រទីបដួងធំ ដូច្នោះ ។ ទ្រង់សំដៅយកព្រះពុទ្ធវចនៈរបស់ភិក្ខុនោះ ទើបត្រាស់បទនេះ ។ បទថា **ទិដ្ឋិយា សុប្បដិវិទ្ធា** (យល់ច្បាស់ដោយការឃើញ) បានដល់ ប្រើបញ្ញាចាក់ធ្លុះទាំងហេតុទាំងផល ។

បទថា **អភិចេតសិកានំ** (ដែលជាធម៌ប្រព្រឹត្តទៅក្នុងចិត្តដ៏ក្រៃលែង)

សេចក្ដីថា ចិត្តដែលបរិសុទ្ធិក្ដីថា ឬអធិចិត្ត លោកហៅថា អភិចេតៈ ឈាន ៤ កើតក្នុងអភិចិត្ត ឈ្មោះថា អភិចេតសិកៈ ន័យម្យ៉ាងទៀត ឈាន ៤ អាស្រ័យអភិចេតៈ ហេតុនោះ ទើបឈ្មោះថា អភិចេតសិកៈ ។ បទថា **ទិដ្ឋធម្មសុខវិហារានំ** (ធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន) បានដល់ ដែលជាធម៌គ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ។ អត្តភាពដែលពិចារណាឃើញប្រចក្ស លោកហៅថា ទិដ្ឋធម៌ ។ អធិប្បាយថា ជាគ្រឿងនៅជាសុខក្នុងទិដ្ឋធម៌នោះ ។ បទនេះ ជាឈ្មោះរបស់រូបាវចរឈានទាំងឡាយ ។ ពិតណាស់ បុគ្គលបានឈាន អង្គុយចូលឈានទាំងនោះ រមែងបាននេក្ខម្មសុខ ដែលមិនសៅហ្មងក្នុងអត្តភាពនេះឯង ព្រោះដូច្នោះ ទើបត្រាស់ថា **ធម៌ជាគ្រឿងនៅជាសុខក្នុងអត្តភាពបច្ចុប្បន្ន** ។ បទថា **និកាមលាភី** (បានតាមត្រូវការ) បានដល់ បានតាមត្រូវការ បានតាមអំណាចសេចក្ដីប្រាថ្នារបស់ខ្លួន លោកអធិប្បាយថា អាចចូលឈានបានគ្រប់ៗ ខណៈដែលប្រាថ្នា ។ បទថា **អកិច្ឆលាភី** (បានដោយមិនលំបាក) លោកអធិប្បាយថា អាចគ្របសង្កត់ធម៌ដែលជាសត្រូវ ហើយចូលឈានបានស្រួល ។ បទថា **អកសិរលាភី** (បានដោយងាយ) បានដល់ បានមិនលំបាក គឺ បានរហ័ស លោកអធិប្បាយថា អាចចេញចាកឈានបានតាមកំណត់ ។ ពិតណាស់ បុគ្គលខ្លះបានឈាន

ប៉ុណ្ណោះ មិនអាចចូលបានក្នុងខណៈដែលប្រាថ្នា ។ បុគ្គលខ្លះអាចចូលឈាន បានតាមបំណង តែក៏គ្របសង្កត់ធម៌ដែលធ្វើឲ្យអន្តរាយបានដោយលំបាក ។ បុគ្គលខ្លះចូលបាន ទាំងគ្របសង្កត់ធម៌ដែលធ្វើឲ្យអន្តរាយបាន ដោយមិនលំបាក តែមិនអាចចេញចាកឈានបានតាមកំណត់ ដូចនាឡិកាយន្ត ។ ក៏សម្បទា ៣ យ៉ាងនេះ មានដល់បុគ្គលណា បុគ្គលនោះ លោកហៅថា **បានដោយមិនលំបាក** ។

បទជាដើមថា **អាសវានំ ខយា** (ព្រោះអាសវៈទាំងឡាយអស់ទៅ) មានអត្ថដូចពោលហើយនោះឯង ។ ក្នុងទីនេះ សូម្បីសីល ក៏ត្រាស់ដល់សីលរបស់ព្រះខីណាស្រពប៉ុណ្ណោះ សូម្បីពហុសច្ចៈ ក៏ត្រាស់ពហុសច្ចៈរបស់ព្រះខីណាស្រពប៉ុណ្ណោះ សូម្បីឈាន ក៏ត្រាស់ឈានចំពោះព្រះខីណា-ស្រពប៉ុណ្ណោះ ។ ចំណែកព្រះអរហត្ត ត្រាស់ដោយបទជាដើមថា **ព្រោះអាសវៈទាំងឡាយអស់ទៅ** ។ តែកិច្ចរបស់មគ្គក្នុងទីនេះ គប្បីជ្រាបថា ទ្រង់ប្រកាសដោយផល (អរហត្តផល) ។

បទថា **ឧទ្ធតេន** (រាយមាយ) បានដល់ ប្រកបដោយឧទ្ធច្ចៈ ។ បទថា **សម្ផញ្ចុ** (ពាក្យរោយរាយ) បានដល់ ពាក្យរោយរាយឥតប្រយោជន៍ ។ បទថា **អសមាហិតសង្កប្បោ** (មានគំនិតមិនតម្កល់ស៊ប់សួន) បានដល់ មាន

ការត្រិះរិះមិនតាំងមាំ ។ បទថា **មិគោ** បានដល់ ដូចម្រឹគ ។ បទថា **អារា** (ឃ្លាតឆ្ងាយ) ប្រែថា ក្នុងទីឆ្ងាយ ។ បទថា **ថាវរេយ្យម្ហា** (ចាកភាពជាថេរៈ) បានដល់ ចាកពីភាពរឹងមាំ ។ បទថា **បាបទិដ្ឋិ** (មានការឃើញលាមក) បានដល់ ការឃើញអាក្រក់ ។ បទថា **អនាទរោ** (មិនអើពើ) បានដល់ វៀរចាកសេចក្ដីអើពើ ។ បទថា **សុត្វា** (មានសុតៈ) បានដល់ ចូលដល់ដោយសូត្រ ។ បទថា **បដិភាណវា** (មានបដិភាណ) សេចក្ដីថា អ្នកប្រកបដោយបដិភាណពីរយ៉ាង ។ បទថា **បញ្ញាយត្ថំ វិបស្សតិ** (ឃើញច្បាស់នូវអត្ថនៃធម៌ដោយបញ្ញា) សេចក្ដីថា រមែងឃើញច្បាស់នូវអត្ថនៃសច្ចៈ ៤ ដោយមគ្គប្បញ្ញាព្រមដោយវិបស្សនា ។ បទថា **បារគូ សព្វធម្មានំ** (ដល់ត្រើយនៃធម៌ទាំងពួង) សេចក្ដីថា ដល់ត្រើយនៃធម៌ មានខន្ធជាដើមទាំងពួង ។ អធិប្បាយថា ជាអ្នកដល់ត្រើយ គឺ ទីបំផុតនៃធម៌ទាំងពួង ដោយការដល់ត្រើយ ៦ យ៉ាង គឺ ដល់ត្រើយនៃអភិញ្ញា ១ ដល់ត្រើយនៃបរិញ្ញា ១ ដល់ត្រើយនៃភាវនា ១ ដល់ត្រើយនៃបហានៈ ១ ដល់ត្រើយនៃសច្ឆិកិរិយា ១ ដល់ត្រើយនៃសមាបត្តិ ១ ។ បទថា **អខិលោ** (មិនមានកិលេសដូចដែកគោលក្នុងចិត្ត) បានដល់ ប្រាសចាកដែកគោល គឺ រាគៈជាដើម ។ បទថា **បដិភាណ** (មានបដិភាណ) បានដល់ ប្រកបដោយបដិភាណ

២ យ៉ាង ។ បទថា ព្រហ្មចរិយស្ស កេវលី បានដល់ នៅចប់ព្រហ្មចរិយៈ ។ បទដ៏សេសក្នុងសូត្រនេះ ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា ទុតិយឧរុវេលសូត្រទី ២

# អដ្ឋកថា លោកសូត្រទី ៣

## *“ព្រះមានព្រះភាគទ្រង់ដឹងលោក និងអារម្មណ៍”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង លោកសូត្រទី ៣ ដូចតទៅនេះ ៖*

[២៤] *បទថា* ***លោកោ*** *(លោក) បានដល់ ទុក្ខសច្ចៈ ។ បទថា* ***អភិសម្ពុទ្ធោ*** *(ត្រាស់ដឹងហើយ) បានដល់ ធ្វើឲ្យជាក់ច្បាស់ហើយដោយញាណ ។ បទថា* ***លោកស្មា*** *(ចាកលោក) បានដល់ ចាកទុក្ខសច្ចៈ ។ បទថា* ***បហីនោ*** *(លះបង់) បានដល់ លះបានហើយដោយអរហត្តមគ្គញាណត្រង់មហាពោធិមណ្ឌស្ថាន ។ បទថា* ***តថាគតស្ស ភាវិត*** *(តថាគតបានធ្វើឲ្យចម្រើនហើយ) ប្រែថា ដែលតថាគតបំពេញឲ្យចម្រើនហើយ ។*

*ព្រះមានព្រះភាគ លុះត្រាស់នូវភាពដែលព្រះអង្គជាពុទ្ធដោយសច្ចៈ ៤ ដោយឋានៈ មានប្រមាណប៉ុណ្ណេះយ៉ាងនេះហើយ ឥឡូវនេះទើបត្រាស់បទមានជាអាទិ៍ថា* ***យំ ភិក្ខវេ*** *(ប្រការដែល) ដើម្បីត្រាស់ភាពដែលព្រះអង្គជាតថាគត ។ ក្នុងបទទាំងនោះ បទថា* ***ទិដ្ឋំ*** *(បានឃើញហើយ) បានដល់ រូបាយតនៈ (អាយតនៈគឺរូប) ។ បទថា* ***សុតំ*** *(បានឮហើយ) បានដល់ សទ្ទាយតនៈ (អាយតនៈគឺសំឡេង) ។ បទថា* ***មុតំ*** *(បានជ្រាបហើយ) បានដល់ អាយតនៈ គឺ ក្លិន រស ផោដ្ឋព្វៈ ព្រោះជាអារម្មណ៍ដែលមកដល់ហើយ*

*ទទួលទុក ។ បទថា* ***វិញ្ញាតំ*** *(បានដឹងហើយ) បានដល់ ធម្មារម្មណ៍ (អារម្មណ៍ គឺ ធម៌) មានសុខ និងទុក្ខជាដើម ។ បទថា* ***បត្តំ*** *(បានប្រសព្វហើយ) បានដល់ ស្វែងរក ឬមិនស្វែងរក ក៏មកដល់ហើយ ។ បទថា* ***បរិយេសិតំ*** *(បានស្វែងរកហើយ) សេចក្តីថា មកដល់ ឬមិនទាន់មកដល់ ក៏ស្វែងរកហើយ ។ បទថា* ***អនុវិចរិតំ មនសា*** *(បានគិតរកតាមផ្លូវចិត្តហើយ) បានដល់ គិតរកដោយចិត្ត ។*

*ដោយបទថា* ***តថាគតេន អភិសម្ពុទ្ធំ*** *(តថាគតបានត្រាស់ដឹង... ហើយ) នេះ ទ្រង់សម្តែងប្រការនេះថា រូបារម្មណ៍ជាដើមថា ពណ៌ខៀវ ពណ៌លឿងណា ប្រាកដតាមចក្ខុទ្វាររបស់មនុស្សលោក ព្រមទាំងទេវលោកនេះ ក្នុងលោកធាតុដែលរកប្រមាណមិនបាន តថាគតត្រាស់ដឹងរូបារម្មណ៍នោះទាំងអស់ យ៉ាងនេះថា សត្វនេះឃើញរូបារម្មណ៍ឈ្មោះនេះ ក្នុងខណៈនេះហើយ កើតសេចក្តីពេញចិត្តខ្លះ ទាស់ចិត្តខ្លះ ជាកណ្តាលខ្លះ ដូច្នេះ ។ មួយទៀត សទ្ទារម្មណ៍ជាដើមថា សំឡេងស្គរ ប្រាកដតាមសោតទ្វាររបស់មនុស្សលោក ព្រមទាំងទេវលោកនេះ ក្នុងលោកធាតុដែលរកប្រមាណមិនបាន ក៏ដូចគ្នា គន្ធារម្មណ៍ជាដើមថា ក្លិនឫស ក្លិនសំបក ប្រាកដតាមឃានទ្វារ រសារម្មណ៍ជាដើមថា រសនៃឫស រសនៃដើម ប្រាកដតាមជិវ្ហាទ្វារ ផោដ្ឋព្វារម្មណ៍មាន*

ធាតុដី ធាតុភ្លើង ធាតុខ្យល់ជាដើម ដូចជា រឹង ទន់ ប្រាកដតាមកាយទ្វារ តថាគតត្រាស់ដឹងផោដ្ឋព្វារម្មណ៍ទាំងអស់នោះ យ៉ាងនេះថា សត្វនេះពាល់ត្រូវផោដ្ឋព្វារម្មណ៍ឈ្មោះនេះ ក្នុងខណៈនេះហើយ កើតសេចក្ដីពេញចិត្តខ្លះ ទាស់ចិត្តខ្លះ ជាកណ្ដាលខ្លះ ដូច្នេះ ។ មួយទៀត ធម្មារម្មណ៍ មានសុខ និងទុក្ខជាដើម ប្រាកដតាមមនោទ្វាររបស់មនុស្សលោក ព្រមទាំងទេវលោកនេះ ក្នុងលោកធាតុដែលរកប្រមាណមិនបាន តថាគតត្រាស់ដឹងធម្មារម្មណ៍នោះទាំងអស់យ៉ាងនេះថា សត្វនេះដឹងធម្មារម្មណ៍ឈ្មោះនេះ ក្នុងខណៈនេះហើយ កើតសេចក្ដីពេញចិត្តខ្លះ ទាស់ចិត្តខ្លះ ជាកណ្ដាលខ្លះ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ក៏អារម្មណ៍ណាដែលសព្វសត្វទាំងនេះ ឃើញហើយ បានឮហើយ ជ្រាបហើយ ដឹងហើយ ក្នុងអារម្មណ៍នោះ តថាគតមិនឃើញ មិនបានឮ មិនជ្រាប ឬមិនដឹង ក៏មិនមែន ចំណែកអារម្មណ៍ដែលមហាជននេះស្វែងរកហើយតែមិនជួបក៏មាន មិនស្វែងរកហើយមិនជួបក៏មាន ស្វែងរកហើយទើបជួបក៏មាន មិនស្វែងរកហើយតែជួបក៏មាន អារម្មណ៍សូម្បីទាំងអស់ឈ្មោះថា ដែលតថាគតមិនជួប គឺ មិនធ្វើឲ្យច្បាស់ដោយញាណ មិនមានទេ ។

បទថា តស្មា តថាគតោតិ វុច្ចតិ (ព្រោះហេតុនោះ មនុស្សលោក

ទើបហៅថា តថាគត) សេចក្ដីថា ហៅថា តថាគត ព្រោះលោកទៅយ៉ាងណា តថាគតក៏ទៅយ៉ាងនោះឯង ។ ចំណែកក្នុងបាលីលោកពោលថា **អភិសម្ពុទ្ធំ** បទនោះ ក៏មានអត្ថតែម្យ៉ាងដូចតថាគតស័ព្ទ ។ គប្បីជ្រាបអត្ថនៃបទខាងចុងថា **តថាគត** ក្នុងគ្រប់វារៈដោយន័យនេះ ។ ការពោលត្រូវនៃតថាគតសព្ទនោះ ពោលទុកដោយពិស្ដារនៃតថាគតសព្ទ ក្នុងអដ្ឋកថាដែលពោលដោយឯកបុគ្គល ។ មួយទៀត ក្នុងសេចក្ដីនេះ សព្ទថា **អញ្ញទត្ថុ** ជានិបាតចុះក្នុងអត្ថថា ចំណែកមួយ ។ ឈ្មោះថា **ទសៈ** (អ្នកឃើញ) ព្រោះឃើញ ។ ឈ្មោះថា **វសវត្តិ** (អ្នកគ្រងអំណាច) ព្រោះប្រើអំណាច ។

បទថា **សព្វលោកំ អភិញ្ញាយ** (ដឹងច្បាស់លោកសន្និវាសទាំងពួង) សេចក្ដីថា ដឹងលោកសន្និវាសដែលជាត្រៃធាតុ (ធាតុបី) ។ បទថា **សព្វលោកេ យថាតថំ** (តាមពិតក្នុងលោកទាំងពួង) សេចក្ដីថា វត្ថុណានីមួយគប្បីដឹងបានក្នុងលោកសន្និវាសដែលជាធាតុបីនោះ ទ្រង់ដឹងវត្ថុទាំងអស់នោះតាមសេចក្ដីពិត មិនវិបរិត ។ បទថា **វិសំយុត្តោ** (ប្រាសចាក) សេចក្ដីថា ប្រាសចាកយោគៈ ព្រោះទ្រង់លះយោគៈ ៤ បាន ។ បទថា **អនុស្សយោ** (បុគ្គលមិនមានតណ្ហា ទិដ្ឋិ និងឥស្សា) សេចក្ដីថា លះបង់ជាសមុច្ឆេទនូវតណ្ហា ទិដ្ឋិ និងឧស្សយា (ឥស្សា) ។ បទថា **សព្វាភិភូ** (គ្របសង្កត់អារម្មណ៍

ទាំងពួង) សេចក្ដីថា ជាអ្នកគ្របសង្កត់អារម្មណ៍ទាំងពួង មានរូបជាដើម បានហើយ ។ បទថា **ធីរោ** (ជាអ្នកប្រាជ្ញ) គឺ បុគ្គលដល់ព្រមដោយធិតិ-បញ្ញា ។ បទថា **សព្វគន្ថប្បមោចនោ** (រួចចាកកិលេសជាគ្រឿងចងបាន) សេចក្ដីថា រួចផុតពីកិលេសជាគ្រឿងដោតក្រងទាំង ៤ បាន ។ បទថា **ផុដ្ឋស្ស** (សម្រេច) កាត់បទជា **ផុដ្ឋា អស្ស** និងបទនេះ ជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃតតិយាវិភត្តិ ។ បទថា **បរមា សន្តិ** (ជាសេចក្ដីស្ងប់ដ៏ក្រៃលែង) បានដល់ និព្វាន ។ ពិតហើយ និព្វាននោះ ដែលធីរជនពាល់ត្រូវហើយ ដោយការសម្រេចព្រោះញាណនោះ ដោយហេតុនោះ លោកទើបពោលថា **និព្វានំ អកុតោភយំ** (ព្រះនិព្វាន... ដែលមិនមានភ័យអំពីទីណាៗ) ដូច្នេះ ។ ម្យ៉ាងទៀត បទថា **បរមា សន្តិ** បានដល់ សេចក្ដីស្ងប់ដ៏កំពូល សួរថា សេចក្ដីស្ងប់ដ៏កំពូលនោះ គឺអ្វី ។ ឆ្លើយថា សេចក្ដីស្ងប់ដ៏កំពូលនោះ គឺ និព្វាន ។ ក៏ព្រោះហេតុដែលក្នុងនិព្វាន មិនមានភ័យសូម្បីពីទីណា ដូច្នោះ និព្វាននោះ លោកទើបហៅថា មិនមានភ័យអំពីទីណាៗ ។ បទថា **វិមុត្តោ ឧបធិសំខយេ** (រួចផុតហើយព្រោះអស់ឧបធិ) សេចក្ដីថា រួចផុតហើយ ព្រោះនិព្វាន ពោលគឺ ធម៌ជាទីអស់ឧបធិ ដោយផលវិមុត្តិ ដែលមាននិព្វាននោះជាអារម្មណ៍ ។ បទថា **សីហោ អនុត្តរោ** (ជាបុគ្គលអង់អាចក្លាហាន

មិនមានបុគ្គលដទៃក្រៃលែងជាង) សេចក្ដីថា តថាគត ឈ្មោះថា ជាបុគ្គលអង់អាចក្លាហាន មិនមានបុគ្គលក្រៃលែងជាង ព្រោះអត្ថថា ទ្រង់អត់ធន់ក្នុងអន្តរាយទាំងឡាយ និងព្រោះអត្ថថា កម្ចាត់កិលេសទាំងឡាយ ។ បទថា **ព្រហ្មំ** (ព្រហ្ម) បានដល់ ប្រសើរ ។ បទថា **ឥតិ** (ព្រោះដឹងព្រះគុណដូច្នេះ) សេចក្ដីថា ព្រោះដឹងគុណរបស់តថាគតយ៉ាងនេះ ។ បទថា **សង្គម្ម** (នាំគ្នាមក) បានដល់ មកប្រជុំគ្នាហើយ ។ បទថា **នំ** គឺ ព្រះតថាគត ។ បទថា **នមស្សន្តិ** (នមស្ការ) សេចក្ដីថា ទេវតា និងមនុស្សទាំងនោះ ដល់ព្រះតថាគតនោះជាសរណៈហើយ នមស្ការហើយ ។ ឥឡូវនេះ កាលនឹងទ្រង់សម្ដែងដល់ទេវតា និងមនុស្សនមស្ការហើយ ទើបត្រាស់បទជាដើមថា **ទន្តោ** (ទ្រង់ហ្វឹកហាត់ព្រះអង្គហើយ) ដូច្នេះ ។ បទនោះ មានសេចក្ដីងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា លោកសូត្រទី ៣

# អដ្ឋកថា កាឡុការាមសូត្រទី ៤

## "ព្រះធម៌ទេសនានៅវត្តកាឡុការាម"

គប្បីជ្រាបវិនិច្ឆ័យក្នុង កាឡុការាមសូត្រទី ៤ ដូចតទៅនេះ ៖

[២៥] កាឡុការាមសូត្រទី ៤ តាំងឡើងព្រោះអត្ថុប្បត្តិ ។ សួរថា ហេតុកើតរឿងអ្វី ។ ឆ្លើយថា រឿងព្រះគុណរបស់ព្រះទសពល ។

បានឮថា នាងចូឡសុភទ្ទា ធីតារបស់អនាថបិណ្ឌិកៈកំណត់ថា យើងនឹងទៅកាន់ផ្ទះរបស់បុត្រកាឡកសេដ្ឋី ក្នុងនគរសាកេត ទើបចូលទៅគាល់ព្រះសាស្តា ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅកាន់ត្រកូលស្វាមីដែលជាត្រកូលរបស់បុគ្គលមិច្ឆាទិដ្ឋិ ប្រសិនបើខ្ញុំព្រះអង្គនឹងបានទទួលការរាប់អានក្នុងត្រកូលនោះ កាលនឹងបញ្ជូនបុរសម្នាក់មក ក៏នឹងយឺតយូរ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គមេត្តាប្រោសទឹកដល់ខ្ញុំព្រះអង្គខ្លះ បានទទួលការទទួលហើយក៏ទៅ ។ កាឡកសេដ្ឋីគិតថា កូនប្រសាររបស់យើងមកហើយ កាលធ្វើការមង្គល ទើបបានចាត់ចែងរបស់ស៊ី និងរបស់បរិភោគជាច្រើន បានអញ្ជើញជីអាក្រាត ៥០០ មក ។ កាលជីអាក្រាតទាំងនោះអង្គុយហើយ ។ លោកសេដ្ឋីទើបបញ្ជូនមនុស្សទៅប្រាប់នាងចូឡសុភទ្ទាថា កូនក្រមុំរបស់ពុកចូរមកសំពះព្រះអរហន្ត ។ អរិយសាវិកាដែលសម្រេចផល

ហើយ ពេលគេនិយាយថា ព្រះអរហន្តប៉ុណ្ណោះ ក៏ក្រោកឡើងទៅ ដោយគិតថា លាភរបស់យើងហ្ន៎ ។ ពេលបានឃើញជីអាក្រាត ដែលសម្តែងការមិនមានសរីទាំងនោះ ទើបនិយាយថា លោកពុក បុគ្គលមិនមានហិរិខាងក្នុង មិនមានឱត្តប្បៈខាងក្រៅបែបនេះ មិនមែនជាសមណៈទេ គិតថាពួកទាំងនេះមិនមែនជាសមណៈ ទើបស្តោះទឹកមាត់ដើរត្រឡប់ទៅកាន់ទីនៅរបស់ខ្លួន ។

គ្រានោះ ពួកជីអាក្រាតនិយាយថា លោកមហាសេដ្ឋី ស្រីកាឡកណ្ណីដូច្នេះ លោកបានមកពីណា ទូទាំងជម្ពូទ្វីបមិនមានស្រីក្រមុំដទៃឬ ហើយក៏នាំគ្នាបរិភាសសេដ្ឋី ។ លោកសេដ្ឋីទើបសូមអង្វរថា លោកអាចារ្យ កម្មដែលខ្ញុំដឹង ឬមិនដឹង ក៏បានធ្វើហួសទៅហើយ ខ្ញុំនឹងដឹងវត្ថុដែលគួរធ្វើក្នុងរឿងនេះ ។ បញ្ជូនពួកជីអាក្រាតទៅហើយ ក៏ទៅរកនាងសុភទ្ទា សួរថាណែ៎នាង ហេតុអ្វី នាងទើបបានធ្វើយ៉ាងនេះ ហេតុអ្វីនាងទើបធ្វើឲ្យព្រះអរហន្តអៀនខ្មាស ។ នាងឆ្លើយថា លោកពុក ធម្មតាថា ព្រះអរហន្តមិនដូច្នេះ ។ គ្រានោះលោកសេដ្ឋី ទើបនិយាយចំពោះនាងថា

សមណៈរបស់នាងដូចម្តេច នាងទើបសរសើរលោកខ្លាំងម្ល៉េះ
សមណៈរបស់នាងមានសីលដូចម្តេច មានមារយាទដូចម្តេច

នាងត្រូវសួរហើយ ចូរប្រាប់សេចក្ដីនោះដល់ពុក ។

នាងទើបឆ្លើយថា

លោកអ្នកមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ តាំងនៅក្នុងមគ្គ
មានគុណដែលស្ងប់ មានចក្ខុដាក់ចុះ និយាយល្មមប្រមាណ
សមណៈរបស់កូនដូច្នេះឯង សមណៈទាំងនេះកាត់កិលេស
ជាគ្រឿងចង ចូលព្រៃនៅតែម្នាក់ឯង មិនមានសំឡាញ់ ដូច
ដំរីផ្ដាច់គ្រឿងចង សមណៈរបស់កូនដូច្នេះឯង ។

លុះពោលយ៉ាងនេះហើយ ទើបឈរពោលព្រះគុណរបស់ព្រះរតនត្រ័យចំពោះមុខសេដ្ឋី ។ សេដ្ឋីស្ដាប់ពាក្យរបស់នាងហើយ ទើបពោលថា បើជាដូច្នោះ យើងនឹងនាំសមណៈរបស់នាងមកធ្វើមង្គល ។ នាងសួរថា លោកពុកនឹងធ្វើកាលណា ។ សេដ្ឋីគិតថា កាលយើងប្រាប់ថា ២-៣ ថ្ងៃ នាងនឹងគប្បីបញ្ជូនទូតទៅឲ្យហៅមក បើដូច្នោះ ទើបបានប្រាប់ដល់នាងថា ស្អែកនេះចុះ នាង ។ ក្នុងវេលាល្ងាច នាងឡើងប្រាសាទជាន់លើ កាន់កាជនៈផ្កាឈើខ្នាតធំ រលឹកដល់ព្រះគុណរបស់ព្រះសាស្ដាហើយ ទើបបាចផ្កាឈើ ៨ កាំ ទៅដើម្បីព្រះទសពល ហើយផ្គងអញ្ជលី ឈរនមស្ការ ។ នាងបានពោលយ៉ាងនេះថា ស្អែកនេះ សូមព្រះអង្គទ្រង់មេត្តាប្រោសទទួលកិច្ចារបស់

ខ្ញុំព្រះអង្គព្រមទាំងភិក្ខុសង្ឃ ៥០០ រូប ។ ផ្កាឈើទាំងនោះ ទៅប្រតិស្ឋាន ជាពិតានខាងលើព្រះទសពល ។ ព្រះសាស្តា កាលទ្រង់ទឹកដល់ ក៏ទ្រង់បាន ឃើញហេតុនោះ ក្នុងវេលាចប់ព្រះធម៌ទេសនា អនាថបិណ្ឌិកមហាសេដ្ឋី នមស្ការព្រះទសពល ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃស្អែកនេះ សូមព្រះអង្គព្រមទាំងភិក្ខុ ៥០០ រូប ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា លោកសេដ្ឋី តថាគតទទួលនិមន្តអំពីនាងចូឡសុភទ្ទា ហើយ ។ លោកសេដ្ឋីទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនឃើញ នរណាមក ។ ព្រះសាស្តាត្រាស់ថា ត្រូវហើយលោកសេដ្ឋី តែឧបាសិកា ដែលជាសប្បុរស សូម្បីនៅឆ្ងាយបំផុតពាន់យោជន៍ ក៏រមែងប្រាកដបាន ដូច ភ្នំហិមវន្ត ទើបត្រាស់ព្រះគាថានេះថា ៖-

ពួកសប្បុរសប្រាកដច្បាស់ក្នុងទីឆ្ងាយ ដូចហិមវន្តបពិត<br>
ចំណែកពួកអសប្បុរស នៅក្នុងទីនុ៎ះឯងក៏មិនមាននរណា<br>
ឃើញ ដូចកូនសរដែលបាញ់ទៅវេលាយប់ ។

អនាថបិណ្ឌិកៈទូលថា សូមព្រះអង្គទ្រង់មេត្តាប្រោសសង្គ្រោះធីតា របស់ខ្ញុំព្រះអង្គចុះ ព្រះអង្គ ថ្វាយបង្គំហើយក៏ត្រឡប់ទៅ ។

ព្រះសាស្តាត្រាស់ចំពោះព្រះអានន្ទថា អានន្ទ យើងនឹងទៅនគរសាកេត

អ្នកចូរឲ្យស្វាគដល់ភិក្ខុ ៥០០ រូប តែកាលនឹងឲ្យ អ្នកគប្បីឲ្យដល់ពួកភិក្ខុដែលសម្រេចអភិញ្ញា ៦ ប៉ុណ្ណោះ ។ ព្រះថេរៈក៏បានធ្វើយ៉ាងនោះ ។ ក្នុងពេលយប់ជ្រៅនៃរាត្រី នាងចូឡសុភទ្ទាគិតថា ធម្មតា ព្រះពុទ្ធទាំងឡាយទ្រង់មានកិច្ចច្រើន ទ្រង់មានករណីយច្រើន តើព្រះអង្គទ្រង់ជ្រាបឬទេហ្ន៎ យើងនឹងធ្វើយ៉ាងណាហ្ន៎ ។ ខណៈនោះ ស្តេចវេស្សវណមហារាជបានពោលនឹងនាងចូឡសុភទ្ទាថា នាងសុភទ្ទាថា នាងកុំខ្វល់ កុំលំបាកចិត្តឡើយ ព្រះមានព្រះភាគនឹងភិក្ខុសង្ឃទ្រង់ទទួលនិមន្ត ដើម្បីសោយភត្តាហារក្នុងថ្ងៃស្អែកនេះហើយ នាងត្រេកអររីករាយត្រៀមទានតែម្យ៉ាង ។ សូម្បីស្តេចសក្កទេវរាជ ទ្រង់ហៅវិស្សុកម្មមកបង្គាប់ថា បាអើយ ព្រះទសពលស្តេចនឹងយាងទៅកាន់សំណាក់របស់នាងចូឡសុភទ្ទា នគរសាកេត អ្នកចូរសាងផ្ទះកំពូល ៥០០ ខ្នង ។ វិស្សុកម្មទេវបុត្រនោះ ក៏បានធ្វើតាមទេវឱង្ការ ។ ព្រះសាស្តាដែលមានភិក្ខុប្រកបដោយអភិញ្ញា ៦ ចំនួន ៥០០ រូប ហែហមហើយ ស្តេចបានទៅកាន់នគរសាកេត ដោយប្រើផ្ទះកំពូលជាយាន ដូចជាស្នាមគំនូសអាកាសដែលមានពណ៌ដូចកែវមណី ។

នាងចូឡសុភទ្ទាថ្វាយទានចំពោះព្រះភិក្ខុសង្ឃ មានអង្គព្រះពុទ្ធជាប្រធាន ថ្វាយបង្គំព្រះសាស្តាទូលថា ចំណែកឪពុកក្មេករបស់ខ្ញុំព្រះអង្គ ជា

មិច្ឆាទិដ្ឋិ សូមព្រះអង្គមេត្តាប្រោសត្រាស់ធម៌ដែលគួរដល់ជនទាំងនោះផង ចុះ ព្រះអង្គ ។ ព្រះសាស្ដាទ្រង់សម្ដែងធម៌ហើយ ។ កាឡកសេដ្ឋីបានជាសោតាបន្ន បានថ្វាយឧទ្យានរបស់ខ្លួនដល់ព្រះទសពល ។ ពួកជីអាក្រាតមិនប្រាថ្នានឹងចេញទៅ (ពីឧទ្យាននោះ) ដោយគិតថា លោកសេដ្ឋីឲ្យដល់ពួកយើងមុនដូច្នេះ ។ លោកសេដ្ឋីបង្គាប់ឲ្យនាំជីអាក្រាតទាំងអស់ចេញទៅដោយពោលថា ពួកលោកចូរទៅ នាំពួកជីអាក្រាតទាំងនោះចេញទៅ ដោយវិធីការដែលនឹងគប្បីនាំចេញទៅឲ្យបាន ដូច្នេះហើយ ទើបឲ្យសាងវិហារក្នុងទីត្រង់នោះឯង ហើយបង្ហូរទឹកធ្វើឲ្យជាព្រហ្មទេយ្យ ។ វិហារនោះ ទើបឈ្មោះថា កាឡការាម ព្រោះកាឡសេដ្ឋីឲ្យសាង ។ សម័យនោះ ព្រះមានព្រះភាគប្រថាប់នៅក្នុងកាឡការាមនោះ ។ ព្រោះហេតុនោះ លោកទើបពោលថា **សាកេតេ វិហរតិ កាឡការាមេ** (ប្រថាប់នៅកាឡការាម ដែននគរសាកេត ។

បទថា **ភិក្ខូ អាមន្តេសិ** (ត្រាស់ហៅភិក្ខុទាំងឡាយមក) បានដល់ព្រះមានព្រះភាគត្រាស់ហៅភិក្ខុ ៥០០ រូបមក ។ បានឮថា ភិក្ខុទាំងនោះជាកុលបុត្រអ្នកនគរសាកេត ស្ដាប់ព្រះធម៌ទេសនារបស់ព្រះសាស្ដាហើយបួសក្នុងសំណាក់របស់ព្រះសាស្ដា អង្គុយនៅសាលាដែលបម្រុង ពោលគុណរបស់ព្រះទសពលថា ឱ! ឈ្មោះថា គុណរបស់ព្រះពុទ្ធទាំងឡាយធំណាស់

ព្រះសាស្ដាទ្រង់ដោះកាឡកសេដ្ឋីដែលជាមិច្ឆាទិដ្ឋិបែបនេះ ចេញពីមិច្ឆាទិដ្ឋិ (ការឃើញខុស) បាន ឲ្យសម្រេចសោតាបត្តិផល ទ្រង់ធ្វើទូទាំងនគរឲ្យស្មើដូចជាទេវលោក ។ ព្រះសាស្ដាទ្រង់ពិចារណាដល់ចិត្តរបស់ភិក្ខុ ដែលពោលសរសើរទាំងនោះ ទើបទ្រង់ព្រះតម្រិះថា កាលតថាគតទៅ ទេសនាកណ្ឌធំនឹងតាំងឡើង វេលាចប់ទេសនា ភិក្ខុទាំង ៥០០ រូបនេះ នឹងតាំងនៅក្នុងព្រះអរហត្តផល ផែនដីធំនឹងកម្រើកដល់ទឹកទ្រផែនដី ហើយស្ដេចទៅកាន់ធម្មសភា ប្រថាប់លើបវរពុទ្ធាសនៈដែលគេក្រាលថ្វាយ ទ្រង់ធ្វើភិក្ខុទាំងនោះឲ្យជាខាងដើមហើយ ទើបទ្រង់ផ្ដើមទេសនានេះថា **យំភិក្ខវេ សទេវកស្ស លោកស្ស** (ម្នាលភិក្ខុទាំងឡាយ វត្ថុណាដែលលោកព្រមទាំងទេវលោក) ។ ព្រះសូត្រនេះ គប្បីជ្រាបថា តាំងឡើងព្រោះរឿងព្រះគុណដោយប្រការដូច្នេះ ។

វេលាចប់ទេសនា ផែនដីធំបានកម្រើកដល់ទឹកទ្រផែនដី ។ បទថា **អព្ភញ្ញាសិ** (ដឹងក្រៃលែងហើយ) បានដល់ បានដឹងដោយបញ្ញាដ៏ក្រៃលែង អធិប្បាយថា ត្រាស់ដឹងហើយ ។ បទថា **វិទិតំ** (ដឹងច្បាស់) បានដល់ ដឹងព្រោះធ្វើឲ្យប្រាកដបាន ។ ដោយបទនេះ ទ្រង់សម្ដែងសេចក្ដីនេះថា ជនពួកដទៃដឹងតែម្យ៉ាង តែតថាគតដឹងហើយធ្វើឲ្យប្រាកដផង ។ ឈ្មោះថា ភូមិ

នៃព្រះសព្វញ្ញុតញ្ញាណ ត្រាស់ដោយបីបទទាំងនេះ ។ បទថា **តំ តថាគតេន ឧបដ្ឋសិ** (តែវត្ថុនោះមិនប្រាកដក្នុងតថាគត) សេចក្ដីថា អារម្មណ៍ដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ នោះ មិនប្រាកដ គឺ មិនចូលទៅដល់តថាគតដោយតណ្ហា ឬដោយទិដ្ឋិ ។ ពិតហើយ ព្រះមានព្រះភាគព្រះអង្គនេះ ទ្រង់ឃើញរូបដោយចក្ខុ ព្រះមានព្រះភាគទ្រង់មិនមានឆន្ទរាគៈ ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់មានចិត្តរួចផុតល្អហើយ ព្រះមានព្រះភាគទ្រង់ស្ដាប់សំឡេងដោយសោតៈ ទ្រង់ធុំក្លិនដោយឃានៈ ទ្រង់ភ្លក់រសដោយជិវ្ហា ទ្រង់ប៉ះខ្ទប់ផោដ្ឋព្វៈដោយកាយ ទ្រង់ដឹងធម៌ដោយមនៈ ព្រះមានព្រះភាគទ្រង់មិនមានឆន្ទរាគៈ ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់មានចិត្តរួចផុតល្អហើយ ព្រោះហេតុនោះ ទើបត្រាស់ថា **វត្ថុនោះមិនប្រាកដក្នុងតថាគត** ។ ក៏ឯភូមិរបស់ព្រះខីណាស្រព គប្បីជ្រាបថា ត្រាស់ដោយបទនេះ ។

បទថា **តំ មមស្ស មុសា** (ពាក្យនោះកប្បីជាពាក្យមុសារបស់យើង) សេចក្ដីថា ពាក្យនោះឯង គប្បីឈ្មោះថា **មុសាវាទ** ។ បទថា **តំបិស្ស តាទិសមេវ** (ពាក្យនោះក៏ជាពាក្យមុសាដូចគ្នា) សេចក្ដីថា ពាក្យនោះក៏គប្បីជាមុសាវាទ ។ បទថា **តំ មមស្ស កលិ** (ពាក្យនោះក៏ជាទោសរបស់យើង) សេចក្ដីថា ពាក្យនោះក៏គប្បីជាទោសដល់យើង ។ ធម្មតា សច្ចភូមិ

គប្បីជ្រាបថា ត្រាស់ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

បទថា **ទិដ្ឋា ទិដ្ឋព្វំ** (ឃើញវត្ថុគប្បីឃើញបាន) បានដល់ ឃើញរូបដែលគួរឃើញហើយ ។ បទថា **ទិដ្ឋំ ន មញ្ញតិ** (មិនសម្គាល់ថាបានឃើញ) សេចក្តីថា រមែងមិនសម្គាល់អាយតនៈ គឺ រូប ដែលឃើញហើយនោះដោយតណ្ហា មានៈ ទិដ្ឋិ ថា យើងក៏ឃើញរូបដែលមហាជនឃើញហើយដូចគ្នា ។ បទថា **អទិដ្ឋំ ន មញ្ញតិ** (មិនសម្គាល់ថាមិនបានឃើញ) សេចក្តីថា រមែងមិនសម្គាល់ដោយតណ្ហាជាដើម សួម្បីយ៉ាងនេះថា យើងឃើញរូបនោះដែលមហាជនមិនបានឃើញ ។ បទថា **ទិដ្ឋព្វំ ន មញ្ញតិ** (មិនសម្គាល់ថាត្រូវឃើញ) សេចក្តីថា រមែងមិនសម្គាល់ ដោយសេចក្តីសម្គាល់ទាំងនោះ សូម្បីយ៉ាងនេះថា យើងក៏ឃើញរូបដែលមហាជនឃើញហើយ ។ ពិតណាស់ រូបដែលគួរឃើញ ក៏ជារូបដែលមហាជនឃើញហើយនុ៎ះឯង ។ ក៏ពាក្យបែបនេះ អ្នកសិក្សារមែងរកបានសូម្បីក្នុងបីកាល ។ អត្ថនៃពាក្យទាំងនោះ ត្រាស់ហើយដោយបទនោះ ។ បទថា **ទិដ្ឋារំ**[១] **ន មញ្ញតិ** (មិនសម្គាល់ថាជាអ្នកឃើញ) សេចក្តីថា រមែងមិនសម្គាល់អ្នកឃើញនេះ ឈ្មោះថា ជាសត្វដោយសេចក្តីសម្គាល់ទាំងនោះ ។ សូម្បីក្នុងឋានៈដ៏សេស ក៏គប្បីជ្រាបអត្ថ

---

(១) បាលី = ទិដ្ឋានំ ។

ដោយន័យនេះឯង ។ ឈ្មោះថា **សញ្ញាតាភូមិ** (ភូមិ គឺ ការសួនទ្រទេ) ក៏ត្រាស់ដោយឋានៈប្រមាណប៉ុណ្ណេះ ។

បទថា **ឥតិ ខោ ភិក្ខវេ** បានដល់ ម្នាលភិក្ខុទាំងឡាយ ដូច្នេះឯង ។ បទថា **តាទិសោវ តាទី** (បុគ្គលស្ថិតនៅដូច្នេះ) សេចក្តីថា មានអាការតែម្យ៉ាង ឈ្មោះថា ការស្ថិតនៅ ។ ពិតណាស់ ព្រះតថាគតទោះស្ថិតក្នុងឥដ្ឋារម្មណ៍ មានលាភជាដើម ក្នុងអនិដ្ឋារម្មណ៍ មានការមិនមានលាភជាដើមក៏ដូច្នោះ ព្រោះហេតុនោះ លោកទើបពោលថា តថាគតទ្រង់ស្ថិតនៅទាំងក្នុងលាភ ទាំងក្នុងការមិនមានលាភ ទ្រង់ស្ថិតនៅទាំងក្នុងយស ទាំងក្នុងការមិនមានយស ទ្រង់ស្ថិតនៅទាំងក្នុងនិន្ទា ទាំងក្នុងសរសើរ ទ្រង់ស្ថិតនៅទាំងក្នុងសុខ ទាំងក្នុងទុក្ខ ។ តថាគត ឈ្មោះថា **ទ្រង់ស្ថិតនៅដូច្នោះ** ក៏ព្រោះភាពជាអ្នកស្ថិតនៅ ។ បទថា **តម្ហា ច បន តាទិម្ហា** (ជាងតថាគតដែលស្ថិតនៅ) សេចក្តីថា ឈ្មោះថា ភូមិនៃបុគ្គលស្ថិតនៅ ដែលត្រាស់ដោយពាក្យប្រមាណប៉ុណ្ណេះថា បុគ្គលស្ថិតនៅដទៃដ៏ក្រៃលែងជាង ឬប្រណីតជាងតថាគតជាអ្នកស្ថិតនៅនោះ មិនមាន ។ កាលព្រះមានព្រះភាគ ទ្រង់អធិប្បាយទេសនាដោយភូមិទាំង ៥ នេះ មហាប្រឹថពីក៏បានកម្រើកជាសាក្សីក្នុងឋានៈទាំង ៥ ។ វេលាចប់ទេសនា សត្វ គឺ ទេវតា និងមនុស្សចំនួន

៨៤.០០០ នាក់ មកដល់ទីនោះ រួមទាំងកុលបុត្រ ៥០០ ដែលបួសថ្មីទាំងនោះ ជាដើម ក៏នាំគ្នាផឹកទឹកអម្រឹតធម៌ហើយ ។

សូម្បីព្រះមានព្រះភាគ ទ្រង់បញ្ចប់ព្រះសូត្រហើយ កាលនឹងទ្រង់កាន់កំពូលធម៌ដោយគាថាទាំងឡាយ ទើបត្រាស់បទថា **យំកិញ្ចិ** (វត្ថុណាមួយ) ជាដើម ។ ក្នុងបទទាំងនោះ បទថា **អជ្ឈោសិតំ សច្ចមុតំ បរេសំ** (ដែលបុគ្គលដទៃវង្វេងជាប់ចិត្ត សម្គាល់ថាពិត) សេចក្តីថា វត្ថុដែលបានឃើញជាដើម ដែលបុគ្គលពួកដទៃសម្គាល់ថាពិត ហើយជាប់ចិត្តដោយការជឿដែលប្រព្រឹត្តតាមបុគ្គលដទៃ គឺ លេបទុកស្រេច ។ បទថា **សយសំវុតេសុ** (សង្រួមល្អហើយដោយខ្លួនឯង) សេចក្តីថា ក្នុងការកាន់យកវត្ថុដែលខ្លួនរវាំងហើយ គឺ ប្រព្រឹត្តកាន់យកហើយ អធិប្បាយថា ក្នុងបុគ្គលដែលមានទិដ្ឋិជាគតិ គេក៏ហៅថា **សង្រួមល្អហើយដោយខ្លួនឯង** ។ បទថា **សច្ចំ មុសា វាបិ បរំ ទហេយ្យ** (មិនគប្បីជឿពាក្យបុគ្គលដទៃថា ពិត ឬកុហក) សេចក្តីថា តថាគតជាអ្នកស្ថិតនៅក្នុងបុគ្គលដែលមានទិដ្ឋិជាគតិ ពោលគឺដែលខ្លួនប្រយ័ត្នឯងហើយទាំងនោះ មិនគប្បីដាក់ចិត្ត មិនគប្បីជឿ មិនគប្បីប្រព្រឹត្តតាមពាក្យ សូម្បីពាក្យណាមួយរបស់បុគ្គលទាំងនោះ ធ្វើការប្រៀបថា ពិត ឬកុហក យ៉ាងនេះថា នេះប៉ុណ្ណោះពិត យ៉ាងដទៃមិនពិត ។ បទ

ថា **ឯត្តញ្ច សល្លំ** (កូនសរ គឺ ទិដ្ឋិនេះ) គឺ តថាគតឃើញកូនសរ គឺ ទិដ្ឋិនេះ ។ បទថា **បដិកច្ច ទិស្វា** (ឃើញ... ពីដំបូងហើយ) សេចក្ដីថា តថាគតឃើញមកពីមុន ត្រង់គល់ពោធិព្រឹក្ស ។ បទថា **វិសត្តា** (ជាប់នៅ) សេចក្ដីថា ពួកបុគ្គលណាជាប់ ជាប់ជំពាក់ ពាក់ព័ន្ធហើយ ។ ក្នុងបទថា **ជានាមិ បស្សាមិ តថេវ ឯតំ** (រមែងឃើញវត្ថុនោះ យ៉ាងនោះដូចគ្នា) នេះ សេចក្ដីថា ពួកសត្វនេះជាប់ចិត្ត លេបស្រេចហើយ ក៏ជាប់ ក៏ជាប់ជំពាក់ ក៏ពាក់ព័ន្ធ សូម្បីតថាគតក៏បានឃើញវត្ថុនេះ វត្ថុនោះក៏ដូចដែលពួកសត្វនេះប្រកាន់ទុក តែតថាគតទាំងឡាយមិនជាប់ជំពាក់យ៉ាងនោះ ។

ចប់អដ្ឋកថា កាឡការាមសូត្រទី ៤

# អដ្ឋកថា ព្រហ្មចរិយសូត្រទី ៥

## “សេចក្តីបំណងនៃការប្រព្រឹត្តព្រហ្មចរិយៈ”

គប្បីជ្រាបវិនិច្ឆ័យក្នុង ព្រហ្មចរិយសូត្រទី ៥ ដូចតទៅនេះ ៖

[២៦] បទថា **ជនកុហនត្ថំ** (ដើម្បីល្បួងលួងមហាជន) សេចក្តីថា ដើម្បីការបញ្ឆោតបន្លំដល់ជន ដោយរឿងកុហនវត្ថុ ៣ យ៉ាង ។ បទថា **ន ជនលបនត្ថំ** (មិនមែនស្រែកហៅមហាជនឲ្យមករាប់អាន) បានដល់ មិនមែនដើម្បីបញ្ចុះបញ្ចូលមហាជន ។ បទថា **ន លាភសក្ការសិលោកានិសំសត្ថំ** (មិនមែនដើម្បីអានិសង្ស គឺ លាភសក្ការៈ និងសេចក្តីសរសើរ) បានដល់ មិនមែនដើម្បីលាភសក្ការៈ មានចីវរជាដើម និងពាក្យសរសើរ ។ បទថា **ន ឥតិវាទប្បមោក្ខានិសំសត្ថំ** (មិនមែនដើម្បីអានិសង្ស គឺ ជាមេលទ្ធិ និងដោះស្រាយលទ្ធិយ៉ាងនេះយ៉ាងនោះ) បានដល់ មិនមែនដើម្បីអានិសង្សជាម្ចាស់លទ្ធិ ដោយហេតុនោះៗ មិនមែនដើម្បីអានិសង្សនឹងដោះលទ្ធិ ។ បទថា **ន ឥតិមំ ជនោ ជានាតុ** (មិនមែនដើម្បីឲ្យមហាជនស្គាល់ខ្លួនថា ជាយ៉ាងនេះ ជាយ៉ាងនោះ) បានដល់ មិនមែនដើម្បីឲ្យមហាជនស្គាល់ថា បានឮថា ភិក្ខុនោះជាយ៉ាងនេះ ។ បទថា **សំវរត្ថំ** (ដើម្បីសង្រួម) បានដល់ ដើម្បីប្រយោជន៍ក្នុងការសង្រួមដោយសំវរៈ ៥ ។ បទថា **បហានត្ថំ** បានដល់

ដើម្បីប្រយោជន៍ក្នុងការលះដោយបហានៈ ៣ ។ បទថា **វិរាគត្ថំ** (ដើម្បីវិរាគៈ) បានដល់ ដើម្បីប្រយោជន៍ក្នុងការប្រាសចាកកិលេស មានរាគៈជាដើម ។ បទថា **និរោធត្ថំ** (ដើម្បីនិរោធ) បានដល់ ដើម្បីប្រយោជន៍ក្នុងការរំលត់កិលេសទាំងនោះឯង ។ បទថា **អនីតិហំ** (ដែលមិនមែនជាការជឿព្រោះបានឮ បានស្តាប់តាមគ្នាមក) បានដល់ វៀរចាកការកាន់តាមគ្នាមកតាមប្រពៃណី មិនប្រព្រឹត្តតាមអ្នកដទៃ ។ បទថា **និព្វានោគធគាមិនំ** (ជាដំណើរទៅក្នុងព្រះនិព្វាន) សេចក្តីថា ជាផ្លូវឈានចុះក្នុងនិព្វាន ។ ពិតណាស់ មគ្គព្រហ្មចរិយៈធ្វើនិព្វានឲ្យជាអារម្មណ៍ហើយ រមែងប្រព្រឹត្តទៅ គឺដើរទៅកាន់និព្វានទុះឯង ។ បទថា **បដិបជ្ជន្តិ** (ដើរតាម) បានដល់ ដើរតាមផ្លូវសូម្បីទាំងពីរយ៉ាង ។ ក្នុងព្រះសូត្រនេះ ត្រាស់ទាំងវដ្តៈទាំងវិវដ្តៈ ក្នុងគាថាត្រាស់វិវដ្តៈតែម្យ៉ាង ។

ចប់អដ្ឋកថា ព្រហ្មចរិយសូត្រទី ៥

# អដ្ឋកថា កុហសូត្រទី ៦

## *"ភិក្ខុអ្នកកុហក"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កុហសូត្រទី ៦ ដូចតទៅនេះ ៖*

*[២៧] បទថា **កុហា** (កុហក) ប្រែថា អ្នកបញ្ឆោតបន្លំ ។ បទថា **ថទ្ធា** (រឹងរូស) បានដល់ រឹងរូសដោយសេចក្តីក្រោធ និងមានះ ។ បទថា **លបា** (រឡេះរឡោះ) បានដល់ និយាយឡេះឡោះ ។ បទថា **សិង្គី** (តម្កើងខ្លួន) សេចក្តីថា បុគ្គលប្រកបដោយកិលេសដែលប្រាកដដូចស្នែងសត្វ ដែលលោកពោលយ៉ាងនេះថា បណ្តាកិលេសទាំងនោះ ការតម្កើងខ្លួន ដូចម្តេច ។ គឺ ការលើកតម្កើង ភាវៈ គឺ ការតម្កើងខ្លួន ភាវៈ គឺ ការលើកខ្លួនក្នុងឥរិយាបថ ៤ កិរិយាដាក់ខ្លួនក្នុងឥរិយាបថ ៤ ភាវៈ គឺ ការមានបុគ្គលហែហម កិរិយាដាក់ខ្លួនជាមួយបុគ្គលហែហម ។ បទថា **ឧន្នឡា** (ក្រអឺតក្រទម) សេចក្តីថា ដូចជាដើមបបុសដែលបះឡើង គឺ លើកមានះទទេៗតាំងឡើង ។ បទថា **អសមាហិតា** (មានចិត្តមិននឹងធឹង) សេចក្តីថា មិនបានសូម្បីត្រឹមតែឯកគ្គតាចិត្ត ។ បទថា **ន មេ តេ ភិក្ខវេ ភិក្ខូ មាមកា** (ភិក្ខុទាំងនោះឈ្មោះថា មិនរាប់អានតថាគត) សេចក្តីថា ភិក្ខុទាំងនោះរបស់តថាគត មិនមែនជាសម្បត្តិរបស់តថាគត ។ ក៏បទនេះថា **ភិក្ខុទាំងនោះរបស់***

តថាគត ត្រាស់ព្រោះបួសឧទ្ទិសព្រះសាស្តា ។ ក្នុងបទថា **តេ ខោ មេ ភិក្ខវេ ភិក្ខូ មាមកា** (ភិក្ខុទាំងនោះឈ្មោះថា រាប់អានតថាគត) ក៏ត្រាស់ព្រោះបួសឧទ្ទិសខ្លួនក្នុងសាសនានេះ តែត្រាស់ថា **មាមកា** (រាប់អានតថាគត) ព្រោះជាអ្នកបដិបត្តិប្រពៃ ។ បទថា **វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជន្តិ** (រមែងដល់សេចក្តីចម្រើនធំទូលាយ) សេចក្តីថា ភិក្ខុទាំងនោះ រមែងដល់សេចក្តីចម្រើន ព្រោះចម្រើនដោយសីលាទិគុណ សេចក្តីលូតលាស់ ព្រោះមិនញាប់ញ័រ សេចក្តីធំទូលាយ ព្រោះផ្សាយទៅក្នុងទីគ្រប់ស្ថាន ។ ក៏ភិក្ខុទាំងនោះ រមែងលូតលាស់ដរាបដល់អរហត្តមគ្គ កាលសម្រេចព្រះអរហត្តផលហើយ ឈ្មោះថា លូតលាស់ហើយ ។ ទាំងក្នុងព្រះសូត្រ ទាំងក្នុងគាថាត្រាស់ទាំងវដ្តៈ និងវិវដ្តៈ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា កុហសូត្រទី ៦

# អដ្ឋកថា សន្តុដ្ឋិសូត្រទី ៧

## “ការសន្តោសដោយបច្ច័យ ៤”

គប្បីជ្រាបវិនិច្ឆ័យក្នុង សន្តុដ្ឋិសូត្រទី ៧ ដូចតទៅនេះ ៖

[២៨] បទថា **អប្បានិ** (មានតម្លៃតិច) ប្រែថា របស់បន្តិចបន្តួច ។ បទថា **សុលភានិ** (រកបានងាយ) សេចក្តីថា គប្បីបានដោយងាយ គឺ នរណាក៏អាចនឹងបានក្នុងទីកន្លែងណាមួយ ។ បទថា **អនវជ្ជានិ** (មិនមានទោស) គឺ ប្រាសចាកទោស ។ បទថា **បិណ្ឌិយាលោបភោជនំ** (អាហារដែលបានមកដោយការដើរបិណ្ឌបាត្រ) បានដល់ អាហារត្រឹមតែដុំបាយដែលត្រាច់ទៅដោយកម្លាំងស្មងបានមក ។ បទថា **បូតិមុត្តំ** (ថ្នាំត្រាំដោយទឹកមូត្រស្អុយ) បានដល់ ទឹកមូត្រណាមួយ ។ កាយសូម្បីមានសម្បុរដូចមាស គេក៏ហៅថា កាយស្អុយ យ៉ាងណា សូម្បីទឹកមូត្រថ្មីៗ គេក៏ហៅថា ទឹកមូត្រស្អុយ ដូច្នោះ ។

បទថា **វិឃាតោ** (សេចក្តីបៀតបៀន) បានដល់ ភាវៈនៃចិត្តមិនប្រាស់ប្រាល អធិប្បាយថា ចិត្តមិនមានទុក្ខ ។ បទថា **ទិសា ន បដិហញ្ញតិ** (នឹងទៅកាន់ទិសណាក៏មិនក្តៅក្រហាយ) សេចក្តីថា ភិក្ខុណាកើតសេចក្តីគិតឡើងថា យើងទៅទីឈ្មោះឯណោះ នឹងបានចីវរជាដើម ចិត្តរបស់ភិក្ខុនោះ

ឈ្មោះថា រមែងក្តៅក្រហាយអស់នូវទិស ។ ភិក្ខុណា មិនកើតសេចក្តីគិតយ៉ាងនោះ ចិត្តរបស់ភិក្ខុនោះ ឈ្មោះថា មិនក្តៅក្រហាយអស់នូវទិស ។ បទថា **ធម្មា** (ធម្ម) គឺ បដិបត្តិធម៌ ។ បទថា **សាមញ្ញស្សានុលោមិកា** (សមគួរដល់ភាពជាសមណៈ) បានដល់ សមគួរដល់សមណធម៌ ។ បទថា **អធិគហិតា** (តម្កល់ទុកមាំហើយ) សេចក្តីថា ធម៌ទាំងអស់នោះ ភិក្ខុដែលមានចិត្តសន្តោសតាំងទុកល្អហើយនៅខាងក្នុងខ្លួន មិនទៅខាងក្រៅ ។

ចប់អដ្ឋកថា សន្តុដ្ឋិសូត្រទី ៧

# អដ្ឋកថា អរិយវង្សសូត្រទី ៨

## *"អរិយវង្ស ៤ ប្រការ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អរិយវង្សសូត្រទី ៨ ដូចតទៅនេះ ៖*

[២៩] *សូត្រអរិយវង្សសូត្រទី ៨ តាំងឡើងប្រព្រឹត្តទៅតាមអជ្ឈាស្រ័យរបស់ព្រះអង្គ បានឮថា ព្រះមានព្រះភាគ ប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរដែលគេក្រាលថ្វាយក្នុងធម្មសភា នាព្រះជេតវនមហាវិហារ ទ្រង់ត្រាស់ហៅភិក្ខុបួនម៉ឺនរូប ដែលអង្គុយហែហមថា* ***ភិក្ខវេ*** *(ម្នាលភិក្ខុទាំងឡាយ) ដូច្នេះហើយ ទើបទ្រង់ផ្ដើមមហាអរិយវង្សសូត្រនេះថា* ***ចត្តារោភិក្ខវេ អរិយវំសា*** *(ម្នាលភិក្ខុទាំងឡាយ អរិយវង្ស ៤ ប្រការនេះ) ជាដើម ដោយអំណាចអជ្ឈាស្រ័យរបស់ព្រះអង្គខ្លះ របស់បុគ្គលដទៃខ្លះ ។ ក្នុងបទទាំងនោះ បទថា* ***អរិយវំសា*** *(អរិយវង្ស) គឺ វង្សរបស់ព្រះអរិយៈទាំងឡាយ ។ អរិយវង្សទី ៨ នេះ ឈ្មោះថា ជាបែបផែនដែលមានមកពីដើមរបស់ព្រះអរិយៈ ជាប្រពៃណីរបស់ព្រះអរិយៈ ដូចខត្តិយវង្ស ព្រាហ្មណវង្ស វេស្សវង្ស សុទ្ទវង្ស សមណវង្ស កុលវង្ស រាជវង្ស ដូច្នោះ ។ ក៏វង្សនេះលោកពោលថា ជាកំពូលនៃវង្សទាំងនេះ ដូចក្លិនដើមក្លាំពាក់ជាដើម ជា*

កំពូលនៃឈើមានក្លិនកើតពីឫសជាដើម ។

សួរថា ព្រះអរិយៈទាំងឡាយដែលមានអរិយវង្សទាំងនោះ គឺ លោកពួកណា ។ ឆ្លើយថា ព្រះពុទ្ធទាំងឡាយ ព្រះបច្ចេកពុទ្ធទាំងឡាយ និងសាវករបស់ព្រះតថាគតទាំងឡាយ លោកហៅថា **ព្រះអរិយៈ** វង្សរបស់ព្រះអរិយៈទាំងនោះ ទើបរួមហៅថា **អរិយវង្ស** ។ មុនអំពីកាលនេះទៅ ក្នុងទីបំផុតបួនអសង្ខេយ្យក្រៃលែងដោយសែនកប្ប ព្រះពុទ្ធស្តេចឧប្បត្តិឡើង ៤ ព្រះអង្គ គឺ **ព្រះតណ្ហង្ករ** ១ **ព្រះមេធង្ករ** ១ **ព្រះសរណង្ករ** ១ **ព្រះទីបង្ករ** ១ វង្សរបស់ព្រះអរិយៈទាំងនោះ រួមឈ្មោះថា **អរិយវង្ស** ។ ខាងក្រោយការបរិនិព្វានរបស់ព្រះពុទ្ធទាំងនោះ កន្លងទៅមួយអសង្ខេយ្យ ព្រះពុទ្ធព្រះនាមថា **កោណ្ឌញ្ញៈ** ស្តេចឧប្បត្តិឡើង ។ល។ ក្នុងកប្បនេះព្រះពុទ្ធស្តេចឧប្បត្តិឡើង ៤ ព្រះអង្គ គឺ **ព្រះកកុសន្ធៈ** ១ **ព្រះកោនាគមនៈ** ១**ព្រះកស្សបៈ** ១ **ព្រះមានព្រះភាគគោតមរបស់ពួកយើង** ១ វង្សរបស់ព្រះអរិយៈទាំងនោះ រួមឈ្មោះថា **អរិយវង្ស** ។ម្យ៉ាងទៀត វង្សរបស់ព្រះអរិយៈទាំងឡាយ គឺ ព្រះពុទ្ធគ្រប់ព្រះអង្គ បច្ចេកពុទ្ធ និងពុទ្ធសាវកទាំងអតីត អនាគត និងបច្ចុប្បន្ន រួមឈ្មោះថា **អរិយវង្ស** ។

ក៏វង្សនៃព្រះអរិយៈទាំងនេះ ឈ្មោះថា **អគ្គញ្ញា** (ដឹងមកថាជាកំពូល)

បានដល់ គប្បីដឹងថាប្រសើរបំផុត ។ ឈ្មោះថា **រត្តញ្ញា** (ដឹងមកយូរហើយ) បានដល់ គប្បីដឹងថា ប្រព្រឹត្តមកយូរហើយ ។ ឈ្មោះថា **វំសញ្ញា** (ដឹងមកថាជាអរិយវង្ស) បានដល់ គប្បីដឹងថា ជាវង្ស គឺ ខ្សែស្រឡាយ ។ បទថា **បោរាណា** (ជាបែបផែនមកពីបុរាណ) បានដល់ មិនមែនកើតឡើងតែឥឡូវនេះ ។ ឈ្មោះថា **អសំកិណ្ណា** (មិនត្រូវលះបង់) បានដល់ មិនមែនខ្ចាត់ខ្ចាយ មិនមែនត្រូវលះបង់ ។ បទថា **អសំកិណ្ណបុព្វា** (មិនធ្លាប់ត្រូវលះបង់) បានដល់ មិនធ្លាប់ខ្ចាត់ខ្ចាយ គឺ ព្រះពុទ្ធក្នុងអតីតទាំងឡាយ មិនធ្លាប់លះបង់ដោយយល់ថា ប្រយោជន៍អ្វីដោយអរិយវង្សទាំងនេះ ។ បទថា **ន សំកីយន្តិ** (មិនត្រូវលះបង់) បានដល់ សូម្បីឥឡូវនេះ លោកទាំងនោះក៏មិនលះបង់ ។ បទថា **ន សំកីយិស្សន្តិ** (នឹងមិនត្រូវលះបង់) បានដល់ សូម្បីព្រះពុទ្ធក្នុងអនាគត ក៏នឹងមិនលះបង់ ។ សមណព្រាហ្មណ៍ពួកណាដែលជាអ្នកដឹងក្នុងលោក អរិយវង្សទាំងនេះ ដែលសមណព្រាហ្មណ៍ទាំងនោះ មិនជំទាស់ហើយ គឺ សមណព្រាហ្មណ៍អ្នកដឹងមិនតិះដៀល មិនទិតៀនហើយ ។

បទថា **សន្តុដ្ឋោ ហោតិ** (ជាអ្នកសន្តោស) សេចក្តីថា ជាអ្នកសន្តោសដោយអំណាចនៃបច្ច័យសន្តោស ។ បទថា **ឥតរីតរេន** (តាមមានតាមបាន) សេចក្តីថា ជាអ្នកសន្តោសដោយបច្ច័យគ្រោតគ្រាត ល្អិត សៅហ្មង ប្រណីត

ថាវៈ និងចាស់ យ៉ាងណាមួយ ។ ដោយពិត ភិក្ខុរមែងជាអ្នកសន្តោស ដោយបច្ច័យតាមដែលបានហើយជាដើម តាមមានតាមបាន គឺ យ៉ាងណាមួយ ក៏ក្នុងចីវរសន្តោសមាន ៣ គឺ **យថាលាភសន្តោស** (ត្រេកអរតាមដែលបាន) **យថាពលសន្តោស** (ត្រេកអរតាមកម្លាំង) **យថាសារុប្បសន្តោស** (ត្រេកអរតាមសមគួរ) ។ សូម្បីក្នុងបិណ្ឌបាតជាដើម ក៏ន័យនេះដូចគ្នា ។ រឿងពិស្តារនៃសន្តោសទាំងនោះ គប្បីជ្រាបដោយន័យដែលព្រះមានព្រះភាគត្រាស់ទុកហើយក្នុងព្រះសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ កុសលធម៌ដែលនៅមិនទាន់កើតឡើង រមែងកើតឡើងដល់ភិក្ខុដែលសន្តោស ជាដើម ។ ដូច្នោះ ព្រះអង្គសំដៅដល់សន្តោសទាំង ៣ នេះ ទើបត្រាស់ថា ភិក្ខុជាអ្នកសន្តោសដោយចីវរតាមមានតាមបាន គឺ ជាអ្នកសន្តោសដោយចីវរ តាមដែលបានហើយជាដើម យ៉ាងណាមួយ ។

ក៏ក្នុងចីវរសន្តោសនេះ ភិក្ខុគប្បីស្គាល់ចីវរ គប្បីស្គាល់ខេត្តចីវរ គប្បីស្គាល់បង្សុកូលចីវរ គប្បីស្គាល់សន្តោសដោយចីវរ គប្បីស្គាល់ធុតង្គដែលជាប់ទាក់ទងនឹងចីវរ ។ ក្នុងប្រការទាំងនោះ ប្រការថា **គប្បីស្គាល់ចីវរ** បានដល់ គប្បីស្គាល់កប្បិយចីវរ ១២ ប្រភេទ ទាំងនេះគឺ ចីវរ ៦ ដែលធ្វើដោយសំបកឈើជាដើម និងចីវរដែលអនុលោម ៦ ដែលធ្វើដោយសំពត់

សាច់ល្អជាដើម និងគប្បីស្គាល់អកប្បិយចីវរជាដើមយ៉ាងនេះ គឺ ចីវរដែលធ្វើដោយស្បូវក្រង ចីវរធ្វើដោយធ្មៃ ចីវរធ្វើដោយបន្ទះឈើក្រង សំពត់កម្ពលធ្វើដោយសក់មនុស្ស សំពត់ស្លឹករឹត ស្បែកខ្លា ស្លាបសត្វ សំពត់ធ្វើដោយដើមឈើ សំពត់ធ្វើដោយវល្លិ៍ សំពត់ធ្វើដោយស្លឹកត្រែទឹក សំពត់ធ្វើដោយដើមចេក សំពត់ធ្វើដោយឫស្សី ។

ប្រការថា **គប្បីស្គាល់ខេត្តចីវរ** បានដល់ គប្បីស្គាល់ខេត្ត ៦ ដោយការកើតឡើងយ៉ាងនេះ គឺ កើតដោយសង្ឃខ្លះ គណៈខ្លះ ញាតិខ្លះ មិត្តខ្លះ ទ្រព្យរបស់ខ្លួនខ្លះ បង្សុកូលខ្លះ និងគប្បីស្គាល់ខេត្ត ៨ ដោយមាតិកា ៨ ។

ប្រការថា **គប្បីស្គាល់បង្សុកូលចីវរ** បានដល់ គប្បីជ្រាបសំពត់បង្សុកូល ២៣ យ៉ាងគឺ

១-សំពត់ដែលគេបោលក្នុងព្រៃជាទីបោលសាកសព

២-សំពត់ដែលគេបោលក្នុងផ្សារ

៣-សំពត់ដែលគេបោលតាមផ្លូវរថ

៤-សំពត់ដែលគេបោលក្នុងគំនរសម្រាម

៥-សំពត់ជូតមន្ទិលគភ៌របស់ស្ត្រីប្រសូតបុត្រ

៦-សំពត់ងូតទឹក

៧-សំពត់ដែលគេចោលតាមកំពង់ផ្លូតទឹក ឬកំពង់ផ្លូវ

៨- សំពត់ដែលគេដណ្តប់សាកសពទៅព្រៃចោលខ្មោច ហើយនាំត្រឡប់មកវិញ

៩-សំពត់ត្រូវភ្លើងឆេះហើយគេចោល

១០-សំពត់ដែលគោទំពារហើយគេចោល

១១-សំពត់កណ្តៀរកាត់ហើយគេចោល

១២-សំពត់កណ្តុរកាត់ហើយគេចោល

១៣-សំពត់ដាច់ជាយហើយគេចោល

១៤-សំពត់ដាច់ខ្សែហើយគេចោល

១៥-សំពត់ដែលគេធ្វើជាទង់

១៦-សំពត់ដែលគេបូជាទុកទ្រង់ជំបូក

១៧-សំពត់របស់ភិក្ខុផងគ្នា

១៨-សំពត់ដែលរលកសមុទ្របន្សាត់ឡើងច្រាំង

១៩-សំពត់ដែលគេទុកចោលក្នុងទីរាជភិសេក

២០-សំពត់ដែលធ្លាក់នៅក្នុងផ្លូវ

២១-សំពត់ដែលត្រូវខ្យល់បន្សាត់ទៅ

២២-សំពត់សម្រេចដោយឫទ្ធិ

២៣-សំពត់ដែលទេវតាថ្វាយ ។

ក៏ក្នុងរឿងសំពត់នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ។ បទថា **សំពត់ជូតមន្ទិលគភ៌របស់ស្ត្រីប្រសូតិបុត្រ** គឺ សំពត់ដែលគេខ្ចប់មន្ទិលគភ៌ទៅចោល ។ បទថា **សពត់ដែលគេរុំមនុស្សស្លាប់ទៅព្រៃខ្មោច ហើយនាំត្រឡប់មកវិញ** គឺ សំពត់ដែលគេរុំសាកសពនាំទៅព្រៃខ្មោច ហើយនាំត្រឡប់មកវិញ ។ បទថា **សំពត់ដែលគេធ្វើជាទង់** គឺ សំពត់ដែលគេឲ្យលើកជាទង់ឡើងហើយ នាំត្រឡប់មកពីទីនោះ ។ បទថា **សំពត់ដែលគេបូជាទុកត្រង់ជំបូក** គឺ សំពត់ដែលគេបូជាទុកត្រង់ជំបូក ។ បទថា **សំពត់ដែលរលកសមុទ្របន្សាត់មកលើច្រាំង** គឺ សំពត់ដែលរលកសមុទ្របន្សាត់ឡើងច្រាំង ។ បទថា **សំពត់ដែលធ្លាក់ក្នុងផ្លូវ** គឺ សំពត់ពួកអ្នកធ្វើដំណើរ ប្រើផ្ទាំងថ្មដំហើយដណ្ដប់ទៅព្រោះខ្លាចចោរ ។ បទថា **សំពត់ដែលសម្រេចដោយឫទ្ធិ** គឺ ចីវររបស់ឯហិភិក្ខុ ។ បទដ៏សេសជាក់ច្បាស់ហើយ ។

ប្រការថា **គប្បីស្គាល់សន្តោសដោយចីវរ** សេចក្ដីថា សន្តោសដោយចីវរ ក្នុងចីវរមាន ២០ គឺ

១-សន្តោសដោយការត្រិះរិះ

២-សន្តោសដោយការធ្វើដំណើរ

៣-សន្តោសដោយការស្វែងរក

៤-សន្តោសដោយការបាន

៥-សន្តោសដោយការទទួលល្មមប្រមាណ

៦-សន្តោសដោយការវៀរចាកសេចក្តីវង្វេង

៧-សន្តោសតាមបាន

៨-សន្តោសតាមកម្លាំង

៩-សន្តោសតាមសមគួរ

១០-សន្តោសដោយទឹក

១១-សន្តោសដោយការនាំ

១២-សន្តោសដោយការធ្វើ

១៣-សន្តោសដោយការប្រមាណ

១៤-សន្តោសដោយអំបោះ

១៥-សន្តោសដោយការដេរ

១៦-សន្តោសដោយការជ្រលក់

១៧-សន្តោសដោយការធ្វើកប្បៈ

១៨-សន្តោសដោយការប្រើប្រាស់

១៩-សន្តោសដោយការវៀរចាកការសន្សំ

២០-សន្តោសដោយការលះបង់

ក្នុងសន្តោសទាំង ២០ នោះ ភិក្ខុដែលត្រេកអរ (ក្នុងគហបតីចីវរ) នៅចាំវស្សាអស់ត្រៃមាសហើយ ត្រិះរិះត្រឹមតែមួយខែក៏គួរ ។ ព្រោះថា លោកបវារណាហើយ រមែងធ្វើចីវរក្នុងខែដែលកើតចីវរ ។ ភិក្ខុដែលសមាទានសំពត់បង្សុកូលជាវត្ត រមែងធ្វើបានកន្លះខែប៉ុណ្ណោះ ។ ការត្រិះរិះអស់កាលមួយខែ ឬកន្លះខែ ដោយប្រការដូច្នេះ ឈ្មោះថា **សន្តោសដោយការត្រិះរិះ** ។ ក៏ភិក្ខុដែលត្រេកអរដោយវិតក្កសន្តោស គប្បីដូចជាព្រះថេរៈអ្នកសមាទានសំពត់បង្សុកូលជាវត្ត អ្នកនៅបាចីនខណ្ឌរាជីវិហារ ។

បានឮថា ព្រះថេរៈមកដោយបំណងថា នឹងថ្វាយបង្គំព្រះចេតិយ ក្នុងចេតិយបព៌តវិហារ ថ្វាយបង្គំព្រះចេតិយហើយ គិតថា ចីវររបស់យើងចាស់ យើងនឹងបានក្នុងទីនៅរបស់ភិក្ខុច្រើនរូប លោកទៅកាន់មហាវិហារ ជួបព្រះសង្ឃត្ថេរៈហើយ ទើបសួរដល់ទីសម្រាក ហើយនៅក្នុងវិហារនោះ ក្នុងថ្ងៃស្អែកទើបកាន់យកចីវរមក ថ្វាយបង្គំព្រះថេរៈ ព្រះថេរៈពោលថា មានការអ្វីអ្នកមានអាយុ ។ លោកម្ចាស់ដ៏ចម្រើន ខ្ញុំនឹងទៅកាន់ទ្វារស្រុក ។ ព្រះថេរៈ

ពោលថា អ្នកមានអាយុ សូម្បីយើងក៏នឹងទៅ ។ លោកទទួលថា ល្អហើយ លោកម្ចាស់ ហើយទើបដើរទៅឈរត្រង់ស៊ុមទ្វារនៃមហាពោធិ គិតថា យើងនឹងបានចីវរដែលពេញចិត្ត ក្នុងទីនៅរបស់លោកអ្នកមានបុណ្យទាំងឡាយ ហើយគិតថា សេចក្តីត្រិះរិះរបស់យើងមិនបរិសុទ្ធ ទើបត្រឡប់ចេញពីទីនុ៎ះឯង ក្នុងថ្ងៃស្អែក ទៅកាន់ទីជិតទីទួល ឈ្មោះបេន្ទមពនៈ ក្នុងថ្ងៃស្អែកក៏ត្រឡប់ពីទ្វារទិសខាងជើងនៃមហាចេតិយ ដូច្នោះដូចគ្នា សូម្បីក្នុងថ្ងៃទី ៤ ក៏បានទៅកាន់សំណាក់ព្រះថេរៈ ។ ព្រះថេរៈគិតថា ការត្រិះរិះរបស់ភិក្ខុនេះនឹងមិនបរិសុទ្ធិ៍ ដូច្នេះហើយ កាន់យកចីវរ សួរបញ្ហា ចូលទៅកាន់ស្រុកជាមួយភិក្ខុនោះឯង ។ ក៏ក្នុងរាត្រីនោះ មនុស្សម្នាក់ ឈឺឧច្ចារៈ ហើយបន្ទោបង់ឧច្ចារៈដាក់សំពត់ ទើបចោលសំពត់នោះក្នុងគំនរសម្រាម ព្រះថេរៈអ្នកសមាទានសំពត់បង្សុកូលជាវត្ត ឃើញសំពត់នោះដែលពួករុយក្បាលខៀវចោមរោម ទើបផ្គងអញ្ជលី ។ ព្រះមហាថេរៈសួរថា អ្នកមានអាយុ ហេតុដូចម្តេចលោកទើបផ្គងអញ្ជលីដល់គំនរសម្រាម ព្រះថេរៈនោះឆ្លើយថា លោកដ៏ចម្រើន ខ្ញុំមិនបានផ្គងអញ្ជលីដល់គំនរសម្រាមទេ ខ្ញុំផ្គងដល់ព្រះទសពល ព្រះបិតារបស់ខ្ញុំ ព្រះទសពលទ្រង់កាន់យកសំពត់ដែលគេរុំសាកសពនាងបុណ្ណទាសីចោល ធ្វើជាសំពត់បង្សុកូល ទ្រង់រលាស់សត្វតូចៗ

ប្រមាណមួយតុម្ពៈ ហើយទ្រង់កាន់យកពីព្រៃចោលខ្មោច ទ្រង់ធ្វើកិច្ចដែលធ្វើបានលំបាក ។ ព្រះមហាថេរៈគិតថា សេចក្តីត្រិះរិះរបស់ព្រះថេរៈអ្នកកាន់សំពត់បង្សុកូលជាវត្តបរិសុទ្ធហើយ សូម្បីព្រះថេរៈអ្នកកាន់បង្សុកូលជាវត្ត ក៏ឈរក្នុងទីនោះឯង ចម្រើនវិបស្សនា សម្រេចផលទាំងបី ហើយកាន់យកសំពត់ផ្ទាំងនោះធ្វើជាចីវរដណ្តប់ទៅកាន់បាចិនខណ្ឌរាជីវិហារ បានសម្រេចព្រះអរហត្តដែលជាផលដ៏កំពូលហើយ ។

ក៏ភិក្ខុកាលនឹងទៅដើម្បីត្រូវការចីវរ មិនគិតថា យើងនឹងបានក្នុងទីណា ទៅដោយមានកម្មដ្ឋានជាធំប៉ុណ្ណោះ ឈ្មោះថា **សន្តោសដោយការធ្វើដំណើរ** ។ ក៏ភិក្ខុកាលនឹងស្វែងរកចីវរ មិនស្វែងរកជាមួយភិក្ខុធម្មតា នាំភិក្ខុដែលមានសេចក្តីខ្មាសគួរស្រឡាញ់ទៅស្វែងរក ឈ្មោះថា **សន្តោសដោយការស្វែងរក** ។ កាលភិក្ខុស្វែងរកយ៉ាងនេះ ឃើញចីវរដែលទាយកនាំមកតែទីឆ្ងាយ មិនត្រិះរិះយ៉ាងនេះថា ចីវរនោះទើបគួរពេញចិត្ត ចីវរនោះមិនគួរពេញចិត្ត ហើយត្រេកអរក្នុងចីវរដែលគ្រោតគ្រាត ឬល្អិតជាដើម តាមដែលខ្លួនបានហើយប៉ុណ្ណោះ ឈ្មោះថា **សន្តោសដោយការបាន** ។ កាលភិក្ខុសូម្បីកាន់យកចីវរដែលខ្លួនបានហើយយ៉ាងនេះ ត្រេកអរក្នុងចីវរដែលមានដល់ខ្លួនឯងថា សំពត់ប៉ុណ្ណោះនឹងជាចីវរ ២ ជាន់ សំពត់ប៉ុណ្ណោះនឹងជា

ចីវរមួយជាន់ ដូច្នេះប៉ុណ្ណោះ ឈ្មោះថា **សន្តោសដោយការទទួលយកតែល្មម** ។ មយ៉ាងទៀត កាលភិក្ខុស្វែងរកចីវរ មិនគិតថា យើងនឹងបានចីវរដែលគួរពេញចិត្តត្រង់ទ្វារផ្ទះរបស់បុគ្គលឯណោះ ហើយត្រាច់ទៅតាមលំដាប់ទ្វារ ឈ្មោះថា **សន្តោសដោយការវៀរចាកសេចក្ដីវង្វេង** ។

កាលភិក្ខុអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយចីវរដែលសៅហ្មង ឬប្រណីតណានីមួយ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរដែលខ្លួនបាន ហើយនោះឯង ឈ្មោះថា **សន្តោសតាមបាន** ។ ការស្គាល់កម្លាំងរបស់ខ្លួន ហើយញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរដែលអាចនឹងឲ្យប្រព្រឹត្តទៅបាន ឈ្មោះថា **សន្តោសតាមកម្លាំង** ។ កាលភិក្ខុថ្វាយចីវរដែលពេញចិត្តដល់ភិក្ខុដទៃហើយ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរណានីមួយរបស់ខ្លួន ឈ្មោះថា **សន្តោសតាមសមគួរ** ។

ការមិនជ្រើសរើសថា ទឹកក្នុងទីណាគួរពេញចិត្ត ក្នុងទីណាមិនគួរពេញចិត្ត ដូច្នេះ ហើយនាំចីវរដោយទឹកដែលសមគួរនាំបានណានីមួយ ឈ្មោះថា **សន្តោសដោយទឹក** ។ ភិក្ខុគួរវៀរទឹកដែលល្អក់ដោយដីលឿង ជ័រឈើ និងស្លឹកឈើស្អុយ ។ កាលភិក្ខុដែលនឹងនាំចីវរ មិនជំដោយឈើជាដើម ញីដោយដៃនាំមក ឈ្មោះថា **សន្តោសដោយការនាំ** ។ មួយទៀត

នឹងនាំចីវរដែលមិនស្អាត សូម្បីដោយទឹកដែលដាក់ឈើស្មោរឲ្យក្តៅ ក៏គួរ កាលភិក្ខុនាំមកយ៉ាងនេះ មិនញុាំងចិត្តឲ្យកម្រើកថា ចីវរនេះគ្រោតគ្រាត ចីវរនេះសាច់ល្អិត ដូច្នេះហើយ ធ្វើដោយវិធីដែលសមល្មមប៉ុណ្ណោះ ឈ្មោះថា **សន្តោសដោយការធ្វើ** ។ ការធ្វើចីវរល្មមបិទមណ្ឌលបីប៉ុណ្ណោះ ឈ្មោះថា **សន្តោសដោយការប្រមាណ** ។ មួយទៀត កាលមិនត្រាច់ទៅដោយគិតថា យើងនឹងស្វែងរកអំបោះដែលពេញចិត្តដើម្បីធ្វើចីវរ ហើយកាន់អំបោះប្រភេទណាមួយនោះឯង ដែលបុគ្គលនាំមកទុកត្រង់ថ្នល់ជាដើម ឬត្រង់ទេវស្ថាន ឬដែលគេនាំមកដាក់ទុកទៀបជើងហើយធ្វើ ឈ្មោះថា **សន្តោសដោយអំបោះ** ។

ក្នុងវេលាភ្ជាប់សំពត់កុសិ គប្បីដេរ ៧ ដង ក្នុងទីមានប្រមាណមួយធ្នាប់ ព្រោះថា កាលលោកធ្វើយ៉ាងនេះ ភិក្ខុណាមិនជាសម្លាញ់ សូម្បីភិក្ខុនោះ ក៏មិនវិនាសធម្មទំនៀម ។ តែក្នុងទីប្រមាណបីធ្នាប់ ក៏គួរដេរ ៧ ដង ។ កាលលោកធ្វើយ៉ាងនេះ សូម្បីភិក្ខុអ្នកធ្វើដំណើរក៏គប្បីជាសម្លាញ់ពិត ។ ភិក្ខុណាមិនជាសម្លាញ់ ភិក្ខុនោះក៏រមែងវិនាសធម្មទំនៀម នេះឈ្មោះថា **សន្តោសដោយការដេរ** ។ ក៏ភិក្ខុនោះនឹងជ្រលក់ចីវរ មិនគួរត្រាច់ស្វែងរកទឹកជ្រលក់ជ្រៃខ្មៅជាដើមមកជ្រលក់ លោកបាននាំទឹកជ្រលក់ មានទឹកជ្រលក់

ចំណិតឈើស្បែងជាដើមណាមួយ ក៏គប្បីជ្រលក់ដោយទឹកជ្រលក់នោះ ។ កាលមិនបានយ៉ាងនោះ គប្បីកាន់យកទឹកជ្រលក់សំបកធ្មៃដែលពួកអ្នកស្រុកទុកចោលក្នុងព្រៃ ឬកាកទឹកជ្រលក់ដែលពួកភិក្ខុដាំទុកចោល ហើយទើបជ្រលក់ នេះឈ្មោះថា **សន្តោសដោយការជ្រលក់** ។ កាលភិក្ខុកាន់យកពណ៌ខៀវ ពណ៌កក់ ពណ៌ខ្មៅ ពណ៌ជាំ ណាទីមួយធ្វើកប្បៈ (ពិន្ទុ) ដែលប្រាកដច្បាស់ដល់អ្នកដែលអង្គុយនៅលើខ្នងដំរី ឈ្មោះថា **សន្តោសដោយការធ្វើកប្បៈ** ។

ការប្រើប្រាស់ល្មមបិទបាំងអវយវៈ ដែលធ្វើសេចក្តីខ្មាសឲ្យកម្រើកប៉ុណ្ណោះ ឈ្មោះថា **សន្តោសដោយការប្រើប្រាស់** ។ ព្រះមហាសិវត្ថេរៈពោលថា ក៏ភិក្ខុបានសំពត់ហើយ តែមិនទាន់បានអំបោះ ឬម្ជុល ឬអ្នកធ្វើនឹងរក្សាទុកក៏គួរ តែកាលបានម្ជុលជាដើម នឹងរក្សាទុកមិនគួរ សូម្បីចីវរដែលធ្វើហើយ បើលោកបំណងនឹងឲ្យដល់សហធម្មិក មានអន្តេវាសិកជាដើម តែអន្តេវាសិកទាំងនោះនៅមិនទាន់ព្រមព្រៀងគ្នា នឹងរក្សាទុកដរាបព្រមព្រៀងគ្នាក៏គួរ កាលអន្តេវាសិកជាដើម ពេលមកដល់ហើយគួរឲ្យតែម្តង កាលមិនអាចនឹងឲ្យ គប្បីអធិដ្ឋានទុក កាលត្រៃចីវរដទៃមានហើយ នឹងអធិដ្ឋានឲ្យជាសំពត់ក្រាលដេកក៏គួរ ព្រោះថា ចីវរដែលមិនអធិដ្ឋាននោះ

ឯង រមែងជាសន្និធិដោយពិត ចីវរដែលអធិដ្ឋានហើយមិនជាសន្និធិ នេះឈ្មោះថា **សន្តោសដោយការវៀរចាកការសន្សំ** ។ មួយទៀត ភិក្ខុកាលនឹងលះបង់មិនគួរឲ្យព្រោះយល់ដល់មុខ គប្បីតាំងនៅក្នុងសារាណីយធម៌ ហើយឲ្យដូច្នេះ នេះឈ្មោះថា **សន្តោសដោយការលះបង់** ។

ប្រការថា **គប្បីស្គាល់ធុតង្គដែលទាក់ទងជាមួយចីវរ** បានដល់ បំសុកូលិង្គ: (អង្គនៃភិក្ខុដែលទ្រទ្រង់សំពត់បង្សុកូលជាវត្ត) និងតេចីវរិង្គ: (អង្គនៃភិក្ខុដែលទ្រទ្រង់ត្រៃចីវរជាវត្ត) ។ គប្បីជ្រាបរឿងពិស្តារនៃធុតង្គទាំងនោះក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ភិក្ខុកាលបំពេញមហាអរិយវង្ស ទាក់ទងជាមួយចីវរសន្តោស ឈ្មោះថា រមែងរក្សាធុតង្គទាំងពីរទាំងនេះទុកបាន កាលរក្សាធុតង្គទាំងនោះ រមែងជាអ្នកសន្តោសដោយមហាអរិយវង្ស គឺ ចីវរសន្តោសដោយប្រការដូច្នេះ ។

បទថា **វណ្ណវាទី** (ជាអ្នកសរសើរ) សេចក្តីថា ភិក្ខុមួយរូបជាអ្នកសន្តោស តែមិនពោលសរសើរសន្តោស ។ មួយរូបមិនសន្តោស តែពោលសរសើរសន្តោស ។ មួយរូប ទាំងមិនសន្តោស ទាំងមិនពោលសរសើរសន្តោស ។ មួយរូប រមែងជាអ្នកសន្តោសផង ពោលសរសើរសន្តោសផង កាលទ្រង់សម្តែងសន្តោសនោះ ទើបត្រាស់ថា **ឥតរីតរចីវរសន្តុដ្ឋិយា ច**

វណ្ណវាទី (ជាអ្នកសរសើរសេចក្តីសន្តោសដោយចីវរ តាមមានតាមបាន) ។

បទថា **អនេសនំ** (ការស្វែងរកមិនគួរ) សេចក្តីថា មិនធ្វើការស្វែងរកដែលមិនសមគួរច្រើនប្រការ មានទូតកម្ម ការទទួលបញ្ជូនដំណឹង ។ បទថា **អប្បដិរូបំ** បានដល់ មិនសមគួរ ។ បទថា **អលទ្ធា ច** បានដល់ មិនបានហើយ ។ ភិក្ខុរូបខ្លះគិតថា យើងនឹងបានចីវរយ៉ាងណាហ្ន៎ នៅរួមជាមួយពួកភិក្ខុដែលមានបុណ្យទាំងឡាយ ធ្វើការបោកបញ្ឆោត រមែងភ័យតក់ស្លុត យ៉ាងណា ភិក្ខុអ្នកសន្តោសមិនបានចីវរ រមែងមិនភ័យតក់ស្លុតយ៉ាងនោះ ។ បទថា **លទ្ធា ច** (បានចីវរហើយ) សេចក្តីថា បានដោយធម៌ បានដោយល្អ ។ បទថា **អគធិតោ** (មិនជាប់ជំពាក់) គឺ ប្រាសចាកគ្រឿងជាប់ដោតក្រង គឺ លោភៈ ។ បទថា **អមុច្ឆិតោ** (មិនប្រាសប្រាល) សេចក្តីថា មិនបានទូវសេចក្តីស្លប់ ព្រោះតណ្ហាមានប្រមាណក្រៃលែង ។ បទថា **អនជ្ឈាបន្នោ** (មិនជ្រុលជ្រប់) សេចក្តីថា ជាអ្នកដែលតណ្ហាមិនគ្របសង្កត់ មិនចងទុក ។ បទថា **អាទីនវទស្សាវី** (ឃើញចំណែកដែលជាទោស) សេចក្តីថា ឃើញទោសក្នុងអាបត្តិដែលទាក់ទងដោយអនេសនា និងងប់ជ្រប់ក្នុងការបរិភោគលាភ ។ បទថា **និស្សរណបញ្ញោ** (ឈ្លាសក្នុងឧបាយដែលដកខ្លួនចេញ) សេចក្តីថា ដឹងច្បាស់ដល់ឧបាយដែលត្រូវដកខ្លួនចេញ ដែលលោក

ពោលថា ត្រឹមតែដើម្បីបំបាត់សេចក្ដីត្រជាក់ប៉ុណ្ណោះ ។

បទថា **ឥតរិតរចីវរសន្តុដ្ឋិយា** (ព្រោះការសន្ដោសដោយចីវរតាមមានតាមបាន) សេចក្ដីថា ព្រោះសន្ដោសដោយចីវរណានីមួយ ។ បទថា **នេវត្ថានុក្កំសេតិ** (មិនតម្កើងខ្លួន) សេចក្ដីថា រមែងមិនលើកខ្លួនថា យើងទ្រទ្រង់សំពត់បង្សុកូលជាប្រក្រតី យើងសមាទាននូវវង្សរបស់ភិក្ខុដែលទ្រទ្រង់សំពត់បង្សុកូលជាប្រក្រតីក្នុងពេលឧបសម្បទ នរណានឹងស្មើដូចយើងដូច្នេះ ។ បទថា **នោ បរំ វម្ភេតិ** សេចក្ដីថា មិនគ្របសង្កត់បុគ្គលដទៃយ៉ាងនេះថា ចំណែកភិក្ខុដទៃៗ ទាំងនេះ មិនសមាទានបង្សុកូល ឬថាភិក្ខុទាំងនោះមិនមានសូម្បីត្រឹមតែទ្រទ្រង់សំពត់បង្សុកូល ។ បទថា **យោ ហិ តត្ថ ទក្ខោ** (ក៏ភិក្ខុណាជាអ្នកឈ្លាស) សេចក្ដីថា ភិក្ខុណាមានទក្ខៈ គឺឈ្លាសវៃក្នុងការៈពោលសរសើរជាដើម ក្នុងចីវរសន្ដោសនោះ ។ បទថា **អនលសោ** (មិនខ្ជិលច្រអូស) សេចក្ដីថា វៀរសេចក្ដីខ្ជិលច្រអូស ដោយការធ្វើជាប់តគ្នា ។ បទថា **សម្បជានោ បតិស្សតោ** (មានសម្បជញ្ញៈមានសតិ) សេចក្ដីថា ប្រកបដោយបញ្ញា គឺ សម្បជញ្ញៈ និងសតិ ។ បទថា **អរិយវំសេ ឋិតោ** (អ្នកតាំងនៅក្នុងអរិយវង្ស) បានដល់ តាំងមាំហើយក្នុងអរិយវង្ស ។

បទថា **ឥតរីតរេន បិណ្ឌបាតេន** (ដោយបិណ្ឌបាតតាមមានតាមបាន) គឺ ដោយបិណ្ឌបាតណានីមួយ ៗ ក៏ក្នុងបិណ្ឌបាតសន្តោសនេះ ភិក្ខុគប្បីស្គាល់បិណ្ឌបាត គប្បីស្គាល់ខេត្តរបស់បិណ្ឌបាត គប្បីស្គាល់សន្តោសក្នុងបិណ្ឌបាត គប្បីស្គាល់ធុតង្គដែលជាប់ដោយបិណ្ឌបាត ។ ក្នុងប្រការទាំងនោះ ប្រការថា បិណ្ឌបាត បានដល់ បិណ្ឌបាត ១៦ គឺ បាយ នំស្រស់ បាយសត្តុ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ បបរ របស់គួរទំពារ របស់គួរភ្លក់ របស់គួរលិទ្ធ ។

បទថា **ខេត្តបិណ្ឌបាត** បានដល់ ខេត្តរបស់បិណ្ឌបាត ១៥ គឺ ៖

១- សង្ឃភត្ត
២- ឧទ្ទេសភត្ត
៣- និមន្តភត្ត
៤- ស្លាកភត្ត
៥- បក្ខិកភត្ត
៦- ឧបោសថិកភត្ត
៧- បាដិបទិកភត្ត
៨- អាគន្តុកភត្ត
៩- គមិកភត្ត
១០- គិលានភត្ត
១១- គិលានុបដ្ឋាកភត្ត
១២- ធុរភត្ត
១៣- កុដិភត្ត
១៤- វារកភត្ត
១៥- វិហារភត្ត

បទថា សន្តោសដោយបិណ្ឌបាត បានដល់ សន្តោសក្នុងបិណ្ឌបាត ១៥ គឺ ៖

១- វិតក្កសន្តោស ២- គមនសន្តោស

៣- បរិយេសនសន្តោស ៤- បដិលាភសន្តោស

៥- បដិគ្គហណសន្តោស ៦- មត្តបដិគ្គហណសន្តោស

៧- លោលុប្បវិវជ្ជនសន្តោស ៨- យថាលាភសន្តោស

៩- យថាពលសន្តោស ១០- យថាសារុប្បសន្តោស

១១- ឧបការសន្តោស ១២- បរិមាណសន្តោស

១៣- បរិភោគសន្តោស ១៤- សន្និធិបរិវជ្ជនសន្តោស

១៥- វិសជ្ជនសន្តោស ។

ក្នុងសន្តោសទាំងនោះ ភិក្ខុអ្នកញ៉ាំងសេចក្តីត្រេកអរ (ក្នុងសេនាសនៈ) លុបលាងមុខស្រេចហើយ ទើបត្រិះរិះ ។ ចំណែកបិណ្ឌបាតិកភិក្ខុទៅព្រមជាមួយគណៈក្នុងវេលាទំនុកបម្រុងព្រះថេរៈពេលល្ងាច គិតយ៉ាងនេះថា ស្អែកនេះ នឹងត្រាច់បិណ្ឌបាតក្នុងទីណា ក្នុងស្រុកឯណោះ លោកម្ចាស់ ដូច្នេះហើយមិនគប្បីត្រិះរិះតពីនោះ ។ កាលភិក្ខុដែលត្រាច់ទៅតែម្នាក់ឯង គប្បីឈរត្រិះរិះក្នុងរោងវិតក្កៈ ។ កាលលោកត្រិះរិះតពីនោះ រមែងឈ្មោះថា

ឃ្លាតឆ្ងាយចាកអរិយវង្ស នេះឈ្មោះថា **វិតក្កសន្តោស** ។

កាលចូលទៅដើម្បីបិណ្ឌបាត ក៏មិនគិតថា យើងនឹងបានក្នុងទីណា គប្បីទៅដោយបំណងក្នុងកម្មដ្ឋានជាធំ នេះឈ្មោះថា **គមនសន្តោស** ។ កាលស្វែងរកក៏មិននាំភិក្ខុជម្មតាទៅ គប្បីនាំភិក្ខុដែលខ្មាសបាប គួរស្រឡាញ់ប៉ុណ្ណោះទៅ នេះឈ្មោះថា **បរិយេសសន្តោស** ។ លោកឃើញបិណ្ឌបាតដែលគេនាំមកពីចម្ងាយ មិនគប្បីឲ្យការគិតកើតឡើងថា នោះរបស់គួរពេញចិត្ត នោះមិនពេញចិត្ត នេះឈ្មោះថា **បដិលាភសន្តោស** ។ លោកមិនគិតថា យើងនឹងទទួលវត្ថុនេះដែលពេញចិត្ត នឹងមិនទទួលវត្ថុនេះដែលមិនពេញចិត្ត ដូច្នេះ ហើយគប្បីទទួលវត្ថុណានីមួយដែលល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅប៉ុណ្ណោះ នេះឈ្មោះថា **បដិគ្គហណសន្តោស** ។

ក៏ក្នុងបដិគ្គហណសន្តោសប្បច្ច័យនេះ ទេយ្យធម៌មានច្រើន ទាយកបំណងនឹងថ្វាយតិច លោកគប្បីទទួលតែតិច ។ ទេយ្យធម៌មានច្រើន ទាំងទាយកបំណងនឹងថ្វាយច្រើន លោកគប្បីទទួលតែល្មមប្រមាណប៉ុណ្ណោះ ។ ទេយ្យធម៌មានមិនច្រើន ទាំងទាយកបំណងនឹងថ្វាយតិច លោកគប្បីទទួលតែតិច ។ ទេយ្យធម៌មានមិនច្រើន ចំណែកទាយកបំណងនឹងថ្វាយច្រើន លោកគប្បីទទួលដោយល្មមប្រមាណ ។ ព្រោះថា ភិក្ខុដែលមិនស្គាល់ប្រមាណ

ក្នុងការទទួល រមែងទម្លាយសេចក្តីជ្រះថ្លារបស់ពួកមនុស្ស ញ៉ាំងសទ្ធាទេយ្យឲ្យធ្លាក់ មិនធ្វើតាមពាក្យទូន្មាន រមែងមិនអាចនឹងយកចិត្តសូម្បីរបស់មាតាបង្កើតបាន ។ ភិក្ខុស្គាល់ប្រមាណហើយ គប្បីទទួលដោយអាការយ៉ាងនេះឯង នេះឈ្មោះថា **មត្តបដិគ្គហណសន្តោស** ។ កាលភិក្ខុមិនទៅកាន់ត្រកូលស្តុកស្តម ដើរទៅតាមលំដាប់ទ្វារ នេះឈ្មោះថា **លោលុប្បវិវជ្ជនសន្តោស** ។ **យថាលាភសន្តោស** ជាដើម មានន័យដែលពោលទុកក្នុងចីវរនោះឯង ។

ការបរិភោគបិណ្ឌបាតហើយ ដឹងឧបការៈយ៉ាងនេះថា យើងនឹងរក្សាសមណធម៌ ដូច្នេះ ទើបបរិភោគ ឈ្មោះថា **ឧបការសន្តោស** ។ ភិក្ខុមិនគប្បីទទួលបាត្រដែលគេដាក់ពេញហើយមកថ្វាយ កាលអនុបសម្បន្នមាន គប្បីឲ្យអនុបសម្បន្ននោះទទួល បើអនុបសម្បន្នមិនមាន លោកឲ្យគេយកចេញខ្លះ ទទួលតែល្មមទទួលបាន នេះឈ្មោះថា **បរិមាណសន្តោស** ។ ការបរិភោគដោយគិតយ៉ាងនេះថា ជាការបន្ទោបង់សេចក្តីស្រេកឃ្លាន នេះជាឧបាយកាត់បន្ថយក្នុងការស្រេកឃ្លាននេះ នេះឈ្មោះថា **បរិភោគសន្តោស** ។ ភិក្ខុមិនគប្បីរក្សាទុកបរិភោគ នេះឈ្មោះថា **សន្និធិបរិវជ្ជនសន្តោស** ។ ភិក្ខុមិនឃើញដល់មុខ តាំងនៅក្នុងសាភាណីយធម៌ គប្បីបរិច្ចាគ នេះឈ្មោះថា **វិសជ្ជនសន្តោស** ។

ចំណែកធុតង្គ ៥ ដែលទាក់ទងជាមួយបិណ្ឌបាត គឺ **បិណ្ឌបាតិកង្គៈ សបទានចារិកង្គៈ ឯកាសនិង្គៈ បត្តបិណ្ឌិកង្គៈ ខលុបច្ឆាភត្តិកង្គៈ** ។ ធុតង្គទាំងនោះ មានរឿងពិស្តារដែលពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ភិក្ខុដែលបំពេញមហាអរិយវង្សទាក់ទងជាមួយបិណ្ឌបាតសន្តោស រមែងរក្សាធុតង្គទាំង ៥ នេះ ។ កាលរក្សាធុតង្គទាំង ៥ នេះ ឈ្មោះថា ជាអ្នកសន្តោសដោយអរិយវង្សទាក់ទងជាមួយបិណ្ឌបាតសន្តោស ។ បទជាដើមថា **ជាអ្នកសរសើរ** គប្បីជ្រាបដោយន័យដែលពោលហើយ ។

ក្នុងបទថា **សេនាសនេន** (ដោយសេនាសនៈ) នេះ គប្បីស្គាល់សេ-នាសនៈ គប្បីស្គាល់ខេត្តសេនាសនៈ គប្បីស្គាល់សន្តោសដោយសេនាសនៈ គប្បីស្គាល់ធុតង្គដែលទាក់ទងជាមួយសេនាសនៈ ។ ក្នុងបទទាំងនោះ បទថា **សេនាសនៈ** បានដល់ សេនាសនៈ ១៥ ទាំងនេះ គឺ ៖ គ្រែ តាំង ពូក ខ្នើយ វិហារ ផ្ទះមួយខ្នង ប្រាសាទ ប្រាសាទត្រងោល ល្អាង ទីស្ងាត់ ប៉ម ផ្ទះទូលាយ គុម្ពឫស្សី គល់ឈើ ឬទីដែលពួកភិក្ខុគេចចេញទៅ ។

បទថា **ខេត្តសេនាសនៈ** បានដល់ ខេត្ត ៦ គឺ ដោយសង្ឃខ្លះ គណៈខ្លះ ញាតិខ្លះ មិត្តខ្លះ ទ្រព្យរបស់ខ្លួនខ្លះ សំពត់បង្សុកូលខ្លះ ។

បទថា **សន្តោសដោយសេនាសនៈ** បានដល់ សន្តោសក្នុងសេនា-

សនៈ ១៥ មានវិតក្កសន្តោសជាដើម ។ សន្តោសទាំងនោះ គប្បីជ្រាប ដោយន័យដែលពោលហើយក្នុងបិណ្ឌបាត ។ ចំណែកធុតង្គ ៥ ដែលទាក់ទងដោយសេនាសនៈ គឺ **អារញ្ញិកង្គៈ រុក្ខមូលិកង្គៈ អព្ភោកាសិង្គៈ សោសានិង្គៈ យថាសន្ថតិកង្គៈ** ។ រឿងពិស្តាររបស់ធុតង្គទាំងនោះ ពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។ កិច្ចដែលបំពេញមហាអរិយវង្សជាប់ដោយសេនាសនសន្តោស រមែងរក្សាធុតង្គទាំង ៥ នេះទុកបាន កាលរក្សាធុតង្គទាំងនេះ រមែងឈ្មោះថា **ជាអ្នកសន្តោសដោយមហាអរិយវង្សជាប់ដោយសេនាសនៈសន្តោស** ។ ចំណែកគិលានបច្ច័យ ក៏នៅក្នុងបិណ្ឌបាតនុ៎ះឯង ។ កិច្ចគប្បីត្រេកអរក្នុងគិលានបច្ច័យនោះដោយ **យថាលាភសន្តោស យថាពលសន្តោស យថាសារុប្បសន្តោស** ប៉ុណ្ណោះ ។ នេសជ្ជិកង្គៈ រមែងចាត់ចូលក្នុងអរិយវង្សប្រការត្រេកអរក្នុងភាវនា ដោយប្រការដូច្នេះ ។ សមដូចពាក្យដែលលោកពោលថា ៖

> ធុតង្គ ៥ យ៉ាង លោកពោលទុកក្នុងសេនាសនៈ ៥ យ៉ាង
> អាស្រ័យអាហារ ១ យ៉ាងប្រកបដោយសេចក្តីព្យាយាម និង
> ២ យ៉ាងអាស្រ័យចីវរ ដូច្នេះ ។

ព្រះមានព្រះភាគត្រាស់អរិយវង្ស គឺ ចីវរសន្តោសជាប្រការដំបូង ដូច

ទ្រង់ក្រាលផែនដី ដូចទ្រង់ធ្វើផ្ទៃសមុទ្រឲ្យពេញ និងដូចទ្រង់បើកអាកាសឲ្យធំទូលាយ ទ្រង់ត្រាស់បិណ្ឌបាតសន្តោសជាប្រការទីពីរ ដូចទ្រង់ឲ្យព្រះច័ន្ទឧទ័យឡើង និងដូចទ្រង់ធ្វើព្រះអាទិត្យរះឡើង ត្រាស់អរិយវង្ស គឺ សេនាសនៈសន្តោសជាប្រការទីបី ដូចទ្រង់លើកភ្នំសិនេរុឡើង ឥឡូវនេះ ដើម្បីត្រាស់អរិយវង្ស គឺ សេចក្តីត្រេកអរក្នុងភាវនាជាប្រការទីបួន ដែលប្រដាប់ដោយន័យមួយពាន់ ទ្រង់ផ្តើមទេសនាថា **បុន ច បរំ ភិក្ខវេ ភិក្ខុ ភាវនារាមោ ហោតិ** (ប្រការមួយទៀត ភិក្ខុជាអ្នកមានភាវនាជាទីរីករាយ) ជាដើម ។

ក្នុងបទនោះ សេចក្តីរីករាយ ឈ្មោះថា **អារាមៈ** អធិប្បាយថា សេចក្តីរីករាយក្រៃលែង ។ ឈ្មោះថា **ភាវនារាមោ** (ជាអ្នកមានភាវនាជាទីរីករាយ) ព្រោះភិក្ខុនោះ រីករាយក្នុងភាវនា ។ ឈ្មោះថា **ភាវនារតោ** (រីករាយហើយក្នុងភាវនា) ព្រោះត្រេកអរហើយក្នុងភាវនា ។ ឈ្មោះថា **បហានារាមោ** (ជាអ្នកមានបហានៈជាទីរីករាយ) ព្រោះភិក្ខុរីករាយក្នុងបហានៈ (ការលះ) ៥ យ៉ាង ម្យ៉ាងទៀត ឈ្មោះថា **ជាអ្នកមានបហានៈជាទីរីករាយ** ព្រោះកាលលះបាន រមែងរីករាយ ។ ក្នុងភាវនា និងបហានៈនេះ គប្បីជ្រាបសេចក្តីយ៉ាងនេះ ។ ពិតណាស់ ភិក្ខុនេះចម្រើនសតិប្បដ្ឋាន ៤ ហើយរមែងរីករាយ អធិប្បាយថា រមែងបានសេចក្តីរីករាយ ។ ចម្រើនសម្មប្បធាន

៤ ហើយក៏ដូចគ្នា កាលចម្រើនឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ អនុបស្សនា ៧ មហាវិបស្សនា ១៨ ពោធិបក្ខិយធម៌ ៣៧ ចម្រើនការបែកអារម្មណ៍ ៣៨ ហើយ រមែងរីករាយ រមែងបានសេចក្ដីត្រេកអរ ។ មួយយ៉ាងទៀត ភិក្ខុកាលលះកិលេស មានកាមច្ឆន្ទៈជាដើមហើយ ក៏រមែងរីករាយ បានទទួលសេចក្ដីរីករាយ ។

ចំណែកក្នុងអរិយវង្សទាំង ៤ នេះ វិន័យបិដកទាំងអស់ ទ្រង់ត្រាស់ដោយធុតង្គ ១៣ និងសេចក្ដីសន្ដោសដោយបច្ច័យ ៤ ដោយអរិយវង្សបីប្រការដំបូង ។ ពីរបិដកដ៏សេស ត្រាស់ដោយអរិយវង្ស ប្រការមានភាវនាជាទីរីករាយ ។ ក៏ភិក្ខុ កាលពោលអរិយវង្ស ប្រការមានភាវនាជាទីរីករាយនេះ គប្បីពោលអំពីនេក្ខម្មបាលីក្នុងបដិសម្ភិទាមគ្គ គប្បីពោលដោយបរិយាយនៃទសុត្តរសូត្រក្នុងទីឃនិកាយ គប្បីពោលអំពីបរិយាយនៃសតិប្បដ្ឋានសូត្រក្នុងមជ្ឈិមនិកាយ គប្បីពោលដោយបរិយាយនៃនិទ្ទេសក្នុងអភិធម្ម ។

បណ្ដាបទទាំងនោះ បទថា **ដោយនេក្ខម្មបាលី** បានដល់ គប្បីពោលតាមនេក្ខម្មបាលីក្នុងបដិសម្ភិទាមគ្គយ៉ាងនេះថា ភិក្ខុកាលចម្រើននេក្ខម្មៈ ក៏រីករាយ កាលលះកាមច្ឆន្ទៈក៏រីករាយ កាលចម្រើនអព្យាបាទក៏រីករាយ កាលលះព្យាបាទក៏រីករាយ កាលចម្រើនអាលោកសញ្ញាក៏រីករាយ លះថីនមិទ្ធៈ

ក៏រីករាយ កាលចម្រើនអវិក្ខេបៈក៏រីករាយ កាលលះឧទ្ធច្ចៈក៏រីករាយ កាលចម្រើនធម្មវវដ្ឋានក៏រីករាយ កាលលះវិចិកិច្ឆាក៏រីករាយ កាលចម្រើនញាណក៏រីករាយ កាលលះអវិជ្ជាក៏រីករាយ កាលចម្រើនបាមោជ្ជៈក៏រីករាយ កាលលះអរតិក៏រីករាយ កាលចម្រើនបឋមជ្ឈានក៏រីករាយ កាលលះនីវរណៈ ៥ ក៏រីករាយ កាលចម្រើនទុតិយជ្ឈានក៏រីករាយ កាលលះវិតក្កវិចារៈក៏រីករាយ កាលចម្រើនតតិយជ្ឈានក៏រីករាយ កាលលះបីតិក៏រីករាយ កាលចម្រើនចតុត្ថជ្ឈានក៏រីករាយ កាលលះសុខទុក្ខក៏រីករាយ កាលចម្រើនអាកាសានញ្ចាយតនសមាបត្តិក៏រីករាយ កាលលះរូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា ក៏រីករាយ កាលចម្រើនវិញ្ញាណញ្ចាយតនសមាបត្តិ ។បេ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិក៏រីករាយ កាលលះអាកិញ្ចញ្ញាយតនសញ្ញា ក៏រីករាយ ។

កាលចម្រើនអនិច្ចានុបស្សនាក៏រីករាយ កាលលះនិច្ចសញ្ញាក៏រីករាយ កាលចម្រើនទុក្ខានុបស្សនាក៏រីករាយ កាលលះសុខសញ្ញាក៏រីករាយ កាលចម្រើនអនត្តានុបស្សនាក៏រីករាយ កាលលះអត្តសញ្ញាក៏រមែងរីករាយ កាលចម្រើននិព្វិទានុបស្សនាក៏រីករាយ កាលលះនន្ទិក៏រីករាយ កាលចម្រើនវិរាគានុបស្សនាក៏រីករាយ កាលលះរាគៈក៏រីករាយ កាលចម្រើននិរោធានុប-

ស្សនាក៏រីកកាយ កាលលះសមុទ័យក៏រីកកាយ កាលចម្រើនបដិនិស្សគ្គា-នុបស្សនាក៏រីកកាយ កាលលះអាទានៈក៏រីកកាយ កាលចម្រើនខយានុបស្សនាក៏រីកកាយ កាលលះឃនសញ្ញាក៏រីកកាយ កាលចម្រើនវយានុបស្សនាក៏រីកកាយ កាលលះអាយូហនៈក៏រីកកាយ កាលចម្រើនវិបរិណាមានុបស្សនាក៏រីកកាយ កាលលះធុវសញ្ញាក៏រីកកាយ កាលចម្រើនអនិមិត្តានុបស្សនាក៏រីកកាយ កាលលះនិមិត្តក៏រីកកាយ កាលចម្រើនអប្បណិហិតានុបស្សនាក៏រីកកាយ កាលលះបណិធិក៏រីកកាយ កាលចម្រើនសុញ្ញតានុបស្សនាក៏រីកកាយ កាលលះអភិវេសៈក៏រីកកាយ កាលចម្រើនអធិប្បញ្ញាធម្មវិបស្សនាក៏រីកកាយ កាលលះសារាទានាភិនិវេសៈក៏រីកកាយ កាលចម្រើនយថាភូតញ្ញាណទស្សនៈក៏រីកកាយ កាលលះសម្មោហាភិនិវេសៈក៏រីកកាយ កាលចម្រើនអាទីនវានុ-បស្សនាក៏រីកកាយ កាលលះអាលយាភិនិវេសៈក៏រីកកាយ កាលចម្រើនបដិ-សង្ខានុបស្សនាក៏រីកកាយ កាលលះអប្បដិសង្ខៈក៏រីកកាយ កាលចម្រើនវិវ-ដ្ដានុបស្សនាក៏រីកកាយ កាលលះសំយោគាភិនិវេសៈក៏រីកកាយ កាលចម្រើនសោតាបត្តិមគ្គក៏រីកកាយ កាលលះកិលេសដែលតាំងនៅរួមជាមួយទិដ្ឋិក៏រីកកាយ កាលចម្រើនសកទាគាមិមគ្គក៏រីកកាយ កាលលះកិលេសយ៉ាងគ្រោតគ្រាតក៏រីកកាយ កាលចម្រើនអនាគាមិមគ្គក៏រីកកាយ កាលលះកិលេសដ៏ល្អិត

ក៏រីកកាយ កាលចម្រើនអរហត្តមគ្គក៏រីកកាយ កាលលះសព្វកិលេសក៏រីកកាយ ។

បទថា ដោយបរិយាយនៃទសុត្តរសូត្រក្នុងទីឃនិកាយ បានដល់ គប្បីពោលដោយបរិយាយនៃទសុត្តរសូត្រក្នុងទីឃនិកាយយ៉ាងនេះថា កាលចម្រើនធម៌មួយក៏រីកកាយ កាលលះធម៌មួយក៏រីកកាយ ។ល។ កាលចម្រើនធម៌ ១០ ក៏រីកកាយ កាលលះធម៌ ១០ ក៏រីកកាយ , កាលចម្រើនធម៌មួយក៏រីកកាយ ដូចម្តេច គឺ កាយគតាសតិដែលប្រកបដោយសេចក្តីរីករាយ ឈ្មោះថា ចម្រើនធម៌មួយក៏រីកកាយ , កាលលះធម៌មួយ ក៏រីកកាយដូចម្តេច គឺ អស្មិមានះ ឈ្មោះថា លះធម៌មួយនេះ ក៏រីកកាយ , កាលចម្រើនធម៌ ២ ក៏រីកកាយដូចម្តេច ។ល។ កាលចម្រើនធម៌ ១០ ក៏រីកកាយដូចម្តេច គឺ កសិណាយតនៈ ១០ ឈ្មោះថា ចម្រើនធម៌ ១០ ទាំងនេះក៏រីកកាយ ។ កាលលះធម៌ ១០ ក៏រីកកាយដូចម្តេច គឺ មិច្ឆត្តៈ ១០ ឈ្មោះថា កាលលះធម៌ ១០ ទាំងនេះក៏រីកកាយ ភិក្ខុជាអ្នកមានភាវនាជាទីរីកកាយ យ៉ាងនេះឯង ។

បទថា ដោយបរិយាយនៃសតិប្បដ្ឋានសូត្រក្នុងមជ្ឈិមនិកាយ បានដល់ គប្បីពោលដោយបរិយាយនៃសតិប្បដ្ឋានសូត្រក្នុងមជ្ឈិមនិកាយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវឯក ។ល។ ចូលទៅតាំងនៅចំពោះ

មុខដល់អ្នក ត្រឹមតែជាញាណ ត្រឹមតែជាអាស្រ័យការរឭក ។ អ្នករមែង មានសន្ដានដែលតណ្ហា និងទិដ្ឋិមិនអាស្រ័យនៅ និងមិនប្រកាន់អ្វីៗ ក្នុងលោក ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានការនោជាទីរីកពាយ រីកពាយហើយក្នុងការនោយ៉ាងនេះឯង ។ ជាអ្នកមានបហានៈជាទីរីកពាយ រីកពាយហើយក្នុងបហានៈ ។ ប្រការមួយទៀត ភិក្ខុកាលដើរ ក៏ដឹងច្បាស់ថា យើងកំពុងដើរ ។ល។ ប្រការមួយទៀត ដូចជាភិក្ខុគប្បីឃើញសរីរៈដែលគេចោលក្នុងព្រៃខ្មោច ។ល។ ជារបស់ផុយរលួយ ជាធូលី លោកក៏បង្អោនចូលមកកាន់កាយនេះឯងថា សូម្បីរាងកាយនេះ ក៏មានសភាពបែបនេះជាធម្មតា មានសភាពយ៉ាងនេះ មិនកន្លងសភាពយ៉ាងនេះបានឡើយ យ៉ាងនេះ ភិក្ខុរមែងពិចារណាឃើញកាយក្នុងកាយជាខាងក្នុងខ្លះ ។ល។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានការនោជាទីរីកពាយយ៉ាងនេះឯង ។

បទថា **ដោយបរិយាយនៃនិទ្ទេសក្នុងអភិធម្ម** បណ្ឌិតគប្បីពោលដោយបរិយាយនៃនិទ្ទេសយ៉ាងនេះថា កាលអ្នកឃើញសង្ខតធម៌សូម្បីទាំងពួង ថាជារបស់មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាសន្និលេស (សេចក្ដីសៅហ្មង) រមែងរីកពាយ ភិក្ខុជាអ្នកមានការនោជាទីរីកពាយយ៉ាងនេះឯង ។

បទថា **នេវត្តានុក្កំសេតិ** (មិនតម្កើងខ្លួន) សេចក្ដីថា ភិក្ខុរមែងមិន

ធ្វើការលើកតម្កើងខ្លួនយ៉ាងនេះថា កាលយើងធ្វើកម្មក្នុងវិបស្សនាថា មិនទៀង ជាទុក្ខ ជាអនត្តា រហូតមកអស់ ៦០ ឆ្នាំ ៧០ ឆ្នាំ សូម្បីបច្ចុប្បន្ននេះ នរណាហ្ន៎ នឹងជាអ្នកស្មើដូចយើង ។ បទថា **នោ បរំ វម្ភេតិ** (មិនគ្រប សង្កត់បុគ្គលដទៃ) សេចក្តីថា រមែងមិនធ្វើការគ្របសង្កត់បុគ្គលដទៃយ៉ាងនេះថា សូម្បីត្រឹមតែវិបស្សនាថាមិនទៀង ជាទុក្ខ ដូច្នេះ ក៏មិនមាន ហេតុអ្វីក៏ពួកលោកលះបង់កម្មដ្ឋានហើយត្រាច់ទៅ បទដ៏សេសមានន័យដូចពោលហើយនោះឯង ។

បទថា **ឥមេ ខោ ភិក្ខវេ ចត្តារោ អរិយវំសា** (ម្នាលភិក្ខុទាំងឡាយ អរិយវង្ស ៤ ប្រការទាំងនេះឯង) សេចក្តីថា ព្រះមានព្រះភាគទ្រង់រំលឹកព្រះសូត្រថា ម្នាលភិក្ខុទាំងឡាយ អរិយវង្សទាំង ៤ នេះ ជាវង្សរបស់ព្រះអរិយៈ ជាខ្សែរបស់ព្រះអរិយៈ ជាផ្លូវរបស់ព្រះអរិយៈ ជាផ្លូវទៅរបស់ព្រះអរិយៈ ឥឡូវនេះ កាលទ្រង់សម្តែងឥស្សរៈដោយអំណាចនៃភិក្ខុដែលបំពេញមហាអរិយវង្ស ទើបត្រាស់ថា **ឥមេហិ ច បន ភិក្ខវេ** (ក៏ភិក្ខុប្រកបដោយអរិយវង្សទាំង ៤ ប្រការនេះ) ជាដើម ។ ក្នុងបទទាំងនោះ បទថា **សោ អរតឹ សហតិ** (អ្នករមែងញាំញីសេចក្តីអផ្សុកបាន) សេចក្តីថា ភិក្ខុនោះប៉ុណ្ណោះ រមែងញាំញីគ្របសង្កត់សេចក្តីអផ្សុក សេចក្តីអផ្សុកដ៏ក្រៃលែង

សេចក្តីធុញទ្រាន់បាន ។ បទថា **ន តំ អរតិ សហតិ** (សេចក្តីអផ្សុកមិនញាំញីភិក្ខុនោះ) សេចក្តីថា ឈ្មោះថា សេចក្តីអផ្សុកក្នុងការចម្រើនអធិកុសលក្នុងសេនាសនៈដែលស្ងាត់ណា សេចក្តីអផ្សុកនោះ រមែងមិនអាចញាំញីគ្របសង្កត់ភិក្ខុនោះបាន ។ បទថា **អរតិរតិសហោ** (ជាអ្នកគ្របសង្កត់ទាំងសេចក្តីអផ្សុក ទាំងសេចក្តីត្រេកអរ) សេចក្តីថា ភិក្ខុដែលមានបញ្ញារមែងញាំញី គឺ អាចគ្របសង្កត់សេចក្តីអផ្សុក និងសេចក្តីត្រេកអរក្នុងកាមគុណ ៥ ។

ឥឡូវនេះ កាលទ្រង់កាន់យកកំពូលធម៌ដោយគាថាទាំងឡាយ ទើបត្រាស់បទថា **នារតី** (សេចក្តីអផ្សុកមិនអាច...) ជាដើម ។ ក្នុងបទទាំងនោះ បទថា **ធីរំ** (អ្នកមានបញ្ញា) គឺ អ្នកមានសេចក្តីព្យាយាម ។ បទថា **នារតី ធីរសំហតិ** (សេចក្តីអផ្សុកមិនគ្របសង្កត់ភិក្ខុអ្នកមានបញ្ញាបានឡើយ) នេះ ជាបទពោលហេតុនៃបទដំបូង ។ ព្រោះហេតុនៃសេចក្តីអផ្សុកនោះមិនញាំញីភិក្ខុដែលមានបញ្ញា គឺ រមែងមិនអាចនឹងញាំញី គឺ គ្របសង្កត់ភិក្ខុដែលមានបញ្ញាបាន ដូច្នោះ សេចក្តីអផ្សុកទើបរកញាំញីភិក្ខុដែលមានបញ្ញាមិនបាន ។ បទថា **ធីរោ ហិ អរតីសហោ** (ព្រោះភិក្ខុអ្នកមានបញ្ញាជាអ្នកគ្របសង្កត់សេចក្តីអផ្សុកបាន) សេចក្តីថា ព្រោះហេតុដែលភិក្ខុជាអ្នក

គ្រប់សង្កត់សេចក្តីអផ្សុកបាន ទើបឈ្មោះថា **អ្នកមានបញ្ញា** ដូច្នោះ លោក ទើបគ្រប់សង្កត់សេចក្តីអផ្សុកបាន ។ បទថា **សព្វកម្មវិហាយីនំ** (អ្នកលះកម្មទាំងពួងបាន) សេចក្តីថា ភិក្ខុលះបង់កម្មដែលប្រព្រឹត្តទៅក្នុងភូមិបីទាំងពួងហើយ គឺ កាត់ផ្តាច់ផ្លូវដោយជុំវិញហើយតាំងនៅ ។ បទថា **បនុណ្ណំ កោ និវារយេ** (ភគៈ ឬទោសៈអ្វីនឹងរាំង) សេចក្តីថា រាគៈក្តី ទោសៈក្តីអ្វីណា នឹងមករារាំងបុគ្គលដែលបន្ទោបង់កិលេសទាំងឡាយបានហើយតាំងនៅ ។ បទថា **នេក្ខំ ជម្ពោនទស្សេវ កោ នំ និន្ទិតុមរហតិ** (នរណានឹងគួរតិះដៀលភិក្ខុដែលបរិសុទ្ធ ដូចមាសជម្ពូនទនោះបាន) សេចក្តីថា នរណាហ្ន៎ គួរនឹងតិះដៀលបុគ្គលនោះ ដែលរួចផុតចាកទោសដែលនឹងគប្បីតិះដៀលដូចដុំមាសធម្មជាតិដែលហៅថា ជម្ពូនុទ ។ បទថា **ព្រហ្មុនាបិ បសំសិតោ** (សូម្បីព្រហ្មក៏សរសើរហោ) សេចក្តីថា សូម្បីព្រហ្មក៏សរសើរបុគ្គលនោះ ។

វេលាចប់ទេសនា ភិក្ខុបួនម៉ឺនរូប ក៏តាំងនៅក្នុងព្រះអរហត្ត ។

ចប់អដ្ឋកថា អរិយវង្សសូត្រទី ៨

# អដ្ឋកថា ធម្មបទសូត្រទី ៩

## "ធម្មបទដែលបណ្ឌិតសរសើរ"

គប្បីជ្រាបវិនិច្ឆ័យក្នុង ធម្មបទសូត្រទី ៩ ដូចតទៅនេះ ៖

[៣០] បទថា **ធម្មបទានិ** (ធម្មបទ) គឺ ចំណែកនៃធម៌ ។ ក្នុងបទថា **អនភិជ្ឈា** ជាដើម គប្បីជ្រាបអនភិជ្ឈា ព្រោះជាសត្រូវរបស់អភិជ្ឈា ។ គប្បីជ្រាប អព្យាបាទ ព្រោះជាសត្រូវរបស់ព្យាបាទ , គប្បីជ្រាប សម្មាសតិ ព្រោះជាសត្រូវរបស់មិច្ឆាសតិ , គប្បីជ្រាប សម្មាសមាធិ ព្រោះជាសត្រូវរបស់មិច្ឆាសមាធិ ។

បទថា **អនភិជ្ឈាលុ** (បុគ្គលមិនមានអភិជ្ឈា) គឺ មិនមានតណ្ហា ។ បទថា **អព្យាបន្នេន ចេតសា** (មានចិត្តមិនព្យាបាទ) សេចក្តីថា មានចិត្តមិនលះប្រក្រតីភាពរហូតអស់កាលទាំងពួង ។ បទថា **សតោ ឯកគ្គចិត្តស្ស** (មានសតិ មានចិត្តតាំងមាំ) សេចក្តីថា បុគ្គលប្រកបដោយសតិ មានចិត្តតាំងមាំក្នុងអារម្មណ៍តែមួយ ។ បទថា **អជ្ឈត្តំ សុសមាហិតោ** (មានចិត្តតាំងមាំនៅខាងក្នុង) សេចក្តីថា ជាបុគ្គលមានចិត្តតាំងមាំដោយល្អនៅខាងក្នុង ។ ត្រាស់វដ្ដៈ និងវិវដ្ដៈទុកទាំងក្នុងព្រះសូត្រ ទាំងក្នុងគាថា ។

ចប់អដ្ឋកថា ធម្មបទសូត្រទី ៩

# អដ្ឋកថា បរិព្វាជកសូត្រទី ១០

## *“ត្រាស់ធម៌ ៤ ប្រការដល់បរិព្វាជក”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បរិព្វាជកសូត្រទី ១០ ដូចតទៅនេះ ៖*

[៣១] *បទថា* **អភិញ្ញាតា** *(អ្នកមានកេរ្តិ៍ឈ្មោះប្រាកដ) បានដល់ អ្នកមានឈ្មោះដែលគេបានស្គាល់ គឺ ប្រាកដ ។ បទថា* **អន្នភារោ** *(អន្នភារៈ) ជាដើម ជាឈ្មោះរបស់បរិព្វាជកនោះ ។ បទថា* **បដិសល្លានា វុដ្ឋិតោ** *(ស្ដេចចេញចាកទីស្ងាត់) បានដល់ ព្រះមានព្រះភាគ ស្ដេចចេញចាកផល-សមាបត្តិ ។ ក៏ផលសមាបត្តិនោះ លោកបំណងថាទីស្ងាត់ក្នុងទីនេះ ។ បទថា* **បចុក្កាយ** *(លើក) គឺ ជំទាស់ ។ បទថា* **អភិជ្ឈាលុំ** *បុគ្គលច្រើនទៅដោយអភិជ្ឈា) គឺ អ្នកមានតណ្ហា ។ បទថា* **កាមេសុ តិព្វសារាគំ** *(មានតម្រេកខ្លាំងក្លាក្នុងកាមទាំងឡាយ) សេចក្ដីថា អ្នកមានតម្រេកច្រើនក្នុងវត្ថុ-កាម ។ បទថា* **តមហំ តត្ថ ឯវំ វទេយ្យំ** *(ក្នុងប្រការនោះ តថាគតនឹងពោលជាមួយបុគ្គលនោះយ៉ាងនេះ) សេចក្ដីថា កាលគេពោលពាក្យនោះ តថាគតនឹងពោលយ៉ាងនេះក្នុងហេតុនោះ ។ បទថា* **បដិក្កោសិតព្វំ មញ្ញេយ្យ** *(មកសម្គាល់ឃើញ... គួរជំទាស់) សេចក្ដីថា បុគ្គលណាមកសម្គាល់ថា គួរជំទាស់ គឺថា គួរហាម ។ បទថា* **សហធម្មិកា** *(សមគួរដល់ហេតុ) បាន*

ដល់ ព្រមនឹងហេតុ ។ បទថា **វាទានុបាតា** (ដែលសមដល់ពាក្យតិះដៀល) សេចក្តីថា ត្រូវពាក្យនិយាយដែលប្រកបដោយធម៌បៀតបៀន អធិប្បាយថា ខុសតាមវាទៈដែលបុគ្គលតិះដៀល គឺ ប្រព្រឹត្តទៅតាមដែលគេពោលរក ។ បទថា **គារយ្ហា ឋានា** (ឋានៈដែលគួរតិះដៀល) គឺ បច្ច័យដែលគួរតិះដៀល ។ បទថា **អាគច្ឆន្តិ** (រមែងបានទទួល) គឺ រមែងចូលដល់ ។

បទថា **ឧក្កលា** (អ្នកជនបទឧក្កលៈ) គឺ អ្នកស្រុកឧក្កលៈ ។ បទថា **វស្សៈ និងភញ្ញៈ** គឺ បរិព្វាជក ២ នាក់ ឈ្មោះវស្សៈ និងភញ្ញៈ ។ បទថា **អហេតុកវាទា** (បុគ្គលជាអហេតុកវាទ) សេចក្តីថា ទាំង ២ នាក់ ជាអ្នកមានវាទៈជាដើមយ៉ាងនេះថា "ហេតុមិនមាន បច្ច័យមិនមាន" ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ។ បទថា **អកិរិយវាទា** (បុគ្គលជាអកិរិយវាទ) សេចក្តីថា អ្នកមានវាទៈបដិសេធកិរិយវាទ យ៉ាងនេះថា "កាលបុគ្គលធ្វើហើយ បាបមិនឈ្មោះថាបុគ្គលបានធ្វើ" ។ បទថា **នត្ថិកវាទា** (បុគ្គលជានត្ថិកវាទ) សេចក្តីថា អ្នកមានវាទៈជាដើមយ៉ាងនេះថា "ទានដែលទាយកឲ្យហើយ មិនមានផល" ។ បុគ្គលទាំង ២ នោះ ជាអ្នកធ្លាក់ចុះក្នុងទស្សនៈទាំង ៣ នេះ ។ សួរថា ក៏ក្នុងបុគ្គលទាំងនោះ កំណត់បានយ៉ាងណា ។ ឆ្លើយថា ក៏បុគ្គលណាកាន់លទ្ធិបែបនេះ អង្គុយស្វាធ្យាយពិចារណា

ហើយ ក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ មិច្ឆាសតិរបស់បុគ្គលនោះ រមែងតាំងមាំនៅក្នុងអារម្មណ៍នោះថា ហេតុមិនមាន បច្ច័យមិនមាន កាលបុគ្គលធ្វើហើយ បាបរមែងមិនឈ្មោះថា បុគ្គលបានធ្វើ ។ល។ ទានដែលទាយកឲ្យហើយមិនមានផល ។ល។ ព្រោះកាយបែកធ្លាយ រមែងដាច់សូន្យ ចិត្តរមែងតម្កល់មាំ ជវនចិត្តទាំងឡាយរមែងស្ទុះទៅ ក្នុងជវនចិត្តទីមួយ បុគ្គលនោះជាអ្នកនៅកែខៃបាន ក្នុងជវនចិត្តទីពីរជាដើមក៏យ៉ាងនោះ តែក្នុងជវនចិត្តទី ៧ បុគ្គលនោះ សូម្បីព្រះពុទ្ធទាំងឡាយក៏កែខៃមិនបាន មិនត្រឡប់មក រមែងដូចជាអរិដ្ឋភិក្ខុ និងកណ្ដកសាមណេរ ។ បណ្ដាទស្សនៈ ៣ យ៉ាងនោះ បុគ្គលខ្លះធ្លាក់ចុះកាន់ទស្សនៈតែមួយ បុគ្គលខ្លះ ២ ទស្សនៈ បុគ្គលខ្លះ ៣ ទស្សនៈ គេរមែងឈ្មោះថា និយតមិច្ឆាទិដ្ឋិកៈនោះឯង គេត្រូវហាមសួគ៌ និងត្រូវហាមព្រះនិព្វាន មិនគួរនឹងទៅកាន់សួគ៌ក្នុងលំដាប់នៃអត្តភាពនោះ នឹងចាំបាច់ពោលថ្វីដល់ព្រះនិព្វាន ។ អធិប្បាយថា សត្វនេះជាអ្នកយាមផែនដី ឈ្មោះថា ជាតំណក្នុងវដ្ដៈ ។ ដោយច្រើន សត្វបែបនេះមិនចេញចាកភព សូម្បីវស្សៈ និងកញ្ញៈបរិព្វាជក ក៏ដូច្នេះ ។ បទថា **និទ្ទារាមតំ ភេសនាឧបារម្ភកយា** (ព្រោះខ្លាចត្រូវនិន្ទាប៉ះខ្ទប់ និងពេបជ្រាយ) សេចក្ដីថា ព្រោះខ្លួនខ្លាចនិន្ទា ខ្លាចការពេបជ្រាយ និងការតិះដៀល ។

*បទថា **អភិជ្ឈាវិនយេ សិក្ខំ** (សិក្សាក្នុងការកម្ចាត់អភិជ្ឈា) សេចក្តីថា ព្រះអរហត្ត ហៅថា ធម៌ជាគ្រឿងកម្ចាត់អភិជ្ឈា អ្នកសិក្សាក្នុងព្រះអរហត្តហើយ ហៅថា បុគ្គលមិនប្រមាទ ។ ទ្រង់ត្រាស់ទាំងវដ្តៈ និងវិវដ្តៈទុកក្នុងព្រះសូត្រហើយ ទើបត្រាស់ផលសមាបត្តិទុកក្នុងព្រះគាថា ដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា បរិព្វាជកសូត្រទី ១០

## ចប់ឱរុវេលវគ្គទី ៣

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# ចក្កវគ្គទី ៤

## អដ្ឋកថា ចក្កសូត្រទី ១

### "ចក្ក ៤"

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចក្កសូត្រទី ១ ដូចតទៅនេះ ៖*

[៣២] *បទថា* ***ចក្កានិ*** *(ចក្រ) គឺ សម្បត្តិ ។ បទថា* ***ចតុចក្កំ វត្តតិ*** *(រមែងមានផល) សេចក្តីថា ចក្រ គឺ សម្បត្តិ ៤ រមែងកើតឡើង គឺប្រព្រឹត្តទៅបន្តគ្នា ។ បរិស័ទ ៤ រមែងប្រាកដព្រមក្នុងស្ថានទីណា ការនៅក្នុងស្ថានទីដែលសមគួរបែបនោះ ឈ្មោះថា* ***បដិរូបទេសវាសៈ*** *។ ការពឹងអាស្រ័យ គឺ សេពគប់រកសប្បុរសមានព្រះពុទ្ធជាដើម ឈ្មោះថា* ***សប្បុរិសូបស្សយៈ*** *។ ការតាំងខ្លួនទុកប្រពៃ គឺ បើជាបុគ្គលប្រកបដោយការមិនមានសទ្ធាជាដើមអំពីមុន ការលះការមិនមានសទ្ធាទាំងនោះចេញ ហើយតាំងនៅក្នុងសទ្ធាជាដើម ឈ្មោះថា* ***អត្តសម្មាបណិធិ*** *។ ភាពជាអ្នកមានកុសលដែលសន្សំទុកក្នុងកាលមុន ឈ្មោះថា* ***បុព្វេកតបុញ្ញតា*** *។ បុព្វេកតបុញ្ញតានេះឯង កាន់យកជាសំខាន់ក្នុងចក្រ ៤ នេះ ។ ព្រោះថា កុសលកម្មបុគ្គលណាធ្វើដោយចិត្តដែលសម្បយុត្តដោយញាណណា ចិត្តដែលសម្បយុត្ត*

ដោយញាណដែលជាកុសលនោះឯង រមែងនាំអ្នកនោះចូលទៅនៅក្នុងទីដ៏សមគួរ ឲ្យគេសេពគប់រកសប្បុរស ក៏បុគ្គលនោះឈ្មោះថា តាំងខ្លួនទុកប្រពៃដោយអាការយ៉ាងនេះ ។ បទថា **បុញ្ញកតោ** (មានសេចក្ដីល្អដែលបានធ្វើទុកអំពីមុន) បានដល់ បានធ្វើបុណ្យទុកហើយ ។ បទថា **សុខញ្ចេតំ អធិ-វត្តតិ**[១] (សេចក្ដីសុខតែងឃុំគ្រងនរជននោះ) សេចក្ដីថា និងសេចក្ដីសុខរមែងឃុំគ្រង គឺ ផ្សាយមកកាន់បុគ្គលនោះ ។

ចប់អដ្ឋកថា ចក្កសូត្រទី ១

---

(១) បិដក = សុខញ្ចេតំ ធិវត្តតិ ។

# អដ្ឋកថា សង្គហសូត្រទី ២

## *"សង្គហវត្ថុ ៤ ប្រការ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សង្គហសូត្រទី ២ ដូចតទៅនេះ ៖*

[៣៣] *បទថា* ***សង្គហវត្ថូនិ*** *(សង្គហវត្ថុ) គឺ ហេតុនៃការសង្គ្រោះគ្នា ។ ក្នុងបទថា* ***ទានញ្ច*** *(ទាន) ជាអាទិ៍ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ក៏បុគ្គលខ្លះគួរទទួលសង្គ្រោះដោយទានតែម្យ៉ាង ក៏គប្បីឲ្យទានតែម្យ៉ាងដល់គេ ។ បទថា* ***បេយ្យវជ្ជំ*** *គឺ និយាយពាក្យគួរស្រឡាញ់ ។ ពិតហើយបុគ្គលខ្លះនិយាយថា បុគ្គលនេះឲ្យវត្ថុដែលគួរឲ្យ តែដោយពាក្យសំដី គេក៏និយាយលុបគុណ ធ្វើឲ្យវិនាសអស់ គេឲ្យធ្វើអ្វី ។ បុគ្គលខ្លះនិយាយថា បុគ្គលនេះមិនឲ្យទានក៏ពិត តែគេក៏និយាយបានពីរោះ ដូចយកប្រេងលាបជើង បុគ្គលដូច្នោះនឹងឲ្យក៏ដោយ មិនឲ្យក៏ដោយ តែពាក្យសំដីរបស់គេរមែងមានតម្លៃរាប់ពាន់ ។ បុគ្គលបែបនេះ រមែងមិនប្រាថ្នាការឲ្យ រមែងប្រាថ្នាតែពាក្យសំដីដែលគួរស្រឡាញ់តែម្យ៉ាង គប្បីពោលតែពាក្យសំដីដែលគួរស្រឡាញ់ដល់គេប៉ុណ្ណោះ ។ បទថា* ***អត្ថចរិយា*** *គឺ និយាយតែរឿងដែលជាប្រយោជន៍ និងធ្វើសេចក្តីចម្រើន ។ ពិតណាស់ បុគ្គលខ្លះមិនមែនប្រាថ្នាតែទាន (ការឲ្យ) មិនមែនប្រាថ្នាតែបិយវាចា (ពាក្យសំដីដែលគួរស្រឡាញ់)*

បើប្រាថ្នាតែការនិយាយដែលជាប្រយោជន៍ ការនិយាយដែលធ្វើនូវសេចក្តីចម្រើនដល់ខ្លួនតែម្យ៉ាង គប្បីពោលតែរឿងបំពេញប្រយោជន៍ដល់បុគ្គលបែបនោះយ៉ាងនេះថា លោកគួរធ្វើកិច្ចនេះ មិនគួរធ្វើកិច្ចនេះ បុគ្គលដូច្នេះគួរសេពគប់ ដូច្នេះមិនគួរសេពគប់ ។ បទថា **សមានត្តតា** គឺ ជាអ្នកមានសុខ មានទុក្ខស្មើគ្នា ។ ពិតហើយ បុគ្គលខ្លះ រមែងមិនប្រាថ្នាសង្គហវត្ថុមានទានជាដើម តែប្រាថ្នាសេចក្តីរួមសុខរួមទុក្ខយ៉ាងនេះ គឺ អង្គុយលើអាសនៈជាមួយគ្នា ដេកលើគ្រែជាមួយគ្នា បរិភោគរួមគ្នា ។ បើគេជាគ្រហស្ថរមែងស្មើគ្នាដោយជាតិ បព្វជិតរមែងស្មើគ្នាដោយសីល ការដាក់ខ្លួនស្មើនេះ គួរធ្វើដល់បុគ្គលនោះ ។

បទថា **តត្ថ តត្ថ យថារហំ** (ក្នុងធម៌នោះៗ តាមគួរ) សេចក្តីថា ការដាក់ខ្លួនស្មើក្នុងធម៌នោះៗ តាមសមគួរ ។ បទថា **រថស្សាណីវ យាយតោ** (ដូចជាក្ដៅរបស់រថដែលវិលទៅបាន) សេចក្តីថា សង្គហធម៌ទាំងនេះ រមែងមានក្នុងលោក ដូចក្ដៅរបស់រថដែលវិលទៅបាន គឺ រមែងភ្ជាប់ជាមួយរថទុកបានដូច្នោះ ។ បទថា **ន មាតា បុត្តការណា** (មាតា... ព្រោះហេតុនៃបុត្ត) សេចក្តីថា បើមាតាមិនគប្បីធ្វើការសង្គ្រោះទាំងនោះដល់បុត្រសោតលោកក៏មិនគប្បីបានទទួលសេចក្តីរាប់អាន ឬបូជា ព្រោះបុត្រជាហេតុ ។

*បទថា* ***សទ្ធហា ឯតេ*** *ជាបឋមាវិភត្តិប្រើក្នុងអត្ថទុតិយាវិភត្តិ មួយទៀត បាឋៈថា* ***សទ្ធហេ ឯតេ*** *ក៏មាន ។ បទថា* ***សមវេក្ខន្តិ*** *(ឃើញសេចក្តីសំខាន់) គឺ រមែងពិចារណាឃើញដោយប្រពៃ ។ បទថា* ***បាសំសា ច ភវន្តិ*** *(ដែលគួរសរសើរ) គឺ ជាបុគ្គលគួរសរសើរ ។*

ចប់អដ្ឋកថា សទ្ធហាសូត្រទី ២

# អដ្ឋកថា សីហសូត្រទី ៣

## *"ព្រះតថាគតប្រៀបដូចជាស្តេចរាជសីហ៍"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សីហសូត្រទី ៣ ដូចតទៅនេះ ៖*

*[៣៤] បទថា **សីហោ** (ស្តេចរាជសីហ៍) បានដល់ រាជសីហ៍ ៤ ប្រភេទ គឺ **តិណរាជសីហ៍ ១ កាឡរាជសីហ៍ ១ បណ្ឌុរាជសីហ៍ ១ កេសររាជសីហ៍ ១** ។ ក្នុងរាជសីហ៍ទាំងនោះ តិណរាជសីហ៍ ស៊ីស្មៅ មានខ្លួនដូចជាមេគោមានសម្បុរដូចសត្វព្រាប ។ កាឡរាជសីហ៍ ស៊ីស្មៅ មានខ្លួនដូចជាមេគោខ្មៅ ។ បណ្ឌុរាជសីហ៍ ស៊ីសាច់ មានខ្លួនដូចជាមេគោ មានសម្បុរដូចស្លឹកឈើទុំ ។ កេសររាជសីហ៍ ប្រកបដោយរោម ចុងកន្ទុយ និងចុងជើងទាំង ៤ ដែលធម្មជាតិតាក់តែងដោយល័ក្ខ តាំងពីសីសៈរបស់កេសររាជសីហ៍នោះ មានស្នាម ៣ ដូចជាគេគូសទុកដោយជក់ នៅត្រង់កណ្តាលខ្នង មានក្រយៅនៅត្រង់ចន្លោះគល់ភ្លៅ ។ ត្រង់ករបស់វា មានស្នាមក (សង្វារ.ក) ដូចជារង្វង់ ដោយសំពត់កម្ពលក្រហមមានតម្លៃរាប់សែន ។ ចំណែកអវយវៈដ៏សេស មានពណ៌ដូចគំនរស្រូវសាលីបរិសុទ្ធ ឬដូចដុំលំអិតនៃខ្យងស័ង្ខ ក្នុងរាជសីហ៍ទាំង ៤ នេះ ទ្រង់បំណងយកកេសររាជសីហ៍ក្នុងទីនេះ ។*

បទថា **មិគរាជា** (ស្ដេចរាជសីហ៍) បានដល់ ជារាជានៃហ្វូងម្រឹគទាំងអស់ ។ បទថា **អាសយា** (ទីអាស្រ័យ) បានដល់ ចេញចាកទីនៅ ។ លោកអធិប្បាយថា រមែងចេញចាកល្អាងមាស ឬល្អាងប្រាក់ ល្អាងកែវមណី ល្អាងកែវផលឹក ឬល្អាងមនោសិលា ។ ក៏កាលនឹងចេញ រមែងចេញដោយហេតុ ៤ គឺ ត្រូវសេចក្ដីងងឹតបៀតបៀន ចេញដើម្បីទទួលពន្លឺ ១ ឈឺឧច្ចារបស្សាវៈ ចេញដើម្បីបន្ទោបង់ឧច្ចារបស្សាវៈ ១ ត្រូវសេចក្ដីស្រេកឃ្លានបៀតបៀន ចេញដើម្បីរកចំណី១ ត្រូវការបន្តពូជបៀតបៀន ចេញដើម្បីស្វែងរកគ្នា ១ ។ តែក្នុងទីនេះ លោកសំដៅយកចេញដើម្បីរកចំណី ។

បទថា **វិជម្ភតិ** (រលាស់កាយ) សេចក្ដីថា រាជសីហ៍ដាក់ជើងក្រោយទាំងពីរឲ្យស្មើគ្នាលើផ្ទៃល្អាងមាស ឬលើផ្ទៃល្អាងប្រាក់ ល្អាងកែវមណី ល្អាងកែវផលឹក ឬល្អាងមនោសិលាណាមួយ បោះជើងមុខទុកត្រង់មុខ ដកចំណែកក្រោយរបស់ខ្លួន បោះចំណែកមុខ បង្អោនខ្នងចុះ ងើបកឡើង ផ្ទុំខ្យល់ចេញតាមច្រមុះប្រៀបដូចសំឡេងរន្ទះ រលាស់ធូលីដែលនៅជាប់ខ្លួន ។ ក៏ស្ដេចរាជសីហ៍រមែងរត់ទៅរត់មកលើផែនដីរលាស់ខ្លួន ដូចកូនគោជំទង់ ឯចំណែកសរីរៈរបស់ស្ដេចរាជសីហ៍ដែលរត់ទៅនោះ ក៏ប្រាកដដូចជាកូនភ្លើងដែលបង្វិលក្នុងទីងងឹត ។ បទថា **អនុវិលោកេតិ** (សម្លឹងមើលដោយជុំវិញ) សួរ

ថា ព្រោះហេតុអ្វី រាជសីហ៍ទើបសម្លឹងមើល ។ ឆ្លើយថា ព្រោះសេចក្តីអាណិតដល់សត្វដទៃ ។ បានឮថា កាលវាបន្លឺសំឡេង សត្វទាំងឡាយមាន ដំរី គោ ក្របីជាដើម ដើរនៅជិតជ្រោះ និងអណ្តូង ក៏ធ្លាក់ទៅក្នុងជ្រោះខ្លះ ក្នុងអណ្តូងខ្លះ វាទើបសម្លឹងមើល ក៏ព្រោះសេចក្តីអាណិតសត្វទាំងនោះ ។ សួរថា ក៏រាជសីហ៍ ខ្លួនជាសត្វកាចស៊ីសាច់របស់សត្វដទៃនោះ នៅមានសេចក្តីអាណិតឬ ។ ឆ្លើយថា នៅមាន ។ ពិតហើយ រាជសីហ៍រមែងមិនចាប់សត្វតូចៗ ដើម្បីជាអាហាររបស់ខ្លួន ដោយគិតថា ប្រយោជន៍អ្វីដល់យើង ព្រោះសត្វជាច្រើនដែលត្រូវសម្លាប់ ។ រាជសីហ៍ធ្វើសេចក្តីអាណិតដោយអាការយ៉ាងនេះ ។ ក៏សេចក្តីនោះ សមពិតដូចលោកពោលថា យើងកុំសម្លាប់សត្វតូចៗ ដែលនៅក្នុងទីមិនរាបស្មើឡើយ ។

បទថា **សីហនាទំ នទតិ** (បន្លឺសំឡេង) សេចក្តីថា គ្រាដំបូង បន្លឺសម្លេងឲ្យសត្វខ្លាចឡើង ៣ ដង ។ ក៏កាលវាឈរលើផែនដីលាស់ខ្លួនហើយបពោញសម្រែក សំឡេងរមែងលាន់គឹកកងទៅដោយជុំវិញរហូតដល់ទី ៣ យោជន៍ ហ្វូងសត្វជើង ២ និងជើង ៤ ដែលនៅខាងក្នុងបីយោជន៍ បានឮសម្លេងគឹកកងរបស់វាហើយ រមែងឈរក្នុងទីដើមមិនបាន ។ បទថា **គោចរាយ បក្កមតិ** (ចេញរកចំណី) បានដល់ រមែងចេញទៅដើម្បីរកចំណី ។

សួរថា យ៉ាងណា ។ ឆ្លើយថា វាឈរលើផែនដីហើយរលាស់ លោតទៅខាងស្តាំ ខាងឆ្វេង ខាងក្រោយ ហើយស្ទុះលោតឡើងរំលងម្រឹគក្នុងទីប្រមាណមួយឧសភៈ បើលោតខ្ពស់ លោតបាន ៤ ឧសភៈខ្លះ ៨ ឧសភៈខ្លះ កាលលោតត្រង់ៗ ទៅក្នុងទីរាប ក៏លោតឆ្លងម្រឹគក្នុងទីប្រមាណ ១៦ ឧសភៈខ្លះ ២០ ឧសភៈខ្លះ ។ កាលលោតចុះពីទីទួល ឬភ្នំ ក៏លោតឆ្លងម្រឹគក្នុងទីប្រមាណ ៦០ ឧសភៈខ្លះ ៨០ ឧសភៈខ្លះ ឃើញដើមឈើ ឬភ្នំក្នុងរវាងផ្លូវ ក៏គេចចេញពីដើមឈើ ឬភ្នំនោះ ក្នុងទីកម្ពស់ប្រមាណមួយឧសភៈតាមផ្លូវស្តាំខ្លះ ផ្លូវឆ្វេងខ្លះ ។ ក៏រាជសីហ៍បន្លឺសំឡេងលើកទី ៣ រមែងប្រាកដខ្លួនក្នុងទីបីយោជន៍ព្រមជាមួយសំឡេងនោះ វាទៅបានបីយោជន៍ ត្រឡប់មកឈរកន្លែងដើម បានឮសំឡេងលាន់គឹកកងរបស់ខ្លួនហើយ ។ រាជសីហ៍រមែងជៀសចេញទៅដោយសន្ទុះជើងដ៏រហ័សយ៉ាងនេះ ។

បទថា **យេភុយ្យេន** បានដល់ ដោយចំណែកច្រើន ។ បទថា **ភយំ សន្តាសំ សំវេគំ**[១] (ភ័យ ញ័រ តក់ស្លុត) គ្រប់បទ ជាឈ្មោះរបស់សេចក្តីតក់ស្លុតនៃចិត្តដូចគ្នា ។ ពិតណាស់ សត្វ និងមនុស្ស បានឮសំឡេងរបស់រាជសីហ៍ ចំណែកច្រើនភ័យខ្លាច ចំណែកតិចមិនភ័យខ្លាច ។ សួរថា ក៏សត្វ

---

(១) បិដក = ភយំ សំវេគំ សន្តាសំ ។

និងមនុស្សប្រចាំណោកតិចទាំងនោះ គឺ នរណា ។ ឆ្លើយថា គឺ **រាជសីហ៍ដែលស្មើគ្នា ដំរីអាជានេយ្យ សេះអាជានេយ្យ គោឧសភអាជានេយ្យ បុរសអាជានេយ្យ ព្រះខីណាស្រព** ។ សួរថា ក៏ព្រោះហេតុអ្វី សត្វ និងមនុស្សទាំងនោះទើបមិនខ្លាច ។ ឆ្លើយថា ជាដំបូងរាជសីហ៍ដែលស្មើគ្នា រមែងមិនខ្លាច ព្រោះគិតថា យើងស្មើគ្នាដោយជាតិ គោត្រ ត្រកូល និងភាពខ្លាំងក្លា ។ ដំរីអាជានេយ្យជាដើម មិនខ្លាច ព្រោះថា ខ្លួនមានសក្កាយទិដ្ឋិជាកម្លាំង ។ ព្រះខីណាស្រពមិនខ្លាច ព្រោះលះសក្កាយទិដ្ឋិបានហើយ ។ បទថា **ពិលាសយា** (ពពួកសត្វនៅក្នុងរូង ក្នុងព្រង់) បានដល់ សត្វដែលដេកនៅក្នុង នៅក្នុងរូង នៅក្នុងព្រង់ មានពស់ ស្ការ និងសត្វទន្សងជាដើម ។ បទថា **ឧទកាសយា** (ពពួកសត្វដែលនៅក្នុងទឹក) បានដល់ សត្វនៅក្នុងទឹក មានត្រី និងអណ្តើកជាដើម ។ បទថា **វនាសយា** (ពពួកសត្វនៅក្នុងព្រៃ) បានដល់ សត្វនៅក្នុងព្រៃ មានដំរី សេះ គោ ម្រឹគជាដើម ។ បទថា **បវិសន្តិ** (ចូល) សេចក្តីថា សត្វទាំងឡាយសម្លឹងមើលផ្លូវដោយគិតថា ឥឡូវនេះ នរណានឹងមកចាប់ ទើបចូលទៅ ។ បទថា **ទឡ្ហេហិ** (ដ៏ជាប់) គឺ ស្ថិត ។ បទថា **វរត្តេហិ** គឺ ដោយចំណងព្រ័ត្រ ។ ក្នុងបទថា **មហិទ្ធិកោ** (មានឫទ្ធិច្រើន) ជាដើម គប្បីជ្រាបថា សត្វសីហៈជាស្តេចសត្វ មានឫទ្ធិច្រើន ដោយអំណាច

ឈរផែនដី រលាស់ខ្លួន លោតបានមួយឧសភៈទៅចំណែកខាងស្តាំជាដើម លោតត្រង់បានប្រមាណ ២០ ឧសភៈជាដើម ។ គប្បីជ្រាបនូវសត្វមានសក្តិធំ ព្រោះជាពជាជាធំជាងម្រឹគដ៏សេស ។ គប្បីជ្រាបចំពោះរាជសីហ៍មានអានុភាពច្រើន ដោយអំណាចនៃសត្វទាំងឡាយ បានឮសំឡេងក្នុងទីបីយោជន៍ដោយជុំវិញហើយ ត្រូវនាំគ្នាគេចចេញទៅ ។

បទថា **ឯវមេវ ខោ** (ដូច្នោះនោះឯង) សេចក្តីថា ព្រះមានព្រះភាគត្រាស់ចំពោះព្រះអង្គទុកក្នុងព្រះសូត្រនោះៗ ដោយប្រការនោះៗ ត្រាស់ដល់ព្រះអង្គប្រៀបដោយរាជសីហ៍ក្នុងព្រះសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ ក៏ពាក្យថា ស្តេចរាជសីហ៍នោះ ជាឈ្មោះរបស់តថាគតអរហន្តសម្មាសម្ពុទ្ធ ។ ត្រាស់ចំពោះព្រះអង្គ ប្រៀបដូចជាពេទ្យ ក្នុងព្រះសូត្រនេះថា សុនក្ខត្តៈពាក្យថា ពេទ្យវះកាត់ នោះជាឈ្មោះរបស់តថាគត ។ ត្រាស់ចំពោះព្រះអង្គ ប្រៀបដូចជាព្រាហ្មណ៍ ក្នុងព្រះសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រាហ្មណ៍ នោះជាឈ្មោះរបស់តថាគត ។ ត្រាស់ចំពោះព្រះអង្គ ប្រៀបដូចជាអ្នកនាំផ្លូវ ក្នុងព្រះសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ ក៏ពាក្យថា បុរសអ្នកឈ្លាសក្នុងផ្លូវ នោះជាឈ្មោះរបស់តថាគត ។ ត្រាស់ចំពោះព្រះអង្គប្រៀបដូចជាព្រះរាជា ក្នុងព្រះសូត្រនេះថា ម្នាលសេលៈ តថាគតជាព្រះរាជា ។

បំណែកក្នុងព្រះសូត្រនេះ ត្រាស់ព្រះអង្គប្រៀបដូចជារាជសីហ៍ ទើបត្រាស់យ៉ាងនោះ ។

ក្នុងសេចក្ដីនេះ មានការប្រៀបដូច្នេះ វេលាដែលព្រះតថាគតបំពេញអភិនិហារក្រោមបាទមូលរបស់ព្រះពុទ្ធទីបង្ករ ទ្រង់បំពេញបារមីទាំងឡាយរហូតអស់វេលាកំណត់រាប់មិនបាន ធ្វើម៉ឺនលោកធាតុញាប់ញ័រ ដោយការបដិសន្ធិ និងដោយការប្រសូតិចាកគភ៌របស់មាតាក្នុងភពចុងក្រោយ ទ្រង់ចម្រើនវ័យហើយ សោយសម្បត្តិដូចទិព្វ ប្រថាប់នៅក្នុងប្រាសាទបីខ្នង គប្បីជ្រាបដូចវេលារាជសីហ៍នៅក្នុងល្អាងមាសជាដើម ។ វេលាដែលតថាគតទ្រង់ប្រថាប់លើសេះកន្ថកៈ មាននាយឆន្នៈជាសម្លាញ់ ស្ដេចយាងចេញតាមផ្លូវទ្វារក៏របើក ក្នុងវេលាមានព្រះជន្មាយុ ២៩ វស្សា ទ្រង់ឈានកន្លងរាជសម្បត្តិទាំងបី (រាជា រាជាធិរាជ ចក្រពត្តិរាជា) នុ៎ះហើយ ទ្រង់គ្រងសំពត់កាសាយៈដែលព្រហ្មថ្វាយក្នុងត្រើយស្ទឹងអនោមា ទ្រង់ព្រះផ្នួសហើយ ស្ដេចក៏ទៅកាន់ក្រុងរាជគ្រឹះក្នុងថ្ងៃទី ៧ យាងបិណ្ឌបាតក្នុងក្រុងរាជគ្រឹះនោះ ទ្រង់ធ្វើភត្តកិច្ចត្រង់ញកក្នុបណ្ឌវៈ រហូតទ្រង់ថ្វាយបដិញ្ញាដល់ព្រះបាទពិម្ពិសារថា ទ្រង់សម្រេចព្រះសម្មាសម្ពោធិញ្ញាណហើយ ស្ដេចនឹងមកដែនមគធៈមុន គប្បីជ្រាប ដូចវេលារាជសីហ៍ចេញចាកល្អាងមាសជាដើម ។

វេលាព្រះតថាគតទ្រង់ថ្វាយបង្គំជាហើយ ស្តេចចូលទៅរកអាឡារ-តាបសកាលាមគោត្រជាដើម រហូតដល់សោយដុំបាយបាយាស ៤៩ ពំនូត ដែលនាងសុជាតាថ្វាយ គប្បីជ្រាបដូចវេលារាជសីហ៍រលាស់ខ្លួន ។

កាលព្រះតថាគតទ្រង់ទទួលស្មៅ (ស្បូវ) ៨ ក្តាប់ ដែលព្រាហ្មណ៍ឈ្មោះសោត្ថិយៈថ្វាយក្នុងវេលាល្ងាច ទេវតាក្នុងម៉ឺនចក្រវាឡអនុមោទនាបូជាដោយរបស់ក្រអូបជាដើម ទ្រង់ធ្វើប្រទក្សិណពោធិព្រឹក្ស ៣ ដង ហើយស្តេចឡើងកាន់ពោធិមណ្ឌលស្ថាន ទ្រង់ក្រាលគ្រឿងក្រាល គឺ ស្បូវក្នុងទីកម្ពស់ ១៤ ហត្ថ ប្រថាប់គង់អធិដ្ឋានសេចក្តីព្យាយាមមានអង្គ ៤ ទ្រង់កម្ចាត់មារ និងពលមារក្នុងខណៈនោះឯង ទ្រង់ជម្រះវិជ្ជា ៣ ក្នុងយាមទាំង ៣ ទ្រង់កូរមហាសមុទ្រ គឺ បដិច្ចសមុប្បាទ ទាំងអនុលោមទាំងបដិលោមដោយគ្រឿងកូរ គឺ យមកញ្ញាណ កាលទ្រង់ត្រាស់ដឹងនូវព្រះសព្វញ្ញុត-ញ្ញាណហើយ ម៉ឺនលោកធាតុក៏ញាប់ញ័រ ដោយអានុភាពនៃព្រះសព្វញ្ញុត-ញ្ញាណនោះ គប្បីជ្រាប ដូចការកម្ចាត់ធូលីក្នុងខ្លួនរបស់រាជសីហ៍ ។

កាលព្រះតថាគតទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ ប្រថាប់នៅត្រង់ពោធិមណ្ឌលស្ថាន ៧ សប្តាហ៍ សោយមធុបាយាសជាព្រះក្រយាហារ ទ្រង់ទទួលអារាធនាសម្តែងធម៌របស់ស្តេចមហាព្រហ្ម ត្រង់គល់អជបាលនិគ្រោធ

ប្រថាប់នៅទីនោះ ក្នុងថ្ងៃទី ១១ ទ្រង់រលឹកថា ស្អែកនេះ ក៏ជាថ្ងៃអាសាឡ្ហបុណ្ណមី ក្នុងវេលាជិតភ្លឺ ទ្រង់ត្រួតមើលថា តថាគតនឹងគប្បីសម្តែងធម៌ដល់នរណាមុនហ្ន៎ ទ្រង់ជ្រាបថា អាឡារតាបស និងឧទ្ទកតាបសអស់ជីវិតហើយ ក៏ទ្រង់ឃើញភិក្ខុបញ្ចវគ្គិយៈសមគួរទទួលព្រះធម៌ទេសនាមុន គប្បីឃើញដូចការក្រឡេកមើលទិសទាំង ៤ របស់រាជសីហ៍ ។

វេលាដែលព្រះតថាគត ទ្រង់កាន់បាត្រ និងចីវររបស់ព្រះអង្គ ស្តេចក្រោកចាកដើមអជបាលនិគ្រោធ ស្តេចទៅអស់ផ្លូវ ១៨ យោជន៍ ខាងក្រោយសោយព្រះក្រយាហារ ដោយសំដៅព្រះហឫទ័យនឹងប្រកាសធម្មចក្រដល់ភិក្ខុបញ្ចវគ្គិយៈ គប្បីឃើញ ដូចវេលារាជសីហ៍ចេញរកចំណីទៅបានបីយោជន៍ ។

វេលាដែលព្រះតថាគតស្តេចទៅអស់ផ្លូវ ១៨ យោជន៍ ទ្រង់ធ្វើភិក្ខុបញ្ចវគ្គិយៈឲ្យយល់ហើយ ប្រថាប់គង់ពត់ភ្នែនលើអចលបល្ល័ង្ក ដែលពួកទេវតាបានប្រជុំព្រមគ្នាម៉ឺនចក្រវាឡហែហមហើយ ទើបប្រកាសព្រះធម្មចក្រ ដោយន័យជាអាទិ៍ថា ទីបំផុត ២ នេះ ដែលអ្នកបួសមិនគួរសេព គប្បីជ្រាបដូចវេលារាជសីហ៍បន្លឺសីហនាទ ។ ក៏កាលតថាគតទ្រង់សម្តែងព្រះធម្មចក្រនេះ សំឡេងឧឃោសនៃធម៌របស់រាជសីហ៍ គឺ ព្រះតថាគត ក៏គ្របដណ្តប់

ម៉ឺនលោកធាតុ ខាងក្រោមដល់អវិចី ខាងលើកវគ្គព្រហ្ម ។ វេលាព្រះតថាគត សម្ដែងលក្ខណៈ ៣ ត្រាស់ធម៌ចែកសច្ចៈ ៤ ព្រមដោយអាការ ១៦ រហូតដល់ពាន់ន័យ ពួកទេវតាដែលមានអាយុវែង ក៏កើតការតក់ស្លុតដោយញាណ គប្បីជ្រាប ដូចវេលាពួកសត្វតូចៗ តក់ស្លុត ព្រោះសំឡេងរបស់រាជសីហ៍ ។

ន័យមួយទៀត ព្រះតថាគតទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ ក៏ដូចរាជសីហ៍ វេលាដែលស្ដេចចេញចាកព្រះគន្ធកុដិ ក៏ដូចរាជសីហ៍ចេញចាកល្អាងមាសជាទីអាស្រ័យ វេលាស្ដេចចូលទៅធម្មសភា ក៏ដូចរាជសីហ៍រលាស់ខ្លួន កាលទ្រង់ក្រឡេកមើលបរិស័ទ ក៏ដូចការក្រឡេកមើលទិស វេលាទ្រង់សម្ដែងធម៌ ក៏ដូចការបន្លឺសីហនាទ កាលស្ដេចទៅបង្ក្រាបលទ្ធិដទៃ ក៏ដូចការចេញរកចំណី ។

ន័យមួយទៀត ព្រះតថាគតក៏ដូចរាជសីហ៍ ការចេញចាកផលសមាបត្តិដែលអាស្រ័យនិព្វានជាអារម្មណ៍ ក៏ដូចការចេញចាកល្អាងមាស ដែលអាស្រ័យហិមវន្តបព៌ត បច្ចវេក្ខណញ្ញាណ ក៏ដូចការរលាស់ខ្លួន ការត្រួតមើលវេនេយ្យសត្វ ក៏ដូចការក្រឡេកមើលទិស ការសម្ដែងធម៌ដល់បរិស័ទដែលមកដល់ហើយ ក៏ដូចការបន្លឺសីហនាទ កាលស្ដេចចូលទៅរកវេនេយ្យសត្វដែលមិនទាន់មកដល់ គប្បីជ្រាប ដូចការចេញទៅរកចំណី ។

បទថា **យទា** (កាលបើ) បានដល់ ក្នុងកាលណា ។ បទថា **តថា-គតោ** (តថាគត) បានដល់ ឈ្មោះថា តថាគត ដោយហេតុ ៨ ប្រការ ដែលពោលហើយក្នុងខាងដើម ។ បទថា **លោកេ** (ក្នុងលោក) គឺ ក្នុងសត្វលោក ។ បទថា **ឧប្បជ្ជតិ** (កើតឡើង) សេចក្តីថា តថាគតឈ្មោះថា កំពុងកើតឡើង តាំងពីអភិនិហារបំពេញព្រះបារមី រហូតដល់ពោធិបល្ល័ង្ក ឬអរហត្តមគ្គញាណ តែកាលសម្រេចអរហត្តផល ឈ្មោះថា បានកើតឡើងហើយ ។ បទថា **អរហំ សម្មាសម្ពុទ្ធោ** (ជាព្រះអរហន្ត ត្រាស់ដឹងឯងដោយប្រពៃ) ជាអាទិ៍ លោកអធិប្បាយទុកពិស្តារហើយក្នុងនិទ្ទេស ពោលដោយពុទ្ធានុស្សតិ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **ឥតិ សក្កាយោ** (សក្កាយៈដូច្នេះ) សេចក្តីថា នេះជាសក្កាយៈ គឺ ប្រមាណប៉ុណ្ណេះជាសក្កាយៈ ក្រៅពែងជាងនេះមិនមាន ឧបាទានក្ខន្ធ ៥ លោកសម្តែងហើយដោយសភាវៈ ដោយកិច្ច ដោយទីបំផុត ដោយកំណត់ ដោយផ្លូវ ដោយហេតុប្រមាណប៉ុណ្ណេះ ។ បទថា **ឥតិ សក្កាយស្ស សមុ-ទយោ** (សក្កាយសមុទ័យដូច្នេះ) បានដល់ នេះឈ្មោះសក្កាយសមុទ័យ ។ បទមានជាអាទិ៍ថា "ព្រោះអាហារកើត រូបទើបកើត" ក៏លោកសម្តែងហើយដោយហេតុប្រមាណប៉ុណ្ណេះ ។ បទថា **ឥតិ សក្កាយស្ស អត្ថង្គមោ** (សក្កាយ

និរោធដូច្នេះ) សេចក្ដីថា នេះជាសក្កាយនិរោធ រលត់សក្កាយៈ ។ បទមានជាអាទិ៍ថា "ព្រោះអាហាររលត់ រូបទើបរលត់" ទាំងអស់ លោកសម្ដែងហើយដោយបទសូម្បីនេះ ។ បទថា **វណ្ណវន្តោ** (មានពណ៌សម្បុរស្អាត) បានដល់ អ្នកមានវណ្ណៈស្អាត ដោយវណ្ណៈនៃសរីរៈ ។ បទថា **ធម្មទេសនំ សុត្វា** (ស្ដាប់ព្រះធម៌ទេសនា... ហើយ) សេចក្ដីថា ទេវតាទាំងនោះបានស្ដាប់ព្រះធម៌ទេសនារបស់ព្រះតថាគត ដែលប្រដាប់ដោយលក្ខណៈ ៥០ ក្នុងបញ្ចក្ខន្ធ ។ បទថា **យេភុយ្យេន** (ដោយច្រើន) សេចក្ដីថា សួរថា វៀរទេវតាពួកណាក្នុងទីនេះ ។ ឆ្លើយថា វៀរទេវតាដែលជាអរិយសាវក ។ ក៏ព្រោះទេវតាដែលជាអរិយសាវកទាំងនោះ មិនកើតសេចក្ដីភ័យខ្លាច ដោយសេចក្ដីតក់ស្លុតនៃចិត្ត ព្រោះលោកអស់អាសវៈហើយ ។ សេចក្ដីសង្វេគដោយញាណ រមែងកើតឡើងដល់លោកអ្នកសង្វេគហើយ ព្រោះលោកបានសម្រេចធម៌ដែលគប្បីសម្រេច ដោយសេចក្ដីព្យាយាមដ៏ប្រពៃក៏មាន ។ ការភ័យខ្លាចដោយសេចក្ដីតក់ស្លុត រមែងកើតឡើងដល់ពួកទេវតាទាំងនេះ បុគ្គលធ្វើទុកក្នុងចិត្តដល់សេចក្ដីមិនទៀងក៏មាន ការភ័យខ្លាចដោយញាណ រមែងកើតឡើងក្នុងវេលាវិបស្សនាមានកម្លាំងក៏មាន ។ បទថា **ភោ** (លោកដ៏ចម្រើនទាំងឡាយ) នោះត្រឹមតែជាពាក្យហៅដោយធម៌ ។ បទថា **សក្កាយ-**

**បរិបន្នា** (អ្នករាប់ចូលក្នុងសក្កាយៈ) បានដល់ រាប់បញ្ចូលទៅក្នុងខន្ធ ៥ ។ ដូច្នោះ កាលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងទោសក្នុងវដ្តៈហើយ ទ្រង់សម្តែងធម៌ នាំត្រៃលក្ខណ៍មក ទេវតាទាំងនោះ ក៏កើតការភ័យខ្លាចដោយញាណ ដោយប្រការដូច្នេះ ។

បទថា **អភិញ្ញាយ** (ត្រាស់ដឹងក្រៃលែង) គឺ ទ្រង់ដឹងហើយ ។ បទថា **ធម្មចក្កំ** (ធម្មក្ក) បានដល់ បដិវេធញ្ញាណខ្លះ ទេសនាញាណខ្លះ ។ ព្រះពុទ្ធប្រថាប់ត្រង់ពោធិបល្ល័ង្ក ទ្រង់ត្រាស់ដឹងសច្ចៈ ៤ ព្រមដោយអាការ ១៦ រហូតដល់ពាន់ន័យ ដោយព្រះញាណណា ព្រះញាណនោះ ឈ្មោះថា **បដិវេធញ្ញាណ** ។ ទ្រង់ប្រកាសព្រះធម្មចក្ក មានបរិវដ្តៈ ៣ អាការ ១២ ដោយព្រះញាណណា ព្រះញាណនោះ ឈ្មោះថា **ទេសនាញាណ** ។ ញាណទាំង ២ យ៉ាងនោះ ជាញាណដែលកើតក្នុងគ្រាដំបូងដល់ព្រះទសពល ។ ក្នុងញាណទាំង ២ នោះ គួរកាន់យកធម្មទេសនាញាណ ក៏ធម្មទេសនាញាណនោះ ឈ្មោះថា **រមែងប្រព្រឹត្តទៅហើយ** ដរាបពេលដែលសោតាបត្តិផលមិនទាន់កើតឡើងដល់ព្រះអញ្ញាកោណ្ឌញ្ញត្ថេរៈ ព្រមដោយព្រហ្ម ១៨ កោដិ កាលសោតាបត្តិផលនោះកើតឡើងហើយ គប្បីជ្រាបថា ធម្មទេសនាញាណ ឈ្មោះថា **ប្រព្រឹត្តទៅហើយ** ។ បទថា **អប្បដិបុគ្គលោ** (រកបុគ្គលប្រៀប

*មិនបាន) គឺ វៀរបុគ្គលដែលនឹងប្រៀបផ្ទឹម ។ បទថា* **យសស្សិនោ** *(មានយស) គឺ ដល់ព្រមដោយបរិវារ ។ បទថា* **តាទិនោ** *(តាទិបុគ្គល) គឺ ជាបុគ្គលមានលក្ខណៈតែម្យ៉ាងដូចគ្នាក្នុងលោកធម៌ មានលាភ និងអត់លាភជាដើម ។*

ចប់អដ្ឋកថា សីហសូត្រទី ៣

# អដ្ឋកថា បសាទសូត្រទី ៤

## *“សេចក្តីជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បសាទសូត្រទី ៤ ដូចតទៅនេះ ៖*

[៣៤] *បទថា* ***អគ្គប្បសាទា*** *(សេចក្តីជ្រះថ្លាដ៏ប្រសើរ) ព្រោះអត្ថថា ជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ ឬសេចក្តីជ្រះថ្លាដ៏ប្រសើរ ។ បទថា* ***យាវតា*** *(មានប្រមាណប៉ុន្មាន) គឺ មានចំនួនប៉ុន្មាន ។ បទថា* ***អបទា*** *(មិនមានជើង) បានដល់ ពួកសត្វមិនមានជើង មានពស់ និងត្រីជាដើម ។ បទថា* ***ទ្វិបទា*** *(ជើង ២) បានដល់ ពួកសត្វជើង ២ មានមនុស្ស និងសត្វបក្សីជាដើម ។ បទថា* ***ចតុប្បទា*** *(ជើង ៤) បានដល់ សត្វជើង ៤ មានដំរី និងសេះជាដើម ។ បទថា* ***ពហុប្បទា*** *(ជើងច្រើន) បានដល់ ពួកសត្វជើងច្រើន មានក្អែបជាដើម ។ បទថា* ***នេវសញ្ញិនាសញ្ញិនោ*** *(មានសញ្ញាក៏មិនមែនមិនមានសញ្ញាក៏មិនមែន) បានដល់ ពួកសត្វដែលកើតក្នុងភវគ្គព្រហ្ម ។ បទថា* ***អគ្គមក្ខាយតិ*** *(អ្នកប្រាជ្ញពោលថា ដ៏ប្រសើរ) សេចក្តីថា ព្រះតថាគត អ្នកប្រាជ្ញពោលថា ជាកំពូល គឺ ប្រសើរបំផុត ដោយគុណទាំងឡាយ ។ បទថា* ***អសង្ខតា*** *(ជាអសង្ខតៈ) សេចក្តីថា លោកពោលកាន់យកព្រះនិព្វានប៉ុណ្ណោះ ។ បទមានជាអាទិ៍ថា* ***វិរាគោ*** *(វិរាគៈ) ជាឈ្មោះរបស់ព្រះនិព្វាននោះឯង ។ ព្រោះ*

ថា កិលេសទាំងឡាយមកដល់ព្រះនិព្វាននោះហើយ ក៏វិនាសអស់ សេចក្តីស្រវឹងទាំងឡាយ មានសេចក្តីស្រវឹងព្រោះរាគៈជាដើម ក៏វិនាសទៅ គឺមិនមាន សេចក្តីស្រេកឃ្លានទាំងឡាយ ក៏វិនាសទៅ អាល័យទាំងឡាយក៏ដកចេញបាន វដ្តៈទាំងឡាយក៏ដាច់ តណ្ហាក៏អស់ វដ្តទុក្ខក៏រលត់ សេចក្តីក្តៅក្រហាយទាំងពួងក៏រលត់ ព្រោះដូច្នោះ និព្វាន ទើបបានឈ្មោះទាំងនោះឯង ។ បទដ៏សេសក្នុងសូត្រនេះ ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា បសាទសូត្រទី ៤

# អដ្ឋកថា វស្សការសូត្រទី ៥

## "វស្សការព្រាហ្មណ៍"

គប្បីជ្រាបវិនិច្ឆ័យក្នុង វស្សការសូត្រទី ៥ ដូចតទៅនេះ ៖

[៣៦] បទថា **អនុស្សរិត** (រឭករឿយៗ) បានដល់ តាមរឭកដល់ ។ អធិប្បាយថា ជាអ្នកអាចរឭកដល់រឿងកន្លងតៗ គ្នាមកបាន ។ បទថា **ទក្ខោ** គឺ ជាបុគ្គលអ្នកឆ្លាតឈ្លាស ។ បទថា **តត្រុបាយាយ** (ដែលជាឧបាយ... ក្នុងកិច្ចការទាំងនោះ) សេចក្តីថា បុគ្គលប្រកបដោយបញ្ញា ដែលជាឧបាយក្នុងកិច្ចនោះៗ បានយ៉ាងនេះថា "ក្នុងវេលានេះគួរធ្វើកិច្ចនេះ" ។ បទថា **អនុមោទិតព្វំ** (គួរអនុមោទនា) បានដល់ ទ្រង់គួរត្រេកអរ ។ បទថា **បដិក្កោសិតព្វំ** បានដល់ គួរជំទាស់ ។ បទថា **នេវ ខោ ត្យាហំ** (តថាគតមិន... ដល់អ្នក) បានដល់ តថាគតមិនអនុមោទនាដល់អ្នក ។ សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទ្រង់ទើបមិនត្រេកអរ ទ្រង់មិនជំទាស់ក្នុងសេចក្តីនោះ ។ ឆ្លើយថា ព្រះអង្គទ្រង់មិនត្រេកអរ ព្រោះជាលោកិយៈ ទ្រង់មិនជំទាស់ ព្រោះកាន់យកប្រយោជន៍ដែលជាលោកិយៈបាន ។ បទថា **ពហុស្ស ជនតា** (ប្រជុំជនដ៏ច្រើន) កាត់បទជា **ពហុ អស្ស ជនតា** ។ ក៏បទនេះ គប្បីជ្រាបថា ជាឆដ្ឋីវិភត្តិប្រើក្នុងអត្ថតតិយាវិភត្តិ ។ បទថា **អរិយេ ញាយេ** (ក្នុង

ញេយ្យធម៌ដ៏ប្រសើរ) គឺ ក្នុងមគ្គព្រមដោយវិបស្សនា ។ បទថា **កល្យាណធម្មតា កុសលធម្មតា** (ភាពជាបុគ្គលមានធម៌ស្អាត ភាពជាបុគ្គលមានធម៌ជាកុសល) ជាឈ្មោះរបស់មគ្គនោះឯង ។ បទថា **យំ វិតក្កំ** (ត្រិះរិះរឿងណា) សេចក្តីថា ត្រិះរិះបណ្តានេក្ខម្មវិតក្កៈជាដើមណាមួយ ។ បទថា **ន តំ វិតក្កំ វិតក្កេតិ** (មិនត្រិះរិះរឿងនោះ) សេចក្តីថា មិនត្រិះរិះបណ្តាកាមវិតក្កៈជាដើម សូម្បីវិតក្កណាមួយ ។ បទក្រៅពីនេះ ជាវេវចនៈរបស់បទថា **វិតក្ក** នោះឯង ។ វិតក្កៈក្នុងបទថា **វិតក្កបថេសុ** (ក្នុងគន្លងនៃការត្រិះរិះទាំងឡាយ) នេះ បានដល់ ផ្លូវនៃវិតក្កៈ ។ ក្នុងបទមានជាអាទិ៍ថា **អហំ ហិ ព្រាហ្មណ** (ព្រាហ្មណ៍ តថាគត) គប្បីជ្រាបថា ដោយន័យទីមួយ ទ្រង់ត្រាស់ដល់សីល និងពហុសច្ចៈរបស់ព្រះខីណាស្រព ដោយន័យទីពីរ និងទីបី ទ្រង់ត្រាស់ដល់កិរិយាវិតក្កៈ (វិតក្កៈកើតពីកិរិយា) និងកិរិយាឈាន (ឈានដែលកើតពីកិរិយា) របស់ព្រះខីណាស្រព ។ ដោយន័យទីបួន ទ្រង់ត្រាស់ដល់ភាពជាព្រះខីណាស្រព ។

បទថា **មច្ចុបាសា បមោចនំ** (ផ្លូវរួចផុតចាកអន្ទាក់មច្ចុ) គឺ ផ្លូវជាទីរួចផុតពីអន្ទាក់នៃមច្ចុ ។ បទថា **ញាយំ ធម្មំ** (ញេយ្យធម៌) គឺ មគ្គព្រមដោយវិបស្សនា ។ បទថា **ទិស្វា ច សុត្វា ច** (ឃើញ... និងបានស្តាប់)

សេចក្ដីថា បានឃើញ និងបានស្ដាប់ហើយដោយញាណនោះឯង ។ បទដ៏សេសក្នុងសូត្រនេះ ងាយទាំងអស់ហើយ ។

ចប់អដ្ឋកថា វស្សការសូត្រទី ៥

# អដ្ឋកថា ទោណសូត្រទី ៦

## *"ទោណព្រាហ្មណ៍ទូលសួរបញ្ហា"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទោណសូត្រទី ៦ ដូចតទៅនេះ ៖*

[៣៧] *ក្នុងបទថា* ***អន្តរា ច ឧក្កដ្ឋំ អន្តរា ច សេតព្យំ*** *(ចន្លោះក្រុងឧក្កដ្ឋៈ និងក្រុងសេតព្យៈ) នេះ បទថា* ***ឧក្កដ្ឋា*** *(ក្រុងឧក្កដ្ឋៈ) បានដល់នគរដែលគេហៅឈ្មោះយ៉ាងនេះ ព្រោះគេតាំងគប់ភ្លើងដែលសាងហើយ ។ បទថា* ***សេតព្យំ*** *(ក្រុងសេតព្យៈ) បានដល់ នគរជាទីកើតរបស់ព្រះកស្សបសម្មាសម្ពុទ្ធគ្រាអតីត ។ ចំណែក* ***អន្តរា*** *ស័ព្ទ ប្រើក្នុងអត្ថថា ហេតុ ខណៈ ចិត្ត កណ្តាល និងចន្លោះ ។ ប្រើក្នុងអត្ថថា* ***ហេតុ*** *បានក្នុងបាលីជាអាទិ៍ថា* ***តទនន្តរំ កោ ជានេយ្យ អញ្ញត្រ តថាគតា*** *(នរណាហ្ន៎ នឹងគប្បីដឹងនូវហេតុនោះ ក្រៅពីតថាគត) , និងថា* ***ជនា សង្គម្ម មន្តេន្តិ មញ្ច តញ្ច កិមន្តរំ*** *(ពពួកជនប្រជុំប្រឹក្សា តថាគត និងលោកហេតុអ្វី) ។ ប្រើក្នុងអត្ថថា* ***ខណៈ*** *បានក្នុងបាលីមានជាអាទិ៍ថា* ***អទ្ទសា មំ ភន្តេ អញ្ញតរា ឥត្ថី វិជ្ជន្តរិកាយ ភាជនំ ធោវន្តី*** *(លោកម្ចាស់ ស្ត្រីម្នាក់កំពុងលាងភាជនៈក្នុងខណៈផ្លេកបន្ទោរ ក៏ឃើញយើង) ។ ប្រើក្នុងអត្ថថា* ***ចិត្ត*** *បានក្នុងបាលីមានជាអាទិ៍ថា* ***យស្សន្តរតោ ន សន្តិ កោបា*** *(សេចក្តីចង្អៀតចង្អល់រមែង*

មិនមាន អំពីចិត្តរបស់បុគ្គលណា) ។ ប្រើក្នុងអត្ថថា កណ្តាល បានក្នុងបាលីជាអាទិ៍ថា **អន្តរា វោសានមាបាទិ** (ដល់នូវការបញ្ចប់ត្រង់កណ្តាល) ។ ប្រើក្នុងអត្ថថា ចន្លោះ បានក្នុងបាលីមានជាអាទិ៍ថា **អបិ ចាយំ តបោទា ទ្វិន្នំ មហានិរយានំ អន្តរិកាយ អាគច្ឆតិ** (មួយទៀត ស្រះទឹកតបោទានេះ រមែងហូរកាត់ចន្លោះមហានរកទាំងពីរ) ។ **អន្តរា** សព្ទនេះ ក្នុងទីនេះ ប្រើក្នុងអត្ថថា ចន្លោះ ព្រោះដូច្នោះ គប្បីឃើញសេចក្តីក្នុងពាក្យនេះ យ៉ាងនេះថា ក្នុងចន្លោះនគរឧក្កដ្ឋៈ និងនគរសេតព្យៈ ។ លោកធ្វើជាទុតិយាវិភត្តិ ព្រោះប្រកបដោយ **អន្តរា** សព្ទ ។ ចំណែកពួកអាចារ្យអ្នកគិតអក្ខរៈក្នុងឋានៈរមែងប្រកប អន្តរា សព្ទ ម្យ៉ាងក្នុងពាក្យនេះ យ៉ាងនេះថា **អន្តរា គាមញ្ច នទិញ្ច យាតិ** (បុគ្គលដើរទៅក្នុងចន្លោះស្រុក និងស្ទឹង) ។ **អន្តរា** សព្ទនោះ គប្បីប្រកបសូម្បីដោយបទទីពីរ កាលមិនប្រកប ក៏មិនជារូបទុតិយាវិភត្តិ តែក្នុងទីនេះ លោកប្រកបហើយ ទើបពោលទុកយ៉ាងនេះ ។

បទថា **អទ្ធានមគ្គប្បដិបន្នោ ហោតិ** គឺ ទ្រង់ទៅផ្លូវឆ្ងាយ អធិប្បាយថា ផ្លូវវែង ។ សួរថា ទ្រង់ទៅផ្លូវឆ្ងាយ ព្រោះហេតុអ្វី ។ ឆ្លើយថា បានឮថា ក្នុងថ្ងៃនោះ ព្រះមានព្រះភាគ ទ្រង់បានឃើញហេតុយ៉ាងនេះថា កាលតថាគតដើរទៅផ្លូវនោះ ទោណព្រាហ្មណ៍ឃើញចេតិយ គឺ ស្នាមជើងរបស់

តថាគត ក៏នឹងតាមស្នាមជើងមកដល់ទីដែលតថាគតអង្គុយ ហើយសួរបញ្ហា បើដូច្នោះ តថាគតនឹងសម្តែងសច្ចធម៌ដល់គេយ៉ាងនេះ ព្រាហ្មណ៍នឹងត្រាស់ដឹងសាមញ្ញផលបីបាន ហើយនឹងពណ៌នាគុណ ឈ្មោះទោណគជ្ជិតៈ មួយម៉ឺនពីរពាន់បទ កាលតថាគតបរិនិព្វានហើយ នឹងរម្ងាប់ការឈ្លោះយ៉ាងធំដែលកើតឡើងទូទាំងជម្ពូទ្វីប ហើយទើបបែងចែកព្រះធាតុទាំងឡាយដល់គ្នា ទើបទ្រង់ធ្វើដំណើរដោយហេតុនេះ ។

បទថា **ទោណោបិ សុទំ ព្រាហ្មណោ** (សូម្បីទោណព្រាហ្មណ៍) សេចក្តីថា សូម្បីទោណព្រាហ្មណ៍ជំនាញត្រៃវេទ កាលទូន្មានសិល្បៈចំពោះពួកមាណព ៥០០ នាក់ ក្នុងថ្ងៃនោះ ក្រោកឡើងពីព្រឹកព្រលឹម ធ្វើសរីរៈកិច្ចស្រេចហើយ ស្លៀកសំពត់តម្លៃ ១០០ ប្រើប្រាស់របស់មានតម្លៃ ៥០០ បំពាក់ដោយយ័ញ្ញ ពាក់ស្បែកជើងខ្សែក្រហម មានមាណព ៥០០ ហែហមបានដើរទៅផ្លូវនោះដូចគ្នា ។ ពាក្យនេះលោកពោលសំដៅដល់ប្រការនោះ ។ បទថា **បាទេសុ** (ស្នាមព្រះបាទ) បានដល់ ក្នុងស្នាមដែលទ្រង់ជាន់ដោយព្រះបាទ ។ បទថា **ចក្កានិ** (ចក្ក) បានដល់ ចក្កលក្ខណៈ (រូបចក្រ) ។ សួរថា កាលព្រះមានព្រះភាគ ទ្រង់ដំណើរទៅ ស្នាមព្រះបាទប្រាកដក្នុងទីដែលទ្រង់ជាន់ទុកឬ ។ ឆ្លើយថា មិនប្រាកដទេ ។ ព្រោះអ្វី ។ ព្រោះស្នាម

ព្រះបាទល្អិត មានកម្លាំងច្រើន និងព្រោះទ្រង់អនុគ្រោះមហាជន ។

ពិតហើយ ព្រះពុទ្ធទាំងឡាយ ទ្រង់មានព្រះឆវីល្អិត ស្នាមទីទ្រង់ជាន់ដូចជាស្ថានទីសំឡឹក ស្នាមព្រះបាទទើបមិនប្រាកដ ។ ស្នាមដែលតថាគតទ្រង់ជាន់ ក៏ត្រឹមតែជាន់ប៉ុណ្ណោះ ស្នាមព្រះបាទទើបមិនប្រាកដក្នុងទីនោះ ព្រោះព្រះអង្គទ្រង់មានកម្លាំងច្រើន ដូចស្នាមជើងរបស់សេះសិន្ធព មានសន្ទុះជើងរហ័សដូចខ្យល់ ព្រោះមានកម្លាំង ជាន់សូម្បីលើស្លឹករបស់បទុម ក៏ត្រឹមតែជាន់ប៉ុណ្ណោះ ដូច្នោះ ។ ចំណែកពួកមហាជន ដើរតាមស្នាមព្រះបាទរបស់ព្រះពុទ្ធទាំងឡាយទៅ កាលមហាជននោះ ឃើញស្នាមព្រះបាទរបស់ព្រះសាស្តា ក៏មិនអាចនឹងដើរជាន់ គប្បីដើរគេចចេញទៅ ។ ព្រោះដូច្នោះ ស្នាមព្រះបាទ សូម្បីមានក្នុងទីដែលទ្រង់ជាន់ហើយ ស្នាមព្រះបាទនោះក៏វិនាសទៅក្លាម ។ ចំណែកទោណព្រាហ្មណ៍បានឃើញ ដោយអំណាចការអធិដ្ឋានរបស់ព្រះតថាគត សូម្បីព្រះមានព្រះភាគ កាលទ្រង់បំណងនឹងសម្តែងចេតិយ គឺ ព្រះបាទដល់បុគ្គលណា ប្រារព្ធដល់បុគ្គលនោះ ទ្រង់អធិដ្ឋានថា “បុគ្គលឈ្មោះឯណោះ ចូរឃើញ” ព្រោះដូច្នោះ សូម្បីព្រាហ្មណ៍នេះបានឃើញ ក៏ដោយអំណាចការអធិដ្ឋានរបស់ព្រះតថាគត ដូចមាគណ្ឌិយព្រាហ្មណ៍ ។

បទថា **បាសាទិកំ** (គួរជ្រះថ្លា) គឺ ឲ្យកើតសេចក្ដីជ្រះថ្លា ។ បទក្រៅពីនេះ ក៏ជាវេវចនៈរបស់បទថា **គួរជ្រះថ្លា** នោះឯង ។ ក្នុងបទថា **ឧត្តម-ទមថសមថមនុប្បត្តំ** (បានទទួលការហ្វឹកហាត់ និងសេចក្ដីស្ងប់ដ៏ឧត្ដម) នេះ គប្បីជ្រាបដូច្នេះ អរហត្តមគ្គ ឈ្មោះថា ការហ្វឹកហាត់ដ៏ខ្ពង់ខ្ពស់ អរហត្ត-មគ្គសមាធិ ឈ្មោះថា សេចក្ដីស្ងប់ដ៏ឧត្ដម អធិប្បាយថា ទ្រង់សម្រេចទាំងពីរយ៉ាងនោះ ។ បទថា **ទន្តំ** (មានខ្លួនទូន្មានហើយ) គឺ អស់អស្មិមានះ ។ បទថា **គុត្តំ** (រក្សាហើយ) គឺ ឃុំគ្រង ។ បទថា **យតិន្ទ្រិយំ** (មានឥន្ទ្រិយរក្សាហើយ) គឺ រក្សាឥន្ទ្រិយ ។ បទថា **នាគំ** (ជាបុគ្គលប្រសើរ) សេចក្ដីថា ឈ្មោះថា **ប្រសើរ** ព្រោះហេតុ ៤ គឺ ព្រោះមិនលុះអគតិ មានឆន្ទាគតិជាដើម ១ ព្រោះមិនត្រឡប់មកកាន់កិលេសដែលលះបានហើយ ១ ព្រោះមិនធ្វើបាប ១ ព្រោះអត្ថថាមានកម្លាំង ១ ។ ក្នុងបទថា **ទេវោ នោ ភវំ ភវិស្សតិ** (តថាគតមិនមែនទេវតា) នេះ ក៏ការសួរ គប្បីបញ្ចប់ដោយពាក្យមានប្រមាណប៉ុណ្ណេះថា "លោកដ៏ចម្រើន ជាទេវតាឬ" តែព្រាហ្មណ៍នេះកាលសួរដោយអនាគតកាលថា "លោកជាទេវរាជមួយអង្គ មានសក្ដិធំក្នុងអនាគតកាលទេដឹង" ទើបពោលយ៉ាងនោះ ។ សូម្បីព្រះមានព្រះភាគ កាលត្រាស់ដោយល្អ ដោយពាក្យសួររបស់ព្រាហ្មណ៍នោះ ទើបត្រាស់ថា តថាគត

មិនមែនជាទេវតាទេ ព្រាហ្មណ៍ ។ ក្នុងបទគ្រប់បទក៏ន័យនេះ ។ បទថា **អាសវា** (អាសវៈ) បានដល់ អាសវៈ ៤ មានកាមាសវៈជាដើម ។ បទថា **បហីនា** (លះបានហើយ) សេចក្តីថា អាសវៈទាំងនោះតថាគតលះបានហើយ ដោយការសម្រេចនូវសព្វញ្ញុតញ្ញាណត្រង់ពោធិបល្ល័ង្ក ។ បទថា **អនុបលិត្តោ លោកេន** (មិនបានជាប់ជំពាក់ដោយលោក) សេចក្តីថា លោក គឺ សង្ខារលោកចូលមកលាបចិត្តតថាគតមិនបាន ព្រោះតថាគតលះគ្រឿងលាប គឺ តណ្ហា និងទិដ្ឋិចេញហើយ ។ បទថា **ពុទ្ធោ** (ពុទ្ធៈ) សេចក្តីថា លោកចូរចាំយើងទុកថា ជាព្រះពុទ្ធ ព្រោះត្រាស់ដឹងសច្ចៈ ៤ ដូច្នេះ ។

បទថា **យេន** (ព្រោះអាសវៈណា) គឺ ព្រោះកិលេសជាគ្រឿងសៅហ្មងណា ។ បទថា **ទេវុបបត្យស្ស** (កំណើតជាទេវតា) សេចក្តីថា តថាគតនឹងគប្បីបានកំណើតជាទេវតា ។ បទថា **វិហង្គមោ** (អ្នកហោះហើរបាន) បានដល់ ទេវតាពួកគន្ធព្វអ្នកហោះហើរបាន ។ បទថា **វិទ្ធស្តា** (ទំលាយ) ប្រែថា កម្ចាត់ហើយ ។ បទថា **វិនឡីកតា** (ធ្វើឲ្យដាច់ខ្សែហើយ) បានដល់ ធ្វើឲ្យប្រាសចាកគ្រឿងប្រកប គឺ ប្រាសចាកគ្រឿងចង ។ បទថា **តោយេននុបលិប្បតិ** (មិនជាប់ដោយទឹក) សេចក្តីថា ផ្កាឈូកសដែលដុះឡើងផុតពីទឹក ប្រហែលមួយហត្ថដែលធ្វើឲ្យស្រះល្អ ធ្វើហ្វូងកមរៈឲ្យរីករាយ ទឹក

*ជាប់មិនបាន ។ បទថា **តស្មា ពុទ្ធោស្មិ ព្រាហ្មណ** (ព្រាហ្មណ៍... ព្រោះដូច្នោះ តថាគតទើបជាព្រះពុទ្ធ) សេចក្តីថា វេលាចប់ទេសនា ព្រាហ្មណ៍ក៏សម្រេចផលបី ហើយទើបពោលគុណ ឈ្មោះថា **ទោណគជ្ជិតៈ** (សំឡេងគ្រហឹមរបស់ទោណព្រាហ្មណ៍) ដោយគាថា ១២.០០០ បទ ក៏កាលព្រះតថាគតបរិនិព្វានហើយ ទោណព្រាហ្មណ៍រម្ងាប់ជម្លោះយ៉ាងធំ ដែលកើតឡើងទូទាំងដែនជម្ពូទ្វីបហើយ ទើបបានបែងចែកព្រះធាតុទាំងឡាយដល់គ្នា ដូចពណ៌នាមកនេះ ។*

ចប់អដ្ឋកថា ទោណសូត្រទី ៦

# អដ្ឋកថា អបរិហានិយសូត្រទី ៧

## *"អបរិហានិយធម៌ ៤"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អបរិហានិយសូត្រទី ៧ ដូចតទៅនេះ ៖*

*[៣៨] បទថា **និព្វានស្សេវ សន្តិកេ** (បដិបត្តិជិតព្រះនិព្វានតែម្យ៉ាង) សេចក្តីថា ភិក្ខុប្រព្រឹត្តនៅក្នុងទីជិតព្រះនិព្វាននោះឯង ។ បទថា **សីលេ បតិដ្ឋិតោ** (តាំងនៅក្នុងសីល) បានដល់ ភិក្ខុតាំងនៅក្នុងបាតិមោក្ខសីល ។ បទថា **ឯវំវិហារី** (នៅយ៉ាងនេះ) បានដល់ កាលនៅយ៉ាងនេះ ។ បទថា **អាតាបី** (ជាអ្នកមានសេចក្តីព្យាយាម) គឺ បុគ្គលប្រកបដោយសេចក្តីព្យាយាម ដែលជាគ្រឿងដុតកិលេស ។ បទថា **យោគក្ខេមស្ស** (គុណដ៏ក្សេមចាកយោគៈ) សេចក្តីថា ដើម្បីសម្រេចគុណដ៏ក្សេមចាកយោគៈ ៤ គឺ ព្រះនិព្វាន ។ បទថា **បមាទេ ភយទស្សិ វា** (ឃើញភ័យក្នុងសេចក្តីប្រមាទដោយប្រក្រតី) បានដល់ ឃើញសេចក្តីប្រមាទថាជាភ័យ ។*

ចប់អដ្ឋកថា អបរិហានិយសូត្រទី ៧

# អដ្ឋកថា បដិលីនសូត្រទី ៨

## "ភិក្ខុអ្នកពួនសម្ងំ"

គប្បីជ្រាបវិនិច្ឆ័យក្នុង បដិលីនសូត្រទី ៨ ដូចតទៅនេះ ៖

[៣៩] បទថា **បនុណ្ណបច្ចេកសច្ចោ** (អ្នកមានបច្ចេកសច្ចៈបន្ទោបង់ហើយ) បានដល់ ភិក្ខុឈ្មោះថា អ្នកមានបច្ចេកសច្ចៈដែលបន្ទោបង់បានហើយ ព្រោះថា ទិដ្ឋិសច្ចៈ ពោលគឺ សេចក្ដីឃើញផ្សេងពីគ្នា ព្រោះប្រកាន់ការឃើញតែម្យ៉ាង យ៉ាងនេះថា ការឃើញនេះប៉ុណ្ណោះពិត នេះប៉ុណ្ណោះពិត លោកបន្ទោបង់ គឺ កម្ចាត់បានហើយ ។ ក្នុងបទថា **សមវយសដ្ឋេសនោ** (ភិក្ខុលះការស្វែងរកដោយសព្វគ្រប់) នេះ បទថា **សមវយ** (សព្វគ្រប់) បានដល់ មិនខ្វះខាត ។ បទថា **សដ្ឋា** (លះបង់) បានដល់ លះបង់ហើយ ។ ឈ្មោះថា **ភិក្ខុលះបង់ការស្វែងរកដោយសព្វគ្រប់** ព្រោះលះបង់ការស្វែងរកដោយអស់ជើង អធិប្បាយថា ភិក្ខុលះការស្វែងរកទាំងអស់គ្រប់យ៉ាងដោយប្រពៃ ។ បទថា **បដិលីនោ** (ភិក្ខុអ្នកពួនសម្ងំ) បានដល់ ភិក្ខុអ្នកពួនសម្ងំ គឺ នៅម្នាក់ឯង ។ បទថា **បុថុជ្ជនសមណព្រាហ្មណានំ** (សមណព្រាហ្មណ៍ទាំងឡាយ) បានដល់ សមណៈ និងព្រាហ្មណ៍ដ៏ច្រើន ។ ក្នុងពាក្យថា **សមណ-ព្រាហ្មណ៍** នេះ ក៏អ្នកដែលចូលទៅបួស ឈ្មោះសមណៈ អ្នកដែលពោល

ថា លោកដ៏ចម្រើន ឈ្មោះថា ព្រាហ្មណ៍ ។

បទថា **បុថុប្បច្ចេកសច្ចានិ** (បច្ចេកសច្ចៈច្រើនយ៉ាង) បានដល់ សច្ចៈតែមួយមានច្រើន ។ បទថា **នុណ្ណានិ** (បន្ទោបង់ហើយ) បានដល់ នាំចេញហើយ ។ បទថា **បនុណ្ណានិ** (កម្ចាត់បង់ហើយ) បានដល់ នាំចេញល្អហើយ ។ បទថា **ចត្តានិ** (លះបង់ហើយ) បានដល់ រលាស់ចេញហើយ ។ បទថា **វន្តានិ** (ខ្ជាក់ហើយ) បានដល់ ខ្ជាក់ចេញហើយ ។ បទថា **មុត្តានិ** (ច្បូតចេញហើយ) គឺ ធ្វើគ្រឿងចងឲ្យដាច់ហើយ ។ បទថា **បហីនានិ** (បណ្តេញបង់ហើយ) ប្រែថា លះបានហើយ ។ បទថា **បដិនិស្សដ្ឋានិ** (បំបាក់បង់ហើយ) បានដល់ លះបង់ចោលហើយ ធ្វើមិនឲ្យដុះឡើងក្នុងចិត្តទៀត ។ បទទាំងនេះគ្រប់បទ ជាបទប្រើជំនួសការលះបង់ ដែលសេចក្តីប្រកាន់ បានប្រកាន់ហើយ ។ បទថា **កាមេសនា បហីនា ហោតិ** (ស្វែងរកកាម... លះបង់បានហើយ) បានដល់ ការស្វែងរកកាម ដែលលះបង់បានហើយដោយអនាគាមិមគ្គ ។ ចំណែកការស្វែងរកភព ក៏កំពុងលះដោយអរហត្តមគ្គ សូម្បីការស្វែងរកព្រហ្មចរិយៈ គឺ អជ្ឈាស្រ័យដែលប្រព្រឹត្តទៅហើយ យ៉ាងនេះថា "យើងនឹងស្វែងរកព្រហ្មចរិយៈ" ក៏ស្ងប់រម្ងាប់ទៅដោយអរហត្តមគ្គ ទុំះឯង ។ ចំណែកការស្វែងរកទិដ្ឋិព្រហ្មចរិយៈ ក៏គប្បីនិយាយបានថា រមែង

រម្ងាប់ដោយសោតាបត្តិមគ្គតែម្យ៉ាង ។ បទថា **ឯវំ ខោ ភិក្ខវេ** (ម្នាលភិក្ខុទាំងឡាយ... ដូច្នេះឯង) សេចក្តីថា កាយសង្ខាររម្ងាប់ហើយដោយចតុត្ថជ្ឈានយ៉ាងនេះក៏ឈ្មោះថា ខ្យល់អស្សាសបស្សាសៈស្ងប់ហើយ ។ បទថា **អស្មិមានោ** (អស្មិមានះ) បានដល់ មានះ ៩ យ៉ាងដែលកើតឡើងថា ជាយើង ។

គាថាទាំងឡាយ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ការស្វែងរកនេះ មាន ២ គឺ ការស្វែងរកកាម ការស្វែងរកភព ។ បទថា **ព្រហ្មចរិយេសនា សហ** (ទាំងការស្វែងរកព្រហ្មចរិយៈ) សេចក្តីថា ការស្វែងរកនោះ មាន ៣ គឺ ការស្វែងរកព្រហ្មចរិយៈ រួមទាំងការស្វែងរក ២ នោះ គប្បីតាំងជាគោលទុកក្នុងទីនេះ ហើយប្រកបសេចក្តីជាមួយបទនេះថា **ឯសនា បដិនិស្សដ្ឋា** (លះការស្វែងរក) ។ បទថា **ឥតិ សច្ចបរាមាសោ ទិដ្ឋិដ្ឋានា សមុស្សយា** (ដកសេចក្តីប្រកាន់ថាពិតយ៉ាងនោះ ពិតយ៉ាងនេះ បើករាងកាយដែលជាទីតាំងនៃទិដ្ឋិចេញ) សេចក្តីថា សេចក្តីប្រកាន់ថា ដូច្នេះពិតៗ និងទីតាំងនៃទិដ្ឋិ ពោលគឺ ទិដ្ឋិទាំងឯង សូម្បីគ្រប់យ៉ាង ដែលហៅថា **សមុស្សយា** រាងកាយ ព្រោះកាយ ត្រូវធាតុ ៤ សាងឡើង គឺ លើកឡើងតាំងទុក ។ គប្បីតាំងជាគោលទុកក្នុងទីនេះ ហើយប្រកបសេចក្តីជាមួយបទនេះថា **ទិដ្ឋិដ្ឋានា សមូហតា** (ដកចោលនូវរាងកាយដែលជាទីតាំងនៃទិដ្ឋិ) ។ សួរថា

នរណាលះបង់ការស្វែងរកទាំងនោះ និងនរណាដកនូវទីតាំងនៃទិដ្ឋិទាំងនោះបានហើយ ។ ឆ្លើយថា ភិក្ខុដែលប្រាសចាកតម្រេកទាំងពួងហើយ បានវិមុត្តិព្រោះអស់តណ្ហា ព្រោះថា ភិក្ខុណាប្រាសចាកតម្រេកហើយ ចាករាគៈទាំងពួង ជាអ្នកប្រកបដោយអរហត្តផលវិមុត្តិ ដែលប្រព្រឹត្តទៅព្រោះអស់តណ្ហា គឺ ព្រោះរលត់ស្និទ្ធ ភិក្ខុនោះលះបង់ការស្វែងរកបានហើយ និងដកកាងកាយដែលជាទីតាំងនៃទិដ្ឋិបានហើយ ។ បទថា **ស វេ សន្តោ** (ភិក្ខុនោះឯងជាអ្នកស្ងប់) សេចក្តីថា ភិក្ខុនោះ គឺ យើញបែបនេះ ឈ្មោះថា ស្ងប់ ព្រោះកិលេសស្ងប់ ។ បទថា **បស្សទ្ធោ** (ស្ងប់រម្ងាប់ហើយ) បានដល់ ស្ងប់ហើយដោយកាយបស្សទ្ធិ និងចិត្តបស្សទ្ធិទាំងពីរ ។ បទថា **អបរាជិតោ** (ធ្វើឲ្យចាញ់មិនបាន) សេចក្តីថា ឈ្មោះថា ដែលនរណាៗ ធ្វើឲ្យចាញ់មិនបានព្រោះឈ្នះសព្វកិលេសហើយ ។ បទថា **មានាភិសមយា** (ព្រោះលះមានៈបាន) គឺ ព្រោះលះសេចក្តីប្រកាន់ខ្លួនបាន ។ បទថា **ពុទ្ធោ** (បានត្រាស់ដឹងហើយ) សេចក្តីថា ជាអ្នកត្រាស់ដឹងសច្ចៈទាំង ៤ ។ ព្រោះហេតុនោះទាំងក្នុងព្រះសូត្រនេះ ទាំងក្នុងព្រះគាថា ទើបត្រាស់ដល់ភិក្ខុអ្នកអស់អាសវៈតែម្យ៉ាង ។

ចប់អដ្ឋកថា បដិលីនសូត្រទី ៨

# អដ្ឋកថា ឧជ្ជយសូត្រទី ៩

## "ឧជ្ជយព្រាហ្មណ៍ទូលសួរបញ្ហា"

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧជ្ជយសូត្រទី ៩ ដូចតទៅនេះ ៖*

[៤០] *បទថា* ***សញ្ញាតំ អាបជ្ជន្តិ*** *(ដល់នូវការសម្លាប់) សេចក្ដីថា សត្វទាំងឡាយរមែងត្រូវសម្លាប់ គឺ ស្លាប់ ។ បទថា* ***និច្ចទានំ*** *(និច្ចទាន) បានដល់ សលាកភត្ត ។ បទថា* ***អនុកុលយញ្ញំ*** *(យញ្ញ គឺ ទានដែលឲ្យតាមត្រកូល) សេចក្ដីថា យញ្ញ គឺ ទានដែលបុគ្គលគប្បីបូជា គឺ គប្បីឲ្យដោយអំណាចតគ្នាមកតាមត្រកូលយ៉ាងនេះ ព្រោះជូនតាជាបុព្វបុរសរបស់យើងទាំងឡាយឲ្យហើយ ។*

*ក្នុងបទថា* ***អស្សមេធំ*** *(អស្សមេធៈ) ជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះ យញ្ញ ឈ្មោះថា អស្សមេធៈ ព្រោះក្នុងយញ្ញនេះ គេសម្លាប់សេះ ពាក្យនោះ ជាឈ្មោះរបស់យញ្ញ ដែលនឹងឲ្យសម្បត្តិគ្រប់យ៉ាងមិនមានសល់វៀរលែងតែផែនដី និងមនុស្សទាំងឡាយ ដែលមានគោលបូជា ២១ យ៉ាង ដែលគប្បីបូជាដោយបរិយញ្ញ (យញ្ញពិសេស) ពីរ ។ យញ្ញ ឈ្មោះថា* ***បុរិសមេធំ*** *ព្រោះក្នុងយញ្ញនេះគេសម្លាប់មនុស្ស ពាក្យនោះ ជាឈ្មោះរបស់យញ្ញដែលនឹងឲ្យសម្បត្តិដូចពោលហើយ ក្នុងអស្សមេធៈ ព្រមដោយផែនដី*

ដែលគប្បីបូជាដោយបរិយញ្ញបួន ។ ឈ្មោះថា **សម្មាបាសំ** ព្រោះក្នុងយញ្ញនេះគេធ្វើអន្ទាក់ដោយនឹម ពាក្យនោះជាឈ្មោះរបស់យញ្ញទាំងអស់ ដែលគេធ្វើត្រៃបូជាដោយអន្ទាក់ ត្រង់ឱកាសដែលថ្ងស់នឹមនោះឲ្យធ្លាក់ ហើយដើរថយក្រោយតាំងពីឱកាសដែលមុជចុះក្នុងស្ទឹងសរស្សវតី គប្បីបូជាដោយគោលជាដើម ដែលលើកទៅបានរាល់ៗ ថ្ងៃ ។ ឈ្មោះថា **វាជបេយ្យំ** ព្រោះក្នុងយញ្ញនេះគេផឹកវាជៈ ពាក្យនោះជាឈ្មោះរបស់យញ្ញ ដែលឲ្យនូវសម្បត្តិ ១៧ ប្រភេទ ដែលមានគោលបូជាធ្វើដោយឈើព្នៅ ដែលគប្បីបូជាដោយសត្វបញ្ចីម ១៧ ប្រភេទ ដោយបរិយញ្ញមួយ ។ ឈ្មោះថា **និរគ្គឡំ** ព្រោះក្នុងយញ្ញនេះ មិនមានឈើស្នៀត ពាក្យនោះ ជាឈ្មោះរបស់យញ្ញដែលកំណត់ទុកក្នុងអស្សមេធៈ ហៅឈ្មោះម្យ៉ាងទៀតថា **សព្វមេធំ** ដែលឲ្យសម្បត្តិដូចពោលហើយក្នុងអស្សមេធៈ ព្រមទាំងផែនដី និងមនុស្សទាំងឡាយដែលគប្បីបូជាដោយបរិយញ្ញ ៩ ។

បទថា **មហារម្ភា** (មានការផ្តើមធំ) បានដល់ មានកិច្ចច្រើន មានករណីយច្រើន មួយទៀត ឈ្មោះថា មានការផ្តើមធំ ក៏ព្រោះការចាប់ផ្តើមសម្លាប់សត្វដ៏ច្រើន ។ ក្នុងបទថា **ន តេ ហោន្តិ មហប្ផលា** (មហាយញ្ញទាំងនោះមិនមានផលច្រើន) នេះ លោកសរុបផលរបស់យញ្ញ ដែលមាន

ចំណែកនៅសល់ ក្នុងអត្ថន័យថា មិនមានចំណែកនៅសល់ ព្រោះដូច្នោះ ទើបមានអធិប្បាយថា ពោលដោយផលដែលគួរប្រាថ្នា ក៏មិនមានផលឡើយ ។ ក៏បទនោះ លោកពោលសំដៅដល់ការផ្តើម ដោយបាណាតិបាតនុ៎ះឯង ។ ចំណែកទានណា ដែលគេឲ្យក្នុងចន្លោះនៃយញ្ញនោះ ទាននោះ រមែងមានផលមិនច្រើន ព្រោះត្រូវការផ្តើមនេះចូលទៅកម្ចាត់បង់ហើយ អធិប្បាយថា មានផលតិច ។ បទថា **ហញ្ញរេ** (ត្រូវផ្តាច់ជីវិត) គឺ រមែងត្រូវសម្លាប់ ។ បទថា **យជន្តិ អនុកុលំ សទា** (បូជាតាមត្រកូលជានិច្ច) សេចក្តីថា ជនពួកណារមែងបូជាយញ្ញតាមត្រកូល សូម្បីជនពួកនោះកើតក្នុងខាងក្រោយ ក៏បូជាតាម ព្រោះបុព្វបុរសទាំងឡាយបានបូជាមកហើយ ។ បទថា **សេ-យ្យោ ហោតិ** (រមែងមានតែសេចក្តីល្អ) បានដល់ រមែងវិសេសពិត ។ បទថា **ន បាបិយោ** (មិនមានសេចក្តីអាក្រក់) បានដល់ មិនមានសេចក្តីអាក្រក់ថោកទាបអ្វីឡើយ ។

ចប់អដ្ឋកថា ឧជ្ជយសូត្រទី ៩

# អដ្ឋកថា ឧទាយិសូត្រទី ១០

## *“ឧទាយីព្រាហ្មណ៍ទូលសួរបញ្ហា”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧទាយិសូត្រទី ១០ ដូចតទៅនេះ ៖*

[៤១] *បទថា* ***អភិសង្ខតំ*** *(ដែលចាត់ចែងទុកយ៉ាងល្អ) គឺ ធ្វើឲ្យជាគំនរ ។ បទថា* ***និរារម្ភំ*** *(ដែលមិនមានការផ្តើមច្រើន) គឺ វៀរចាកការសម្លាប់សត្វ ។ បទថា* ***យញ្ញំ*** *(យញ្ញ) គឺ ទេយ្យធម៌ ។ ពិតណាស់ ទេយ្យធម៌នោះ គេហៅថា យញ្ញ ព្រោះគេគប្បីបូជា ។ បទថា* ***កាលេន*** *(តាមកាល) គឺ តាមកាលដែលគួរ គឺ សមគួរ ។ បទថា* ***ឧបសំយន្តិ*** *(រមែងជាប់ទៅ) គឺ រមែងចូលទៅដល់ ។ បទថា* ***កុលំ គតឹ*** *(ត្រកូល និងគតិ) សេចក្តីថា បុគ្គលឈានកន្លងហើយនូវត្រកូល និងគតិក្នុងវដ្តៈ ។ បទថា* ***បុញ្ញស្ស កោវិទា*** *(បុគ្គលឆ្លាតឈ្លាសក្នុងរឿងបុណ្យ) សេចក្តីថា ការឆ្លាតឈ្លាសក្នុងបុណ្យដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា* ***យញ្ញេ*** *(ក្នុងយញ្ញ) គឺ ក្នុងទានតាមប្រក្រតី ។ បទថា* ***សទ្ធេ*** *(ក្នុងបុណ្យ) គឺ ក្នុងទានឧទ្ទិសដើម្បីអ្នកស្លាប់ ។ បទថា* ***ហុញ្ញំ កត្វា*** *(ចាត់ចែងទេយ្យធម៌ឲ្យជារបស់គួរបូជាតាមសមគួរហើយ) សេចក្តីថា ចាត់ចែងទេយ្យធម៌ឲ្យជារបស់គួរបូជា ។ បទថា* ***សង្ឃេ ព្រហ្មចារិសុ*** *(ក្នុងបុគ្គលអ្នកប្រព្រឹត្តព្រហ្មចារ្យ*

*ទាំងឡាយដែលជាស្រែល្អ) សេចក្តីថា ក្នុងដីស្រែល្អ ពោលគឺ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈ ។ បទថា* ***សម្បត្តំ*** *(សម្បត្តិល្អ) គឺ ដល់ល្អហើយ ។ បទថា* ***ទក្ខិណេយ្យេសុ យំ កតំ*** *(យញ្ញដែលធ្វើក្នុងបុគ្គលជាទក្ខិណេយ្យៈ) សេចក្តីថា យញ្ញដែលសម្រេចក្នុងទក្ខិណេយ្យបុគ្គលដ៏សមគួរ ដែលបុគ្គលបូជាហើយដោយប្រពៃ ។ បទថា* ***សទ្ធោ*** *(មានសទ្ធា) សេចក្តីថា ឈ្មោះថា មានសទ្ធា ព្រោះជឿក្នុងគុណរបស់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ បទថា* ***មុត្តេន ចេតសា*** *(មានចិត្តផុតស្រឡះ) បានដល់ មានចិត្តលះបង់ហើយ ។ ដោយបទនេះ លោកសម្តែងការបរិច្ចាគដោយទឹកចិត្តផុតស្រឡះហើយ ។*

ចប់អដ្ឋកថា ឧទាយិសូត្រទី ១០

## ចប់ចក្កវគ្គទី ៤

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# រោហិតស្សវគ្គទី ៥

## អដ្ឋកថា សមាធិសូត្រទី ១

*"សមាធិភាវនា ៤"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សមាធិសូត្រទី ១ ដូចតទៅនេះ ៖*

*[៤២] បទថា **ញាណទស្សនប្បដិលាភាយ** (ដើម្បីការបាននូវញាណទស្សនៈ) សេចក្តីថា ដើម្បី បានញាណទស្សនៈ គឺ ទិព្វចក្ខុ ។ បទថា **ទិវា សញ្ញំ អធិដ្ឋាតិ** (អធិដ្ឋានទិវាសញ្ញា) សេចក្តីថា រមែងតាំងសេចក្តីកំណត់យ៉ាងនេះថា ពេលថ្ងៃ ដូច្នេះ ។ បទថា **យថា ទិវា តថា រត្តឹ** (ដូចគ្នានោះឯង គឺ ទាំងថ្ងៃទាំងយប់) សេចក្តីថា ធ្វើទុកក្នុងចិត្តដល់អាលោកសញ្ញា ក្នុងវេលាពេលថ្ងៃយ៉ាងណា រមែងធ្វើទុកក្នុងចិត្តដល់អាលោកសញ្ញានោះ សូម្បីក្នុងពេលយប់ក៏ដូច្នោះនុ៎ះឯង ។ សូម្បីក្នុងបទទីពីរ ក៏ន័យនេះដូចគ្នា ។ បទថា **សប្បភាសំ** (ដែលប្រកបដោយពន្លឺ) បានដល់ មានពន្លឺ គឺ ទិព្វចក្ខុញាណ សូម្បីធ្វើចិត្តឲ្យដូចជាពន្លឺបានហើយក៏ពិត ទោះជាយ៉ាងនោះ បណ្ឌិតក៏គប្បីកំណត់សេចក្តីយ៉ាងនេះ ។ តែក្នុងទីនេះ លោកបំណងពន្លឺ គឺ ទិព្វចក្ខុញាណ ។ បទថា **វិទិតា** (ដឹង) បានដល់ ប្រាកដហើយ ។*

សួរថា យ៉ាងណា វេទនាដែលដឹងហើយ ឈ្មោះថាកើតឡើង ដែលដឹងហើយ ឈ្មោះថា រលត់ទៅ ។ ឆ្លើយថា ភិក្ខុក្នុងធម្មវិន័យនេះ រមែងកំណត់វត្ថុ រមែងកំណត់អារម្មណ៍ ព្រោះភិក្ខុនោះកំណត់វត្ថុ និងអារម្មណ៍ហើយ ក៏បានដឹងយ៉ាងនេះថា វេទនាកើតឡើងយ៉ាងនេះ តាំងនៅយ៉ាងនេះ រលត់ទៅយ៉ាងនេះ ឈ្មោះថា កើតឡើងប្រាកដ ឈ្មោះថាតាំងនៅប្រាកដ ឈ្មោះថា រលត់ទៅប្រាកដ ។ សូម្បីក្នុងសញ្ញា និងវិតក្កៈក៏ន័យនេះដូចគ្នា ។ បទថា **ឧទយព្វយានុបស្សី** (ពិចារណារឿយៗ នូវការកើត និងការរលត់) បានដល់ពិចារណាឃើញការកើតឡើង និងការវិនាសទៅ ។ បទថា **ឥតិ រូបំ** (រូបយ៉ាងនេះ) សេចក្តីថា រូបយ៉ាងនេះ រូបមានប៉ុណ្ណេះ រូបដទៃក្រៅនេះមិនមាន ។ បទថា **ឥតិ រូបស្ស សមុទយោ** (ការកើតឡើងនៃរូបយ៉ាងនេះ) សេចក្តីថា ការកើតឡើងនៃរូបយ៉ាងនេះ ។ ចំណែកបទថា **អត្ថង្គមោ** (ការរលត់ទៅ) លោកសំដៅដល់ការបែកធ្លាយ ។ សូម្បីក្នុងវេទនាជាដើម ក៏ន័យនេះដូចគ្នា ។

បទថា **ឥទញ្ច បន មេតំ ភិក្ខវេ សន្ធាយ ភាសិតំ** (ក៏តថាគតសម្គាល់សេចក្តីនេះ បានពោលទុកក្នុងបុណ្ណកបញ្ហាក្នុងបារាយនវគ្គ) សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ពាក្យជាដើមថា ព្រោះពិចារណាដឹង... ក្នុងលោក

តថាគតពោលហើយក្នុងបុណ្ណកប្បញ្ហា (សោឡសបញ្ហា) ពាក្យនោះ តថាគតពោលសំដៅដល់ផលសមាបត្តិនេះ ។ ក្នុងបទទាំងនោះ បទថា **សង្ខាយ** (ព្រោះពិចារណាដឹង) បានដល់ ដឹងដោយញាណ ។ បទថា **លោកស្មិ** (ក្នុងលោក) បានដល់ ក្នុងលោក គឺ ពួកសត្វ ។ បទថា **បរោបរានិ** (អារម្មណ៍ដ៏ឧត្តម និងថោកទាប) បានដល់ ឧត្តម និងថោកទាប គឺ ខ្ពស់ និងទាប ។ បទថា **ឥញ្ជិតំ** (សេចក្តីញាប់ញ័រ) បានដល់ ការកម្រើក ។ បទថា **នត្ថិ កុហិញ្ចិ លោកេ** (ក្នុងលោកណាៗ របស់បុគ្គលណាមិនមាន) សេចក្តីថា សេចក្តីញាប់ញ័ររបស់បុគ្គលណា ក្នុងទីណាៗ មិនថា ក្នុងខន្ធមួយក្តី អាយតនៈមួយក្តី ធាតុមួយក្តី អារម្មណ៍មួយក្តី រមែងមិនមានក្នុងលោក ។ បទថា **សន្តោ** (ជាអ្នកស្ងប់) សេចក្តីថា បុគ្គលនោះជាអ្នកស្ងប់ ព្រោះស្ងប់កិលេសដែលជាសត្រូវ ។ បទថា **វិធូមោ** (មិនមានផ្សែង គឺ សេចក្តីក្រោធ) សេចក្តីថា ជាអ្នកប្រាសចាកកិលេសដូចផ្សែង ព្រោះផ្សែង គឺ សេចក្តីក្រោធ ។ ក្នុងព្រះសូត្រនេះ ត្រាស់ដល់ឯកគ្គតាក្នុងមគ្គ ក្នុងគាថាត្រាស់ដល់ផលសមាបត្តិតែម្យ៉ាង ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា សមាធិសូត្រទី ១

# អដ្ឋកថា បញ្ហាព្យាករណសូត្រទី ២

## “បញ្ហាព្យាករណ៍ ៤”

គប្បីជ្រាបវិនិច្ឆ័យក្នុង បញ្ហាព្យាករណសូត្រទី ២ ដូចតទៅនេះ ៖

[៤៣] បទថា **យោ ច នេសំ តត្ថ តត្ថ ជានាតិ អនុធម្មតំ** (ភិក្ខុណាដឹងសេចក្ដីសមគួរនៃបញ្ហាទាំងនោះក្នុងឋានៈនោះៗ) សេចក្ដីថា ភិក្ខុណាដឹងការពោលបញ្ហាទាំងនោះ ក្នុងឋានៈនោះៗ ។ បទថា **ចតុបញ្ហស្ស កុសលោ អាហុ ភិក្ខុំ តថាវិធំ** (ភិក្ខុនោះហៅថា ជាអ្នកឈ្លាសក្នុងបញ្ហា ៤) សេចក្ដីថា លោកហៅភិក្ខុនោះ យ៉ាងនេះថា អ្នកឈ្លាសក្នុងបញ្ហាទាំង ៤ ។ បទថា **ទុរាសទោ ទុប្បសហោ** (ជាបុគ្គលដែលគេបៀតបៀនបានដោយក្រ គ្របសង្កត់បានដោយក្រ) សេចក្ដីថា ដែលនរណាៗ មិនអាចនឹងប៉ះខ្ទប់ ឬគ្របសង្កត់បាន ។ បទថា **គម្ភីរោ** (ជាអ្នកជ្រាលជ្រៅ) សេចក្ដីថា ជាអ្នកជ្រាលជ្រៅដូចមហាសមុទ្រសីទន្តរៈទាំង ៧ ។ បទថា **ទុប្បធំសិយោ** (លំបាកនឹងនរណាៗ កម្ចាត់) បានដល់ បុគ្គលណាៗ កម្ចាត់បានដោយក្រ អធិប្បាយថា នរណាៗ មិនអាចនឹងឲ្យគេលែងការប្រកាន់ ប្រការដែលគេកាន់យកហើយបាន ។ បទថា **អត្ថេ អនត្ថេ ច** (ក្នុងផ្លូវចម្រើន និងផ្លូវវិនាស) បានដល់ ក្នុងសេចក្ដីចម្រើន និងក្នុងសេចក្ដីវិនាស ។ បទថា **អត្ថាភិសមយា**

*(ព្រោះបានប្រយោជន៍) បានដល់ ព្រោះរួមយកសេចក្តីចម្រើនទុកបាន ។*

*បទថា* ***ធីរោ បណ្ឌិតោតិ បវុច្ចតិ*** *(បុគ្គលឈ្លាសវៃ... លោកទើបហៅថាបណ្ឌិត) សេចក្តីថា បុគ្គលដែលប្រកបដោយសេចក្តីឈ្លាសវៃ គេហៅយ៉ាងនេះថា "បុគ្គលនេះជាបណ្ឌិត" ដូច្នេះ ។*

ចប់អដ្ឋកថា បញ្ហាព្យាករណសូត្រទី ២

# អដ្ឋកថា បឋមកោធសូត្រទី ៣

*"បុគ្គលអ្នកក្រោធ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមកោធសូត្រទី ៣ ដូចតទៅនេះ ៖*

[៤៤] *បទថា **កោធគរុ ន សទ្ធម្មគរុ** (បុគ្គលធ្ងន់ក្នុងសេចក្តីក្រោធ មិនធ្ងន់ក្នុងព្រះសទ្ធម្ម) សេចក្តីថា បុគ្គលកាន់យកសេចក្តីក្រោធជាសំខាន់ មិនកាន់យកព្រះសទ្ធម្ម សូម្បីកាន់យកព្រះសទ្ធម្ម តែមិនធ្វើឲ្យសំខាន់ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ បទថា **វិរូហន្តិ** (រមែងលូតលាស់) បានដល់ រមែងចម្រើន ឬរមែងតាំងមាំ មិនញាប់ញ័រដោយសទ្ធា ដែលជាមូលដល់ព្រមហើយ ។*

ចប់អដ្ឋកថា បឋមកោធសូត្រទី ៣

# អដ្ឋកថា ទុតិយកោធសូត្រទី ៤

*"បុគ្គលអ្នកក្រោធ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយកោធសូត្រទី ៤ ដូចតទៅនេះ ៖*

[៤៥] *បទថា* ***កោធគរុតា*** *(ភាពជាអ្នកធ្ងន់ក្នុងសេចក្តីក្រោធ) បាន ដល់ ភាពជាធ្ងន់ទៅក្នុងសេចក្តីក្រោធ ។ ក្នុងបទទាំងពួង ក៏មានន័យនេះ ឯង ។*

ចប់អដ្ឋកថា ទុតិយកោធសូត្រទី ៤

# អដ្ឋកថា បឋមរោហិតស្សសូត្រទី ៥

## *"រោហិតស្សទេវបុត្តទូលសួរបញ្ហា"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមរោហិតស្សសូត្រទី ៥ ដូចតទៅនេះ ៖*

[៤៦] *បទថា* **យត្ថ** *(ក្នុងទីបំផុតលោកណា) សេចក្តីថា ផែនដីក្នុងឱកាសមួយនៃលោកក្នុងចក្រវាឡ ។ បទថា* **ន ចវតិ ន ឧបបជ្ជតិ** *(មិនចុតិ មិនបដិសន្ធិ) នេះ ទ្រង់កាន់យកហើយដោយអំណាចចុតិ និងបដិសន្ធិតៗ គ្នាទៅ ។ បទថា* **គមនេន** *(ដោយការដើរផ្លូវ) គឺ ដោយការប្រើជើងដើរទៅ ។ បទថា* **លោកស្ស អន្តំ** *(ទីបំផុតលោក) សេចក្តីថា ព្រះសាស្តាត្រាស់សំដៅដល់ទីបំផុតរបស់សង្ខារលោក ។ ក្នុងបទថា* **ញាតេយ្យំ** *(គប្បីដឹង) ជាដើម សេចក្តីថា ដែលបុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ ។ ព្រោះហេតុនោះ ទេវបុត្រទូលសួរទីបំផុតនៃលោកក្នុងចក្រវាឡ ព្រះសាស្តាក៏ត្រាស់ឆ្លើយទីបំផុតរបស់សង្ខារលោក ។ ចំណែកទេវបុត្រនោះ រីករាយក្នុងបញ្ហាថា "ការពោលដោះស្រាយរបស់ព្រះសាស្តា សមនឹងបញ្ហារបស់ខ្ញុំ" ទើបទូលថា* **អច្ឆរិយំ** *(គួរអស្ចារ្យ) ដូច្នេះជាដើម ។*

*បទថា* **ទឡ្ហធម្មោ** *(បុគ្គលមាំទាំ) បានដល់ អ្នកសិក្សាព្រួញទុកដ៏មាំ គឺ បានយកព្រួញដ៏ស្រាល (បាញ់) ។ បទថា* **ធនុគ្គហោ** *(នាយខ្មាន់ធ្នូ) បាន*

ដល់ អាចារ្យអ្នកបង្រៀនធ្នូ ។ បទថា **សុសិក្ខិតោ** (បានហ្វឹកហាត់សិល្បៈធ្នូល្អហើយ) គឺ អ្នកបានសិក្សាសិល្បៈធ្នូមក ១២ ឆ្នាំ ។ បទថា **កតហត្ថោ** (ស្ទាត់ជំណាញ) សេចក្តីថា មានដៃជំនាញហើយ ដោយអាចបាញ់ចុងរោមទ្រាយ ក្នុងរយៈប្រមាណមួយឧសភៈបាន ។ បទថា **កតុបាសនោ** (សម្រេចការបាញ់ហើយ) បានដល់ បាញ់ធ្នូយ៉ាងជំនាញបានសម្តែង (ការប្រឡង) សិល្បៈធ្នូមកហើយ ។ បទថា **អសនេន** គឺ កូនសរ ។ បទថា **អតិបាតេយ្យ** (ឲ្យរំលង) គឺ កន្លងទៅ ។ ទេវបុត្រសម្តែងសម្បត្តិ គឺ សេចក្តីរហ័សរបស់ខ្លួនថា យើងនឹងកន្លងចក្រវាឡមួយទៅ ដូចជាកូនសរនោះកន្លងស្រមោលដើមត្នោត ។

បទថា **បុរត្ថិមា សមុទ្ទា បច្ឆិមោ** (ពីសមុទ្រខាងកើតដល់សមុទ្រខាងលិច) សេចក្តីថា ទេវបុត្រពោលថា ការឈានមួយជំហានទៅបានក្នុងចម្ងាយ ដូចសមុទ្រខាងលិចដែលឆ្ងាយពីសមុទ្រខាង កើតដូច្នោះ ។ បានឮថា ឥសីនោះ ឈរនៅត្រង់កណ្តាប់មាត់នៃចក្រវាឡខាងកើត ឈានជើងកន្លងកណ្តាប់មាត់នៃចក្រវាឡខាងលិច ឈានជើងទីពីរទៀត ក៏កន្លងកណ្តាប់មាត់ចក្រវាឡដទៃ ។ បទថា **ឥច្ឆាគតំ** (មានសេចក្តីប្រាថ្នា) ប្រែថា សេចក្តីប្រាថ្នានោះឯង ។ បទថា **អញ្ញត្រេវ** (វៀរ) គឺ លោកសម្តែងដល់

ការមិនបង្អែបង្អង់ ។ បានឮថា ក្នុងវេលាភិក្ខាចារ ឥសីនោះ ជម្រះធ្មេញដោយឈើស្ទន់ឯនាគលតា លុបលាងមុខក្នុងស្រះអនោតាត កាលបានវេលាក៏ត្រាច់បិណ្ឌបាតក្នុងឧត្តរកុរុទ្វីប អង្គុយត្រង់កណ្ដាប់មាត់ចក្រវាឡ ធ្វើភត្តកិច្ច ។ ឈប់សម្រាកក្នុងទីនោះមួយស្របក់ ក៏ត្រាច់ទៅទៀត ។ បទថា **វស្សសតាយុកោ** (មានអាយុ ១០០ ឆ្នាំ) សេចក្ដីថា សម័យនោះ ជាសម័យដែលមនុស្សមានអាយុវែង ។ ចំណែកឥសីនេះ ផ្ដើមដើរកាលអាយុលើស ១០០ ឆ្នាំ ។ បទថា **វស្សសតជីវី** (មានជីវិតនៅអស់ ១០០ ឆ្នាំ) សេចក្ដីថា គេមានជីវិត ១០០ ឆ្នាំ ដោយមិនមានអន្តរាយ ។ បទថា **អន្តរាយេវ កាលកតោ** (ស្លាប់ក្នុងរវាងនោះឯង) សេចក្ដីថា មិនទាន់ដល់ទីបំផុតនៃលោកក្នុងចក្រវាឡ ក៏ស្លាប់មុនក្នុងរវាងនោះ ។ តែគេស្លាប់ក្នុងទីនោះហើយ ទើបមកកើតក្នុងចក្រវាឡនេះ ។

បទថា **អប្បត្វា** (នៅមិនដល់) សេចក្ដីថា នៅមិនទាន់ដល់ទីបំផុតនៃសង្ខារលោក ។ បទថា **ទុក្ខស្ស** (ទុក្ខ) គឺ វដ្ដទុក្ខ ។ បទថា **អន្តកិរិយំ** (ធ្វើទីបំផុត) គឺ ធ្វើឲ្យដល់ទីបំផុត ។ បទថា **កឡេវរេ** គឺ ក្នុងអត្តភាព ។ បទថា **សសញ្ញម្ហិ សមនកេ** (ដែលមានសញ្ញា និងមានចិត្ត) គឺ មានសញ្ញា និងមានចិត្ត ។ បទថា **លោកំ** (លោក) គឺ ទុក្ខសច្ចៈ ។ បទថា **លោក-**

***សមុទយំ*** *គឺ សមុទយសច្ចៈ ។ បទថា* ***លោកនិរោធំ*** *គឺ និរោធសច្ចៈ ។ បទថា* ***បដិបទំ*** *(បដិបទា) គឺ មគ្គសច្ចៈ ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងថា អ្នកមានអាយុ តថាគតរមែងមិនបញ្ញត្តិសច្ចៈ ៤ នេះ ចុះក្នុងស្មៅ និងឈើជាដើម តែតថាគតរមែងបញ្ញត្តិចុះក្នុងកាយនេះ ដែលមានមហាភូត ៤ ប៉ុណ្ណោះ ។ បទថា* ***សមិតាវី*** *(ស្ងប់បាបហើយ) បានដល់ អ្នកមានបាបស្ងប់ហើយ ។ បទថា* ***នាសីសតិ*** *(រមែងមិនប្រាថ្នា) គឺ មិនបំណង ។*

ចប់អដ្ឋកថា បឋមរោហិតស្សសូត្រទី ៥

# អដ្ឋកថា ទុតិយរោហិតស្សសូត្រទី ៦

*“រោហិតស្សទេវបុត្តទូលសួរបញ្ហា”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយរោហិតស្សសូត្រទី ៦ ដូចតទៅនេះ ៖*

[៤៧] *ក្នុងទុតិយរោហិតស្សសូត្រទី ៦ មានសេចក្ដីងាយហើយនោះ*

ឯង ។

ចប់អដ្ឋកថា ទុតិយរោហិតស្សសូត្រទី ៦

# អដ្ឋកថា សុវិទូរសូត្រទី ៧

## *"វត្ថុដែលឆ្ងាយសែនឆ្ងាយ ៤ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុវិទូរសូត្រទី ៧ ដូចតទៅនេះ ៖*

*[៤៨] បទថា **សុវិទូរវិទូរានិ** (វត្ថុដែលឆ្ងាយសែនឆ្ងាយ) សេចក្តីថា មិនជិតគ្នាដោយបរិយាយណាៗ គឺ ឆ្ងាយសែនឆ្ងាយទាំងឯង ។ បទថា **នភញ្ច ភិក្ខវេ បឋវី ច** (មេឃ និងដី) បានដល់ អាកាស និងផែនដីធំ ។ ក្នុងពីរយ៉ាងនោះ ឈ្មោះថា អាកាសមិនឆ្ងាយពីផែនដី សូម្បីប្រមាណ ២ ធ្នាប់ក៏ពិត តែលោកក៏នៅពោលថា ឆ្ងាយសែនឆ្ងាយ ព្រោះមិនជាប់គ្នា ។*

*បទថា **វេរោចនោ** គឺ ព្រះអាទិត្យ ។ បទថា **សតញ្ច ភិក្ខវេ ធម្មោ** (ធម៌របស់សប្បុរស) សេចក្តីថា ពោធិបក្ខិយធម៌ ៣៧ មានសតិប្បដ្ឋាន ៤ ជាដើម ។ បទថា **អសតញ្ច ធម្មោ** (ធម៌របស់អសប្បុរស) សេចក្តីថា អសទ្ធម្មដែលផ្សេងដោយទិដ្ឋិ ៦២ ។ បទថា **បភង្ករោ** (ព្រះអាទិត្យ) គឺ អស្តង្គត ។ បទថា **អព្យាយិកោ ហោតិ** (រមែងមិនព្រាត់ប្រាស) បានដល់ មិនប្រែទៅជាសភាពដទៃ ។ បទថា **សតំ សមាគមោ** (សមាគមនៃសប្បុរស) សេចក្តីថា ការសមាគមរបស់បណ្ឌិតមិនបានព្រាត់ប្រាសចាកគ្នា ។ បទថា **យាវម្បិ តិដ្ឋេយ្យ** (តាំងនៅយូរ) សេចក្តីថា នឹងគប្បីតាំងនៅយូរប៉ុនណា ។*

*បទថា **តថេវ ហោតិ** (ក៏ស្ថិតនៅដូច្នោះ) សេចក្ដីថា ក៏ស្ថិតនៅដូច្នោះ មិនលះបង់ប្រក្រតី ។ បទថា **ខិប្បញ្ហិ វេតិ** (រហ័សព្រោត់ប្រាស) គឺ រមែងវិនាសរហ័ស ។*

ចប់អដ្ឋកថា សុវិទូរសូត្រទី ៧

# អដ្ឋកថា វិសាខសូត្រទី ៨

## *“វិសាខបញ្ចាលិបុត្តសម្តែងធម្មីកថា”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិសាខសូត្រទី ៨ ដូចតទៅនេះ ៖*

[៤៩] *បទថា **បញ្ចាលិបុត្តោ** (បញ្ចាលិបុត្ត) គឺ ជាបុត្ររបស់នាងព្រាហ្មណី ឈ្មោះ **បញ្ចាលី** ។ បទថា **បោរិយា វាចាយ** (ដោយពាក្យសំដីអ្នកក្រុង) គឺ ដោយវាចាដែលបរិបូរណ៍ ។ បទថា **វិស្សដ្ឋាយ** (ច្បាស់ល្អ) គឺ អណ្តាតមិនព័ន្ធ ។ បទថា **អនេឡគលាយ** (ប្រាសចាកទោស) សេចក្តីថា មិនមានទោស មិនតតាក់តតុប ព្យញ្ជនៈមិនឃ្លៀងឃ្លាត ។ បទថា **បរិយាបន្នាយ** (រាប់ចូលក្នុងនិព្វាន) គឺ ដែលរាប់បញ្ចូលក្នុងវិវដ្តៈ ។ បទថា **អនិស្សិតាយ** (មិនអាស្រ័យវដ្តៈ) គឺ មិនអាស្រ័យវដ្តៈ ។ អធិប្បាយថា ពោលពាក្យអាស្រ័យតែវិវដ្តៈប៉ុណ្ណោះ មិនពោលពាក្យអាស្រ័យវដ្តៈ ។*

*បទថា **នាភាសមានំ** (កាលមិននិយាយចេញមក) គឺ កាលមិននិយាយក៏មិនមាននរណាស្គាល់ ។ បទថា **អមតំ បទំ** (អមតបទ) បានដល់ បទ គឺ ព្រះនិព្វាន ។ បទថា **ភាសយេ** (គប្បីប្រកាស) បានដល់ គប្បីធ្វើឲ្យភ្លឺច្បាស់ (និយាយ) ។ បទថា **ជោតយេ** (គួរបំភ្លឺ) ជាវេវចនៈរបស់បទថា **គប្បីប្រកាស** នោះឯង ។ បទថា **បគ្គណ្ហេ ឥសីនំ ធជំ** (សរសើរធម៌ដែល*

ជាទង់របស់ឥសី) សេចក្តីថា លោកុត្តរធម៌ ៩ យ៉ាង ហៅឈ្មោះថា ទង់ របស់ពួកឥសី ព្រោះអត្ថថា ខ្ពស់ខ្ពាយទៅ ។ អធិប្បាយថា គប្បីលើកតម្កើង លោកុត្តរធម៌នោះ គឺ គប្បីពោលលើកឲ្យខ្ពស់ ។ ពួកឥសី ឈ្មោះថា មាន សុភាសិតជាទង់ ព្រោះអត្ថថា មានសុភាសិតដែលសម្តែងពីលោកុត្តរធម៌ ៩ ជាទង់ ។ បទថា **ឥសយោ** (ឥសីទាំងឡាយ) បានដល់ ព្រះអរិយៈទាំង ឡាយ មានព្រះពុទ្ធជាដើម ។ បទថា **ធម្មោ ហិ ឥសីនំ ធជោ** (ការពិត ធម៌ជាទង់របស់ពួកឥសី) សេចក្តីថា លោកុត្តរធម៌ ឈ្មោះថា ជាទង់របស់ ពួកឥសី ដោយន័យដែលពោលហើយក្នុងខាងក្រោយ ។

ចប់អដ្ឋកថា វិសាខសូត្រទី ៨

# អដ្ឋកថា វិបល្លាសសូត្រទី ៩

## "វិបល្លាសក្នុងធម៌ ៤ ប្រការ"

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិបល្លាសសូត្រទី ៩ ដូចតទៅនេះ ៖*

[៥០] *បទថា* ***សញ្ញាវិបល្លាសា*** *(សញ្ញាវិបល្លាស) សេចក្តីថា មានសញ្ញា (សេចក្តីសម្គាល់) ឃ្លៀងឃ្លាត អធិប្បាយថា មានសញ្ញា ៤ វិបរិត (សេចក្តីសម្គាល់ដែលផ្ទុយគ្នា) ។ សូម្បីក្នុងពីរបទដ៏សេស ក៏ន័យនេះដូចគ្នា ។ បទថា* ***អនិច្ចេ និច្ចន្តិ សញ្ញាវិបល្លាសោ*** *(សញ្ញាវិបល្លាស... ក្នុងវត្ថុមិនទៀងថាទៀង) សេចក្តីថា កើតសេចក្តីសម្គាល់ប្រកាន់យ៉ាងនេះថា ទៀងក្នុងវត្ថុដែលមិនទៀង ឈ្មោះថា សញ្ញាវិបល្លាស ។ បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងគ្រប់បទ ដោយន័យនេះ ។*

*បទថា* ***អនត្តនិ ច អត្តា*** *(សម្គាល់ថា ជាអត្តាក្នុងវត្ថុមិនមែនជាអត្តា) សេចក្តីថា ជាអ្នកមានសេចក្តីសម្គាល់យ៉ាងនេះថា ជាអត្តាក្នុងវត្ថុដែលជាអនត្តា ។ បទថា* ***មិច្ឆាទិដ្ឋិហតា*** *(ត្រូវការឃើញខុសនាំទៅហើយ) សេចក្តីថា សត្វនឹងសម្គាល់តែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែន ក៏ត្រូវសូម្បីមិច្ឆាទិដ្ឋិដែលកំពុងកើតឡើងដឹកនាំទៅហើយ ដូចសញ្ញា ។ បទថា* ***ខិត្តចិត្តា*** *(ការគិតរវើរវាយទៅ) សេចក្តីថា បុគ្គលប្រកបដោយចិត្តរវើរវាយដែលកំពុងកើតឡើង ដូច*

សញ្ញា និងទិដ្ឋិ ។ បទថា **វិសញ្ញិនោ** (មានការសម្គាល់វិបល្លាស) នោះត្រឹមតែជាទេសនា ។ អធិប្បាយថា មានសញ្ញា ចិត្ត និងទិដ្ឋិដែលវិបរិត ។ បទថា **តេ យោគយុត្តា មារស្ស** (សត្វទាំងនោះឈ្មោះថា ត្រូវចំណងរបស់មារចងទុក) សេចក្តីថា សត្វទាំងនោះឈ្មោះថា ប្រកបនៅក្នុងចំណងរបស់មារ ។ បទថា **អយោគក្ខេមិនោ** (ជាបុគ្គលមិនក្សេមចាកយោគៈ) សេចក្តីថា ជាបុគ្គលមិនដល់នូវសេចក្តីក្សេមចាកយោគៈ ៤ គឺ ព្រះនិព្វាន ។ បទថា **សត្តា** (សត្វ) គឺ បុគ្គលទាំងឡាយ ។ បទថា **ពុទ្ធា** (ព្រះពុទ្ធទាំងឡាយ) គឺ អ្នកត្រាស់ដឹងសច្ចៈ ៤ ។ បទថា **ឥមំ ធម្មំ** (ធម៌នេះ គឺ សច្ចធម៌ ៤ ។ បទថា **សចិត្តំ បច្ចលទ្ធា**[១] បានដល់ ត្រឡប់បានការគិតជារបស់ខ្លួនឯង ។ បទថា **អនិច្ចតទ្ទក្ខុំ**[២] (ឃើញវត្ថុមិនទៀងថាមិនទៀង) បានដល់ បានឃើញថាជារបស់មិនទៀងពិត ។ បទថា **អសុភតទ្ទសំ** (ឃើញវត្ថុដែលមិនស្អាត) បានដល់ បានឃើញថាជារបស់មិនស្អាតពិត ។ បទថា **សម្មាទិដ្ឋិសមាទានា** (កាន់យកនូវសម្មាទិដ្ឋិ) បានដល់ អ្នកកាន់យកសម្មាទស្សនៈ ។ បទថា **សព្វំ ទុក្ខំ ឧបច្ចគុំ** (ក៏កន្លងផុតទុក្ខទាំងពួងបាន) សេចក្តីថា កន្លងផុតវដ្តទុក្ខទាំងអស់បាន ។

ចប់អដ្ឋកថា វិបល្លាសសូត្រទី ៩

---

បិដក ១ បច្ចលត្ថុ , ២ អនិច្ចតោ ទុក្ខំ ។

# អដ្ឋកថា ឧបក្កិលេសសូត្រទី ១០

## *"គ្រឿងសៅហ្មង ៤ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧបក្កិលេសសូត្រទី ១០ ដូចតទៅនេះ ៖*

[៥០] *បទថា* ***ឧបក្កិលេសា*** *(គ្រឿងសៅហ្មង) សេចក្តីថា ឈ្មោះថា គ្រឿងសៅហ្មង ព្រោះធ្វើឲ្យសៅហ្មង មិនឲ្យផូរផង់ ។ បទថា* ***មហិយា*** *គឺ អ័ព្ទ ។ បទថា* ***ធូមរជោ*** *បានដល់ ផ្សែង និងផង់ធូលី ។ បទថា* ***រាហុ*** *សេចក្តីថា អ័ព្ទ ផ្សែង និងផង់ធូលី ទាំងបីខាងដើម ជាឧបក្កិលេសដែលទៅ មិនដល់ព្រះច័ន្ទព្រះអាទិត្យ ចំណែករាហូ គប្បីជ្រាបថា លោកពោលដោយ អំណាចជាគ្រឿងសៅហ្មងទៅដល់ព្រះច័ន្ទព្រះអាទិត្យ ។ បទថា* ***សមណព្រាហ្មណា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ*** *(សមណព្រាហ្មណ៍... មិនស្អាត*[១] *ភ្លឺ រុងរឿង) សេចក្តីថា រមែងមិនស្អាត ព្រោះសេចក្តីស្អាតដោយ គុណ , មិនភ្លឺ ព្រោះភ្លឺដោយគុណ , រមែងមិនរុងរឿង ព្រោះសេចក្តីរុងរឿង ដោយគុណ ។ បទថា* ***សុរាមេរយបានា អប្បដិវិរតា*** *(មិនវៀរចាកការផឹក សុរាមេរ័យ) សេចក្តីថា មិនវៀរចាកការផឹកសុរា ៥ យ៉ាង និងមេរ័យ ៤ យ៉ាង ។*

---

*(១) បិដក ប្រែថា ក្តៅ ។*

*បទថា* ***អវិជ្ជានិវុតា*** *(ដែលអវិជ្ជាបិទបាំងហើយ) សេចក្តីថា ជាបុគ្គលត្រូវអវិជ្ជាហ៊ុមព័ទ្ធហើយ គឺបិទបាំងទុកហើយ ។ បទថា* ***បិយរូបាភិនន្ទិនោ*** *(ភ្លើតភ្លើនត្រេកអរក្នុងរូប) សេចក្តីថា ភ្លើតភ្លើនត្រេកអរក្នុង បិយរូប (វត្ថុគួរស្រឡាញ់) សាតរូប (វត្ថុជាទីត្រេកអរ) ។ បទថា* ***សាទិយន្តិ*** *(រីករាយ) គឺ រមែងពេញចិត្តទទួល ។ បទថា* ***អវិទ្ទសុ*** *(ចោតល្ងង់) គឺ អន្ធពាល ។ បទថា* ***សនេត្តិកា*** *(ត្រូវតណ្ហាចងទៅ) សេចក្តីថា ត្រូវនាំទៅដោយខ្សែ គឺតណ្ហា ។ បទថា* ***កដសី*** *(អត្តភាព) គឺ ត្តខ្ទួន ។ បទថា* ***ឃោរំ*** *(កាច)[១] គឺ កាចផ្តើម ។ ទាំងក្នុងព្រះសូត្រ ទាំងក្នុងគាថា ត្រាស់វដ្តៈតែម្យ៉ាង ។*

ចប់អដ្ឋកថា ឧបក្កិលេសសូត្រទី ១០

## ចប់រោហិតស្សវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# ចប់បឋមបណ្ណាសកៈ

---

*(១) បិដក ប្រែថា ក្លៀវក្លា ។*

# ទុតិយបណ្ណាសកៈ

## បុញ្ញាភិសន្ទវគ្គវណ្ណនាទី ១

## អដ្ឋកថា បឋមបុញ្ញាភិសន្ទសូត្រទី ១

*"ពោលដោយធារបុណ្យកុសល"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនុពុទ្ធសូត្រទី ១ ដូចតទៅនេះ ៖*

[៥២] *បទថា* ***បុញ្ញាភិសន្ទា*** *(ធារបុណ្យ)*[១] *បានដល់ ការហូរមកនៃបុណ្យ អធិប្បាយថា ការកើតឡើងនៃបុណ្យ ។ បទថា* ***កុសលាភិសន្ទា*** *(ធារកុសល) នោះ ជាវេវចនៈរបស់បទថា* ***ធារបុណ្យ*** *នោះឯង ។ ធារបុណ្យ ធារកុសល ឈ្មោះថា* ***សុខស្សាហារា*** *(នាំមកនូវសេចក្តីសុខ) ក៏ព្រោះការហូរមកនៃបុណ្យទាំងនោះ នាំនូវសេចក្តីសុខមកឲ្យ ។ ឈ្មោះថា* ***សោវគ្គិកា*** *(ឲ្យនូវផលដ៏ប្រសើរ) ព្រោះឲ្យអារម្មណ៍ មានរូបជាដើមល្អ ។ ឈ្មោះថា* ***សុខវិបាក*** *(មានសេចក្តីសុខជាវិបាក) ព្រោះបុណ្យទាំងនោះ មានសេចក្តីសុខជាផល ។ ឈ្មោះ* ***សគ្គសំវត្តនិកា*** *(ជាផ្លូវសួគ៌) ព្រោះប្រព្រឹត្តទៅដើម្បីកើតក្នុងសួគ៌ ។*

---

*(១) បុញ្ញាភិសន្ទា បិដកប្រែថា អានិសង្សជាទីហូរមកនៃបុណ្យ ។*

បទថា **ចីវរំ បរិភុញ្ជមានោ** (បរិភោគចីវរ) សេចក្តីថា ភិក្ខុបានសំពត់ ដើម្បីធ្វើចីវរ ទើបរក្សាឯង ព្រោះមូល និងអំបោះជាដើមមិនមានខ្លះ ធ្វើឯងខ្លះ ឲ្យអ្នកដទៃធ្វើខ្លះ ដណ្តប់ឯងខ្លះ នូវសំពត់នោះ ក្នុងវេលាសំពត់ចាស់ ធ្វើជាសំពត់ក្រាលដេកខ្លះ មិនអាចធ្វើជាសំពត់ក្រាលដេកបាន ក៏ធ្វើជាសំពត់ធូលីខ្លះ ហែកសំពត់ដែលមិនគួរនឹងជូតធូលីចេញធ្វើជាសំពត់ជូតជើងខ្លះ ក៏ហៅថា បរិភោគហើយ ។ តែកាលណាគិតថា សំពត់នេះនរណាមិនអាចធ្វើជាសំពត់ជូតជើងបាន ក៏បោះចោលទៅ កាលនោះឈ្មោះថា មិនបរិភោគ ។ បទថា **អប្បមាណំ ចេតោសមាធឹ** (ចេតោសមាធិជាធម៌ប្រមាណមិនបាន) គឺ អរហត្តផលសមាធិ ។ ដោយបទថា **អប្បមាណោ តស្ស បុញ្ញាភិសន្ទោ** (ធារបុណ្យកុសលរបស់ទាយកនោះ រមែងប្រមាណមិនបាន) នេះ ត្រាស់ដល់បុញ្ញចេតនារបស់ទាយកថា រាប់ប្រមាណមិនបាន ព្រោះថា បុញ្ញចេតនារបស់ទាយកនោះ ដែលប្រព្រឹត្តទៅហើយដោយអំណាចការរលឹកដល់រឿយៗថា "ភិក្ខុជាព្រះខីណាស្រព បរិភោគចីវររបស់យើង" ឈ្មោះថា ប្រមាណមិនបាន ពាក្យនេះត្រាស់សំដៅដល់ប្រការនោះ ។ ចំណែកក្នុងបិណ្ឌបាតជាដើម ភិក្ខុណាបរិភោគបិណ្ឌបាត មានជីវិតតាំងនៅដោយបិណ្ឌបាតនោះបានសូម្បី ៧ ថ្ងៃ មិនបរិភោគបិណ្ឌបាតដទៃ ។ ភិក្ខុនោះឈ្មោះថា បរិភោគ

ហើយនូវបិណ្ឌបាតនោះឯង តាំងនៅបានសូម្បី ៧ ថ្ងៃ ។ ក៏ក្នុងសេនាសនៈមួយកន្លែង ភិក្ខុបន្រ្ទមខ្លះ អង្គុយខ្លះ ស្នាក់នៅក្នុងពេលយប់ និងពេលថ្ងៃជាដើម ឈ្មោះថា បរិភោគជានិច្ច ដរាបលោកមិនទាន់លះបង់ចោលសេនាសនៈដែលបានហើយ ទៅកាន់សេនាសនៈដទៃ ។ ក៏កាលមានជំងឺ ត្រូវស្ងប់រម្ងាប់ដោយថ្នាំប្រភេទណាមួយ លោកឈ្មោះថា បរិភោគហើយ ដរាបដែលលោកមិនទាន់បរិភោគថ្នាំដទៃ ។

បទថា *ពហុភេរវំ* (ប្រកបដោយវត្ថុដែលគួរភ័យច្រើន) បានដល់ប្រកបដោយអារម្មណ៍ដែលគួរស្ញប់ស្ញែងដ៏ច្រើន ។ បទថា *រតនគណានំ* (នៃរតនៈផ្សេងៗ) បានដល់ រតនៈដែលប្រសើរ ៧ យ៉ាង ។ បទថា *អាលយំ* (ទីកំណើត) បានដល់ ស្ថានទីនៅអាស្រ័យ ។ បទថា *បុថូ សវន្តិ* (ទន្លេទាំងឡាយហូរទៅ) បានដល់ ទន្លេជាច្រើនហូរទៅ ។ បទដ៏សេសក្នុងបទទាំងពួង ងាយហើយ ។

ចប់អដ្ឋកថា បឋមបុញ្ញាភិសន្ទសូត្រទី ១

# អដ្ឋកថា ទុតិយបុញ្ញាភិសន្ទសូត្រទី ២

## *"ពោលដោយធារបុណ្យកុសល"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយបុញ្ញាភិសន្ទសូត្រទី ២ ដូចតទៅនេះ ៖*

[៥៣] *បទថា* ***អរិយកន្តេហិ*** *(អរិយកន្តសីល) គឺ សីលដែលសម្បយុត្តដោយមគ្គ និងផល ។ ក៏សីលទាំងនោះ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត របស់ព្រះអរិយៈទាំងឡាយ ។ ពាក្យដែលនឹងគប្បីពោលក្នុងព្រះសូត្រមានត្រឹមប៉ុណ្ណេះ ក្រៅពីនោះពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។*

*ក្នុងគាថាគប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា* ***សទ្ធា*** *សេចក្តីថា លោកបំណងយកសទ្ធារបស់ព្រះសោតាបន្នបុគ្គល ។ សុម្បីសីល ក៏ជាសីលរបស់ព្រះសោតាបន្នបុគ្គលនុ៎ះឯង ។ បទថា* ***ឧជុភូតញ្ច ទស្សនំ*** *(និងការឃើញរបស់បុគ្គលណាដែលឃើញត្រង់) សេចក្តីថា ការឃើញរបស់បុគ្គលដែលអស់អាសវៈ ឈ្មោះថា ជាការឃើញត្រង់ ព្រោះលោកមិនមានការវៀចផ្លូវកាយជាដើម ។ បទថា* ***អាហុ*** *(ពោល) បានដល់ ហៅ ។ បទថា* ***បសាទំ*** *(នូវសេចក្តីជ្រះថ្លា) គឺ នូវសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ បទថា* ***ធម្មទស្សនំ*** *(ការឃើញធម៌) គឺ ឃើញសច្ចធម៌ ។*

ចប់អដ្ឋកថា ទុតិយបុញ្ញាភិសន្ទសូត្រទី ២

# អដ្ឋកថា បឋមសង្វាសសូត្រទី ៣

## *"ការនៅរួមគ្នាជាស្វាមីភរិយា"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសង្វាសសូត្រទី ៣ ដូចតទៅនេះ ៖*

[៥៤] *បទថា* ***សម្ពហុលាបិ ខោ គហបតី ច គហបតានិយោ ច*** *(ចំណែកគហបតី និងគហបតានីមានចំនួនច្រើន) សេចក្តីថា គហបតី និងគហបតានីជាច្រើន កាលទៅធ្វើអាវាហមង្គល ឬវិវាហមង្គល ក៏បានធ្វើដំណើរទៅផ្លូវនោះដូចគ្នា ។ បទថា* ***សំវាសា*** *(ការនៅរួម... គ្នា) សេចក្តីថា ការនៅរួមគ្នា គឺ ការរួមជាមួយគ្នា ។ បទថា* ***ឆវោ ឆវាយ*** *(ស្វាមីខ្មោច... ជាមួយភរិយាខ្មោច) សេចក្តីថា ឈ្មោះថា ស្វាមីខ្មោច ព្រោះស្លាប់ ដោយការស្លាប់នៃគុណ នៅរួមជាមួយភរិយាខ្មោច ព្រោះស្លាប់ ដោយការស្លាប់នៃគុណដូចគ្នា ។ បទថា* ***ទេវិយា សទ្ធឹ*** *(ជាមួយភរិយាទេវតា) សេចក្តីថា បុរសខ្មោច នៅរួមជាមួយស្ត្រីទេវតាដោយគុណទាំងឡាយ ។ បទថា* ***ទុស្សីលោ*** *(ជាបុគ្គលទ្រុស្តសីល) គឺ ស្វាមីជាអ្នកមិនមានសីល ។ បទថា* ***បាបធម្មោ*** *(មានធម៌លាមក) គឺ មានធម៌ថោកទាប ។ បទថា* ***អក្កោសកបរិភាសកោ*** *(ជេរផ្តាសាថា) សេចក្តីថា ជេរដោយរឿងសម្រាប់ជេរ ១០ ជេរដោយសម្តែងការគំរាមបំភ័យ ។ បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងបទទាំង*

ពួងយ៉ាងនេះ ។

បទថា **ភរិយា** (កំណាញ់) បានដល់ កំណាញ់ស្វិតស្វាញ ។ បទថា **ជានិបតយោ** (ភរិយាស្វាមី) បានដល់ ប្ដី និងប្រពន្ធ ។ បទថា **វទញ្ញូ** (ដឹងសេចក្ដីបំណងរបស់សូម) បានដល់ ដឹងនូវអត្ថនៃពាក្យរបស់យាចក ។ បទថា **សញ្ញតា** (សង្រួមក្នុងសីល) បានដល់ ប្រកបដោយសេចក្ដីសង្រួមក្នុងសីល ។ បទថា **ធម្មជីវិនោ** (ចិញ្ចឹមជីវិតដោយប្រពៃ) បានដល់ ឈ្មោះថា ចិញ្ចឹមជីវិតដោយធម៌ ព្រោះតាំងនៅក្នុងធម៌ចិញ្ចឹមជីវិត ។ បទថា **អត្ថា សម្បចុរា ហោន្តិ** (រមែងបង្កើតសេចក្ដីចម្រើនច្រើន) សេចក្ដីថា ពួកបុគ្គលទាំងនោះ រមែងបានប្រយោជន៍ ពោលគឺ សេចក្ដីចម្រើនដ៏ច្រើន ។ បទថា **ផាសុកំ ឧបជាយតិ** (នៅជាមួយគ្នាជាអ្នកមានសេចក្ដីសុខ) សេចក្ដីថា នៅជាមួយគ្នាយ៉ាងសុខសាន្ត ។ បទថា **កាមកាមិនោ** (អ្នកនៅមានការប្រាថ្នាក្នុងកាម) បានដល់ អ្នកនៅមានសេចក្ដីប្រាថ្នាក្នុងកាម ។

ចប់អដ្ឋកថា បឋមសំវាសសូត្រទី ៣

# អដ្ឋកថា ទុតិយសង្វាសសូត្រទី ៤

## *“ការនៅរួមគ្នាជាស្វាមីភរិយា”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសង្វាសសូត្រទី ៤ ដូចតទៅនេះ ៖*

[៥៥] *ទុតិយសំវាសសូត្រទី ៤ ទ្រង់ត្រាស់កំណត់ទេសនាដោយកម្មបថ ។ បទដ៏សេសក៏ជាដូច្នោះដូចគ្នា ។ ក៏ក្នុងព្រះសូត្រសូម្បីទាំងពីរនេះ ត្រាស់វត្តបដិបត្តិសម្រាប់អ្នកនៅគ្រប់គ្រងផ្ទះ សូម្បីដល់គ្រហស្ថដែលជាព្រះសោតាបន្នៈ និងព្រះសកទាគាមីផង ។*

ចប់អដ្ឋកថា ទុតិយសំវាសសូត្រទី ៤

# អដ្ឋកថា បឋមសមជីវិសូត្រទី ៥

## “ធម៌ជាគ្រឿងនៅស្មើគ្នា”

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសមជីវិសូត្រទី ៥ ដូចតទៅនេះ ៖

[៥៦] បទថា **តេនុបសង្កមិ** (ស្តេចចូលទៅ) សួរថា ព្រះមានព្រះភាគ ស្តេចចូលទៅរកដើម្បីអ្វី ។ ឆ្លើយថា ដើម្បីទ្រង់អនុគ្រោះ ។ ពិតហើយ ព្រះតថាគតកាលស្តេចទៅកាន់ដែននោះ ស្តេចរមែងទៅដើម្បីទ្រង់សង្គ្រោះអ្នកទាំងពីរនេះប៉ុណ្ណោះ ។ បានឮថា **នកុលបិតា** បានជាបិតារបស់ព្រះតថាគតមកហើយ ៥០០ ជាតិ ជាតា ៥០០ ជាតិ ជាឪពុកមា ៥០០ ជាតិ ។ សូម្បី **នកុលមាតា** ក៏បានជាមាតាមក ៥០០ ជាតិ ជាជីដូន ៥០០ ជាតិ ជាម្តាយមីង ៥០០ ជាតិ បុគ្គលទាំងនោះ បាននូវសេចក្តីស្រឡាញ់ដូចជាបុត្រ ផ្តើមតាំងពីវេលាខ្លួនឃើញព្រះសាស្តា ទើបចូលទៅរក ហើយសម្រេចជាសោតាបន្នក្នុងបឋមទស្សនៈ (ការឃើញគ្រាដំបូង) ដូចមេគោឃើញកូនគោហើយជាប់ជំពាក់ក្នុងកូនគោ ក៏ហៅថា **ហន្តាត ហន្តាត** ដូច្នេះ ។ ក្នុងនិវេសន៍ គេបានចាត់ចែងអាសនៈទុកថ្វាយដល់ភិក្ខុ៥០០ រូប ជាប្រចាំព្រះមានព្រះភាគ ស្តេចទើបចូលទៅរកដើម្បីអនុគ្រោះអ្នកទាំងនោះ ដោយប្រការដូច្នេះ ។ បទថា **អតិចរិតា** (បានប្រព្រឹត្តក្រៅចិត្ត) បានដល់ ប្រព្រឹត្ត

*ក្បត់ចិត្ត ។*

*បទថា* ***អភិសម្បរាយញ្ច*** *(និងជាតិមុខ) បានដល់ និងក្នុងលោកខាងមុខ ។ បទថា* ***សមសទ្ធា*** *(មានសទ្ធាស្មើគ្នា) បានដល់ ជាអ្នកស្មើគ្នាដោយសទ្ធា ។ សូម្បីក្នុងសីលជាដើម ក៏ន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា បឋមសមជីវិសូត្រទី ៥

# អដ្ឋកថា ទុតិយសមជីវិសូត្រទី ៦

*"ធម៌ជាគ្រឿងនៅស្មើគ្នា"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសមជីវិសូត្រទី ៦ ដូចតទៅនេះ ៖*

[**៥៧**] *ទ្រង់សម្តែងដល់ពួកភិក្ខុតែម្យ៉ាង ៗ ពាក្យដ៏សេសក្នុងទីទាំងពួង ក៏ដូចនោះឯង ។*

ចប់អដ្ឋកថា ទុតិយសមជីវិសូត្រទី ៦

# អដ្ឋកថា សុប្បវាសសូត្រទី ៧

## *“នាងសុប្បវាសាកោលិយធិតា”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុប្បវាសសូត្រទី ៧ ដូចតទៅនេះ ៖*

*[៥៨] បទថា **បជ្ជនេលំ** (បជ្ជនេលៈ) ជាឈ្មោះរបស់និគមនេះ ។ បទថា **កោលិយានំ** (របស់អ្នកដែនកោលិយៈ) បានដល់ របស់រាជត្រកូលកោលិយៈ ។ បទថា **អាយុំ ខោ បន ទត្វា** (គ្រាឲ្យអាយុហើយ) បានដល់ គ្រាឲ្យអាយុទានហើយ ។ បទថា **អាយុស្ស ភាគិនី ហោតិ** (រមែងជាអ្នកមានចំណែកអាយុ) បានដល់ ជាស្ត្រីបានចំណែកនៃអាយុ ឬជាអ្នកកើតមានអាយុ អធិប្បាយថា ជាអ្នកបានអាយុ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។*

*បទថា **រសសា ឧបេតំ** (មានរស) បានដល់ កោជនាហារប្រកបដោយរស គឺ ដល់ព្រមដោយរស ។ បទថា **ឧជ្ជុគតេសុ** (ក្នុងលោកដែលប្រព្រឹត្តត្រង់) សេចក្តីថា ក្នុងព្រះខីណាស្រពដែលប្រព្រឹត្តត្រង់ ព្រោះវៀរចាកការវៀចផ្លូវកាយជាដើមហើយ ។ បទថា **ចរណោបបន្នេសុ** (អ្នកប្រកបដោយចរណៈ) សេចក្តីថា អ្នកប្រកបដោយចរណធម៌ ១៥ ។ បទថា **មហគ្គតេសុ** គឺ អ្នកដល់នូវភូមិធម៌ដ៏ខ្ពស់ ។ បទនោះ ជាឈ្មោះរបស់ព្រះខីណាស្រព ។*

បទថា **បុញ្ញេន បុញ្ញំ សំសន្ទមានា** (ជាទក្ខិណាដែលរួបរួមបុណ្យដោយបុណ្យ) បានដល់ ការបន្តបុណ្យដោយបុណ្យ ។ បទថា **មហប្ផលា លោកវិទូន វណ្ណិតា** (ព្រះពុទ្ធទាំងឡាយទ្រង់ដឹងច្បាស់លោក ទ្រង់សរសើរថា ជាទក្ខិណាទានមានផលច្រើន) សេចក្តីថា ទក្ខិណា ពោលគឺ ទានបែបនេះ ព្រះពុទ្ធទាំងឡាយទ្រង់ដឹងច្បាស់នូវលោក ព្រោះទ្រង់ដឹងច្បាស់នូវលោកទាំង ៣ ហើយ ត្រាស់សរសើរហើយ អធិប្បាយថា ព្រះពុទ្ធទាំងឡាយទ្រង់សរសើរហើយ ។ បទថា **យញ្ញមនុស្សរន្តា** (រឭកដល់យញ្ញ) បានដល់ រឭកដល់យញ្ញ គឺ ទាន ។ បទថា **វេទជាតា** បានដល់ កើតសេចក្តីត្រេកអរហើយ ។

ចប់អដ្ឋកថា សុប្បវាសសូត្រទី ៧

# អដ្ឋកថា សុទត្តសូត្រទី ៨

## *"សុទត្តគហបតី"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុទត្តសូត្រទី ៨ ដូចតទៅនេះ ៖*

[៥៩] *បទថា* ***សញ្ញតានំ*** *(បុគ្គលសង្រួម) បានដល់ បដិគ្គាហកៈ អ្នកសង្រួមផ្លូវកាយ និងវាចា ។ បទថា* ***បរទត្តភោជិនំ*** *(បរិភោគរបស់បុគ្គលដទៃឲ្យ) បានដល់ អ្នកបរិភោគរបស់ដែលបុគ្គលដទៃឲ្យហើយ ទើបញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ។ បទថា* ***កាលេន*** *(តាមកាល) បានដល់ តាមកាលដែលគួរ ។ បទថា* ***សក្កច្ចំ ទទាតិ*** *(ឲ្យ... ដោយគោរព) សេចក្តីថា ធ្វើសក្ការៈហើយឲ្យដោយដៃរបស់ខ្លួន ។ បទថា* ***ចត្តារិ ឋានានិ អនុប្បវេច្ឆតិ*** *(បុគ្គលនោះឈ្មោះថា ឲ្យឋានៈ ៤ ប្រការ) សេចក្តីថា រមែងបង្ហូរ គឺ រមែងឲ្យនូវហេតុ ៤ ។ បទថា* ***យស ហោតិ*** *(រមែងមាន... មានយស) បានដល់ មានបរិវារច្រើន ។*

ចប់អដ្ឋកថា សុទត្តសូត្រទី ៨

# អដ្ឋកថា ភោជនសូត្រទី ៩

*"ទាយកអ្នកឲ្យភោជន"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភោជនសូត្រទី ៩ ដូចតទៅនេះ ៖*

[៦០] *ទ្រង់ត្រាស់ដល់ពួកភិក្ខុតែម្យ៉ាង ។ ពាក្យដ៏សេសក្នុងសូត្រនេះងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា ភោជនសូត្រទី ៩

# អដ្ឋកថា គិហិសាមិចិសូត្រទី ១០

## *“ការបដិបត្តិបដិបទាសមគួរដល់គ្រហស្ថ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង គិហិសាមិចិសូត្រទី ១០ ដូចតទៅនេះ ៖*

[៦១] *បទថា* ***គិហិសាមីចិបដិបទំ*** *(បដិបទាសមគួរដល់គ្រហស្ថ) បានដល់ ដែលវត្តបដិបត្តិដែលសមគួរដល់គ្រហស្ថ ។ បទថា* ***បច្ចុបដ្ឋិតោ ហោតិ*** *(ទំនុកបម្រុង) សេចក្តីថា តាំងសតិទុកដោយល្អ ព្រោះជាបុគ្គលបំណងនឹងនាំទៅប្រគេន អធិប្បាយថា ចូលទៅប្រគេនចីវរដល់ភិក្ខុសង្ឃ ។*

*បទថា* ***ឧបដ្ឋិតា*** *បានដល់ ទំនុកបម្រុង ។ បទថា* ***តេសំ ទិវា ច រត្តោ ច*** *(ដល់បណ្ឌិតទាំងនោះ ទាំងថ្ងៃទាំងយប់) សេចក្តីថា ក៏បណ្ឌិតណា រមែងទំនុកបម្រុងដោយបច្ច័យ ៤ យ៉ាងនេះ បុណ្យរមែងចម្រើនដល់បណ្ឌិតនោះ គ្រប់កាលទាំងពេលថ្ងៃទាំងពេលយប់ ដោយអំណាចការបរិច្ចាគនិងដោយការរព្ញកដល់ ។ បទថា* ***សគ្គញ្ច កមតិដ្ឋានំ*** *(រមែងទៅកាន់ឋានៈគឺ សួគ៌) សេចក្តីថា បណ្ឌិតនោះ លុះធ្វើកម្មដែលចម្រើនហើយ រមែងទៅកាន់ឋានសួគ៌ ។*

*ក្នុងព្រះសូត្រទាំង ៤ នេះ ទ្រង់ត្រាស់វត្តបដិបត្តិសម្រាប់អ្នកគ្រប់*

*គ្រងផ្ទះ រមែងគួរដល់គ្រហស្ថដែលជាសោតាបន្ន និងសកទាគាមីផង ។*

ចប់អដ្ឋកថា គិហិសាមិចិសូត្រទី ១០

## ចប់បុញ្ញាភិសន្ទវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# បត្តកម្មវគ្គវណ្ណនាទី ២

## អដ្ឋកថា បត្តកម្មសូត្រទី ១

*"ពោលដោយកម្មដែលសមគួរ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បត្តកម្មសូត្រទី ១ ដូចតទៅនេះ ៖*

[៦២] *បទថា* ***ឥដ្ឋា*** *(ជាទីប្រាថ្នា) គួរប្រាថ្នា ព្រោះបដិសេធធម៌ដែលមិនគួរប្រាថ្នា ។ បទថា* ***កន្តា*** *(ជាទីត្រេកអរ) ព្រោះឈានចូលទៅក្នុងចិត្ត ។ បទថា* ***មនាបា*** *(ជាទីគាប់ចិត្ត) ព្រោះធ្វើចិត្តឲ្យឆ្អែតឲ្យចម្រើន ។ បទថា* ***ទុល្លភា*** *(រកបានលំបាក) បានដល់ បានដោយលំបាកក្រៃលែង ។ បទថា* ***ភោគា*** *(ភោគសម្បត្តិ) បានដល់ អារម្មណ៍ មានរូបជាដើម ដែលបុគ្គលគប្បីបរិភោគ ។ បទថា* ***សហធម្មេន*** *(ដោយផ្លូវល្អ) សេចក្តីថា សូមភោគសម្បត្តិចូរកើតឡើងដោយធម៌ កុំចូលទៅកម្ចាត់ធម៌ ហើយកើតឡើងដោយអធម៌ឡើយ ។ ម្យ៉ាងទៀត បទថា* ***ដោយផ្លូវល្អ*** *គឺ មានហេតុ អធិប្បាយថា ភោគសម្បត្តិចូរកើតឡើងដោយការណ៍ គឺ តំណែង មានតំណែងសេនាបតី និងសេដ្ឋីជាដើម ។ បទថា* ***យសោ*** *(យស) បានដល់ បរិវារសម្បត្តិ ។ បទថា* ***សហ ញាតីហិ*** *(ព្រមទាំងញាតិ) បានដល់ ព្រមទាំងបណ្តាញាតិ ។ បទថា* ***សហ ឧបជ្ឈាយេហិ*** *(ព្រមទាំងឧបជ្ឈាយ៍) បានដល់ ព្រម*

ទាំងសំឡាញ់ធ្លាប់ឃើញ និងសំឡាញ់សេពគប់ ដែលហៅថា ឧបជ្ឈាយ៍ ព្រោះជួយមើលក្នុងរឿងសុខ និងទុក្ខ ។

បទថា **អកិច្ចំ ករោតិ** (រមែងធ្វើការដែលមិនគួរធ្វើ) គឺ ធ្វើការដែលមិនគួរធ្វើ ។ បទថា **កិច្ចំ អបរាធេតិ** (លះបង់កិច្ចដែលគួរធ្វើ) គឺ កាលមិនធ្វើកិច្ចដែលគួរធ្វើ ឈ្មោះថា លះបង់កិច្ចនោះ ។ បទថា **ធំសតិ** (រមែងវិនាស) បានដល់ រមែងធ្លាក់ទៅ គឺ រមែងសាបសូន្យ ។ បទថា **អភិជ្ឈាវិសមលោភ** បានដល់ សេចក្តីលោភចង់បានដ៏មានកម្លាំង ។ បទថា **បជហាតិ (លះបង់)** បានដល់ បន្ទោបង់ គឺ នាំចេញទៅ ។ បទថា **មហាបញ្ញោ** (អ្នកមានបញ្ញាធំ) បានដល់ អ្នកមានបញ្ញាច្រើន ។ បទថា **បុថុប្បញ្ញោ** បានដល់ អ្នកមានបញ្ញាក្រាស់ ។ បទថា **អាបាថទសោ** (អ្នកយល់អត្ថតាមគន្លងនៃពាក្យ) សេចក្តីថា គេយល់អត្ថនោះៗ តាំងនៅក្នុងគន្លងធម៌ រមែងមកកាន់គន្លង ដែលជាអត្ថដ៏សុខុមនៃធម៌នោះ ។ បទថា **ឧដ្ឋានវិរិយាធិគតេហិ** (ដែលបានមកដោយការខ្នះខ្នែង) បានដល់ ដែលបានមកដោយការព្យាយាម ពោលគឺ ការខ្នះខ្នែង ។ បទថា **ពាហាពលបរិចិតេហិ** (ដែលសន្សំដោយកម្លាំងដៃ) បានដល់ ដែលសន្សំឲ្យច្រើនបានដោយកម្លាំងដៃ ។ បទថា **សេទាវក្ខិត្តេហិ** (ហូរញើសចេញព្រោះធ្វើការងារ) គឺ ញើសហូរ ។

អធិប្បាយថា ដោយសេចក្តីព្យាយាមធ្វើការងារដោយញើសហូរ ។ បទថា **ធម្មិកេហិ** (ត្រូវតាមធម៌) បានដល់ ប្រកបដោយធម៌ ។ បទថា **ធម្មលទ្ធេហិ** (ដែលបានមកដោយធម៌) គឺ បានមកដោយមិនកន្លងកុសលកម្មបថ ១០ ។ បទថា **បត្តកម្មានិ** (កម្មដែលសមគួរ) បានដល់ កម្មដែលសមគួរ ។ បទថា **សុខេតិ** (ចិញ្ចឹម... ឲ្យជាសុខ) បានដល់ ធ្វើឲ្យគេមានសេចក្តីសុខ ។ បទថា **បីណេតិ** (ឲ្យឆ្អែត) បានដល់ រមែងធ្វើឲ្យឆ្អែតស្កប់ស្កល់ សម្បូរណ៍ដោយកម្លាំង ។

បទថា **ឋានំ គតំ ហោតិ** (ជាការប្រព្រឹត្តដល់ហេតុហើយ) បានដល់ ជាហេតុ សួរថា ហេតុនោះដូចម្តេច ។ ឆ្លើយថា ការងារដែលគប្បីធ្វើដោយភោគៈទាំងឡាយ ជាកម្មណាមួយក្នុងបត្តកម្ម ៤ ជាហេតុដែលកើតតែភោគ-ទ្រព្យនោះឯង ។ បទថា **បត្តគតំ** (ជាការសមគួរហើយ) បានដល់ ជាឋានៈដែលគួរដល់ហើយ ។ បទថា **អាយតនសោ បរិភុត្តំ** (ជាការប្រើភោគទ្រព្យដោយផ្លូវដែលគួរប្រើហើយ) បានដល់ បរិភោគហើយដោយហេតុនោះឯង ក៏កើតតែភោគទ្រព្យ ។

បទថា **បរិយោធាយ វត្តតិ** (រមែងបំបាត់) បានដល់ រមែងបិទបាំងទុក ។ អរិយសាវកបរិច្ចាគទ្រព្យ ដើម្បីប្រយោជន៍ដល់ការរំលត់ភ្លើងដែល

ចេះផ្ទះជាដើម រមែងការពារផ្លូវនៃសេចក្តីអន្តរាយទាំងនោះ ដូចជាគ្រាអន្តរាយទាំងឡាយកើតឡើងពីភ្លើងជាដើម ដូច្នោះ ។ បទថា **សោត្ថឹ អត្តានំ ករោតិ** (រមែងធ្វើខ្លួនឲ្យជាសុខចាកអន្តរាយនោះ) សេចក្តីថា រមែងធ្វើខ្លួនឲ្យរួចផុតភ័យ មិនមានអន្តរាយ ។ បទថា **ញាតិពលឹ** គឺ ការសង្គ្រោះញាតិ ។ បទថា **អតិថិពលឹ** គឺ ទទួលភ្ញៀវ ។ បទថា **បុព្វបេតពលឹ** គឺ ធ្វើបុណ្យឧទ្ទិសឲ្យញាតិអ្នកស្លាប់ ។ បទថា **រាជពលឹ** គឺ ចំណែកដែលគួរធ្វើចំពោះព្រះរាជា ។ បទថា **ទេវតាពលឹ** គឺ ធ្វើបុណ្យឧទ្ទិសឲ្យទេវតា ។ បទថា **ញាតិពលឹ** ជាដើមនោះ ជាឈ្មោះរបស់ទាន ដែលគប្បីឲ្យតាមសមគួរដល់បុគ្គលនោះៗ ។

បទថា **ខន្តិសោរច្ចេ និវិដ្ឋា** (អ្នកតាំងនៅក្នុងខន្តិសោរច្ចៈ) សេចក្តីថា តាំងនៅក្នុងអធិវាសនខន្តិ និងក្នុងភាពជាអ្នកមានសីលល្អ ។ បទថា **ឯកមត្តានំ ទមេន្តិ** (ទូន្មានតែខ្លួនមួយ) សេចក្តីថា រមែងទូន្មានអត្តភាពរបស់ខ្លួនតែម្យ៉ាង ដោយការទូន្មានឥន្ទ្រិយ ។ បទថា **សមេន្តិ** (រម្ងាប់) សេចក្តីថា រមែងស្ងប់ចិត្តរបស់ខ្លួន ដោយការស្ងប់កិលេស ។ បទថា **បរិនិព្វាបេន្តិ** (រលត់កិលេស) សេចក្តីថា រមែងរលត់ ដោយការរលត់កិលេស ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឧទ្ធគ្គិកំ** (យ៉ាងខ្ពស់) ជាដើម ទក្ខិណា ឈ្មោះថា

**ឧទ្ធគ្គិកា** (យ៉ាងខ្ពស់) ព្រោះមានផលក្នុងខាងលើ ដោយអំណាចឲ្យផលក្នុងភូមិខ្ពស់ៗ ឡើងទៅ ។ ទក្ខិណាជាប្រយោជន៍ដ៏សម្បូរដល់សួគ៌ ព្រោះហេតុនោះ ទើបឈ្មោះថា **សោវគ្គិកា** (ដែលឲ្យផលដ៏ប្រសើរ) ព្រោះឲ្យកើតក្នុងសួគ៌នោះ ។ បទថា **សុខវិបាកា** (មានសុខជាវិបាក) ព្រោះមានសុខជាវិបាកក្នុងទីកើតហើយ ។ ឈ្មោះថា **សគ្គសំវត្តនិកា** (ជាផ្លូវសួគ៌) ព្រោះធ្វើអារម្មណ៍ដែលល្អ គឺ របស់វិសេស ១០ យ៉ាង មានវណ្ណទិព្វជាដើមឲ្យកើត អធិប្បាយថា រមែងតាំងទក្ខិណាដូច្នោះទុក ។

បទថា **អរិយធម្មេ ឋិតោ** (ឈ្មោះថាតាំងនៅក្នុងអរិយធម៌) គឺ តាំងនៅក្នុងបញ្ចសីល បញ្ចធម៌ ។ បទថា **បេច្ច សគ្គេ បមោទតិ** (លះលោកនេះទៅហើយ រមែងរីករាយក្នុងសួគ៌) សេចក្តីថា នរជននោះទៅបរលោកហើយ រមែងរីករាយក្នុងសួគ៌ដែលខ្លួនបដិសន្ធិ ។ គ្រហស្ថមិនថាជា ព្រះសោតាបន្ន និងព្រះសកទាគាមី ឬអនាគាមីក៏ដោយ បដិបទានេះរមែងបានដូចគ្នាគ្រប់បុគ្គលនោះឯង ។

ចប់អដ្ឋកថា បត្តកម្មសូត្រទី ១

# អដ្ឋកថា អានណ្យសូត្រទី ២

## *"សុខកើតពីការមិនជំពាក់បំណុល"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អានណ្យសូត្រទី ២ ដូចតទៅនេះ ៖*

[៦៣] *បទថា* ***អធិគមនីយានិ*** *(គួរបានទទួល) គឺ គប្បីដល់ ។ បទថា* ***កាមភោគិនា*** *(អ្នកបរិភោគកាម) គឺ អ្នកបរិភោគវត្ថុកាម និងកិលេសកាម ។ បណ្តាសុខ មានអត្ថិសុខជាដើម សុខដែលកើតឡើង ព្រោះភោគទ្រព្យមានហើយ ឈ្មោះថា* ***អត្ថិសុខ*** *(សុខកើតពីការមានទ្រព្យ) ។ សុខដែលកើតឡើងដល់បុគ្គលដែលប្រើប្រាស់ភោគទ្រព្យ ឈ្មោះថា* ***ភោគសុខំ*** *(សុខកើតពីការចាយវាយទ្រព្យបរិភោគ) ។ សុខដែលកើតឡើងថា យើងមិនជំពាក់បំណុល ឈ្មោះថា* ***អនណសុខំ*** *(សុខកើតពីការមិនជំពាក់បំណុល) ។ សុខដែលកើតឡើងពីការប្រាសចាកទោស មិនមានទោស ឈ្មោះថា* ***អនវជ្ជសុខំ*** *(សុខកើតពីការប្រកបការងារដែលប្រាសចាកទោស ។*

*បទថា* ***កុញ្ជំ*** *(ការចាយ) បានដល់ កាលបរិភោគ ។ បទថា* ***បញ្ញា វិបស្សតិ*** *(រមែងពិចារណាឃើញដោយបញ្ញា) បានដល់ រមែងសម្លឹងឃើញដោយបញ្ញា ។ បទថា* ***ឧភោ ភាគេ*** *(ទាំងពីរចំណែក) បានដល់ ពីរចំណែក អធិប្បាយថា ពិចារណាឃើញដោយបញ្ញា រមែងដឹងទាំងពីរចំណែកយ៉ាង*

*នេះថា សេចក្ដីសុខ ៣ ខាងដើម ចាត់ជាចំណែកមួយ ។ សុខកើតពីការប្រកបការងារដែលមិនមានទោស ចាត់ជាចំណែកមួយ ។ បទថា* ***អនវជ្ជសុខស្សេតំ*** *(សុខ ៣ ប្រការខាងដើមនោះ... នៃសុខកើតពីការប្រកបការងារដែលប្រាសចាកទោស) សេចក្ដីថា សុខសូម្បី ៣ យ៉ាងនោះ រមែងមិនដល់ចំណែកទី ១៦ នៃសុខដែលកើតពីការប្រកបការងារមិនមានទោស ដូច្នេះ ។*

ចប់អដ្ឋកថា អានណ្យសូត្រទី ២

# អដ្ឋកថា សព្រហ្មសូត្រទី ៣

*"ត្រកូលដែលមានព្រហ្ម"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សព្រហ្មសូត្រទី ៣ ដូចតទៅនេះ ៖*

[៦៤] *បានពណ៌នាទុកហើយក្នុងតិកនិបាត ។ បទថា **សបុព្វទេវានិ** (មានបុព្វទេវតា) ជាបទដែលប្លែកក្នុងសូត្រនេះ ។*

ចប់អដ្ឋកថា សព្រហ្មសូត្រទី ៣

# អដ្ឋកថា និរយសូត្រទី ៤

*“ធម៌ជាហេតុឲ្យកើតក្នុងនរក”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង និរយសូត្រទី ៤ ដូចតទៅនេះ ៖*

[៦៥] *ក្នុងសូត្រនេះ មានសេចក្តីងាយគ្រប់បទ ។*

ចប់អដ្ឋកថា និរយសូត្រទី ៤

## អដ្ឋកថា រូបសូត្រទី ៥

### "បុគ្គលដែលកាន់យករូបជាប្រមាណ"

គប្បីជ្រាបវិនិច្ឆ័យក្នុង រូបសូត្រទី ៥ ដូចតទៅនេះ ៖

[៦៦] បុគ្គលកាន់ប្រមាណក្នុងរូបហើយជ្រះថ្លា ឈ្មោះថា **រូបប្បមាណោ** (កាន់យករូបជាប្រមាណ) ។ បទថា **រូបប្បសន្នោ** (ជ្រះថ្លាក្នុងរូប) ជាវេវចនៈនៃបទថា **កាន់យករូបជាប្រមាណ** នោះឯង ។ បុគ្គលកាន់ប្រមាណក្នុងសំឡេងគឹកកងហើយជ្រះថ្លា ឈ្មោះថា **ឃោសប្បមាណោ** (មានសំឡេងគឹកកងជាប្រមាណ) ។ បុគ្គលកាន់ប្រមាណក្នុងសេចក្តីសៅហ្មងរបស់ចីវរ និងបាត្រហើយជ្រះថ្លា ឈ្មោះ **លូខប្បមាណោ** (មានសេចក្តីសៅហ្មងជាប្រមាណ) ។ បុគ្គលកាន់ប្រមាណក្នុងធម៌ហើយជ្រះថ្លា ឈ្មោះថា **ធម្មប្បមាណោ** (មានធម៌ជាប្រមាណ) ។ បទក្រៅពីនេះ ជាវេវចនៈរបស់បទទាំងនោះឯង ។ ព្រោះចែកសត្វទាំងអស់ចេញជាបីចំណែក ពីរចំណែកកាន់យករូបជាប្រមាណ មួយចំណែកមិនកាន់យករូបជាប្រមាណ ។ ព្រោះចែកសត្វទាំងអស់ចេញជាប្រាំចំណែក បួនចំណែកកាន់យកសំឡេងជាប្រមាណ មួយចំណែកមិនកាន់យកសំឡេងជាប្រមាណ ។ ព្រោះចែកសត្វទាំងអស់ចេញជាដប់ចំណែក ប្រាំបួនចំណែកកាន់យកសេចក្តីសៅហ្មងជាប្រមាណ មួយ

---

※ = ២/៣ , ៤/៥ , ៩/១០ , ១/១០០.០០០

ចំណែកមិនកាន់យកសេចក្ដីសៅហ្មងជាប្រមាណ ។ កាលបែកសត្វទាំងអស់ចេញជាមួយសែនចំណែក តែមួយចំណែកប៉ុណ្ណោះ កាន់យកធម៌ជាប្រមាណដ៏សេសគប្បីជ្រាបថា មិនកាន់យកធម៌ជាប្រមាណទេ ។

បទថា **រូបេន បាមឹសុ** (មានរូបជាប្រមាណ) សេចក្ដីថា បុគ្គលពួកណាឃើញរូបហើយជ្រះថ្លា បុគ្គលពួកនោះ ឈ្មោះថា មានរូបជាប្រមាណ អធិប្បាយថា រាប់អានហើយ ។ បទថា **ឃោសេន អន្វគូ** (បណ្ដោយទៅតាមសំឡេង) សេចក្ដីថា បុគ្គលពួកណាហួរទៅតាមសំឡេង អធិប្បាយថា បុគ្គលពួកនោះមានសំឡេងជាប្រមាណ ហើយទើបជ្រះថ្លា ។ បទថា **ឆន្ទរាគវសូបេតា** (ធ្លាក់ក្នុងអំណាចសេចក្ដីពេញចិត្តហើយ) បានដល់ ធ្លាក់ក្នុងអំណាចសេចក្ដីពេញចិត្ត និងស្រឡាញ់ហើយ ។ បទថា **អជ្ឈត្តញ្ច ន ជានាតិ** (រមែងមិនដឹង "គុណធម៌" ខាងក្នុង) សេចក្ដីថា បុគ្គលល្ងង់ខ្លៅរមែងមិនស្គាល់គុណខាងក្នុងរបស់គេ ។ បទថា **ពហិទ្ធា ច ន បស្សតិ** (ទាំងមិនឃើញ "វត្តបដិបត្តិ" ខាងក្រៅ) សេចក្ដីថា រមែងមិនឃើញវត្តបដិបត្តិខាងក្រៅរបស់គេ ។ បទថា **សមន្តាវរណោ** (ត្រូវសំឡេងបិទបាំង "បញ្ញា" បានដល់ ត្រូវសំឡេងបិទបាំងជានិច្ច ។ម្យ៉ាងទៀត ឈ្មោះថា **ត្រូវសំឡេងបិទបាំងដោយជុំវិញ** ព្រោះសំឡេងរាំងដោយជុំវិញ ។ បទថា **ឃោសេន វុយ្ហតិ**

សេចក្តីថា បុគ្គលល្ងង់នោះត្រូវសំឡេងបន្សាត់នាំទៅ មិនមែនត្រូវគុណនាំទៅទេ ។ បទថា **អជ្ឈត្តញ្ច ន ជានាតិ ពហិទ្ធា ច វិបស្សតិ** (មិនឃើញខាងក្នុង តែឃើញចំណែកខាងក្រៅ) សេចក្តីថា បុគ្គលមិនដឹងគុណខាងក្នុង តែឃើញការបដិបត្តិខាងក្រៅរបស់គេ ។ បទថា **ពហិទ្ធា ផលទស្សាវី** (ឃើញតែផល "លាភសក្ការៈ" ខាងក្រៅ) សេចក្តីថា ឃើញផលសក្ការៈខាងក្រៅ ដែលបុគ្គលដទៃធ្វើដល់គេ ។ បទថា **វិនីវរណទស្សាវី** (ឃើញច្បាស់មិនមានអ្វីជាគ្រឿងបិទបាំង) សេចក្តីថា ឃើញមិនមានអ្វីបិទបាំង ។ បទថា **ន សោ ឃោសេន វុយ្ហតិ** (បុគ្គលនោះមិនត្រូវសំឡេងបន្សាត់នាំទៅ) សេចក្តីថា បុគ្គលនោះ ទើបមិនត្រូវសំឡេងដឹកនាំទៅ ។

ចប់អដ្ឋកថា រូបសូត្រទី ៥

# អដ្ឋកថា សភាគសូត្រទី ៦

## *"បុគ្គលមានរាគៈជាដើម"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សភាគសូត្រទី ៦ ដូចតទៅនេះ ៖*

*[៦៧] បទថា* ***មោហជំ***[១] ***វាបិ អវិទ្ទសុ*** *(បុគ្គលល្ងង់ធ្វើអកុសលកម្ម ដែលកើតព្រោះមោហៈខ្លះ) សេចក្តីថា បុគ្គលល្ងង់ គឺ មិនមែនបណ្ឌិត ធ្វើ អកុសលកម្មដែលកើតឡើងព្រោះមោហៈខ្លះ ។ បទថា* ***សវិឃាតំ*** *(ដែលមានសេចក្តីចង្អៀតចង្អល់) គឺ ប្រព្រឹត្តទៅជាមួយទុក្ខ ។ បទថា* ***ទុក្ខុទ្រយំ*** *(មានផលជាទុក្ខ) គឺ បន្ថែមទុក្ខតទៅទៀត ។ បទថា* ***អចក្ខុកា*** *(មិនមានចក្ខុ) គឺ វៀរចាកបញ្ញាចក្ខុ ។ បទថា* ***យថា ធម្មា តថា សន្តា*** *(ធម៌ ៣ មានហើយ យ៉ាងណា គេក៏នៅហើយយ៉ាងនោះ) សេចក្តីថា ធម៌មានរាគៈជាដើម តាំងនៅយ៉ាងណា បុគ្គលល្ងង់ទាំងនោះ ក៏មានសភាពយ៉ាងនោះ ។ បទថា* ***ន តស្សេវន្តិ មញ្ញរេ*** *(មិនដឹងខ្លួនថា ជាយ៉ាងនោះ) សេចក្តីថា គេរមែងមិនស្គាល់ គឺ រមែងមិនដឹងខ្លួនថា យើងជាយ៉ាងនោះ មានសភាពយ៉ាងនោះឯងផង ។ ទាំងក្នុងព្រះសូត្រទាំងក្នុងព្រះគាថា ត្រាស់វដ្តៈតែម្យ៉ាង ។*

ចប់អដ្ឋកថា សភាគសូត្រទី ៦

---

*(១) បិដក = មោជំ ។*

# អដ្ឋកថា អហិសូត្រទី ៧

## *"ផ្សាយមេត្តាចិត្តដល់ត្រកូលស្តេចពស់"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អហិសូត្រទី ៧ ដូចតទៅនេះ ៖*

[៦៨] *បទថា* ***ឥមានិ ចត្តារិ អហិរាជកុលានិ*** *(ត្រកូលស្តេចពស់ទាំង ៤ នេះ) ត្រាស់សំដៅដល់ពិសដែលត្រូវពស់ខាំ ពិសដែលត្រូវពស់ខាំពួកណាមួយ ពិសទាំងអស់នោះ នៅក្នុងត្រកូលស្តេចពស់ទាំង ៤ នេះ ។ បទថា* ***អត្តគុត្តិយា*** *គឺ ដើម្បីឃុំគ្រងខ្លួន ។ បទថា* ***អត្តរក្ខាយ*** *គឺ ដើម្បីរក្សាខ្លួន ។ បទថា* ***អត្តបរិត្តាយ*** *គឺ ដើម្បីការពារខ្លួន ។ អធិប្បាយថា តថាគតទើបអនុញ្ញាតបរិត្តទុកដូច្នេះ ។*

*ឥឡូវនេះ ភិក្ខុគប្បីធ្វើបរិត្តនោះដោយវិធីណា កាលទ្រង់សម្តែងវិធីនោះ ទើបត្រាស់ថា* ***វិរូបក្ខេហិ មេ*** *(របស់យើង ចូរមានជាមួយពស់ត្រកូលវិរូបក្ខៈទាំងឡាយ) ជាដើម ។ ក្នុងបទទាំងនោះ បទថា* ***វិរូបក្ខេហិ*** *(ជាមួយពស់ត្រកូលវិរូបក្ខៈទាំងឡាយ) បានដល់ មានមេត្តាចិត្តជាមួយពស់ត្រកូលវិរូបក្ខៈទាំងឡាយ ។ សូម្បីក្នុងត្រកូលពស់ដ៏សេស ក៏ន័យនេះដូចគ្នា ។ បទថា* ***អបាទកេហិ*** *បានដល់ ជាមួយសត្វមិនមានជើងទាំងឡាយ ។ សូម្បីក្នុងសត្វដ៏សេសក៏មានន័យនេះដូចគ្នា ។ សេចក្តីថា ជាដំបូង ទ្រង់ត្រាស់មេត្តា*

ចំពោះ ដោយឋានៈប្រមាណប៉ុណ្ណោះហើយ ឥឡូវនេះ ទើបផ្តើមបទថា **សព្វេ សត្តា** (សត្វទាំងពួង) នេះ ដើម្បីត្រាស់មេត្តាមិនចំពោះ ។ ក្នុងបទទាំងនោះ បទថា **សព្វេ បាណា** (សត្វដែលមានខ្យល់ដកដង្ហើមទាំងអស់) ទាំងអស់នេះ ជាពាក្យពោលដល់បុគ្គលប៉ុណ្ណោះ ។ បទថា **ភទ្រានិ បស្សន្តុ** (ចូរប្រសព្វតែសេចក្តីចម្រើន) សេចក្តីថា ចូរឃើញតែអារម្មណ៍ដែលចម្រើនចិត្តចុះ ។ បទថា **មា កញ្ចិ បាបមាគមា** (កុំបានទទួលទោសដ៏លាមកអ្វីៗ ឡើយ) សេចក្តីថា វត្ថុដែលជាបាបដ៏លាមកកុំបានមកប្រសព្វក្នុងសត្វណាៗ ឡើយ ។ ក្នុងបទថា **អប្បមាណោ ពុទ្ធោ** (ព្រះពុទ្ធទ្រទ្រង់គុណរកប្រមាណមិនបាន) នេះ គប្បីជ្រាប ពុទ្ធគុណថា **ពុទ្ធោ** ពិតណាស់ ពុទ្ធគុណទាំងនោះឈ្មោះថា ហួសពីការប្រមាណ ។ សូម្បីក្នុងពីរបទដ៏សេស ក៏ន័យនេះឯង ។ បទថា **បមាណវន្តានិ** (មានគុណល្មមប្រមាណ) បានដល់ ប្រកបហើយដោយប្រមាណនៃគុណ ។ បទថា **ឧណ្ណានាភី** បានដល់ ពីងពាងមានរោមត្រង់ពោះ ។ បទថា **សរពូ** បានដល់ តុកកែក្នុងផ្ទះ ។ បទថា **កតា មេ រក្ខា កតា មេ បរិត្តា** (ការរក្សាយើងបានធ្វើហើយ ការការពារយើងបានធ្វើហើយ) សេចក្តីថា ការរក្សា និងការការពារ ខ្ញុំបានធ្វើហើយ ដល់ជនប្រមាណប៉ុណ្ណោះ ។ បទថា **បដិក្កមន្តុ ភូតានិ** (សូមសត្វទាំងឡាយចូរចៀសចេញ) សេចក្តីថា

*សត្វទាំងឡាយសូម្បីទាំងអស់ ដែលខ្ញុំធ្វើការការពារហើយ ចូរចៀសចេញទៅ អធិប្បាយថា កុំបៀតបៀនខ្ញុំឡើយ ។*

ចប់អដ្ឋកថា អហិសូត្រទី ៧

# អដ្ឋកថា ទេវទត្តសូត្រទី ៨

## "រឿងព្រះទេវទត្ត"

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទេវទត្តសូត្រទី ៨ ដូចតទៅនេះ ៖*

[៦៩] *បទថា* ***អចិរបក្កន្តេ ទេវទត្តេ*** *(កាលព្រះទេវទត្តគេចចេញទៅមិនយូរ) សេចក្តីថា កាលទេវទត្តធ្វើសង្ឃភេទហើយ ចៀសចេញទៅមិនយូរ ។ បទថា* ***បរាភវាយ*** *(ដើម្បីសេចក្តីវិនាស) បានដល់ ដើម្បីសេចក្តីសាបសូន្យ ដើម្បីសេចក្តីវិនាស ។ បទថា* ***អស្សតរី*** *(សូម្បីសេះអស្សតរ) សេចក្តីថា សេះអស្សតរ កើតក្នុងផ្ទៃរបស់មេលា ។ បទថា* ***អត្តវធាយ គព្ភំ គណ្ហាតិ*** *(មេសេះអស្សតរតាំងគភ៌សម្រាប់សម្លាប់ខ្លួន) សេចក្តីថា បុគ្គលទាំងឡាយផ្សំមេលានោះជាមួយបាសេះ មេសេះអស្សតរនោះក៏តាំងផ្ទៃ កាលដល់វេលាក៏កើតកូនមិនបាន ឈរយកជើងទាំង ២ កកាយផែនដី ដូច្នោះ គេទើបចងជើងទាំង ៤ របស់វាទុកទ្រង់បង្គោល ៤ ហើយវះពោះនាំកូនចេញ វាក៏ស្លាប់ក្នុងទីនោះឯង ព្រោះហេតុនេះ ទ្រង់ទើបត្រាស់ដល់មេសេះអស្សតរនោះ ។*

ចប់អដ្ឋកថា ទេវទត្តសូត្រទី ៨

# អដ្ឋកថា បធានសូត្រទី ៩

## *"សេចក្ដីព្យាយាម ៤ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បធានសូត្រទី ៩ ដូចតទៅនេះ ៖*

[៧០] *សេចក្ដីព្យាយាមដើម្បីប្រយ័ត្នចំពោះកិលេស គឺ ដើម្បីបិទផ្លូវចូលរបស់កិលេស ឈ្មោះ* ***សំវរប្បធានំ*** *(ព្យាយាមប្រយ័ត្ន) ។ ព្យាយាមដើម្បីលះ ឈ្មោះ* ***បហានប្បធានំ*** *(ព្យាយាមលះ) ។ ព្យាយាមដើម្បីចម្រើនកុសលធម៌ ឈ្មោះ* ***ភាវនាប្បធានំ*** *(ព្យាយាមបំពេញ) ។ ព្យាយាមដើម្បីតាមរក្សាកុសលធម៌ទាំងនោះ ឈ្មោះ* ***អនុរក្ខនាបធានំ*** *(ព្យាយាមតាមរក្សាទុក) ។*

ចប់អដ្ឋកថា បធានសូត្រទី ៩

# អដ្ឋកថា ធម្មិកសូត្រទី ១០

## *"អ្នកប្រព្រឹត្តធម៌ និងមិនមែនធម៌"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ធម្មិកសូត្រទី ១០ ដូចតទៅនេះ ៖*

[៧១] *បទថា **អធម្មិកា ហោន្តិ** (មិនប្រព្រឹត្តធម៌) សេចក្តីថា ព្រះរាជាទាំងឡាយមិនប្រព្រឹត្តធម៌ ដោយមិនរក្សាសួយ ១០ ចំណែក ដែលព្រះរាជាជំនាន់មុនទ្រង់តាំងទុកហើយ និងមិនដាក់ទោសតាមសមគួរដល់កំហុស រក្សាសួយហួសការកំណត់ និងដាក់ទោសហួសកំណត់ ។ បទថា **រាជយុត្តា** (ខ្ញុំរាជការទាំងឡាយ) បានដល់ ក្នាក់ងារជាមេដែលមាននាទីធ្វើការរាជការនៅក្នុងជនបទរបស់ព្រះរាជា ។ បទថា **ព្រាហ្មណគហបតិកា** (ព្រាហ្មណ៍និងគហបតី) បានដល់ ព្រាហ្មណ៍ និងគហបតីទាំងឡាយ អ្នកនៅខាងក្នុងក្រុង ។ បទថា **នេគមជានបទា** បានដល់ អ្នកនិគម និងអ្នកជនបទ ។ បទថា **វិសមំ** (មិនស្មើ) សេចក្តីថា ខ្យល់ក៏ប្រែប្រួលទៅ មិនត្រូវតាមរដូវ ។ បទថា **វិសមា** (ប្រែប្រួល) សេចក្តីថា ខ្យល់បក់មិនស្មើ បក់ខ្លាំងខ្លះ បក់តិចខ្លះ ។ បទថា **អបញ្ញសា** (ខ្យល់ក្រៅផ្លូវ) បានដល់ ខ្យល់ខុសផ្លូវ បក់ខុសផ្លូវ ។ បទថា **ទេវតា បរិកុបិតា ភវន្តិ** (ទេវតាទាំងឡាយក៏ខឹងសម្បា) សេចក្តីថា ព្រោះថា កាលខ្យល់បក់ខុសផ្លូវ បក់មិនស្មើ ដើមឈើទាំងឡាយ*

ក៏បាក់ វិមានក៏រញ្ជួយ ព្រោះដូច្នោះ ពួកទេវតាក៏ខឹងសម្បា ។ ទេវតាទាំងនោះ ទើបមិនឲ្យភ្លៀងធ្លាក់តាមរដូវកាល ។ ព្រោះហេតុនោះ ទើបត្រាស់ថា **ទេវោ ន សម្មា ធារំ អនុប្បវេច្ឆតិ** (ភ្លៀងក៏មិនធ្លាក់តាមរដូវកាល) ។ បទថា **វិសមបាកីនិ សស្សានិ ភវន្តិ** (ស្រូវទាំងឡាយក៏ទុំមិនល្អ) សេចក្តីថា ស្រូវទាំងឡាយក៏ទុំមិនស្មើគ្នា យ៉ាងនេះគឺ ក្នុងទីកន្លែងមួយមូលដើម ក្នុងទីកន្លែងមួយដាក់ទឹកដោះ ទីកន្លែងមួយចាស់ ។

បទថា **សមំ នក្ខត្តានិ តារករូបានិ បរិវត្តន្តិ** (ផ្កាយនក្ខត្តឫក្សទាំងឡាយក៏ដើរមិនស្មើ) សេចក្តីថា ផ្កាយនក្ខត្តឫក្សទាំងឡាយ រមែងវិលស្មើ ដូចថ្ងៃពេញបូណ៌មីនោះ បាននក្ខត្តឫក្សនោះៗ ក្នុងខែនោះយ៉ាងនេះថា ថ្ងៃពេញបូណ៌មីខែ ១២ បាននក្ខត្តឫក្សក្នុងខែ ១២ ប៉ុណ្ណោះ ថ្ងៃពេញបូណ៌មីខែមិគសិរ បាននក្ខត្តឫក្សក្នុងខែមិគសិរប៉ុណ្ណោះ ដូច្នោះ ។ បទថា **សមំ វាតា វាយន្តិ** (ខ្យល់ក៏បក់ប្រក្រតី) សេចក្តីថា ខ្យល់ទាំងឡាយមិនមែនបក់មិនស្មើ បក់ក្នុងរដូវកាលប៉ុណ្ណោះ រមែងបក់ក្នុងរដូវដែលសមគួរដល់ជនបទទាំងនោះ យ៉ាងនេះ គឺ ខ្យល់ខាងជើងបក់ ៦ ខែ ខ្យល់ខាងត្បូងបក់ ៦ ខែ ។ បទថា **សមា** (ស្មើ) សេចក្តីថា ខ្យល់បក់ស្មើ មិនខ្លាំងពេកទៅមិនតិចពេក ។ បទថា **បញ្ចសា** (ខ្យល់ត្រូវផ្លូវ) បានដល់ ខ្យល់ដែល

បក់ត្រូវផ្លូវ រមែងបក់តាមផ្លូវនុ៎ះឯង មិនមែនបក់ខុសផ្លូវទេ ។

បទថា **ជិម្ហំ គច្ឆតិ** (ទៅផ្លូវខុស) បានដល់ ដើរផ្លូវខុស គឺ រមែងកាន់យកតែទីមិនមែនកំពង់ ។ បទថា **នេត្តេ ជិម្ហំ គតេ សតិ** (ព្រោះហេតុដែលមេគោហ្វូងនាំផ្លូវខុស) បានដល់ គោ ឈ្មោះថា **នេត្តា** ព្រោះនាំទៅ ។ អធិប្បាយថា កាលមេគោនាំដើរខុសផ្លូវ កាន់យកតែទីមិនមែនកំពង់ គោសូម្បីពីក្រៅនេះ រមែងកាន់យកតែទីមិនមែនកំពង់តាមគ្នាទៅ ។ បាឋៈថា **នេន្តេ** ដូច្នេះក៏មាន ។ បទថា **ទុក្ខំ សេតិ** បានដល់ រមែងដេកកើតទុក្ខ អធិប្បាយថា ប្រសព្វទុក្ខហើយ ។

ចប់អដ្ឋកថា ធម្មិកសូត្រទី ១០

## ចប់បត្តកម្មវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# អបណ្ណកវគ្គវណ្ណនាទី ៣

## អដ្ឋកថា បធានសូត្រទី ១

*"សេចក្ដីព្យាយាមជាហេតុអស់អាសវៈ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បធានសូត្រទី ១ ដូចតទៅនេះ ៖*

[៧២] *បទថា* ***អបណ្ណកប្បដិបទា*** *គឺ ការបដិបត្តិមិនខុស ។ បទថា* ***យោនិ ចស្ស អារទ្ធា ហោតិ*** *(ហេតុនៃការអស់អាសវៈ ឈ្មោះថា ភិក្ខុនោះបានផ្ដើមហើយ) សេចក្ដីថា ក៏ហេតុនៃការអស់អាសវៈរបស់ភិក្ខុនោះ បរិបូរណ៍ហើយ ។ បទថា* ***អាសវានំ ខយាយ*** *(នៃការអស់អាសវៈ) បានដល់ដើម្បីព្រះអរហត្ត ។*

ចប់អដ្ឋកថា បធានសូត្រទី ១

# អដ្ឋកថា ទិដ្ឋិសូត្រទី ២

*"ទិដ្ឋិជាហេតុអស់អាសវៈ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទិដ្ឋិសូត្រទី ២ ដូចតទៅនេះ ៖*

[៧៣] *ក្នុងសូត្រនេះ មានអត្ថងាយហើយនោះឯង ។*

ចប់អដ្ឋកថា ទិដ្ឋិសូត្រទី ២

# អដ្ឋកថា សប្បុរិសសូត្រទី ៣

## *“ធម៌របស់អសប្បុរស និងសប្បុរស”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សប្បុរិសសូត្រទី ៣ ដូចតទៅនេះ ៖*

[៧៤] *បទថា* ***អវណ្ណោ*** *(ជាប្រការវិនាស) បានដល់ មិនមែនគុណ ។ បទថា* ***បាតុករោតិ*** *(ផ្សាយ) បានដល់ ប្រាប់ធ្វើឱ្យប្រាកដ ។ បទថា* ***បញ្ហាភិនីតោ*** *(ត្រូវសាកសួរ) បានដល់ ត្រូវនាំមកសួរ ។ បទថា* ***អហាបេត្វា អលម្ពេត្វា*** *(មិនខ្វះខាត មិនបញ្ចិតបញ្ចៀង) បានដល់ ធ្វើមិនឱ្យខ្វះ ឱ្យពិស្តារពេញទី ។ មួយទៀត ក្នុងសេចក្តីនេះ អសប្បុរស រមែងបិទបាំងសេចក្តីវិនាសរបស់ខ្លួន ព្រោះជាអ្នកប្រាថ្នាលាមក សប្បុរស រមែងបិទបាំងកិត្តិគុណរបស់ខ្លួន ព្រោះជាអ្នកខ្មាស ។ ព្រោះហេតុដែលអសប្បុរសមិនមានហិរិឱត្តប្បៈ នៅរួមគ្នាក៏មើលងាយ ចំណែកសប្បុរសប្រកបដោយហិរិឱត្តប្បៈ នៅរួមគ្នាក៏មិនមើលងាយ ដូច្នោះ ឥឡូវនេះ ដើម្បីទ្រង់សម្តែងសាធកៈភាពជាសប្បុរស ប្រៀបដូចកូនប្រសារថ្មី ទើបត្រាស់ថា* ***សេយ្យថាបិ ភិក្ខវេ វធុកា*** *(ម្នាលភិក្ខុទាំងឡាយ កូនប្រសាស្រី... យ៉ាងណា) ជាដើម ។ ក្នុងបទទាំងនោះ បទថា* ***វធុកា*** *(កូនប្រសាស្រី) បានដល់ កូនប្រសារ ។ បទថា* ***តិព្វំ*** *(ច្រើន) គឺ កោតក្រែងច្រើន ។ បទដ៏សេសក្នុងសូត្រនេះងាយទាំងអស់*

*នោះឯង ។*

ចប់អដ្ឋកថា សប្បុរិសសូត្រទី ៣

# អដ្ឋកថា បឋមអគ្គសូត្រទី ៤

## *"ធម៌ដ៏ប្រសើរ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអគ្គសូត្រទី ៤ ដូចតទៅនេះ ៖*

[៧៥] *បទថា* ***សីលគ្គំ*** *(សីលដ៏ប្រសើរ) គឺ ខ្ពង់ខ្ពស់បំផុត ។ ក្នុងបទទាំងពួង ក៏មានន័យនេះឯង ។*

ចប់អដ្ឋកថា បឋមអគ្គសូត្រទី ៤

# អដ្ឋកថា ទុតិយអគ្គសូត្រទី ៥

## “ធម៌ដ៏ប្រសើរ”

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអគ្គសូត្រទី ៥ ដូចតទៅនេះ ៖*

*[៧៦] បទថា **រូបគ្គំ** (រូបដ៏ប្រសើរ) សេចក្តីថា បុគ្គលពិចារណារូបណាហើយ រមែងសម្រេចព្រះអរហត្ត រូបនេះ ឈ្មោះថា រូបដ៏ប្រសើរ សូម្បីក្នុងបទដ៏សេសក៏ន័យនេះឯង ។ ចំណែកក្នុងបទថា **ភវគ្គំ** (ភពដ៏ប្រសើរ) នេះ បុគ្គលតាំងនៅក្នុងអត្តភាពណា រមែងសម្រេចព្រះអរហត្តក្នុងអត្តភាពនោះ ឈ្មោះថា ភពដ៏ប្រសើរនោះឯង ។*

ចប់អដ្ឋកថា ទុតិយអគ្គសូត្រទី ៥

# អដ្ឋកថា កុសិនារាសូត្រទី ៦

## *"ពុទ្ធកិច្ចក្នុងកុសិនារា"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កុសិនារាសូត្រទី ៦ ដូចតទៅនេះ ៖*

*[៧៧] បទថា* ***ឧបវត្តនេ*** *(ត្រង់ផ្លូវកណ្តាលបត់ចូល) បានដល់ ក្នុងទីកណ្តាលផ្លូវនៃដើមសាលៈដែលដុះនៅទិសខាងកើត វៀងទៅ ហើយបត់តាមផ្លូវទៅទិសខាងជើង ។ បទថា* ***អន្តរេ យមកសាលានំ*** *(ចន្លោះដើមសាលៈមួយគូ) បានដល់ ក្នុងចន្លោះដើមសាលៈពីរដើម ។ បទថា* ***កង្ខា*** *(សេចក្តីសង្ស័យ) បានដល់ សេចក្តីងឿងឆ្ងល់ ។ បទថា* ***វិមតិ*** *(សេចក្តីងឿងឆ្ងល់) គឺ មិនអាចនឹងកាត់ក្តីបាន ។ សេចក្តីសង្ខេប ក្នុងប្រការនេះ មានដូច្នេះថា ភិក្ខុរូបណាគប្បីកើតសេចក្តីសង្ស័យថា ព្រះពុទ្ធ ឬមិនមែនព្រះពុទ្ធ ព្រះធម៌ ឬមិនមែនព្រះធម៌ ព្រះសង្ឃ ឬមិនមែនព្រះសង្ឃ មគ្គ ឬមិនមែនមគ្គ បដិបទា ឬមិនមែនបដិបទា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងប្រាប់សេចក្តីនោះដល់ភិក្ខុរូបនោះ ពួកអ្នកចូរសួរចុះ ។*

*បទថា* ***សត្ថុគារវេនបិ ន បុច្ឆេយ្យាថ*** *(អ្នកទាំងឡាយមិនសួរ ព្រោះសេចក្តីគោរពក្នុងព្រះសាស្តា) សេចក្តីថា បើពួកអ្នកមិនសួរ ព្រោះសេចក្តីគោរពក្នុងព្រះសាស្តាយ៉ាងនេះថា ពួកយើងបួសក្នុងសម្នាក់របស់ព្រះសាស្តា*

សូម្បីបច្ច័យ ៤ ជារបស់ព្រះសាស្តារបស់ពួកយើង ពួកយើងមិនសង្ស័យ រហូតអស់កាលប្រមាណប៉ុណ្ណោះហើយ ក៏មិនគួរនឹងធ្វើសេចក្តីសង្ស័យក្នុងថ្ងៃនេះ ដែលជាបច្ឆិមកាល ។ ដោយបទថា **សហាយកោបិ ភិក្ខវេ សហាយកស្ស អារោចេតុ** (សូម្បីភិក្ខុដែលជាសំឡាញ់ក៏ចូរប្រាប់ដល់សំឡាញ់តៗគ្នាទៅ ទ្រង់សម្តែងថា បណ្តាពួកអ្នក ភិក្ខុណាជាសំឡាញ់ ឃើញសំឡាញ់របស់ភិក្ខុណា ភិក្ខុនោះចូរប្រាប់ដល់ភិក្ខុនោះ តថាគតនឹងប្រាប់ដល់ភិក្ខុមួយរូប ពួកអ្នកស្តាប់ពាក្យរបស់ភិក្ខុនោះហើយ ក៏នឹងនាំគ្នាអស់សង្ស័យ ។ បទថា **ឯវំ បសន្នោ** (ខ្ញុំព្រះអង្គជ្រះថ្លា... យ៉ាងនេះ) សេចក្តីថា ខ្ញុំព្រះអង្គជឿយ៉ាងនេះ ។ បទថា **ញាណមេវ** (បានដឹង) សេចក្តីថា ញាណដែលធ្វើឲ្យប្រចក្សដល់ការៈដែលភិក្ខុមិនមានសេចក្តីសង្ស័យ មិនមែនត្រឹមតែការជឿរបស់តថាគតក្នុងសេចក្តីនេះ ។ បទថា **ឥមេសំ ហិ អានន្ទ** (អានន្ទ... នេះ) សេចក្តីថា បណ្តាភិក្ខុប្រមាណ ៥០០ រូបនេះ ដែលអង្គុយនៅខាងក្នុងវាំងនន ។ បទថា **យោ បច្ឆិមកោ** (ភិក្ខុដែលមានគុណធម៌ទាបបំផុត) ទ្រង់ត្រាស់ដល់ព្រះអានន្ទត្ថេរៈ ដែលជាភិក្ខុអ្នកមានគុណទាបទីបំផុត ។

អដ្ឋកថាកុសិនារា សូត្រទី ៦

# អដ្ឋកថា អចិន្តេយ្យសូត្រទី ៧

## *"អចិន្តេយ្យ ៤ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អចិន្តេយ្យសូត្រទី ៧ ដូចតទៅនេះ ៖*

*[៧៨] បទថា* ***អចិន្តេយ្យានិ*** *បានដល់ មិនគួរគិត ។ បទថា* ***នចិន្តេតព្វានិ*** *សេចក្តីថា បុគ្គលមិនគួរគិត ព្រោះជាអចិន្តេយ្យទាំងឯង ។ បទថា* ***យានិ ចិន្តេន្តោ*** *(អ្នកគិត) គឺ គិតវត្ថុដែលមិនមានហេតុពួកណា ។ បទថា* ***ឧម្មាទស្ស*** *(នៃសភាពឆ្កួត) បានដល់ ភាពជាបុគ្គលឆ្កួត ។ បទថា* ***វិឃាតស្ស*** *(សេចក្តីលំបាក) គឺ ជាទុក្ខ ។ បទថា* ***ពុទ្ធវិសយោ*** *(ពុទ្ធវិស័យ) ប្រែថា វិស័យរបស់ព្រះពុទ្ធទាំងឡាយ គឺ ការប្រព្រឹត្តទៅ និងអានុភាពរបស់ព្រះពុទ្ធគុណ មានព្រះសព្វញ្ញុតញ្ញាណជាដើម ។ បទថា* ***ឈានវិសយោ*** *បានដល់ ឈានវិស័យក្នុងអភិញ្ញា ។ បទថា* ***កម្មវិបាកោ*** *(កម្មវិបាក) បានដល់ វិបាករបស់កម្ម មានកម្មដែលគប្បីសោយផលក្នុងបច្ចុប្បន្នជាដើម ។ បទថា* ***លោកចិន្តា*** *សេចក្តីថា ការគិតរឿងលោក ដូចជា នរណាសាងព្រះច័ន្ទ និងព្រះអាទិត្យ នរណាសាងផែនដីធំ នរណាសាងមហាសមុទ្រ នរណាសាងសត្វឲ្យកើត នរណាសាងភ្នំ នរណាសាងដើមស្វាយ ដើមត្នោត និងដើមដូងជាដើម ។*

ចប់អដ្ឋកថា អចិន្តេយ្យសូត្រទី ៧

---

# អដ្ឋកថា ទក្ខិណាសូត្រទី ៨

## “សេចក្តីបរិសុទ្ធនៃទក្ខិណា”

គប្បីជ្រាបវិនិច្ឆ័យក្នុង ទក្ខិណាសូត្រទី ៨ ដូចតទៅនេះ ៖

[៧៩] បទថា **ទក្ខិណាវិសុទ្ធិយោ** (សេចក្តីបរិសុទ្ធនៃទក្ខិណា) បានដល់ ហេតុទាំងឡាយនៃសេចក្តីបរិសុទ្ធរបស់ទក្ខិណា គឺ ទាន ។ បទថា **ទាយកតោ វិសុជ្ឈតិ** (បរិសុទ្ធចំណែកទាយក) សេចក្តីថា រមែងបរិសុទ្ធព្រោះមានផលច្រើន ។ បទថា **កល្យាណធម្មោ** (មានកល្យាណធម៌) គឺ ជាអ្នកមានធម៌ដែលស្អាត ។ បទថា **បាបធម្មោ** (មានបាបធម៌) គឺ ជាអ្នកមានធម៌ដ៏លាមក ។ ក្នុងបទថា **បរិសុទ្ធចំណែកទាយក** នេះ គួរពោលដល់ព្រះវេស្សន្តរមហារាជ ។ បានឮថា វេស្សន្តរមហារាជនោះ ឲ្យទារកដល់ព្រាហ្មណ៍ឈ្មោះជូជក ធ្វើមហាប្រថពីឲ្យកម្រើកហើយ ។ ក្នុងបទថា **បដិគ្គាហកតោ វិសុជ្ឈតិ** (បរិសុទ្ធចំណែកបដិគ្គាហកៈ) នេះ គួរពោលដល់អ្នកប្រមង់ (អ្នកនេសាទ) ដែលនៅត្រង់ទ្វារមាត់ទន្លេកល្យាណី ។ បានឮថា អ្នកប្រមង់នោះ បានថ្វាយបិណ្ឌបាតបីដងដល់ព្រះទីឃសុមនត្ថេរៈ ដេកលើគ្រែមរណៈពោលថា បិណ្ឌបាតដែលបានថ្វាយដល់លោកម្ចាស់ទីឃសុមនត្ថេរ ជួយយើងបាន ។ ក្នុងបទថា **នេវ ទាយកតោ** (មិនបរិសុទ្ធខាងទាយក) នេះ គួរពោល

ដល់នាយព្រានអ្នកនៅស្រុកវឌ្ឍមានៈ ។ បានឮថា ព្រាននោះកាលធ្វើបុណ្យឧទ្ទិសដើម្បីអ្នកដែលស្លាប់ ទើបបានឲ្យដល់បដិគ្គាហកៈអ្នកទ្រុស្តសីលមួយនាក់អស់បីដង ។ ក្នុងលើកទីបី អមនុស្ស (អ្នកស្លាប់ទៅកើតជាប្រេត) ស្រែកថា បដិគ្គាហកៈទ្រុស្តសីលប្លន់យើង ។ ទក្ខិណាដល់អ្នកស្លាប់នោះក្នុងវេលាដែលទក្ខិណាដែលគេថ្វាយដល់ភិក្ខុអ្នកមានសីលមួយរូបហើយ ។ ក្នុងបទថា *ទាយកតោ ចេវ បដិគ្គាហកតោ ច វិសុជ្ឈតិ* (បរិសុទ្ធទាំងខាងទាយកទាំងខាងបដិគ្គាហកៈ) នេះ បណ្ឌិតគួរពោលដល់អសទិសទាននោះឯង ។

ចប់អដ្ឋកថា ទក្ខិណាសូត្រទី ៨

# អដ្ឋកថា វណិជ្ជសូត្រទី ៩

## "ពោលអំពីការធ្វើជំនួញ"

គប្បីជ្រាបវិនិច្ឆ័យក្នុង វណិជ្ជសូត្រទី ៩ ដូចតទៅនេះ ៖

[៨០] បទថា **តាទិសាវ** (តែមួយដូចគ្នា) សេចក្តីថា ការធ្វើជំនួញដូចគ្នា គឺ ស្រដៀងគ្នានោះ ។ បទថា **ឆេទគាមិនី ហោតិ** (អស់ដើម) គឺដាច់ទុន អធិប្បាយថា ផលកម្រៃដែលប្រាថ្នាសាបសូន្យអស់ ។ បទថា **នយថាធិប្បាយា ហោតិ** (មិនបានចំណេញដូចបំណង) សេចក្តីថា បានផលចំណេញមិនដូចបំណង ។ បទថា **បរាធិប្បាយា ហោតិ** (ច្រើនជាងសេចក្តីបំណង) សេចក្តីថា បានផលចំណេញច្រើន គឺ ច្រើនជាងដែលខ្លួនប្រាថ្នា ។ ក្នុងបទថា **សមណំ វា ព្រាហ្មណំ វា** (សមណៈក្តី ព្រាហ្មណ៍ក្តី) នេះ គប្បីជ្រាបថា ជាសមណៈ ឬព្រាហ្មណ៍ ព្រោះមានបាបស្ងប់ហើយ មានបាបបានបន្សាត់បង់ហើយ ។ បទថា **វទ ភន្តេ បច្ចយេន** (លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ត្រូវការបច្ច័យ និមន្តប្រាប់ចុះ) សេចក្តីថា រមែងបវារណា គឺនិមន្តយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់គប្បីសូមបច្ច័យ ៤ យ៉ាង មានចីវរជាដើមបាន ។ បទថា **យេន បវារេតិ** (បវារណាដោយបច្ច័យណា) សេចក្តីថា គេរមែងបវារណាកំណត់ទុកដោយបច្ច័យណា ។

បទថា **តំ ន ទេតិ** (មិនប្រគេនបច្ច័យនោះ) សេចក្តីថា គេមិនប្រគេនបច្ច័យនោះគ្រប់ប្រការ ។ បទថា **តំ ន យថាធិប្បាយំ ទេតិ** (ប្រគេនបច្ច័យនោះមិនតាមបំណង) សេចក្តីថា គេរមែងមិនអាចប្រគេនបច្ច័យនោះតាមដែលសមណព្រាហ្មណ៍នោះប្រាថ្នា គឺ ប្រគេនតិចតួច ។ បទថា **យថាធិ-ប្បាយំ ទេតិ** (ប្រគេន... តាមបំណង) សេចក្តីថា សមណព្រាហ្មណ៍នោះរមែងប្រាថ្នាបច្ច័យប៉ុនណា គេក៏ប្រគេនបច្ច័យប៉ុណ្ណោះ ។ បទថា **បរធិ-ប្បាយំ ទេតិ** (ប្រគេន... ក្រៃលែងជាងបំណងប្រាថ្នា) សេចក្តីថា គេបវារណាបច្ច័យទុកតិច តែប្រគេនច្រើន ។

ចប់អដ្ឋកថា វណិជ្ជសូត្រទី ៩

# អដ្ឋកថា កម្មោជសូត្រទី ១០

*"ហេតុធ្វើឲ្យមាតុគ្រាមមិនទៅកាន់ដែនកម្ពោជៈ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កម្ពោជសូត្រទី ១០ ដូចតទៅនេះ ៖*

*[៨១] បទថា **នេវ សភាយំ និសីទតិ** (មិនអង្គុយក្នុងសភា) សេចក្តីថា មាតុគ្រាម រមែងមិនអង្គុយក្នុងសភាវិនិច្ឆ័យដើម្បីធ្វើការវិនិច្ឆ័យ ។ បទថា **ន កម្មន្តំ បយោជេតិ** (មិនប្រកបការងារធំ) សេចក្តីថា មិនប្រកបការងារធំ មានកសិកម្ម និងពាណិជ្ជកម្មជាដើម ។ បទថា **ន កម្ពោជំ គច្ឆតិ** (មិនទៅដែនកម្ពោជៈ) សេចក្តីថា មិនទៅកាន់ដែនកម្ពោជៈ ដើម្បីរួបរួមភោគទ្រព្យ ។ ក៏ពាក្យនោះមានត្រឹមតែមាតិកាប៉ុណ្ណោះ ។ អធិប្បាយថា មិនទៅខាងក្រៅដែនកន្ទែងណាមួយ ។ ក្នុងបទជាដើមថា **កោធនោ** (ជាអ្នកក្រោធ) សេចក្តីថា មាតុគ្រាមត្រូវសេចក្តីក្រោធរួបរឹតហើយ ឈ្មោះថា មិនស្គាល់ប្រយោជន៍ និងមិនមែនប្រយោជន៍ ព្រោះសេចក្តីក្រោធ ។ ឈ្មោះថា មិនអត់ធន់ក្នុងសម្បត្តិអ្នកដទៃ ព្រោះសេចក្តីប្រណែន ។ ឈ្មោះថា មិនអាចនឹងឲ្យទ្រព្យដើម្បីធ្វើកិច្ចដែលគួរធ្វើបាន ព្រោះសេចក្តីកំណាញ់ ។ ឈ្មោះថា មិនអាចនឹងចាត់ចែងធ្វើកិច្ចការដែលសមគួរធ្វើបាន ព្រោះមិនមានបញ្ញា ។*

*ព្រោះដូច្នោះ មាតុគ្រាម ទើបមិនធ្វើការអង្គុយក្នុងសភាជាដើមទាំងនេះឯង ។*

ចប់អដ្ឋកថា កម្ពោជសូត្រទី ១០

## ចប់អបណ្ណកវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# មចលវគ្គវណ្ណនាទី ៤

## អដ្ឋកថា ចាណាតិចាតសូត្រទី ១

*"អ្នកធ្វើ និងអ្នកវៀរចាកបាណាតិបាត"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បាណាតិបាតសូត្រទី ១ ដូចតទៅនេះ ៖*

[៨២-៨៥] *សូត្រទី ១ ដល់ទី ៤ មានអត្ថងាយហើយ ។*

# អដ្ឋកថា តមសូត្រទី ៥

## "បុគ្គលមកងងឹត ទៅងងឹត"

គប្បីជ្រាបវិនិច្ឆ័យក្នុង តមសូត្រទី ៥ ដូចតទៅនេះ ៖

[៨៦] បុគ្គលដែលប្រកបដោយសេចក្តីងងឹត ។ មានបទជាដើមថា **នីចកុលេ បច្ចាជាតោ** ឈ្មោះថា **តមោ** (មកងងឹត) ។ បុគ្គលឈ្មោះថា **តមបរាយនោ** (មានងងឹតនៅខាងមុខ) ព្រោះចូលដល់សេចក្តីងងឹត គឺ នរកទៀត ដោយកាយទុច្ចរិតជាដើម សូម្បីដោយបទទាំងពីរដូចពោល ជាការត្រាស់ដល់សេចក្តីងងឹតនៃខន្ធប៉ុណ្ណោះ ។ បុគ្គលឈ្មោះថា **ជោតិ** (មកភ្លឺ) ព្រោះប្រកបដោយសេចក្តីភ្លឺ មានបទជាដើមថា **អឌ្ឍកុលេ បច្ចាជាតោ** (កើតក្នុងត្រកូលស្តុកស្តម) អធិប្បាយថា ជាអ្នកភ្លឺស្វាង ។ បុគ្គលឈ្មោះថា **ជោតិបរាយនោ** (ភ្លឺទៅខាងមុខ) ព្រោះចូលដល់សភាពភ្លឺ ដោយការចូលដល់សួគ៌ទៀត ដោយការសុចរិតជាដើម ។ គប្បីជ្រាបពីរបទសូម្បីក្រៅពីនេះ ដោយន័យនេះ ។

បទថា **វេណកុលេ** (ត្រកូលអ្នកត្បាញផែង) បានដល់ ក្នុងត្រកូលជាងត្បាញផែង ។ បទថា **នេសាទកុលេ** (ត្រកូលព្រាន) បានដល់ ក្នុងត្រកូលព្រានបរបាញ់ម្រឹគជាដើម ។ បទថា **រថការកុលេ** (ត្រកូលអ្នកធ្វើរថ)

បានដល់ ក្នុងត្រកូលជាងស្បែក ។ បទថា **បុក្កុសកុលេ** បានដល់ ត្រកូលអ្នកចោលសម្រាម ។ ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងត្រកូលវិបត្តិដោយហេតុប្រមាណប៉ុណ្ណេះហើយ ព្រោះហេតុដែលបុគ្គលខ្លះ សូម្បីទឹងកើតក្នុងត្រកូលអ្នកចោលសម្រាម ក៏គង់មានទ្រព្យច្រើនបាន តែបុគ្គលបែបនេះមិនដូច្នោះទេ ដូច្នោះ ឥឡូវនេះ ដើម្បីទ្រង់សម្តែងភោគវិបត្តិរបស់បុគ្គលនោះទើបត្រាស់ថា **ទលិទ្ទេ** (ទាំងក្រលំបាក) ជាដើម ។ ក្នុងបទទាំងនោះ បទថា **ទាំងក្រលំបាក** បានដល់ ប្រកបដោយសេចក្តីក្រ មានបាយទឹក និងភោជនតិច ។ បទថា **កសិរវុត្តិកេ** (ប្រព្រឹត្តចិញ្ចឹមជីវិតបានលំបាក) បានដល់ រស់នៅដោយសេចក្តីទុក្ខ ។ អធិប្បាយថា ឲ្យចូលដល់ត្រកូលដែលបុគ្គលទាំងឡាយឲ្យគេត្រេកអរដោយសេចក្តីព្យាយាម ។ បទថា **យត្ថ កសិរេន ឃាសច្ឆាទោ លព្ភតិ** (រកអាហារ និងសំពត់ស្លៀកដណ្តប់បានដោយត្រដាបត្រដួស) សេចក្តីថា ក្នុងត្រកូលដែលគេបានបាយបបរ និងអាហារ ឬគ្រឿងស្លៀកដណ្តប់ល្មមបិទបាំងអវយវៈ ដោយសេចក្តីលំបាក ។

ព្រោះហេតុដែលបុគ្គលសូម្បីកើតក្នុងត្រកូលនេះ ជាអ្នកព្រមដោយឧបធិសម្បត្តិ តាំងនៅក្នុងសេចក្តីសម្រេចនៃអត្តភាព តែបុគ្គលនេះមិនបានដូច្នោះទេ ដូច្នោះ ឥឡូវនេះ ដើម្បីទ្រង់សម្តែងវិបត្តិផ្លូវរាងកាយរបស់គេ

ទើបត្រាស់ថា **សោ ច ហោតិ ទុព្វណ្ណោ** (ជាបុគ្គលមានពណ៌សម្បុរអាក្រក់) ជាដើម ។ ក្នុងបទទាំងនោះ បទថា **ទុព្វណ្ណោ** (មានពណ៌សម្បុរអាក្រក់) បានដល់ ជាបុគ្គលមានសម្បុរដូចជន្ទត់ភ្លើង ដូចបីសាចធូលី ។ បទថា **ទុទ្ទសិកោ** (មិនគួរមើល) បានដល់ សូម្បីមាតាបង្កើតឃើញគេក៏មិនពេញចិត្ត ។ បទថា **ឱកោដិមកោ** បានដល់ ជាមនុស្សតឿ ។ បទថា **កាណោ** (ខ្វះភ្នែក) បានដល់ ខ្វាក់ភ្នែកម្ខាងខ្លះ ខ្វាក់ភ្នែកទាំងពីរខាងខ្លះ ។ បទថា **កុណី** (ក្ញែង) បានដល់ មានដៃពិការម្ខាងខ្លះ មានដៃពិការទាំងពីរខាងខ្លះ ។ បទថា **ខញ្ជោ** (ខ្ញក) បានដល់ មានជើងខ្ញកតែម្ខាងខ្លះ មានជើងខ្ញកទាំងពីរខាងខ្លះ ។ បទថា **បក្ខហតោ** បានដល់ ខ្វិន ។

បទថា **បទីបេយ្យស្ស** (គ្រឿងប្រទីប) បានដល់ គ្រឿងឧបករណ៍របស់ប្រទីប មានប្រេង និងតួកាជនៈជាដើម ។ ក្នុងបទថា **ឯវំ ខោ ភិក្ខវេ** (ដូច្នេះឯង ម្នាលភិក្ខុទាំងឡាយ) នេះ បុគ្គលមួយមិនទាន់ឃើញពន្លឺខាងក្រៅ ស្លាប់ក្នុងគភ៌របស់មាតា ហើយកើតក្នុងអបាយវិលវល់នៅអស់ទាំងកប្ប សូម្បីបុគ្គលនោះ ក៏ឈ្មោះថា មកងងឹតហើយមានងងឹតទៅខាងមុខ ។ គេក៏គប្បីជាបុគ្គលកុហក ។ លោកអធិប្បាយថា ព្រោះថា អ្នកកុហកបានទទួលផលសម្រេចបែបនេះ ។ ក្នុងបទទាំងនេះ ទ្រង់សម្តែងដល់ការមកដែល

ជាវិបត្តិ និងបច្ច័យក្នុងបច្ចុប្បន្នវិបត្តិ ដោយបទថា **នីចេ កុលេ** (ក្នុងត្រកូលទាប) ជាដើម ។ ទ្រង់សម្តែងបច្ច័យដែលប្រព្រឹត្តទៅហើយវិបត្តិ ដោយបទថា **ទលិទ្ទេ** (ក្រលំបាក) ជាដើម ។ ទ្រង់សម្តែងឧបាយចិញ្ចឹមជីវិតវិបត្តិ ដោយបទថា **កសិរវុត្តិកេ** (ចិញ្ចឹមជីវិតលំបាក) ជាដើម ។ ទ្រង់សម្តែងអត្តភាពវិបត្តិ ដោយបទថា **ទុព្វណ្ណោ** (មានពណ៌សម្បុរអាក្រក់) ជាដើម ។ ទ្រង់សម្តែងហេតុនៃទុក្ខដែលមកប្រសព្វ ដោយបទថា **ពហ្វាពាធោ** (ច្រើនដោយរោគ) ជាដើម ។ ទ្រង់សម្តែងហេតុនៃសុខវិបត្តិ និងគ្រឿងឧបភោគវិបត្តិ ដោយបទថា **ន លាភី** (ប្រាថ្នាមិនបាន) ជាដើម ។ ទ្រង់សម្តែងហេតុនៃបុគ្គលងងឹតទៅខាងមុខមកប្រសព្វចូលផង ដោយបទថា **កាយេន ទុច្ចរិតំ** (ទុច្ចរិតដោយកាយ) ជាដើម ។ ទ្រង់សម្តែងការចូលដល់សេចក្តីងងឹតក្នុងសម្បរាយភព ដោយបទថា **កាយស្ស ភេទា** (កាយបែកធ្លាយ) ជាដើម ។ សុក្កបក្ខ (ចំណែកល្អ) គប្បីជ្រាបដោយន័យផ្ទុយគ្នា ដូចពោលមកហើយ ។

ចប់អដ្ឋកថា តមសូត្រទី ៥

# អដ្ឋកថា ឱណតសូត្រទី ៦

## *"បុគ្គលមកទាប ទៅទាប"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឱណតសូត្រទី ៦ ដូចតទៅនេះ ៖*

*[៨៧] បទថា* **ឱណោណតោ** *(បុគ្គលមកទាប ទៅទាប) សេចក្ដីថា បុគ្គលមកទាបក្នុងបច្ចុប្បន្ន ក៏កាន់តែទាបទៅក្នុងអនាគត ។ បទថា* **ឱណតុណ្ណតោ** *(បុគ្គលមកទាប ទៅខ្ពស់) សេចក្ដីថា បុគ្គលមកទាបបច្ចុប្បន្ន នឹងខ្ពស់ទៅក្នុងអនាគត ។ បទថា* **ឧណ្ណតោណតោ** *(បុគ្គលមកខ្ពស់ ទៅទាប) សេចក្ដីថា បុគ្គលមកខ្ពស់ក្នុងបច្ចុប្បន្ន ក៏នឹងទៅទាបក្នុងអនាគត ។ បទថា* **ឧណ្ណតុណ្ណតោ** *(បុគ្គលមកខ្ពស់ ទៅខ្ពស់) សេចក្ដីថា បុគ្គលមកខ្ពស់ក្នុងបច្ចុប្បន្ន ក៏នឹងខ្ពស់ទៅក្នុងអនាគត ។ ក៏សេចក្ដីពិស្ដារនៃបទទាំងនោះ គប្បីជ្រាបដោយន័យដែលពោលទុកហើយ ។*

ចប់អដ្ឋកថា ឱណតសូត្រទី ៦

# អដ្ឋកថា បុត្តសូត្រទី ៧

## *"សមណៈមិនញាប់ញ័រ ដូចព្រះរាជឱរសច្បង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បុត្តសូត្រទី ៧ ដូចតទៅនេះ ៖*

*[៨៨] បទថា **សមណមចលោ** បានដល់ សមណៈមិនញាប់ញ័រ ។ ម អក្សរ ធ្វើជាបទសន្ធិ ។ អធិប្បាយថា សមណៈដែលមិនមានសេចក្តីញាប់ញ័រ ។ ទ្រង់សម្តែងព្រះសេក្ខៈសូម្បី ៧ ពួកដោយបទនេះ ។ ព្រះសេក្ខៈនោះ ឈ្មោះថា មិនញាប់ញ័រ ព្រោះលោកតាំងមាំដោយសទ្ធាដែលជាមូលក្នុងព្រះសាសនា ។ បទថា **សមណបុណ្ឌរិកោ** (ជាសមណៈបុណ្ឌរិក) បានដល់ សមណៈដូចឈូកស ។ ធម្មតាឈូកសកើតក្នុងស្រះ មានត្របក ៩៩ សន្លឹក ។ ដោយបទនេះ ទ្រង់សម្តែងព្រះខីណាស្រពជាសុក្ខវិបស្សកៈអ្នកបំពេញវិបស្សនាសុទ្ធ ។ ព្រោះថា ព្រះខីណាស្រពសុក្ខវិបស្សកៈនោះ ឈ្មោះថា សមណៈដូចឈូកស ព្រោះលោកនៅមានគុណមិនទាន់បរិបូរណ៍ ព្រោះឈាន និងអភិញ្ញាមិនមាន ។ បទថា **សមណបទុមោ** (ជាសមណៈបទុម) បានដល់ សមណៈដូចឈូកក្រហម ។ ធម្មតាឈូកក្រហមកើតក្នុងស្រះ មានត្របកមួយរយសន្លឹក ។ បទនេះ ទ្រង់សម្តែងព្រះខីណាស្រពដែលជាឧភតោភាគវិមុត្ត ។ ព្រោះថា ព្រះខីណាស្រពឧភតោភាគវិមុត្តនោះ*

ឈ្មោះថា សមណៈដូចឈូកក្រហម ព្រោះលោកមានគុណបរិបូរ ព្រោះមានទាំងឈាន និងអភិញ្ញា ។ បទថា **សមណេសុ សមណសុខុមាលោ** (ជាសមណៈសុខុមាលក្នុងពួកសមណៈ) សេចក្តីថា បណ្តាសមណៈសូម្បីទាំងអស់នោះ សមណៈសុខុមាល ជាអ្នកមានកាយ និងចិត្តទន់ភ្លន់ ប្រាសចាកសេចក្តីទុក្ខផ្លូវកាយ និងផ្លូវចិត្ត ជាអ្នកមានសេចក្តីសុខតែម្យ៉ាង ។ ដោយបទថា **សមណសុខុមាល** នោះ ទ្រង់សម្តែងព្រះអង្គឯង និងសមណៈសុខុមាលដូចព្រះអង្គ ។

លុះទ្រង់តាំងមាតិកាយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់ចែកទៅតាមលំដាប់ ទើបត្រាស់ថា **កថញ្ច ភិក្ខវេ** (ក៏...ជាយ៉ាងណា) ជាដើម ។ ក្នុងបទទាំងនោះ បទថា **សេក្ខោ** បានដល់ ព្រះសេក្ខៈ ៧ ពួក ។ បទថា **បដិបទោ** (ជាអ្នកនៅបដិបត្តិ) បានដល់ នៅប្រព្រឹត្តបដិបត្តិ ។ បទថា **អនុត្តរំ យោគក្ខេមំ បត្ថយមានោ វិហរតិ** (នៅប្រាថ្នាធម៌ដែលក្សេមចាកយោគៈដ៏កំពូល) សេចក្តីថា ជាអ្នកប្រាថ្នាព្រះអរហត្ត ។ បទថា **មុទ្ធាភិសិត្តស្ស** (មុទ្ធាភិសេក) សេចក្តីថា ជាអ្នកបានទទួលទឹកស្រោចលើព្រះសិរសា គឺក្សត្រិយ៍មុទ្ធាភិសេក អធិប្បាយថា ទ្រង់បានមុទ្ធាភិសេកហើយ ។ បទថា **អភិសេកោ** បានដល់ ជាអ្នកគួរនឹងបានទទួលអភិសេក ។ បទថា **អនភិសិត្តោ** បានដល់ ជាអ្នកមិនទាន់បានអភិសេក ។ បទថា **មចលប្បត្តោ** (ទ្រង់

មិនញាប់ញ័រ) សេចក្តីថា មិនញាប់ញ័រ មានការប្រាថ្នាមុតមាំ ដើម្បីប្រយោជន៍ដល់ការអភិសេក ព្រោះជាព្រះឱរសរបស់ព្រះរាជា ដែលជាក្សត្រិយ៍មុទ្ធាភិសេក ព្រោះជាជេដ្ឋឱរសក្នុងបណ្តាព្រះឱរសទាំងឡាយ និងព្រោះមិនទាន់បានអភិសេក ។ ម អក្សរ ជានិបាត ។

បទថា **កាយេន ផុសិត្វា** (ពាល់ត្រូវ... ដោយកាយ) សេចក្តីថា ពាល់ត្រូវហើយដោយនាមកាយ ។ បទថា **យាចិតោវ ពហុលំ ចីវរំ បរិភុញ្ជតិ** (បើទាយកអង្វរ ទើបប្រើប្រាស់ចីវរច្រើន) សេចក្តីថា សមណៈសុខមាល ដោយច្រើនប្រើប្រាស់ចីវរ ដែលទាយកបង្អោនចូលទៅប្រគេនដោយសូមយ៉ាងនេះថា លោកម្ចាស់មេត្តាប្រើប្រាស់ចីវរនេះ ចីវរដែលគេមិនអង្វរក៏ប្រើប្រាស់តិច ដូចព្រះពកុលៈ ឯបិណ្ឌបាត ក៏ដូចព្រះសីវលី ក្នុងផ្លូវទៅព្រៃឈើគគី ។ សេនាសនៈ ក៏ដូចព្រះអានន្ទ ក្នុងអដ្ឋកនាគរសូត្រ គិលានបច្ច័យ ក៏ដូចព្រះបិលិន្ទវច្ឆៈ ។ បទថា **តេសំ** (ដើម្បីសព្រហ្មចារីប៉ុណ្ណោះ... ដល់ភិក្ខុនោះ) កាត់បទជា **តេ អស្ស** ។ បទថា **មនាបេនេវ** (ដែលគួរចម្រើនចិត្ត) បានដល់ ដែលជាទីពេញចិត្ត ។ បទថា **សមុទាចរន្តិ** (រមែងប្រព្រឹត្ត) សេចក្តីថា រមែងធ្វើ ឬប្រព្រឹត្តកិច្ចដែលគួរធ្វើ ។ បទថា **ឧបហារំ ឧបហរន្តិ** (រមែងបង្អោនចូលទៅ) សេចក្តីថា មិត្តសព្រហ្មចារីទាំង

ឡាយ រមែងបង្អោនចូលទៅ គឺ បង្អោនចូលទៅនូវវត្ថុដែលពេញចិត្ត ទាំងផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **សន្និបាតិកានិ** (ដែលជាសន្និបាត) សេចក្តីថា ដែលកើតព្រោះការប្រជុំគ្នានៃសមុដ្ឋានទាំងឡាយ (ប្រមាត់ ស្លេស្ម៍ ខ្យល់) ។ បទថា **ឧតុបរិណាមជានិ** (ដែលកើតពីការប្រែប្រួលនៃរដូវ) បានដល់ កើតពីការផ្លាស់ប្តូរនៃរដូវ គឺ ពីរដូវដែលត្រជាក់ពេក ឬក្តៅពេក ។ បទថា **វិសមបរិហារជានិ** (កើតពីការរក្សាមិនស្មើ) បានដល់ កើតពីការរក្សាមិនស្មើ មានការអង្គុយយូរ ឬឈរយូរជាដើម ។ បទថា **ឱបក្កមិកានិ** (កើតព្រោះត្រូវប្រទូស្ត) សេចក្តីថា កើតព្រោះត្រូវប្រទូស្ត (ពីអ្នកដទៃ) មានការសម្លាប់ និងការចងដើម ។ បទថា **កម្មវិបាកជានិ** (កើតដោយអំណាចវិបាករបស់កម្ម) បានដល់ កើតពីអំណាចនៃវិបាករបស់កម្ម ដែលធ្វើហើយក្នុងកាលមុនតែម្យ៉ាង ស្ងួប្បីវៀរចាកហេតុទាំងនេះ ។ ក្នុងបទថា **ចតុន្នំ ឈានានំ** (នូវឈាន ៤) នេះ លោកបំណងដល់កិរិយាឈានប៉ុណ្ណោះ ទាំងរបស់ព្រះខីណាស្រព ទាំងរបស់ព្រះពុទ្ធទាំងឡាយ ។ បទដ៏សេសមានអត្ថងាយហើយនោះឯង ។

ចប់អដ្ឋកថា បុត្តសូត្រទី ៧

# អដ្ឋកថា សំយោជនសូត្រទី ៨

## *“អ្នកអស់សំយោជនៈ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សំយោជនសូត្រទី ៨ ដូចតទៅនេះ ៖*

[៨៩] *ព្រះសោតាបន្ន ហៅថា **សមណមចលោ** (សមណៈដែលមិនញាប់ញ័រ) ព្រោះលោកបានសទ្ធាតាំងមាំហើយក្នុងព្រះសាសនា ។ ព្រះសកទាគាមី ហៅថា **សមណបុណ្ឌរិកោ** (សមណៈឈូកស) ព្រោះលោកជាអ្នកមានគុណមិនច្រើន ដូចឈូកសមានត្របកមិនច្រើន ។ ព្រះអនាគាមី ហៅថា **សមណបទុម** (សមណៈឈូកក្រហម) ដូចឈូកក្រហមដែលមានត្របកមួយរយសន្លឹក ព្រោះលោកមានគុណច្រើនជាងព្រះសកទាគាមីនោះ ។ ព្រះខីណាស្រពអ្នកដល់ទន់ភ្លន់ ហៅថា **សមណសុខមាលោ** ព្រោះកិលេសដែលធ្វើសេចក្ដីរឹងរូស លោកដកបានហើយដោយប្រការទាំងពួង ។*

ចប់អដ្ឋកថា សំយោជនសូត្រទី ៨

# អដ្ឋកថា ទិដ្ឋិសូត្រទី ៩

## "បុគ្គលមានការឃើញត្រូវ"

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទិដ្ឋិសូត្រទី ៩ ដូចតទៅនេះ ៖*

[៩០] *ដោយបទជាដើមថា* ***សម្មាទិដ្ឋិកោ*** *(អ្នកមានការឃើញត្រូវ) ទ្រង់សំដៅដល់ព្រះសេក្ខៈ ៧ ពួក ដូចក្នុងសូត្រដំបូង ដោយអំណាចមគ្គមានអង្គ ៨ ។ វារៈទីពីរ ត្រាស់ព្រះខីណាស្រពសុក្ខវិបស្សកៈ ដែលចម្រើនវិបស្សនាសុទ្ធ ព្រមដោយអរហត្តផលញាណ និងអរហត្តផលវិមុត្តិ ដោយអំណាចនៃមគ្គមានអង្គ ១០ ឬដោយអំណាចនៃមគ្គមានអង្គ ៨ ។ ក្នុងវារៈទីបី ត្រាស់ព្រះខីណាស្រពអ្នកជាឧភតោភាគវិមុត្ត ។ វារៈទីបួន ត្រាស់ដល់ព្រះតថាគត និងព្រះខីណាស្រពដូចជាព្រះតថាគត ។ ដូច្នោះ ព្រះសូត្រនេះ ព្រះអង្គត្រាស់ដោយអំណាចបុគ្គល ដែលពោលក្នុងសូត្រដំបូង ។ តែក្នុងព្រះសូត្រនេះផ្សេងគ្នាត្រឹមតែទេសនាប៉ុណ្ណោះ ។*

ចប់អដ្ឋកថា ទិដ្ឋិសូត្រទី ៩

# អដ្ឋកថា ខន្ធសូត្រទី ១០

## *"សមណៈ ៤ ពួក"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ខន្ធសូត្រទី ១០ ដូចតទៅនេះ ៖*

[៩១] *ពាក្យថា ១ ត្រាស់ដល់ព្រះសេក្ខបុគ្គល អ្នកមិនផ្តើមសេចក្តីព្យាយាមដើម្បីព្រះអរហត្ត តាំងនៅដោយសេចក្តីប្រមាទ ។ ពាក្យថា ២ ត្រាស់ដល់ព្រះសេក្ខបុគ្គលអ្នកមិនបានឈាន តែផ្តើមវិបស្សនា នៅដោយសេចក្តីមិនប្រមាទ ។ ពាក្យថា ៣ ត្រាស់ដល់ព្រះសេក្ខបុគ្គល អ្នកផ្តើមវិបស្សនា នៅដោយសេចក្តីមិនប្រមាទ បានវិមោក្ខ ៨ ។ ពាក្យថា ៤ ត្រាស់ដល់ព្រះខីណាស្រពជាសុខមាលដ៏យ៉ាងក្រៃលែង ។*

ចប់អដ្ឋកថា ខន្ធសូត្រទី ១០

### ចប់មចលវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៦ សូត្រ

# អសុរវគ្គវណ្ណនាទី ៥

## អដ្ឋកថា អសុរសូត្រទី ១

*"បុគ្គលដូចជាអសុរ និងទេវតា"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អសុរសូត្រទី ១ ដូចតទៅនេះ ៖*

[៩២] *បទថា **អសុរោ** បានដល់ បុគ្គលគួរស្អប់ ដូចជាអសុរ ។ បទថា **ទេវោ** បានដល់ បុគ្គលស្អាតដោយគុណ ធ្វើឲ្យកើតសេចក្តីជ្រះថ្លា ដូចជាទេវតា ។*

ចប់អដ្ឋកថា អសុរសូត្រទី ១

# អដ្ឋកថា បឋមសមាធិសូត្រទី ២

*“ពោលដោយសមាធិ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសមាធិសូត្រទី ២ ដូចតទៅនេះ ៖*

*[៩៣] បទថា **អជ្ឈត្តំ ចេតោសមថស្ស** (សេចក្តីស្ងប់ក្នុងខាងក្នុង) បានដល់ អប្បនាចិត្តសមាធិខាងក្នុងខ្លួន ។ បទថា **អធិប្បញ្ញាធម្មវិបស្សនាយ** សេចក្តីថា វិបស្សនាញាណដែលកំណត់សង្ខារជាអារម្មណ៍ ។ ពិតណាស់ វិបស្សនាញាណនោះ រាប់ថា ជាអធិប្បញ្ញា និងជាវិបស្សនា ក្នុងធម៌ទាំងឡាយ ពោលគឺ បញ្ចក្ខន្ធ ព្រោះដូច្នោះ ទើបហៅថា អធិប្បញ្ញាធម្មវិបស្សនា ។*

ចប់អដ្ឋកថា បឋមសមាធិសូត្រទី ២

# អដ្ឋកថា ទុតិយសមាធិសូត្រទី ៣

## *"ពោលដោយសមាធិ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសមាធិសូត្រទី ៣ ដូចតទៅនេះ ៖*

[៩៤] *បទថា* ***យោគោ ករណីយោ*** *(ធ្វើការប្រកបសេចក្តីព្យាយាម) សេចក្តីថា គប្បីធ្វើសេចក្តីខ្វល់ខ្វាយ ។ បទថា* ***ឆន្ទោ*** *(ឆន្ទៈ) គឺ សេចក្តីពេញចិត្តប្រាថ្នានឹងធ្វើ ។ បទថា* ***វាយាមោ*** *គឺ សេចក្តីព្យាយាម ។ បទថា* ***ឧស្សាហោ*** *គឺ សេចក្តីព្យាយាមក្រៃលែងជាងសេចក្តីព្យាយាមនោះ ។ បទថា* ***ឧស្សោឡ្ហី*** *(សេចក្តីព្យាយាមដ៏ខ្លាំង) សេចក្តីថា សេចក្តីព្យាយាមខ្លាំងដូចទាញរទេះដែលជាប់ល្បប់ ។ បទថា* ***អប្បដិវានី*** *(មិនធូថយ) បានដល់មិនថយក្រោយ ។*

ចប់អដ្ឋកថា ទុតិយសមាធិសូត្រទី ៣

# អដ្ឋកថា តតិយសមាធិសូត្រទី ៤

## *"ពោលដោយសមាធិ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយសមាធិសូត្រទី ៤ ដូចតទៅនេះ ៖*

*[៩៥] ក្នុងបទថា* ***ឯវំ ខោ អាវុសោ សង្ខារា ទដ្ឋព្វា*** *(សង្ខារទាំងឡាយ គប្បីឃើញយ៉ាងនេះ) ជាដើម គប្បីឃើញអត្ថយ៉ាងនេះថា ម្នាលអ្នកមានអាយុទាំងឡាយ ធម្មតាថា សង្ខារទាំងឡាយគប្បីពិចារណាថា ជារបស់មិនទៀង គប្បីកំណត់ដោយសេចក្តីមិនទៀង គប្បីឃើញច្បាស់ថាមិនទៀង ថាជាទុក្ខ ថាជាអនត្តា ក៏ដូច្នោះ ។ សូម្បីក្នុងបទថា* ***ឯវំ ខោ អាវុសោ ចិត្តំ សណ្ឋបេតព្វំ*** *(ចិត្តគប្បីតាំងទុកយ៉ាងនោះ) ជាដើម គប្បីឃើញអត្ថយ៉ាងនេះថា អ្នកមានអាយុទាំងឡាយ ចិត្តគប្បីតាំងនៅបានដោយអំណាចបឋមជ្ឈាន គប្បីបង្អោនទៅដោយអំណាចបឋមជ្ឈាន គប្បីធ្វើអារម្មណ៍ឲ្យតែមួយដោយអំណាចបឋមជ្ឈាន គប្បីឲ្យជាសមាធិដោយបឋមជ្ឈាន ចិត្តនឹងតាំងនៅបានដោយអំណាចទុតិយជ្ឈានជាដើម ក៏យ៉ាងនោះ ។ ក្នុងព្រះសូត្រទាំង ៣ នេះ ត្រាស់សមថៈ និងវិបស្សនា ជាលោកិយៈ និងលោកុត្តរៈនោះឯង ។*

ចប់អដ្ឋកថា តតិយសមាធិសូត្រទី ៤

# អដ្ឋកថា ឆវាលាតសូត្រទី ៥

## *"បុគ្គលប្រៀបដូចអង្កត់ឧសដុតខ្មោច"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឆវាលាតសូត្រទី ៥ ដូចតទៅនេះ ៖*

*[៩៦] បទថា* ***ឆវាលាតំ*** *(អង្កត់ឧសដុតខ្មោច) បានដល់ អង្កត់ឧសដុតខ្មោចក្នុងព្រៃខ្មោច ។ បទថា* ***មជ្ឈេ គូថគតំ*** *បានដល់ ត្រង់កណ្តាលក៏ប្រលាក់លាមក ។ បទថា* ***នេវ គាមេ កដ្ឋត្ថំ ផរតិ*** *(រមែងមិនសម្រេចប្រយោជន៍ដែលនឹងប្រើជាគ្រឿងឈើក្នុងផ្ទះ) សេចក្តីថា មិនសម្រេចបានប្រយោជន៍ដែលនឹងប្រើជាគ្រឿងឈើក្នុងផ្ទះ ព្រោះមិនគួរនាំចូលទៅដើម្បីប្រយោជន៍ដល់សំភារៈ មេដំបូល ឈើរនុក បង្កង់ សសរ និងជណ្តើរជាដើម មិនសម្រេចប្រយោជន៍ដែលនឹងប្រើជាគ្រឿងឈើក្នុងព្រៃ ព្រោះមិនគួរនាំចូលមកធ្វើខ្ទមក្នុងស្រែ ឬគ្រែ កាលចាប់ត្រង់ចុងទាំងពីរ ក៏រមែងឆេះដៃ កាលចាប់ត្រង់កណ្តាល ក៏ប្រលាក់លាមក ។ បទថា* ***តថូបមំ*** *(មានឧបមាដូច្នោះ) សេចក្តីថា បុគ្គលនោះក៏ដូចគ្នា ។ បទថា* ***អភិក្កន្តតរោ*** *(ល្អជាង) គឺ ប្រសើរជាង ។ បទថា* ***បណីតតរោ*** *(ប្រណីតជាង) គឺ ខ្ពស់ជាង ។ បទថា* ***គវា ខីរំ*** *(ទឹកដោះគោ) បានដល់ ទឹកដោះមេគោ ។ ក្នុងបទថា* ***ខីរម្ហា ទធិ*** *(ទឹកដោះជូរល្អជាងទឹកដោះ) ជាដើម សេចក្តីថា តែមួយ*

យ៉ាង ជារបស់ប្រសើរជាងមុនៗ ។ ចំណែកសប្បិមណ្ឌៈ គឺ ជុំទឹកដោះថ្លា ជាកំពូលក្នុងទឹកដោះជាដើមទាំងពួងនោះ ។ ក្នុងបទថា **អគ្គោ** (បុគ្គលកំពូល) ជាដើម គប្បីជ្រាបថា ជាបុគ្គលកំពូល ប្រសើរបំផុត ជាប្រមុខ ខ្ពង់ខ្ពស់ និងជាចំបង ដោយគុណទាំងឡាយ ។ បុគ្គលដែលទ្រុស្តសីល ទ្រង់ត្រាស់ប្រៀបដូចជាអង្កត់ឧសដុតខ្មោច តែគប្បីជ្រាបថា ទ្រង់ត្រាស់បុគ្គលដែលមានសុតៈតិច អ្នកលះបង់ការងារ ប្រៀបដូចគោ ។

ចប់អដ្ឋកថា ជវាលតសូត្រទី ៥

# អដ្ឋកថា រាគសូត្រទី ៦

## *"បុគ្គលបដិបត្តិដើម្បីកម្ចាត់រាគៈ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង រាគសូត្រទី ៦ ដូចតទៅនេះ ៖*

[៩៧] *ក្នុងរាគសូត្រ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា រាគសូត្រទី ៦

# អដ្ឋកថា និសន្តិសូត្រទី ៧

*“បុគ្គលត្រាស់ដឹងរហ័ស”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង និសន្តិសូត្រទី ៧ ដូចតទៅនេះ ៖*

*[៩៨] បទថា **ខិប្បនិសន្តិ** (បុគ្គលត្រាស់ដឹងរហ័ស) សេចក្តីថា បុគ្គលស្តាប់បានរហ័ស អាចត្រាស់ដឹងរហ័ស ។ បទថា **ធតានញ្ច ធម្មានំ** (ធម៌ដែលចង់ចាំទុកបាន) សេចក្តីថា ធម៌ដែលជាបាលី ក៏ចាំទុកបានរហ័ស ។ បទថា **អត្ថុបបរិក្ខី** (បុគ្គលពិចារណាអត្ថ) បានដល់ ជាអ្នកពិចារណាអត្ថ ។ បទថា **អត្ថមញ្ញាយ ធម្មមញ្ញាយ** (ដឹងអត្ថដឹងធម៌ទូទៅ) បានដល់ ដឹងដល់អដ្ឋកថា និងបាលី ។ បទថា **ធម្មានុធម្មប្បដិបន្នោ ហោតិ** (បដិបត្តិធម៌សមគួរដល់ធម៌) បានដល់ ជាអ្នកបដិបត្តិបដិបទាដែលជាចំណែកខាងដើម ព្រមទាំងសីល ជាធម៌ដែលសមគួរដល់លោកុត្តរធម៌ ៩ ។ បទថា **នោ ច កល្យាណវាចោ ហោតិ** (តែជាអ្នកមានវាចាមិនពីរោះ) បានដល់ តែជាអ្នកនិយាយមិនល្អ ។ បទថា **ន កល្យាណវាក្ករណោ** (មានពាក្យសំដីមិនផ្អែម-ល្ហែម) សេចក្តីថា ជាបុគ្គលមានសំឡេងមិនពីរោះ ។ **នោ** អក្សរ គួរប្រកបជាមួយបទថា **បោរិយា** (ជាសំដីអ្នកក្រុង) ជាដើម សេចក្តីថា មិនមែនជាអ្នកប្រកបដោយវាចាដែលអាចបង្អួលបង្ហាញឲ្យគេអាចអត្ថ ដោយបទ និងព្យញ្ជនៈ*

ដែលមិនបាននៅត្រង់ក ពេញដោយគុណ មិនតតាក់តតុប មិនមានទោស ។

ក្នុងបទទាំងពួង ក៏គប្បីជ្រាបសេចក្តីដោយឧបាយនេះ ។

ចប់អដ្ឋកថា និសន្តិសូត្រទី ៧

# អដ្ឋកថា អត្តហិតសូត្រទី ៨

## *“បុគ្គលបដិបត្តិដើម្បីប្រយោជន៍ខ្លួន”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អត្តហិតសូត្រទី ៨ ដូចតទៅនេះ ៖*

[៩៩] *ទ្រង់ត្រាស់ដោយអំណាចអធ្យាស្រ័យនៃបុគ្គលខ្លះ ដោយលម្អនៃទេសនាញាណរបស់ព្រះទសពល ។*

ចប់អដ្ឋកថា អត្តហិតសូត្រទី ៨

# អដ្ឋកថា សិក្ខាសូត្រទី ៩

*"ពោលអំពីសិក្ខាបទ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សិក្ខាសូត្រទី ៩ ដូចតទៅនេះ ៖*

[១០០] *សិក្ខាសូត្រ ទ្រង់ត្រាស់ដោយអំណាចនៃពៀរ ៥ យ៉ាង ។*

ចប់អដ្ឋកថា សិក្ខាសូត្រទី ៩

# អដ្ឋកថា ចោតលិយសូត្រទី ១០

## *“ពោតលិយបរិញ្ញជក”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ពោតលិយសូត្រទី ១០ ដូចតទៅនេះ ៖*

*[១០១] បទថា* ***កាលេន*** *សេចក្ដីថា តាមកាលដែលសមគួរ ។ បទថា* ***ខមតិ*** *គឺ ពេញចិត្ត ។ បទថា* ***យទិទំ តត្រ តត្រ កាលញ្ញុតា*** *(ភាពជាបុគ្គលស្គាល់កាលក្នុងទីនោះៗ) សេចក្ដីថា ការស្គាល់កាលក្នុងស្ថានទីនោះៗ ។ លោកសម្ដែងថា ការស្គាល់កាលនោះៗ ហើយពោលតិះដៀលបុគ្គលដែលគួរតិះដៀល និងពោលសរសើរបុគ្គលដែលគួរសរសើរ ជាប្រក្រតីរបស់បណ្ឌិតទាំងឡាយ ។*

ចប់អដ្ឋកថា ចោតលិយសូត្រទី ១០

## ចប់អសុរវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# ចប់ទុតិយបណ្ណាសកៈ

# តតិយបណ្ណាសកៈ

## វលាហកវគ្គវណ្ណនាទី ១

## អដ្ឋកថា បឋមវលាហកសូត្រទី ១

*"បុគ្គលប្រៀបដូចជាមេឃ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមវលាហកសូត្រទី ១ ដូចតទៅនេះ ៖*

[១០២] *បទថា* ***វលាហក*** *(មេឃ) គឺ មេឃភ្លៀង ។ បទថា* ***គាសិតា ហោតិ នោ កត្តា*** *(ជាបុគ្គលនិយាយ តែមិនធ្វើ) សេចក្តីថា បុគ្គលខ្លះនិយាយតែម្យ៉ាងថា យើងនឹងធ្វើវត្ថុនេះៗ តែមិនធ្វើ ។ បទថា* ***កត្តា ហោតិ នោ គាសិតា*** *(ជាបុគ្គលធ្វើ តែមិននិយាយ) សេចក្តីថា បុគ្គលខ្លះមិននិយាយ តែធ្វើ ដោយគិតថា យើងគួរនឹងធ្វើវត្ថុនេះៗ ។ គប្បីជ្រាបសេចក្តីក្នុងបទទាំងពួងយ៉ាងនេះ ។*

ចប់អដ្ឋកថា បឋមវលាហកសូត្រទី ១

# អដ្ឋកថា ទុតិយវលាហកសូត្រទី ២

*“បុគ្គលប្រៀបដូចជាមេឃ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយវលាហកសូត្រទី ២ ដូចតទៅនេះ ៖*

[១០៣] *ក្នុងសូត្រនេះ មានអត្ថងាយហើយនោះឯង ។*

ចប់អដ្ឋកថា ទុតិយវលាហកសូត្រទី ២

# អដ្ឋកថា កុម្ភសូត្រទី ៣

## "បុគ្គលប្រៀបដូចក្អមទឹក"

គប្បីជ្រាបវិនិច្ឆ័យក្នុង កុម្ភសូត្រទី ៣ ដូចតទៅនេះ ៖

[១០៤] បទថា **កុម្ភា** គឺ ក្អម ។ បទថា **តុច្ឆោ បិហិតោ** (ក្អមទទេ បានដល់ ក្អមទទេបិទគម្រប ។ បទថា **បូរោ វិវដោ** (ក្អមពេញ បើក) បានដល់ ក្អមមានទឹកពេញ បើកគម្រប ។ សូម្បីក្នុងពីរបទដ៏សេស ក៏ន័យនេះដូចគ្នា ។

ចប់អដ្ឋកថា កុម្ភសូត្រទី ៣

# អដ្ឋកថា ឧទករហទសូត្រទី ៤

## *“បុគ្គលប្រៀបដូចអន្លង់ទឹក”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧទករហទសូត្រទី ៤ ដូចតទៅនេះ ៖*

[១០៩] *ក្នុងបទថា* ***ឧត្តានោ គម្ភីរោភាសោ*** *(អន្លង់ទឹករាក់មានឱភាសជ្រៅ) ជាដើម សេចក្តីថា អន្លង់ទឹកខ្មៅ ព្រោះមានពណ៌លាយដោយទឹកស្លឹកឈើចាស់ៗ ឈ្មោះថា មានឱភាសជ្រៅ “ធ្លុះស្រមោលទៅជ្រៅ” ។ អន្លង់ទឹកមានពណ៌ថ្លាស្អាតដូចកែវមណី ឈ្មោះថា មានស្រមោលរាក់ ។*

ចប់អដ្ឋកថា ឧទករហទសូត្រទី ៤

# អដ្ឋកថា អម្ពសូត្រទី ៥

## *"បុគ្គលប្រៀបដូចផ្លែស្វាយ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អម្ពសូត្រទី ៥ ដូចតទៅនេះ ៖*

[១០៦] *បទថា **អាមំ បក្កវណ្ណី** (ផ្លែស្វាយខ្ចីមានសម្បុរទុំ) សេចក្តីថា កាលពិនិត្យមើលជាផ្លែស្វាយខ្ចី តែប្រាកដដូចជាទុំ ។ បទទាំងពួងគប្បីឃើញយ៉ាងនេះ ។*

ចប់អដ្ឋកថា អម្ពសូត្រទី ៥

# អដ្ឋកថា មូសិកាសូត្រទី ៦

## *“បុគ្គលប្រៀបដូចសត្វកណ្ដុរ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មូសិកាសូត្រទី ៦ ដូចតទៅនេះ ៖*

[១០៧] *ដែលនៅហៅថា រន្ធ កណ្ដុរពួកណាកកាយរន្ធ តែមិននៅក្នុងរន្ធនោះ កណ្ដុរប្រភេទនោះ ហៅថា កាយរន្ធតែមិននៅ ។ បាលីថា* **ខន្តា** *ដូច្នេះក៏មាន ។ បទទាំងពួងគប្បីជ្រាបដោយន័យនេះ ។*

ចប់អដ្ឋកថា មូសិកាសូត្រទី ៧

# អដ្ឋកថា ពលិពទ្ទសូត្រទី ៨[១]

## "បុគ្គលប្រៀបដូចជាគោពលិពទ្ទ"

*គប្បីជ្រាបវិនិច្ឆ័យក្នុង ពលិពទ្ទសូត្រទី ៨ ដូចតទៅនេះ ៖*

[១០៨] *គោពលិពទ្ទ (គោបម្រើ) ណា រមែងញាំញីហ្វូងគោរបស់ខ្លួន មិនញាំញីហ្វូងគោដទៃ គោពលិពទ្ទនេះ ឈ្មោះថា កាចតែក្នុងហ្វូងគោរបស់ខ្លួន មិនកាចក្នុងហ្វូងគោដទៃ ។ បទទាំងពួងគប្បីជ្រាបយ៉ាងនេះ ។ បទថា* **ឧព្វេជេតា ហោតិ** *(គំរាម) បានដល់ បៀតបៀន គឺ ចាក់ដោតធ្វើឲ្យកើតសេចក្ដីភ័យខ្លាច ។*

ចប់អដ្ឋកថា ពលិទ្ទសូត្រទី ៨

---

*(១) បិដក = ពលិវទ្ទ ។*

# អដ្ឋកថា រុក្ខសូត្រទី ៩

## *"បុគ្គលប្រៀបដូចដើមឈើ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង រុក្ខសូត្រទី ៩ ដូចតទៅនេះ ៖*

[១០៩] *បទថា **ផេគ្គុ ផេគ្គុបរិវារោ** (ដើមឈើស្រោយ មានដើមឈើស្រោយជាបរិវារ) សេចក្តីថា ដើមឈើស្រោយមិនមានខ្លឹម មានដើមឈើស្រោយដូចគ្នាហែហម ។ បទថា **សារបរិវារោ** (មានដើមឈើខ្លឹមជាបរិវារ) សេចក្តីថា ដើមឈើមានខ្លឹម មានឈើគគីជាដើមហែហម ។ ក្នុងបទទាំងពួងក៏ន័យនេះ ។*

ចប់អដ្ឋកថា រុក្ខសូត្រទី ៩

# អដ្ឋកថា អាសីវិសសូត្រទី ១០

## *“បុគ្គលប្រៀបដូចអសិរពិស”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាសីវិសសូត្រទី ១០ ដូចតទៅនេះ ៖*

[១១០] *បទថា **អាគតវិសោ ន ឃោរវិសោ** (អសិរពិសមានពិសរហ័ស តែពិសមិនកាច) សេចក្ដីថា ពិសរបស់អាសិរពិសជ្រួតជ្រាបឆាប់ តែពិសមិនកាច មិនបៀតបៀនអស់កាលយូរ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះឯង ។*

ចប់អដ្ឋកថា អាសីវិសសូត្រទី ១០

## ចប់វលាហកវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# កេសិវគ្គវណ្ណនាទី ២

## អដ្ឋកថា កេសិសូត្រទី ១

### "រឿងនាយកេសីអ្នកបង្ហាត់សេះ"

គប្បីជ្រាបវិនិច្ឆ័យក្នុង កេសីសូត្រទី ១ ដូចតទៅនេះ ៖

[១១១] បទថា **កេសី** ជាឈ្មោះរបស់នាយសារថីអ្នកបង្ហាត់សេះ ។ ឈ្មោះថា សារថីអ្នកបង្ហាត់សេះ ព្រោះធ្វើសេះដែលបង្ហាត់ឲ្យយល់ ទើបបង្ហាត់ ។ ក្នុងបទថា **សណ្ហេនបិ ទមេតិ**[១] (ហ្វឹកហាត់... ដោយវិធីល្អខ្លះ) ជាដើម នាយសារថីធ្វើសក្ការៈល្មមសមគួរដល់សេះនោះ គឺ ឲ្យស៊ីភោជនល្អ ឲ្យផឹកទឹកឆ្ងាញ់ និយាយដោយពាក្យផ្អែមល្ហែមហើយ ទើបបង្ហាត់ ឈ្មោះថា បង្ហាត់ដោយវិធីល្អ ។ កាលបង្ហាត់ដោយចងជើង ចងមាត់ជាដើម និងចាក់ដោយជន្លួញ វាយដោយរំពាត់ និយាយពាក្យគ្រោតគ្រាត ឈ្មោះថា បង្ហាត់ដោយវិធីអាក្រក់ ។ កាលធ្វើទាំងពីរវិធីនោះ តាមកាលដែលគួរ ឈ្មោះថា បង្ហាត់ទាំងវិធីល្អ និងទាំងវិធីអាក្រក់ ។

ចប់អដ្ឋកថា កេសិសូត្រទី ១

---

(១) បិដក ជា សណ្ហេនបិ វិនេមិ ។

# អដ្ឋកថា ជវសូត្រទី ២

## *"ភាពរហ័សរបស់សេះ និងរបស់ភិក្ខុ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ជវសូត្រទី ២ ដូចតទៅនេះ ៖*

[១១២] *បទថា* ***អាជ្ជវេន*** *(ស្មោះត្រង់) គឺ ភាពជាសត្វស្មោះត្រង់ ។ បទថា* ***ជវេន*** *(រហ័ស) គឺ សន្ទុះដើររហ័ស ។ បទថា* ***ខន្តិយា*** *(អត់ធន់) បានដល់ មានសេចក្ដីអត់ធន់ គឺ អត់ទ្រាំ ។ បទថា* ***សោរច្ចេន*** *(ស្ងប់ស្ងៀម) គឺ មានសេចក្ដីស្អាតជាប្រក្រតី ។ ក្នុងអង្គនៃគុណរបស់បុគ្គល ។ បទថា* ***រហ័ស*** *បានដល់ ដោយកម្លាំងរហ័សនៃញាណ ។ បទដ៏សេសក្នុងសូត្រនេះ មានសេចក្ដីងាយទាំងនោះឯង ។*

*ចប់អដ្ឋកថា ជវសូត្រទី ២*

# អដ្ឋកថា បតោទសូត្រទី ៣

## *"ជន្ទញរបស់សារថី"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បតោទសូត្រទី ៣ ដូចតទៅនេះ ៖*

[១១៣] *បទថា **បតោទច្ឆាយំ** (ស្រមោលជន្ទញ) សេចក្តីថា ស្រមោលនៃជន្ទញដែលលើកឡើងដើម្បីនឹងចាក់ ។ បទថា **សំវិជតិ** (ស្លុត) សេចក្តីថា តក់ស្លុតដោយកំណត់ថា យើងត្រូវសន្ធិញជើង ។ បទថា **សំវេគំ អាបជ្ជតិ** (ដល់នូវសេចក្តីសង្វេគ) បានដល់ ដល់នូវសេចក្តីតក់ស្លុត ។ បទថា **លោមវេធវិទ្ធោ** (ត្រូវចាក់ដោយជន្ទញដ៏មុតស្រួច) សេចក្តីថា ពេលត្រូវជន្ទញចាក់ចុះរណ្តៅរោម ។ បទថា **ចម្មវេធវិទ្ធោ** (ត្រូវចាក់ដោយជន្ទញដល់ស្បែក) បានដល់ យកជន្ទញចាក់មុតស្បែក ។ បទថា **អដ្ឋិវេធវិទ្ធោ** (ត្រូវចាក់ដោយជន្ទញដល់ឆ្អឹង) បានដល់ យកជន្ទញចាក់ទម្លុះដល់ឆ្អឹង ។ បទថា **កាយេន** គឺ ដោយនាមកាយ ។ បទថា **បរមសច្ចំ** (នូវបរមត្ថសច្ចៈ) គឺ និព្វាន ។ បទថា **សច្ឆិករោតិ** (ធ្វើឲ្យច្បាស់) គឺ ពាល់ត្រូវ ។ បទថា **បញ្ញាយ** (ដោយបញ្ញា) គឺ មគ្គប្បញ្ញាព្រមទាំងវិបស្សនា ។*

ចប់អដ្ឋកថា បតោទសូត្រទី ៣

# អដ្ឋកថា នាគសូត្រទី ៤

## *"អង្គរបស់ដំរី និងរបស់ភិក្ខុ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង នាគសូត្រទី ៤ ដូចតទៅនេះ ៖*

[១១៤] *បទថា* ***អដ្ឋិកត្វា*** *(ធ្វើទុកក្នុងចិត្ត) គឺ ជាអ្នកប្រកបដោយការចងចាំ ។ ក្នុងបទនេះថា* ***តិណាវនិន្នាទសទ្ទានំ*** *(សំឡេងគឹកកងនៃ... ស្គរជ័យ) ស្គរជ័យ ឈ្មោះថា* ***តិណាវៈ*** *។ បទថា* ***និន្នាទសទ្ទោ*** *(សំឡេងគឹកកង) បានដល់ ដូចសំឡេងផ្សំតែមួយ សូម្បីរបស់គ្រឿងវាយ និងផ្លុំគ្រប់យ៉ាង ។ ក្នុងបទថា* ***ឃាំសា*** *(របោម) ជាដើម បទថា* ***ឃាំសា*** *បានដល់ របោម ។ បទថា* ***មកសា*** *បានដល់ មូស ។ បទថា* ***ខិប្បញ្ញេវ គន្តា ហោតិ*** *(ជាអ្នកទៅបានរហ័ស) សេចក្តីថា ភិក្ខុបំពេញសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សនៈ ហើយទៅដាច់រហ័ស ។*

ចប់អដ្ឋកថា នាគសូត្រទី ៤

# អដ្ឋកថា ឋានសូត្រទី ៥

## *"ហេតុនៃសេចក្តីវិនាស និងសេចក្តីចម្រើន"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឋានសូត្រទី ៥ ដូចតទៅនេះ ៖*

[១១៥] *បទថា* ***ឋានានិ*** *បានដល់ ហេតុ ។ បទថា* ***អនត្ថាយ សំវត្តតិ*** *(រមែងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស) សេចក្តីថា រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីមិនចម្រើន ។ ក៏ក្នុងបទនេះ បាបកម្មមានទុក្ខ មានសេចក្តីចង្អៀតចង្អល់ មានការជីកអន្លង់ចាប់ត្រី និងកាត់ទី.តនៃផ្ទះជាដើម គប្បីជ្រាបថា ជាហេតុទី ១ ការងារមានការបោលសម្រាមជាដើម និងការងារមានការបូកកំបោរសេ ប្រក់ផ្ទះ និងបោសទីមិនស្អាតជាដើម ចំពោះគ្រហស្ថអ្នកចញ្ចឹមជីវិតដោយប្រពៃ គប្បីជ្រាបថា ជាហេតុទី ២ កម្មមានការផឹកសុរា លាបគ្រឿងក្រអូប និងការប្រដាប់ផ្កាឈើជាដើម និងកម្មមានបាណាតិបាតជាដើម ដែលប្រព្រឹត្តទៅហើយដោយអំណាចសេចក្តីត្រេកអរ គប្បីជ្រាបថា ជាហេតុទី ៣ កុសលកម្មដែលប្រកបដោយសោមនស្ស ក្នុងកិច្ចកម្មជាដើមយ៉ាងនេះ គឺ ការស្មៀកដណ្តប់សំពត់ស្អាត និងកាន់យកផ្កាឈើ និងគ្រឿងក្រអូបជាដើម ទៅក្នុងវេលាទៅស្តាប់ធម៌ ការសំពះព្រះចេតិយ ការសំពះដើមពោធិ ការស្តាប់ធម្មកថាដ៏ពីរោះ ការសមា-*

*ទានសីល ៥ គប្បីជ្រាបថា ជាហេតុទី ៤ ។ បទថា* ***បុរិសត្ថាមេ*** *(ក្នុងរឿងកម្លាំងរបស់បុរស) សេចក្ដីថា ក្នុងកម្លាំង គឺ ញាណរបស់បុរស ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះឯង ។*

ចប់អដ្ឋកថា ឋានសូត្រទី ៥

# អដ្ឋកថា អប្បមាទសូត្រទី ៦

## *"សេចក្តីមិនប្រមាទដោយឋានៈ ៤ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អប្បមាទសូត្រទី ៦ ដូចតទៅនេះ ៖*

[១១៦] *បទថា **យតោ ខោ** (ក្នុងកាលណា) គឺ កាលណានោះឯង ។ បទថា **សម្បរាយិកស្ស** (ដែលមកដល់ក្នុងថ្ងៃខាងមុខ) នោះ ត្រឹមតែជាទេសនា ។ តែព្រះខីណាស្រព មិនខ្លាចចំពោះសេចក្តីស្លាប់ដែលនឹងមានមកក្នុងកាលខាងមុខ ទាំងមិនខ្លាចចំពោះសេចក្តីស្លាប់ដែលនឹងមានក្នុងបច្ចុប្បន្ន ។ ក៏ព្រះខីណាស្រពនោះ ព្រះមានព្រះភាគទ្រង់បំណងក្នុងទីនេះ តែអាចារ្យពួកខ្លះពោលថា ទ្រង់បំណងយកព្រះអរិយៈទាំងឡាយសូម្បីព្រះសោតាបន្ន ព្រោះព្រះបាលីថា **សម្មាទិដ្ឋិ ភាវិតា** បានចម្រើនសម្មាទិដ្ឋិហើយ ។*

ចប់អដ្ឋកថា អប្បមាទសូត្រទី ៦

# អដ្ឋកថា អារក្ខសូត្រទី ៧

## "សតិជាគ្រឿងរក្សា"

គប្បីជ្រាបវិនិច្ឆ័យក្នុង អារក្ខសូត្រទី ៧ ដូចតទៅនេះ ៖

[១១៧] បទថា **អត្តរូបេន** (ដោយសមគួរដល់ខ្លួន) បានដល់ តាមអនុរូប គឺ តាមគួរដល់ខ្លួន អធិប្បាយថា តាមសេចក្តីប្រាថ្នាប្រយោជន៍ដ៏ធំទូលាយ ។ បទថា **រជនីយេសុ** (ជាទីតាំងនៃសេចក្តីប្រាថ្នា) បានដល់ ក្នុងធម៌ជាបច្ច័យនៃរាគៈ ។ បទថា **ធម្មេសុ** (ក្នុងធម៌) បានដល់ ក្នុងសភាវៈ គឺ អារម្មណ៍ដែលគួរប្រាថ្នា ។ ន័យក្នុងបទទាំងពួងគប្បីជ្រាបយ៉ាងនេះ ។ បទថា **នច្ចន្តិ** (រមែងមិនរន្ធត់) សេចក្តីថា រមែងមិនរន្ធត់ដោយអំណាចទិដ្ឋិ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។ បទថា **ន ច បន សមណវចនហេតុបិ គច្ឆន្តិ** (រមែងមិនប្រព្រឹត្តទៅ សូម្បីព្រោះហេតុនៃពាក្យរបស់សមណៈ) សេចក្តីថា រមែងមិនវៀចវេរ សូម្បីព្រោះហេតុនៃពាក្យរបស់សមណៈអ្នកពោលវាទៈផ្សេងគ្នា គឺ មិនលះបង់ទិដ្ឋិរបស់ខ្លួនដោយអំណាចទិដ្ឋិរបស់សមណៈទាំងនោះ ។ សូម្បីក្នុងទីនេះ ក៏ទ្រង់បំណងយកព្រះខីណាស្រពប៉ុណ្ណោះ ។

ចប់អដ្ឋកថា អារក្ខសូត្រទី ៧

---

# អដ្ឋកថា សំវេជនីយសូត្រទី ៨

## *"សំវេជនីយស្ថាន ៤ កន្លែង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សំវេជនីយសូត្រទី ៨ ដូចតទៅនេះ ៖*

[១១៨] *បទថា* ***ទស្សនីយានិ*** *(ស្ថានទីគួរឃើញ) បានដល់ ប្រកបដោយហេតុដែលគួរឃើញ ។ បទថា* ***សំវេជនីយានិ*** *(គួរឲ្យកើតសេចក្ដីសង្វេគ) បានដល់ ស្ថានទីឲ្យកើតសេចក្ដីសង្វេគ ។*

ចប់អដ្ឋកថា សំវេជនីយសូត្រទី ៨

# អដ្ឋកថា បឋមភយសូត្រទី ៩

*"ភ័យ ៤ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមភយសូត្រទី ៩ ដូចតទៅនេះ ៖*

[១១៩] *ភ័យដែលប្រារព្ធជាតិកើតឡើង ឈ្មោះថា ជាតិភ័យ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះឯង ។*

ចប់អដ្ឋកថា បឋមភយសូត្រទី ៩

# អដ្ឋកថា ទុតិយភយសូត្រទី ១០

*"ភ័យ ៤ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយភយសូត្រទី ១០ ដូចតទៅនេះ ៖*

[១២០] *ភ័យដែលអាស្រ័យភ្លើង ឈ្មោះថា អគ្គិភ័យ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះឯង ។*

ចប់អដ្ឋកថា ទុតិយភយសូត្រទី ១០

## ចប់កេសិវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# ភយវគ្គវណ្ណនាទី ៣

## អដ្ឋកថា បឋមភយសូត្រទី ១

*"ភ័យ ៤ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមភយសូត្រទី ១ ដូចតទៅនេះ ៖*

[១២១] *បទថា* ***អត្តានុវាទភយំ*** *បានដល់ ភ័យកើតឡើងដល់បុគ្គលដែលតិះដៀលខ្លួន ។ បទថា* ***បរានុវាទភយំ*** *បានដល់ ភ័យកើតពីការតិះដៀលរបស់អ្នកដទៃ ។ បទថា* ***ទណ្ឌភយំ*** *បានដល់ ភ័យកើតព្រោះអាស្រ័យកម្មករណ៍ ៣២ ប្រការ ។ បទថា* ***ទុគ្គតិភយំ*** *បានដល់ ភ័យកើតព្រោះអាស្រ័យអបាយ ៤ ។ ក្នុងបទជាដើមថា* ***ឥទំ វុច្ចតិ ភិក្ខវេ អត្តានុវាទភយំ*** *(ម្នាលភិក្ខុទាំងឡាយ នេះហៅថា អត្តានុវាទភ័យ) មុនដំបូង ហិរិខាងក្នុងរមែងកើតឡើងដល់អ្នកពិចារណាឃើញអត្តានុវាទភ័យ ហិរិនោះ រមែងញុំាងសេចក្តីសង្រួមឲ្យកើតក្នុងត្រៃទ្វាររបស់គេ សេចក្តីសង្រួមក្នុងត្រៃទ្វារ ចាត់ជាចតុបារិសុទ្ធិសីល លោកតាំងនៅក្នុងចតុបារិសុទ្ធិសីលនោះហើយ ចម្រើនវិបស្សនា រមែងតាំងនៅក្នុងផលដ៏ប្រសើរ ។ ចំណែកឱត្តប្បៈខាងក្រៅរមែងកើតឡើងដល់អ្នកពិចារណាឃើញបរានុវាទភ័យ និងទណ្ឌភ័យ ឱត្តប្បៈនោះ រមែងញុំាងសេចក្តីសង្រួមឲ្យកើតក្នុងត្រៃទ្វាររបស់គេ ។ សេចក្តីសង្រួម*

ក្នុងត្រៃទ្វារ ចាត់ជាចតុបារិសុទ្ធិសីល ។ លោកតាំងនៅក្នុងចតុបារិសុទ្ធិ-សីលនោះហើយ ចម្រើនវិបស្សនា រមែងតាំងនៅក្នុងផលដ៏ប្រសើរ ។ ហិរិខាងក្នុង រមែងកើតឡើងដល់អ្នកពិចារណាឃើញទុគតិភ័យ ហិរិនោះ រមែងញាំងសេចក្តីសង្រួមឲ្យកើតក្នុងត្រៃទ្វាររបស់គេ ។ សេចក្តីសង្រួមក្នុងត្រៃទ្វារ ចាត់ជាចតុបារិសុទ្ធិសីល ។ លោកតាំងនៅក្នុងចតុបារិសុទ្ធិសីលនោះហើយចម្រើនវិបស្សនា រមែងតាំងនៅក្នុងផលដ៏ប្រសើរ ។

ចប់អដ្ឋកថា បឋមភយសូត្រទី ១

# អដ្ឋកថា ទុតិយភយសូត្រទី ២

## *"ភ័យ ៤ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយភយសូត្រទី ២ ដូចតទៅនេះ ៖*

*[១២២] បទថា **ឧទកោរោហន្តស្ស** (អ្នកចុះទឹក) គឺ បុគ្គលអ្នកចុះកាន់ទឹក ។ បទថា **បាដិកង្ខិតព្វានិ** (គប្បីសង្ឃឹមបាន) បានដល់ ត្រូវប្រសព្វ ។ បទថា **សុសុកាភយំ** បានដល់ ភ័យ គឺ ត្រីកាច ។ បទថា **មុខាវរណំ មញ្ញេ ករោន្តិ** (រមែងធ្វើទំនងដូចជាបិទមាត់) សេចក្តីថា ភិក្ខុទាំងនេះ រមែងធ្វើដូចបិទមាត់ ។ បទថា **ឱទរិកត្តស្ស** (នៃភាពជាបុគ្គលឃើញដល់ផ្ទៃ) បានដល់ នៃបុគ្គលប្រាថ្នាអាហារព្រោះមានពោះធំ ។ ក្នុងបទថា **អរក្ខិតេនេវ កាយេន** (មិនរក្សាកាយ) ជាដើម គប្បីជ្រាបសេចក្តីដូច្នេះ លោកមានកាយមិនរក្សា ព្រោះមិនមានការសង្រួម ៣ យ៉ាង ក្នុងកាយទ្វារ , មានវាចាមិនរក្សា ព្រោះមិនមានការសង្រួម ៤ យ៉ាង ក្នុងវចីទ្វារ ។*

ចប់អដ្ឋកថា ទុតិយភយសូត្រទី ២

# អដ្ឋកថា បឋមឈានសូត្រទី ៣

## *“បុគ្គលអ្នកចម្រើនឈាន”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមឈានសូត្រទី ៣ ដូចតទៅនេះ ៖*

[១២៣] *បទថា* ***តទស្សាទេតិ*** *(ពេញចិត្ត... បឋមឈាននោះ) សេចក្តីថា រមែងត្រេកអរក្នុងឈាននោះ ព្រោះពេញចិត្ត ។ បទថា* ***និកាមេតិ*** *(ពេញចិត្ត) បានដល់ នៅប្រាថ្នា ។ បទថា* ***វិត្តឹ អាបជ្ជតិ*** *(ដល់នូវសេចក្តីរីករាយ) គឺ ដល់នូវសេចក្តីត្រេកអរ ។ បទថា* ***តទធិមុត្តោ*** *(បង្អោនចិត្តទៅក្នុងបឋមឈាននោះ) គឺ ចុះចិត្តស៊ប់ក្នុងបឋមឈាននោះ ឬបង្អោនចិត្តទៅកាន់បឋមឈាននោះ ។ បទថា* ***តព្ពហុលវិហារី*** *(នៅក្នុងបឋមឈាននោះដោយចំណែកច្រើន) បានដល់ នៅច្រើនដោយបឋមឈាននោះ ជាប្រក្រតី ។ បទថា* ***សហព្យតំ ឧបប្បជ្ជតិ*** *(រមែងចូលដល់ភាពជាសំឡាញ់) បានដល់ រមែងទៅនៅរួមគ្នា គឺ រមែងកើតក្នុងទេវតានោះ ។*

*ក្នុងបទថា* ***កប្បោ អាយុប្បមាណំ*** *(១ កប្ប ជាប្រមាណអាយុ) នេះ បឋមឈាន មានទាប មានកណ្តាល និងប្រណីត ។ ក្នុងបឋមឈាននោះ ចំណែកទី ៣ នៃកប្ប ជាប្រមាណអាយុរបស់ទេវតាដែលកើតឡើងដោយបឋមឈានខាងទាប ពាក់កណ្តាលកប្ប របស់ទេវតាដែលកើតឡើងដោយ*

បឋមឈានជាកណ្ដាល ១ កប្ប របស់ទេវតាដែលកើតឡើងដោយបឋម-ឈានប្រណីត ។ លោកពោលបទនេះ សំដៅដល់ប្រការនោះ ។ បទថា **និរយំបិ គច្ឆតិ** (រមែងចូលដល់នរកខ្លះ) សេចក្ដីថា អ្នកដែលនៅជាបុថុជ្ជន រមែងត្រាច់ទៅមក ព្រោះកម្មដែលនឹងត្រូវទៅនរក ព្រោះគេលះមិនទាន់បាន តែនឹងមិនមែនតជាប់គ្នានោះទេ ។ បទថា **តស្មឹយេវ ភវេ បរិនិព្វាយតិ** (រមែងបរិនិព្វានក្នុងភពនោះឯង) សេចក្ដីថា សាវករបស់ព្រះមានព្រះភាគ នៅក្នុងរូបភពនោះហើយ រមែងបរិនិព្វាន នឹងមិនចុះមកខាងក្រោម ។ បទថា **យទិទំ គតិយា ឧបបត្តិយា សតិ** (គឺក្នុងកាលគតិ និងឧប្បត្តិនោះមានហើយ) សេចក្ដីថា កាលគតិ ឧប្បត្តិមានហើយ អធិប្បាយថា អរិយសាវកដែលជាព្រះសេក្ខៈ មិនធ្លាក់ចុះដោយអំណាចបដិសន្ធិ បរិនិព្វានក្នុងរូបភពនោះឯង គឺ ក្នុងព្រហ្មលោកជាន់ខ្ពស់ឡើងទៅ ព្រោះទុតិយឈានជាដើមណាមួយ ចំណែកបុថុជ្ជន រមែងទៅនរកជាដើមបាន នេះជាហេតុផ្សេងគ្នា ។

សូម្បីក្នុងបទថា **ទ្វេ កប្បា** (២ កប្ប) នេះ ទុតិយឈានក៏មានបីយ៉ាង ដោយន័យដែលពោលហើយនុ៎ះឯង ។ ក្នុងទុតិយឈាននោះ ៨ កប្ប ជាប្រមាណអាយុរបស់ទេវតាដែលកើតដោយទុតិយឈានប្រណីត , ៤ កប្ប ដោយទុតិយឈានកណ្ដាល , ២ កប្ប ដោយទុតិយឈានថ្នាក់ទាប លោក

ពោលបទនេះ សំដៅដល់ប្រការនោះ ៗ ក្នុងបទថា **ចត្តារោ កប្បា** (៤ កប្ប) នេះ គប្បីនាំបទដែលពោលទុកក្នុងខាងក្រោយថា ១ កប្ប , ២ កប្ប ដូច្នេះ មកអធិប្បាយក៏នឹងជ្រាបបាន ៗ បទថា **កប្បោ** (កប្ប) ជាឈ្មោះនៃការគុណ ៤ ដង ព្រោះដូច្នោះ គប្បីឃើញអត្ថក្នុងសេចក្តីនេះ ដូច្នេះថា មួយកប្ប ពីរកប្ប បួនកប្ប ៗ លោកអធិប្បាយថា កប្បណាដែលលោកពោលហើយ ជាដំបូង រាប់កប្បនោះ ២ ដង មក ១ គុណជាមួយ ២ កប្ប , យក ២ គុណជាមួយ ៤ កប្ប ៗ យក ២ គុណនឹង ៤ កប្បនោះម្តងទៀត ទើប បាន ៨ កប្ប យក ២ គុណបានជា ១៦ ជា ៣២ ជា ៦៤ គប្បីជ្រាបថា ៦៤ កប្ប លោកកាន់យកដោយអំណាចបណីតឈានក្នុងទីនេះ យ៉ាងនេះ ៗ បទនេះថា **បញ្ច កប្បសតានិ** (៥០០ កប្ប) លោកពោលដោយអំណាចនៃ ឧបបត្តិឈានដែលប្រណីតប៉ុណ្ណោះ មួយទៀត ប្រមាណអាយុប៉ុណ្ណោះក្នុង វេហប្ផលា ព្រោះព្រហ្មលោកបីជាន់នេះ មិនមានដូចក្នុងបឋមឈានភូមិជា ដើម ព្រោះដូច្នោះ លោកទើបពោលយ៉ាងនេះ ៗ

ចប់អដ្ឋកថា បឋមឈានសូត្រទី ៣

# អដ្ឋកថា ទុតិយឈានសូត្រទី ៤

## "បុគ្គលអ្នកចម្រើនឈាន"

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយឈានសូត្រទី ៤ ដូចតទៅនេះ ៖*

[១២៤] *រូបនោះឯង ឈ្មោះថា* ***រូបគតំ*** *(រូប) ។ សូម្បីក្នុងបទដ៏សេសក៏ន័យនេះឯង ។ ក្នុងបទជាដើមថា* ***អនិច្ចតោ*** *(ជារបស់មិនទៀង) មានអធិប្បាយថា (បុគ្គលនោះពិចារណាឃើញធម៌ទាំងនោះ) ថាជារបស់មិនទៀង ព្រោះអត្ថថា មានហើយមិនមាន ។* ***រោគតោ*** *(ជារោគ) ព្រោះអត្ថថា ឈឺចាប់ ។* ***គណ្ឌតោ*** *(ជាបូស) ព្រោះអត្ថថា ប្រទូស្តខាងក្នុង ,* ***សល្លតោ*** *(ដូចកូនសរ) ព្រោះអត្ថថា ចាក់ដោត ,* ***អឃតោ*** *(ជារបស់តានតឹង) ព្រោះអត្ថថា ជាទុក្ខ ,* ***អាពាធតោ*** *(ជារបស់បៀតបៀន) ព្រោះអត្ថថាលំបាក ,* ***បរតោ*** *(ជាដទៃ) ព្រោះអត្ថថា មិនស្តាប់បង្គាប់ ,* ***បលោកតោ*** *(ជារបស់ត្រូវបែកធ្លាយទៅ) ព្រោះអត្ថថា ទ្រុឌទ្រោម ,* ***សុញ្ញតោ*** *(ជារបស់ទទេ) ព្រោះអត្ថថា មិនមែនសត្វ ,* ***អនត្តតោ*** *(ជារបស់មិនមែនខ្លួន) ព្រោះអត្ថថា មិននៅក្នុងអំណាច ។ ក៏ក្នុងសេចក្តីនេះគប្បីជ្រាបថា លោកពោល* ***អនិច្ចលក្ខណៈ*** *ដោយពីរបទថា* ***អនិច្ចតោ បលោកតោ*** *(ជារបស់មិនទៀង ជារបស់ត្រូវបែកធ្លាយ) ។ លោកពោល* ***អនត្តលក្ខណៈ*** *ដោយពីរបទ*

ថា **សុញ្ញតោ អនត្តតោ** (ជារបស់សូន្យទទេ និងមិនមែនជារបស់ខ្លួន) ។ លោកពោល **ទុក្ខលក្ខណៈ** ដោយបទដ៏សេស ។ បទថា **សមនុបស្សតិ** (រមែងពិចារណាឃើញ) គឺ ពិចារណាឃើញដោយញាណ ។ បុគ្គលកាល លើកបញ្ចក្ខន្ធឡើងកាន់ត្រៃលក្ខណ៍ ពិចារណាឃើញហើយ រមែងធ្វើឲ្យជាក់ច្បាស់នូវមគ្គបី ផលបី ។ បទថា **សុទ្ធាវាសានំ ទេវានំ សហព្យតំ ឧបបជ្ជតិ** (រមែងចូលដល់ភាពជាសំឡាញ់របស់ទេវតាពួកសុទ្ធាវាស) សេចក្តីថា បុគ្គលដែលតាំងនៅក្នុងជាន់សុទ្ធាវាសនោះ ត្រូវចម្រើនចតុត្ថឈានហើយ ទើបនឹងចូលដល់បាន ។

ចប់អដ្ឋកថា ទុតិយឈានសូត្រទី ៤

## អដ្ឋកថា បឋមមេត្តាសូត្រទី ៥

*"បុគ្គលចម្រើនមេត្តា"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមមេត្តាសូត្រទី ៥ ដូចតទៅនេះ ៖*

[១២៥] *មេត្តា ទ្រង់សម្តែងដោយអំណាចបឋមឈាន ករុណា ជាដើម ទ្រង់សម្តែងដោយអំណាចទុតិយឈានជាដើម ។*

ចប់អដ្ឋកថា បឋមមេត្តាសូត្រទី ៥

# អដ្ឋកថា ទុតិយមេត្តាសូត្រទី ៦

## *"បុគ្គលចម្រើនមេត្តា"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយមេត្តាសូត្រទី ៦ ដូចតទៅនេះ ៖*

[១២៦] *ទុតិយមេត្តាសូត្រ គប្បីជ្រាបដោយន័យដូចពោលក្នុងសូត្រទី ៤ នោះឯង ។*

ចប់អដ្ឋកថា ទុតិយមេត្តាសូត្រទី ៦

# អដ្ឋកថា បឋមតថាគតអច្ឆរិយសូត្រទី ៧

## "សេចក្ដីអស្ចារ្យរបស់ព្រះតថាគត"

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមតថាគតអច្ឆិយសូត្រទី ៦ ដូចតទៅនេះ ៖

[១២៧] បទថា **បាតុភាវា** (ព្រោះសេចក្ដីប្រាកដ) គឺ ព្រោះប្រាកដឡើង ។ ក្នុងបទថា **កុច្ឆឹ ឱក្កមតិ** (ស្ដេចចុះកាន់គភ៌) នេះ បានដល់ ទ្រង់ចុះកាន់គភ៌ហើយ ។ ពិតហើយ កាលព្រះពោធិសត្វនោះ ចុះកាន់ព្រះគភ៌ហើយ ពន្លឺក៏មានយ៉ាងនោះ កាលកំពុងចុះកាន់ ពន្លឺក៏មានយ៉ាងនោះ ។ បទថា **អប្បមាណោ** (រកប្រមាណមិនបាន) បានដល់ មានប្រមាណក្រៃលែងឡើង គឺ បរិបូណ៌ធំទូលាយ ។ បទថា **ឧឡារោ** (ដ៏ក្រៃលែង) ជាវេវចនៈរបស់បទថា **អប្បមាណោ** នុ៎ះឯង ។ ក្នុងបទថា **ទេវានំ ទេវានុភាវំ** (ទេវានុភាពរបស់ទេវតាទាំងឡាយ) នេះ បានដល់ អានុភាពដែលរកប្រមាណមិនបានរបស់ពួកទេវតា ស្មើសំពត់ដែលស្លៀកដណ្ដប់ ផ្សាយទៅបានរហូត ១២ យោជន៍ របស់សរីរៈក៏យ៉ាងនោះ របស់វិមានក៏យ៉ាងនោះ អធិប្បាយថា កន្លងទេវានុភាពនៃទេវតានោះ ។ បទថា **លោកន្តរិកា** (លោកន្តនរក) សេចក្ដីថា ទីទំនេរក្នុងចន្លោះចក្រវាឡ ៣ នីងមានលោកន្តនរកនៅ ១ កន្លែង ដូចចន្លោះនៃកង់រទេះ ៣ ដែលទល់គ្នា ឬតាំងជាប់គ្នានិងគ្នា ក៏មានទីទំនេរ

ត្រង់កណ្តាល ។ ក៏លោកន្តរិកនរកនោះ ពោលដោយប្រមាណ បាន ៨ ពាន់យោជន៍ ។ បទថា **អឃា** (ទីចំហ) គឺ បើកជានិច្ច ។ បទថា **អសំវុតា** (មិនមានអ្វីបិទបាំង) គឺ មិនមានស្ថានទីសូម្បីខាងក្រោម ។ បទថា **អន្ធការា** គឺ ងងឹតសូប ។ បទថា **អន្ធការតិមិសា** (មើលមិនឃើញអ្វី) សេចក្តីថា ប្រកបដោយសេចក្តីងងឹត ធ្វើឲ្យដូចជាភ្នែកខ្វាក់ភ្នែក ព្រោះហាមការកើតឡើងនៃចក្ខុវិញ្ញាណ បានឮថា ចក្ខុវិញ្ញាណមិនកើតក្នុងលោកន្តរិកនរកនោះទេ ។ បទថា **ឯវំ មហិទ្ធិកានំ** (មានឫទ្ធិច្រើនយ៉ាង) សេចក្តីថា បានឮថា ព្រះច័ន្ទ និងព្រះអាទិត្យប្រាកដក្នុងទ្វីបទាំងបី ព្រមគ្នាក្នុងគ្រាតែមួយ ទើបមានឫទ្ធិច្រើនយ៉ាងនេះ ព្រះច័ន្ទ និងព្រះអាទិត្យបញ្ចេញពន្លឺកម្ចាត់ភាពងងឹតបាន ៩ សែនយោជន៍ ក្នុងទិសតែមួយ ទើបមានអានុភាពច្រើនយ៉ាងនេះ ។ បទថា **អាភា នានុភោន្តិ** (ពន្លឺ... ក្តីមិនដល់) គឺ ពន្លឺមិនគ្រប់ ។ បានឮថា ព្រះច័ន្ទ និងព្រះអាទិត្យទាំងនោះ គោចរទៅកណ្តាលចក្រវាឡបពិត ឯលោកន្តរិកនរកកន្លងផុតចក្រវាឡបពិត ព្រោះដូច្នោះ ពន្លឺនៃព្រះច័ន្ទ និងព្រះអាទិត្យទាំងនោះ ទើបក្តីទៅមិនដល់ទីនោះ ។

បទថា **យេបិ តត្ថ សត្តា** (សូម្បីពួកសត្វដែលកើតក្នុងនរកនោះ) សេចក្តីថា សត្វសូម្បីពួកណាកើតហើយក្នុងលោកន្តរមហានរកនោះ ។ សួរ

ថា សត្វទាំងនោះ ធ្វើកម្មអ្វី ទើបកើតក្នុងលោកន្តរិកនរកនោះ ។ ឆ្លើយថា សត្វដែលធ្វើកម្មធ្ងន់ ធ្វើនូវកំហុសដ៏ធ្ងន់ចំពោះមាតាបិតា និងធ្វើនូវកំហុសប្រទូស្តដ៏ខ្លាំងចំពោះសមណព្រាហ្មណ៍អ្នកទ្រទ្រង់ធម៌ និងធ្វើកម្មដទៃ មានសម្លាប់សត្វរាល់ៗ ថ្ងៃជាដើម ទើបទៅកើតដូចអភ័យចោរ និងនាគចោរជាដើម ក្នុងតម្ពបណ្ណិទីប (លង្កា) សត្វទាំងនោះ មានអត្តភាពទំហំ ៣ គាវុត មានក្រចកវែង ដូចសត្វប្រចៀវ យកក្រចកតោងព្យួរនៅត្រង់ជើងភ្នំចក្រវាឡ ដូចជាសត្វប្រចៀវតោងព្យួរនៅត្រង់ដើមឈើដូច្នោះ កាលដៃប៉ះទៅត្រូវគ្នានិងគ្នា ក៏សម្គាល់ថា យើងបានចំណីហើយ ដូច្នេះ ក៏ស្ទុះដេញវិលទៅជុំវិញហើយរបូតធ្លាក់ទៅក្នុងទឹកទ្រលោក ប្រៀបដូចជាផ្លែស្រគំត្រូវខ្យល់ប្រហារហើយ ក៏ដាច់ធ្លាក់ទៅក្នុងទឹក ពេលធ្លាក់ចុះទៅដល់ ក៏រលាយទៅក្នុងទឹកក្រុត បីដូចម្សៅធ្លាក់ទៅក្នុងទឹកហើយរលាយទៅ ដូច្នោះ ។ បទថា **អញ្ញេបិ កិរ ភោ សន្តិ សត្តា** (លោកដ៏ចម្រើន បានឮថា សូម្បីសត្វពួកដទៃដែលកើតក្នុងទីនេះក៏មាន) សេចក្តីថា សត្វទាំងនោះឃើញគ្នាក្នុងថ្ងៃនោះ ទើបបានដឹងថា បានឮថា សត្វពួកដទៃមកកើតក្នុងទីនេះ ដើម្បីសោយទុក្ខនេះ ដូចយើងទាំងឡាយសោយទុក្ខធំហើយ ដូច្នោះ ។ តែពន្លឺនេះ នឹងភ្លឺសូម្បីត្រឹមតែហុតយាគូមួងក៏មិនមាន ពន្លឺមួយជួរវេលាដែលសត្វដេកលក់ ហើយ

ភ្ញាក់ឡើង ចិត្តក៏ស្រស់ថ្លា ដូច្នោះ ។ ចំណែកព្រះទីឃភាណកាចារ្យពោល ថា ពន្លឺនោះ ក្ដីត្រឹមតែពេលដែលសត្វនិយាយថា អ្វីនេះ ក៏បាត់ទៅ ដូច ជាពន្លឺផ្លេកបន្ទោរ ត្រឹមតែមួយផ្ទាត់ម្រាមដៃប៉ុណ្ណោះ ។

ចប់អដ្ឋកថា បឋមអច្ឆរិយសូត្រទី ៧

# អដ្ឋកថា ទុតិយតថាគតអច្ឆរិយសូត្រទី ៨

## *"សេចក្តីអស្ចារ្យរបស់ព្រះតថាគត"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយតថាគតអច្ឆិយសូត្រទី ៨ ដូចតទៅនេះ ៖*

*[១២៨] បញ្ចកាមគុណ ឬវត្ថុៈទាំងអស់ ឈ្មោះថា* **អាល័យ** *ព្រោះអត្ថថា ត្រូវតណ្ហា និងទិដ្ឋិចាប់ទុក ។ ឈ្មោះថា* **អាភមោ** *(ជាទីរីករាយ) ព្រោះជាទីត្រេកអរនៃសត្វ ។ ឈ្មោះថា* **អាលយារាមា** *(មានអាល័យជាទីរីករាយ) ព្រោះពួកសត្វមានអាល័យជាទីត្រេកអរ ។ ឈ្មោះថា* **អាលយរតា** *(ត្រេកអរក្នុងអាល័យ) ព្រោះត្រេកអរហើយក្នុងអាល័យ ។ ឈ្មោះថា* **អាលយសម្មុទិតា** *(រីករាយក្នុងអាល័យ) ព្រោះរីករាយហើយក្នុងអាល័យ ។ បទថា* **អនាលយេ ធម្មេ** *(ធម៌ដែលរកសេចក្តីអាល័យមិនបាន) បានដល់ អរិយធម៌អាស្រ័យវិវដ្តៈ និព្វាន ដែលផ្ទុយគ្នានឹងអាល័យ ។ បទថា* **សុស្សូតិ** *(រមែងស្តាប់ដោយល្អ) គឺ ជាអ្នកប្រាថ្នាស្តាប់ ។ បទថា* **សោតំ ឱទហតិ** *(ផ្ទៀងត្រចៀកស្តាប់) បានដល់ ផ្ទៀងត្រចៀកស្តាប់ ។ បទថា* **អញ្ញាចិត្តំ ឧបដ្ឋបេតិ** *(តាំងចិត្តដើម្បីដឹង) បានដល់ ចូលទៅតាំងចិត្តដើម្បីនឹងដឹងទូទៅដល់ធម៌ ។ ការប្រកាន់ខ្លួន ឬវត្ថុៈទាំងអស់នោះឯង ព្រោះអត្ថថា ពួកសត្វគប្បីប្រកាន់ ឈ្មោះថា* **មានោ** *(មានះ) ។ បទថា* **មានវិនយេ**

**ធម្មេ** (ធម៌ជាគ្រឿងកម្ចាត់មានះ) គឺ ធម៌ដែលជាគ្រឿងកម្ចាត់នូវមានះ ។ ធម៌ដែលផ្ទុយគ្នានឹងសេចក្ដីស្ងប់ ឬវដ្តៈនោះឯង ឈ្មោះថា **អនុបសមៈ** ព្រោះអត្ថថា មិនស្ងប់ ។ បទថា **ឱបសមិកេ** (ដែលធ្វើសេចក្ដីស្ងប់) បានដល់ធម៌ដែលធ្វើសេចក្ដីស្ងប់ គឺ អាស្រ័យវិវដ្តៈ គឺ និព្វាន ។ ឈ្មោះថា **អវិជ្ជាគតា** (អ្នកធ្លាក់នៅក្នុងអវិជ្ជា) ព្រោះអត្ថថា ទៅ គឺ ប្រកបដោយអវិជ្ជា ។ ឈ្មោះថា **អណ្ឌភូតា** (អ្នកងងឹត) ព្រោះដូចជាមនុស្សខ្វាក់ភ្នែក ព្រោះត្រូវគំនរងងឹត គឺ អវិជ្ជាបិទបាំងទុក ។ ឈ្មោះថា **បរិយោនទ្ធា** (ត្រូវអវិជ្ជារួបរឹត) ព្រោះត្រូវអវិជ្ជាហ៊ុមព័ទ្ធទុកដោយជុំវិញ ។ ក្នុងបទថា **អវិជ្ជា-វិនយេ** (ធម៌ជាគ្រឿងកម្ចាត់អវិជ្ជា) មានអធិប្បាយថា ព្រះអរហត្តហៅថាធម៌ជាគ្រឿងកម្ចាត់អវិជ្ជា កាលធម៌ ដែលអាស្រ័យនូវធម៌ជាគ្រឿងកម្ចាត់អវិជ្ជានោះ ដែលព្រះតថាគតសម្ដែងហើយ ។ ក្នុងសូត្រនេះត្រាស់វដ្តៈទុក ៤ ឋានៈ ត្រាស់វិវដ្តៈទុក ៤ ឋានៈ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា ទុតិយអច្ឆរិយសូត្រទី ៨

# អដ្ឋកថា អានន្ទអច្ឆរិយសូត្រទី ៩

## “សេចក្ដីអស្ចារ្យរបស់ព្រះអានន្ទ”

*គប្បីជ្រាបវិនិច្ឆ័យក្នុង អានន្ទអច្ឆរិយសូត្រទី ៩ ដូចតទៅនេះ ៖*

[១២៩] *បទថា* ***ភិក្ខុបរិសា អានន្ទំ ទស្សនាយ*** *(ភិក្ខុបរិស័ទចូលទៅដើម្បីជួបអានន្ទ) សេចក្ដីថា ភិក្ខុពួកណាបំណងនឹងគាល់ព្រះមានព្រះ-ភាគ ក៏ចូលទៅរកព្រះថេរៈ ឬភិក្ខុពួកណាបានស្ដាប់គុណ គឺ សេចក្ដីល្អរបស់ព្រះថេរៈថា បានឮថា ព្រះអានន្ទគួរជ្រះថ្លាដោយសព្វគ្រប់ ល្អ គួរសរសើរ ជាពហុស្សូត ជាធម្មកថឹក ជាអ្នកធ្វើពួកឲ្យស្អាត ទើបនាំគ្នាមកទ្រង់សំដៅដល់ភិក្ខុទាំងនោះ ទើបត្រាស់ថា ភិក្ខុបរិស័ទចូលទៅដើម្បីជួបអានន្ទ ។ ក្នុងគ្រប់បទក៏ន័យនេះ ។ បទថា* ***អត្តមនា*** *(មានចិត្តត្រេកអរ) សេចក្ដីថា ភិក្ខុបរិស័ទនោះមានចិត្តរីករាយ គឺ មានចិត្តត្រេកអរថា ការជួបរបស់យើងសមដូចការបានស្ដាប់មក ។ បទថា* ***ធម្មំ*** *(ធម៌) សេចក្ដីថា លោកពោលធម៌ផ្នែកខាងទទួលបែបនេះថា លោកដ៏មានអាយុទាំងឡាយសប្បាយទេឬ ល្មមញុំាងជីវិតឲ្យប្រព្រឹត្តទៅបានទេឬ លោកទាំងឡាយនៅធ្វើកិច្ចកម្មក្នុងយោនិសោមនសិការទេឬ លោកនៅបំពេញអាចរិយវត្ត និងឧបជ្ឈាយវត្តទេឬ ។ បណ្ដាបុគ្គលទាំងនោះ ក្នុងភិក្ខុនីក៏នឹងពោលបដិសណ្ឋារៈ*

ផ្សេងគ្នាដូច្នេះថា ប្អូនស្រីទាំងឡាយ អ្នកទាំងឡាយសមាទានប្រព្រឹត្តនូវគរុធម៌ ៨ ដែរឬ ។ ក្នុងឧបាសកទាំងឡាយ លោកមិនធ្វើបដិសណ្ឋារៈយ៉ាងនេះ ដោយពាក្យថា ឧបាសកមកល្អហើយ លោកមិនអាពាធសីសៈ ឬអវយវៈខ្លះទេឬ កូនប្រុសស្រីរបស់លោក មិនមានរោគភ័យទេឬ តែលោកនឹងធ្វើបដិសណ្ឋារៈយ៉ាងនេះថា ឧបាសកយ៉ាងណា ចូររក្សាសរណៈ ៣ សីល ៥ ចូរធ្វើឧបោសថមួយខែ ៨ ដងចុះ ចូរចញ្ចឹមមាតាបិតា ចូរទំនុកបម្រុងសមណព្រាហ្មណ៍ដែលទ្រទ្រង់ធម៌ចុះ ។ សូម្បីក្នុងឧបាសិកាទាំងឡាយ ក៏ន័យនេះឯង ។

ចប់អដ្ឋកថា អានន្ទអច្ឆរិយសូត្រទី ៩

# អដ្ឋកថា ចក្កវត្តិអច្ឆរិយសូត្រទី ១០

## “សេចក្ដីអស្ចារ្យរបស់ស្ដេចចក្រពត្តិ”

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចក្កវត្តិអច្ឆរិយសូត្រទី ១០ ដូចតទៅនេះ ៖*

[១៣០] *បទថា* ***ខត្តិយបរិសា*** *បានដល់ ពួកខត្តិយៈដែលអភិសេក និងដែលមិនទាន់អភិសេក ។ បានឮថា ខត្តិយៈទាំងនោះ បានស្ដាប់ពាក្យពោលអំពីគុណរបស់ស្ដេចចក្រពត្តិនោះថា ធម្មតាថា ស្ដេចចក្រពត្តិ ល្អគួរជ្រះថ្លា ត្រាច់ទៅផ្លូវអាកាសបាន គ្រប់គ្រងរាជសម្បត្តិ ទ្រទ្រង់ធម៌ ជាធម្មរាជា កាលបានឃើញ ក៏ដូចនឹងបានស្ដាប់មក ក៏រីករាយ ។ បទថា* ***ភាសតិ*** *(ទ្រង់មានព្រះតម្រាស់) សេចក្ដីថា ស្ដេចចក្រពត្តិទ្រង់បានធ្វើបដិសណ្ឋារៈថា “លោកពុកម្ដាយទាំងឡាយ លោកទាំងឡាយនៅបំពេញរាជធម៌ រក្សាប្រពៃណីដែរឬ” ។ ចំណែកក្នុងព្រាហ្មណ៍ទាំងឡាយ ក៏ទ្រង់ធ្វើបដិសណ្ឋារៈយ៉ាងនេះថា “លោកអាចារ្យទាំងឡាយ លោកទាំងឡាយបង្រៀនមន្តដែរឬ សិស្សទាំងឡាយនៅរៀនមន្តទេឬ លោករមែងបានទក្ខិណាខ្លះ សំពត់ខ្លះ គោក្របីខ្លះឬ” ។ ក្នុងគហបតីទាំងឡាយ ទ្រង់ធ្វើបដិសណ្ឋារៈយ៉ាងនេះថា “បាអើយ អ្នកមិនត្រូវបៀតបៀនដោយតម្លៃពិន័យ ឬដោយគ្រឿងឃុំឃាំងក្រៅពីរាជត្រកូលខ្លះទេឬ ភ្លៀងធ្លាក់ត្រូវតាមរដូវកាល*

*ដែរឬ ស្រាវអន្តរទាំងឡាយបានផលសម្បូរណ៍ដែរឬ” ។ ក្នុងសមណៈទាំងឡាយ ទ្រង់ធ្វើបដិសណ្ឋារៈយ៉ាងនេះថា “លោកដ៏ចម្រើន បរិក្ខាររបស់បព្វជិតរកបានងាយឬទេ សូមលោកទាំងឡាយកុំលះបង់សមណធម៌ឡើយ ។*

ចប់អដ្ឋកថា ចក្កវត្តិអច្ឆរិយសូត្រទី ១០

## ចប់ភយវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# បុគ្គលវគ្គវណ្ណនាទី ៤

## អដ្ឋកថា សំយោជនសូត្រទី ១

*"ពោលដោយសំយោជនៈ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សំយោជនសូត្រទី ១ ដូចតទៅនេះ ៖*

[១៣១] *បុគ្គលខ្លះបានឧប្បត្តិភព បានភពក្នុងចន្លោះ ដោយសំយោជនៈពួកណា សំយោជនៈពួកនោះ ឈ្មោះថា* ***ឧប្បត្តិប្បដិលាភិកានិ*** *(ដែលជាបច្ច័យដើម្បីឲ្យបានឧប្បត្តិ) ។ បទថា* ***ភវប្បដិលាភិកានិ*** *(ដែលជាបច្ច័យឲ្យបានភព) បានដល់ ដែលជាបច្ច័យដល់ការបានឧប្បត្តិភព ។ បទថា* ***សកទាគាមិស្ស*** *(ព្រះសកទាគាមី) នេះ លោកកាន់យកដោយចំណែកខ្ពស់បំផុតក្នុងព្រះអរិយៈទាំងឡាយ ដែលនៅលះសំយោជនៈមិនទាន់បាន ក៏ព្រោះហេតុនេះ អន្តរាឧប្បត្តិ (ការកើតក្នុងចន្លោះ) របស់ព្រះអរិយបុគ្គលដែលជាអន្តរាបរិនិព្វាយីមិនមាន តែលោកចូលឈានណាក្នុងទីនោះ ឈាននោះរាប់ថា ជាបច្ច័យដល់ឧប្បត្តិភព ព្រោះឈានជាចំណែកកុសលធម៌ ដូច្នោះ ទើបត្រាស់ចំពោះព្រះអរិយបុគ្គលដែលជាអន្តរាបរិនិព្វាយីនោះថា លះសំយោជនៈដែលជាបច្ច័យដើម្បីបានឧប្បត្តិ តែនៅលះសំយោជនៈដែលជាបច្ច័យដើម្បីឲ្យបានភពមិនបាន ។ សំដៅដល់សំយោជនៈចំណែកដែលលះមិនទាន់ក្នុង*

ឱរម្ភាគិយសំយោជនៈទាំងឡាយ ទើបត្រាស់ថា លះឱរម្ភាគិយសំយោជនៈ មិនបាន ដោយសេចក្តីមិនផ្សេងគ្នានៃសកទាគាមីបុគ្គល ។ បទដ៏សេសក្នុង សូត្រនេះ ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា សំយោជនសូត្រទី ១

# អដ្ឋកថា បដិភាណសូត្រទី ២

## "បុគ្គលដែលឆ្លើយបានត្រឹមត្រូវ"

*គប្បីជ្រាបវិនិច្ឆ័យក្នុង បដិភាណសូត្រទី ២ ដូចតទៅនេះ ៖*

[១៣២] *បទថា* ***យុត្តប្បដិភាណោ នោ មុត្តប្បដិភាណោ*** *(បុគ្គលដែលឆ្លើយបានត្រឹមត្រូវតែមិនរហ័ស) សេចក្តីថា បុគ្គលកាលដោះស្រាយបញ្ហា ក៏ដោះស្រាយបានត្រូវក៏ពិត តែដោះស្រាយបានមិនរហ័ស គឺ សន្សឹមៗ ទើបដោះស្រាយ ។ បទទាំងពួង គប្បីជ្រាបដោយន័យនេះ ។*

ចប់អដ្ឋកថា បដិភាណសូត្រទី ២

# អដ្ឋកថា ឧគ្ឃដិតញ្ញូសូត្រទី ៣

## "បុគ្គលដែលដឹងបានរហ័ស"

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧគ្ឃដិតញ្ញូសូត្រទី ៣ ដូចតទៅនេះ ៖*

[១៣៣] *គប្បីជ្រាបសេចក្ដីផ្សេងគ្នានៃបុគ្គលសូម្បី ៤ ពួក ដោយសូត្រនេះ ។ ឧគ្ឃដិតញ្ញូបុគ្គលដូចម្ដេច ។ បុគ្គលត្រាស់ដឹងធម៌ ខណៈដែលលោកលើកមាតិកាឡើងសម្ដែងហៅថា* **ឧគ្ឃដិតញ្ញូបុគ្គល** *។ វិបចិតញ្ញូបុគ្គលដូចម្ដេច ។ បុគ្គលត្រាស់ដឹងធម៌ កាលដែលលោកចែកសេចក្ដីដោយពិស្ដារ ហៅថា* **វិបចិតញ្ញូបុគ្គល** *។ នេយ្យបុគ្គលដូចម្ដេច ។ បុគ្គលត្រូវរៀន ត្រូវសាកសួរ ត្រូវធ្វើទុកក្នុងចិត្តដោយឧបាយ ត្រូវសេពគប់ជាមួយកល្យាណមិត្ត ទើបត្រាស់ដឹងធម៌តាមលំដាប់ ហៅថា* **នេយ្យបុគ្គល** *។ បទបរមបុគ្គលដូចម្ដេច ។ បុគ្គលស្ដាប់ច្រើនក្ដី និយាយច្រើនក្ដី ចាំច្រើនក្ដី រៀនច្រើនក្ដី ក៏មិនអាចត្រាស់ដឹងធម៌ក្នុងជាតិនេះ ហៅថា* **បទបរមបុគ្គល** *។*

ចប់អដ្ឋកថា ឧគ្ឃដិតញ្ញូសូត្រទី ៣

# អដ្ឋកថា ឧដ្ឋានសូត្រទី ៤

## *"អ្នកចិញ្ចឹមជីវិតដោយផលនៃការប្រឹងប្រែង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧដ្ឋានសូត្រទី ៤ ដូចតទៅនេះ ៖*

[១៣៤] *បុគ្គលពួកមួយ ប្រើពេលវេលាឲ្យកន្លងទៅ ដោយសេចក្តីព្យាយាម គឺ សេចក្តីប្រឹងប្រែងប៉ុណ្ណោះ បានអ្វីមកក៏ត្រឹមតែជាផលនៃសេចក្តីព្យាយាមនោះ ចិញ្ចឹមជីវិត គេអាស្រ័យតែសេចក្តីប្រឹងប្រែងនោះ មិនបានផលបុណ្យអ្វី បុគ្គលពួកនេះ ឈ្មោះថា* **ឧដ្ឋានផលូបជីវី ន កម្មផលូបជីវី** *(ចិញ្ចឹមជីវិតដោយផលនៃសេចក្តីប្រឹងប្រែង មិនរស់នៅដោយផលរបស់កម្ម) ។ ចំណែកពួកទេវតាសូម្បីទាំងអស់ តាំងពីទេវតាជាន់ចាតុម្មហារាជជាដើមទៅ ព្រោះចូលទៅអាស្រ័យផលបុណ្យចិញ្ចឹមជីវិត វៀរសេចក្តីព្យាយាម គឺ សេចក្តីប្រឹងប្រែង ទើបឈ្មោះថា* **កម្មផលូបជីវី ន ឧដ្ឋានផលូបជីវី** *(ចិញ្ចឹមជីវិតដោយផលរបស់កម្ម មិនមែនចិញ្ចឹមជីវិតដោយផលនៃសេចក្តីប្រឹងប្រែង) ។ ឥស្សរជន មានព្រះរាជា មហាមាត្ររបស់ព្រះរាជាជាដើម ឈ្មោះថា* **ឧដ្ឋានផលូបជីវី ចេវ កម្មផលូបជីវី ច** *(ចិញ្ចឹមជីវិតដោយផលនៃសេចក្តីប្រឹងប្រែង និងចិញ្ចឹមជីវិតដោយផលរបស់កម្ម ។ ពួកសត្វនរក ឈ្មោះថា* **នេវ ឧដ្ឋានផលូបជីវី ន កម្មផលូបជីវី** *(ចិញ្ចឹមជីវិតដោយ*

ផលនៃសេចក្តីប្រឹងប្រែងក៏មិនមែន ដោយផលរបស់កម្មក៏មិនមែន ។ ផលបុណ្យនោះឯង លោកបំណងថា ជាផលរបស់កម្មក្នុងសូត្រនេះ ផលបុណ្យនោះ មិនមានដល់ពួកសត្វនរកទាំងនោះ ។

ចប់អដ្ឋកថា ឧដ្ឋានសូត្រទី ៤

# អដ្ឋកថា សាវជ្ជសូត្រទី ៥

## "ពោលដោយបុគ្គលមានទោស"

គប្បីជ្រាបវិនិច្ឆ័យក្នុង សាវជ្ជសូត្រទី ៥ ដូចតទៅនេះ ៖

[១៣៥] អ្នកពួកទីមួយ បានដល់ បុថុជ្ជនដែលល្ងង់ខ្លៅ ពួកទីពីរ បានដល់ លោកិយបុថុជ្ជនដែលបំពេញកុសលក្នុងចន្លោះៗ ពួកទីបី បានដល់ ព្រះសោតាបន្ន សូម្បីព្រះសកទាគាមី និងអនាគាមី ក៏រួមជាមួយបុគ្គលពួកទីបីនោះដូចគ្នា ពួកទីបួន បានដល់ ព្រះខីណាស្រព ពិតហើយ ព្រះខីណាស្រពនោះ រកទោសមិនបានដោយចំណែកមួយ ។

ចប់អដ្ឋកថា សាវជ្ជសូត្រទី ៥

# អដ្ឋកថា បឋមសីលសូត្រទី ៦

## *“បុគ្គលធ្វើឲ្យបរិបូរណ៍ក្នុងសីល”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសីលសូត្រទី ៦ ដូចតទៅនេះ ៖*

*[១៣៦] បុគ្គលពួកទីមួយ បានដល់ លោកិយមហាជន ពួកទីពីរ បានដល់ ព្រះសោតាបន្ន និងព្រះសកទាគាមី អ្នកបំពេញវិបស្សនាសុទ្ធ ពួកទីបី បានដល់ ព្រះអនាគាមី ពិតណាស់ ព្រះអនាគាមីនោះ ព្រោះហេតុដែលបានឈានដែលធ្វើឧប្បត្តិឲ្យកើតសូម្បីខណៈនោះ ដូច្នោះ លោកសូម្បីបំពេញវិបស្សនាសុទ្ធ ក៏ធ្វើឲ្យបរិបូរណ៍ក្នុងសមាធិដោយពិត ពួកទីបួន បានដល់ ព្រះខីណាស្រពប៉ុណ្ណោះ ពិតហើយ ព្រះខីណាស្រពនោះ ឈ្មោះថា ធ្វើឲ្យបរិបូរណ៍ក្នុងសីល សមាធិ និងបញ្ញាទាំងអស់ ព្រោះលោកលះធម៌ដែលជាសត្រូវចំពោះសីលជាដើមទាំងអស់ បានហើយ ។*

ចប់អដ្ឋកថា បឋមសីលសូត្រទី ៧

# អដ្ឋកថា ទុតិយសីលសូត្រទី ៧

## *"បុគ្គលដែលធ្ងន់ក្នុងសីល"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសីលសូត្រទី ៧ ដូចតទៅនេះ ៖*

[១៣៧] *គប្បីជ្រាបការកំណត់បុគ្គល ដោយន័យដែលពោលហើយក្នុងបឋមសីលសូត្រ ។*

ចប់អដ្ឋកថា ទុតិយសីលសូត្រទី ៧

# អដ្ឋកថា និក្កដ្ឋសូត្រទី ៨

## *“បុគ្គលដែលកាយ និងចិត្តចេញ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង និក្កដ្ឋសូត្រទី ៨ ដូចតទៅនេះ ៖*

[១៣៨] *បទថា* ***និក្កដ្ឋកាយោ*** *(មានកាយចេញ) គឺ មានកាយចេញទៅ ។ បទថា* ***អនិក្កដ្ឋចិត្តោ*** *(តែចិត្តមិនចេញ) គឺ មានចិត្តមិនចេញទៅ ។ លោកអធិប្បាយថា បុគ្គលមានកាយប៉ុណ្ណោះចេញពីស្រុក សូម្បីនៅក្នុងព្រៃក៏មានចិត្តចូលស្រុកទុំះឯង ។ អត្ថគ្រប់បទ គប្បីជ្រាបដោយន័យនេះ ។*

ចប់អដ្ឋកថា និក្កដ្ឋសូត្រទី ៨

# អដ្ឋកថា ធម្មកថិកសូត្រទី ៩

## "ធម្មកថិក ៤ ពួក"

*គប្បីជ្រាបវិនិច្ឆ័យក្នុង ធម្មកថិកសូត្រទី ៩ ដូចតទៅនេះ ៖*

[១៣៩] *បទថា* ***អសហិតំ*** *(មិនប្រកបដោយប្រយោជន៍ គឺ មិនអាស្រ័យប្រយោជន៍ ។ បទថា* ***ន កុសលា ហោតិ*** *(ក៏ជាអ្នកមិនឆ្លាត) គឺជាអ្នកមិនឈ្លាសវៃ ។ បទថា* ***សហិតាសហិតស្ស*** *(ដល់ប្រយោជន៍ និងមិនមែនប្រយោជន៍) បានដល់ ដល់វត្ថុដែលប្រកបដោយប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ ។ អត្ថក្នុងបទទាំងពួង គប្បីជ្រាបយ៉ាងនេះ ។*

ចប់អដ្ឋកថា ធម្មកថិកសូត្រទី ៩

# អដ្ឋកថា វាទីសូត្រទី ១០

*"អ្នកនិយាយ ៤ ពួក"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វាទីសូត្រទី ១០ ដូចតទៅនេះ ៖*

[១៤០] *បទថា* ***អត្ថតោ បរិយាទានំ គច្ឆតិ*** *(អ្នកពោលតែងចាញ់ដោយអត្ថ) សេចក្តីថា អ្នកពោលត្រូវសួរដល់អដ្ឋកថា ក៏រមែងចាញ់ មិនអាចនឹងឆ្លើយបាន ។ បទថា* ***នោ ព្យញ្ជនតោ*** *(តែមិនចាញ់ក្នុងព្យញ្ជនៈ) សេចក្តីថា តែព្យញ្ជនៈរបស់គេប្រព្រឹត្តទៅបាន រមែងមិនចាញ់ ។ ក្នុងបទគ្រប់បទ ក៏ន័យនេះឯង ។*

ចប់អដ្ឋកថា វាទីសូត្រទី ១០

## ចប់បុគ្គលវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# អាភាវគ្គវណ្ណនាទី ៥

## អដ្ឋកថា អាភាសូត្រទី ១

*"ពន្លឺ ៤ ប្រការ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាភាសូត្រទី ១ ដូចតទៅនេះ ៖*

[១៤១] *ព្រះច័ន្ទនោះឯង ឈ្មោះថា ចន្ទាភា ដោយអំណាចពន្លឺរស្មី ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះឯង ។*

ចប់អដ្ឋកថា អាភាសូត្រទី ១

# អដ្ឋកថា បភាសូត្រទី ២

## *“រស្មី ៤ ប្រការ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បភាសូត្រទី ២ ដូចតទៅនេះ ៖*

[១៤២] *សូម្បីក្នុងសូត្រទីពីរជាដើម ព្រះច័ន្ទ ឈ្មោះថា* **ចន្ទាភា** *ដោយអំណាចពន្លឺ ។ ព្រះច័ន្ទ ឈ្មោះថា* **ចន្ទាលោក** *ដោយអំណាចពន្លឺ ។ ព្រះច័ន្ទ ឈ្មោះថា* **ចន្ទោភាស** *ដោយអំណាចថ្លៃងពន្លឺ ។ ព្រះច័ន្ទ ឈ្មោះថា* **ចន្ទប្បជ្ជោត** *ដោយអំណាចពន្លឺរុងរឿង ។ សេចក្ដីក្នុងបទទាំងពួង គប្បីជ្រាបយ៉ាងនេះ ។*

ចប់អដ្ឋកថា បភាសូត្រទី ២

# អដ្ឋកថា អាលោកសូត្រទី ៣

## *"សេចក្តីរុងរឿង ៤ ប្រការ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាលោកសូត្រទី ៣ ដូចតទៅនេះ ៖*

[១៤៣] *មិនមានអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា អាលោកសូត្រទី ៣

## អដ្ឋកថា ឱភាសសូត្រទី ៤

*"ឱភាស ៤ ប្រការ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឱភាសសូត្រទី ៤ ដូចតទៅនេះ ៖*

[១៤៤] *មិនមានអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា ឱភាសសូត្រទី ៤

# អដ្ឋកថា បជ្ជោតសូត្រទី ៥

## *“ពន្ទីរស្មី ៤ ប្រការ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បជ្ជោតសូត្រទី ៥ ដូចតទៅនេះ ៖*

[១៤៥] *មិនមានអដ្ឋកថាកែសេចក្ដីទេ ។*

ចប់អដ្ឋកថា បជ្ជោតសូត្រទី ៥

# អដ្ឋកថា បឋមកាលសូត្រទី ៦

*“ពោលដោយកាល”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមកាលសូត្រទី ៦ ដូចតទៅនេះ ៖*

[១៤៦] *បទថា* ***កាលោ*** *(កាល) គឺ កាលដែលសមគួរ ៗ បទថា* ***កាលេន ធម្មស្សវនំ*** *(ការស្តាប់ធម៌តាមកាល) បានដល់ ការស្តាប់ធម៌ក្នុងវេលាដែលសមគួរ ៗ បទថា* ***ធម្មសាកច្ឆា*** *(ការសន្ទនាធម៌) សេចក្តីថា ការសន្ទនាដែលប្រព្រឹត្តទៅដោយអំណាចការសួរ និងការឆ្លើយបញ្ហា ៗ*

ចប់អដ្ឋកថា បឋមកាលសូត្រទី ៦

# អដ្ឋកថា ទុតិយកាលសូត្រទី ៧

*"ពោលដោយកាល"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយកាលសូត្រទី ៧ ដូចតទៅនេះ ៖*

[១៤៧] *បទថា* **កាលា** *(កាល) នោះ ជាឈ្មោះនៃកុសលធម៌ដែលប្រព្រឹត្តទៅដោយអំណាចការស្តាប់ធម៌ជាដើមក្នុងកាលនោះៗ កាលទាំងនោះនឹងជាក់ច្បាស់ និងនឹងប្រព្រឹត្តទៅ ។ បទថា* **អាសវានំ ខយំ** *(ការអស់អាសវៈ) បានដល់ ព្រះអរហត្ត ។*

ចប់អដ្ឋកថា ទុតិយកាលសូត្រទី ៧

# អដ្ឋកថា ទុច្ចរិតសូត្រទី ៨

## “ពោលដោយវចីទុច្ចរិត”

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុច្ចរិតសូត្រទី ៨ ដូចតទៅនេះ ៖*

[១៤៨] *អដ្ឋកថាទុច្ចរិតសូត្រទី ៨ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា ទុច្ចរិតសូត្រទី ៨

# អដ្ឋកថា សុចរិតសូត្រទី ៩

## *“ពោលដោយវចីសុចរិត”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុចរិតសូត្រទី ៩ ដូចតទៅនេះ ៖*

[១៤៩] *បទថា **សណ្ហវាចា** បានដល់ វាចាទន់ភ្លន់ ។ បទថា **មន្តាភាសា** បានដល់ រឿងដែលកំណត់ដោយបញ្ញា ពោលគឺ ការដឹងហើយទើបពោល ។*

ចប់អដ្ឋកថា សុចរិតសូត្រទី ៩

# អដ្ឋកថា សារសូត្រទី ១០

*"ពោលដោយសារៈ ៤ ប្រការ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សារសូត្រទី ១០ ដូចតទៅនេះ ៖*

[១៥០] *បទថា **សីលសារោ** (សីលសារៈ) គឺ សីលដែលឲ្យដល់សារៈ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះឯង ។*

ចប់អដ្ឋកថា សារសូត្រទី ១០

## ចប់អាហារវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៦ សូត្រ

## ចប់តតិយបណ្ណាសកៈ

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 USA |
| -ភិក្ខុ ចៅ សៀប វត្តអូស្ត្រាលី | $ 500 AUS |
| -ភិក្ខុធម្មបញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ សហរដ្ឋអាមេរិក ព្រមទាំងពុទ្ធបរិស័ទ | $ 920 USA |
| -ឧបាសក សោម រតនៈ ព្រមទាំងភរិយា និងបុត្ត | $ 200 USA |
| -ឧបាសក តាំង សុជល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ | កុំព្យូទ័របត់មួយគ្រឿង |